# កិច្ចតែងការបង្រៀន

# គណិតវិទ្យា




# ៧


កិច្ចការស្រាវជ្រាវ គរុនិស្សិតគណិតវិទ្យា ក្រុម៥ ជំនាន់ទី១៧

ដឹកនាំដោយសាស្ត្រាចារ្យ ថៃ ហេង

| | | | |
|---|---|---|---|
| ម៉ៃ គីមយស់ | ឈី រតនា | ហ៊ី គីមហាក់ | ហួន ណូ |
| ឃាង សុខលាភ | ឡុង សុផល | ប៊ុន បញ្ញា | មាស មករា |
| ដើក ចំនាន | ដោប ផល | ប៉ែន មុនីជោតិ | ស សុធា |
| ស៊ុន សីវិឍ | ហេង គីមឆេង | ម៉ាត់ សាឡេះ | លឿម ម៉េងគ្រាម |
| ជា មាន | តេង សំណាង | ម៉ៅ យ៉ា | |

# វិទ្យាស្ថានជាតិអប់រំ

# កម្រងកិច្ចតែងការបង្រៀន

## គណិតវិទ្យាថ្នាក់ទី៧

**រៀបរៀងដោយៈ**

គរុនិស្សិតកម្រិតឧត្តម បរិញ្ញា+១ ជំនាន់ទី១៧

ឯកទេស គណិតវិទ្យា-រូបវិទ្យា ក្រុមទី៥

**ដឹកនាំដោយលោកសាស្ត្រាចារ្យៈ** ថៃ ហេង

## ឆ្នាំសិក្សា ២០១១-២១១២

ព្រះរាជាណាចក្រកម្ពុជា

ក្រសួងអប់រំយុវជន និងកីឡា                ជាតិ សាសនា ព្រះមហាក្សត្រ

វិទ្យាស្ថានជាតិអប់រំ

**តារាងចំណែងចែកភារកិច្ច និងការទទួលខុសត្រូវធ្វើកិច្ចតែងការបង្រៀន**

**របស់គរុនិស្សិតកម្រិតឧត្តម បរិញ្ញា+១ ជំនាន់ទី១៧**

**ឯកទេស គណិតវិទ្យា-រូបវិទ្យា ក្រុមទី៥**

| ល.រ | គោត្តនាម-នាម | ភេទ | ក្របខណ្ឌខេត្ត | ធ្វើកិច្ចតែងការលើមេរៀន |
|---|---|---|---|---|
| ១ | ម៉ៃ គឹមយស់ | ប្រុស | ព្រះវិហារ | មេរៀនទី៥៖ ចំនួនទសភាគ |
| ២ | លី រតនា | ប្រុស | ព្រះវិហារ | មេរៀនទី១៨៖ មាឌនិងផ្ទៃក្រឡាខាងនៃស៊ូលីត |
| ៣ | ហ៊ី គឹមហាក់ | ប្រុស | ព្រះវិហារ | មេរៀនទី៩៖ សមីការដឺក្រេទី១មានមួយអញ្ញាត |
| ៤ | ហួន ណូ | ប្រុស | ព្រះវិហារ | មេរៀនទី១៣៖ មុំ |
| ៥ | ហ៊ាង សុងលាប | ប្រុស | រតនគីរី | មេរៀនទី១០៖ វិសមភាព |
| ៦ | ឡុង សុវង្ស | ប្រុស | រតនគីរី | មេរៀនទី៨៖ កន្សោមពីជគណិត |
| ៧ | ប៊ុន បញ្ញា | ប្រុស | មណ្ឌលគីរី | មេរៀនទី២១៖ ក្រាបសរសរ |
| ៨ | មាស មករា | ប្រុស | មណ្ឌលគីរី | មេរៀនទី១៤៖ បន្ទាត់ស្រប បន្ទាត់កែង |
| ៩ | ដើក ចំណាន | ប្រុស | កោះកុង | មេរៀនទី១៦៖ បរិមាត្រនិងផ្ទៃក្រឡាពហុកោណ |
| ១០ | ដោប វង្ស | ប្រុស | កោះកុង | មេរៀនទី៦៖ ភាគរយ |
| ១១ | ប៉ែន មុនីជោតិ | ប្រុស | កោះកុង | មេរៀនទី១៥៖ រូបធរណីមាត្រដែលមានវិមាត្រពីរ |
| ១២ | ស សុធា | ប្រុស | កោះកុង | មេរៀនទី១៩៖ ភាពឆ្លុះ |
| ១៣ | ស៊ីន សំរិទ្ធ | ប្រុស | កោះកុង | មេរៀនទី២៖ តួចែកនិងពហុគុណ |
| ១៤ | ហេង គីមឆេង | ប្រុស | កោះកុង | មេរៀនទី១១៖ ផលធៀបនិងសមាមាត្រ |
| ១៥ | ម៉ាត់ សាឡេះ | ប្រុស | កែប | មេរៀនទី៧៖ រង្វាស់ រង្វាល់ |
| ១៦ | លៀម ម៉េងគ្រាម | ប្រុស | កែប | មេរៀនទី១២៖ សញ្ញាណដំបូងនៃរូបធរណីមាត្រ |
| ១៧ | ជា មាន | ប្រុស | ព្រះសីហនុ | មេរៀនទី៣៖ ចំនួនគត់រ៉ឺឡាទីប |
| ១៨ | តេង សំណាង | ប្រុស | ព្រះសីហនុ | មេរៀនទី៤៖ ប្រភាគ |
| ១៩ | ម៉ៅ យ៉ា | ប្រុស | ព្រះសីហនុ | មេរៀនទី២០៖ ប្រូបាប |

ដោយឡែកចំពោះមេរៀនដែលនៅសល់មាន៖

មេរៀនទី១៖ ចំនួនគត់ ធ្វើកិច្ចតែងការបង្រៀនដោយ ម៉ាត់ សាឡេះ និង លៀម ម៉េងគ្រាម

មេរៀនទី១៧៖ រង្វង់ ដោយ ហេង គឹមឆេង

មេរៀនទី២២៖ ក្រាបផ្លិត ដោយ ស៊ីន សំរិទ្ធ

រៀបរៀងដោយ៖ ក្រុមគរុនិស្សិត បរិញ្ញា+១ ជំនាន់ទី១៧ ឯកទេស គណិត-រូប ក្រុមទី៥

ជំនួយការបច្ចេកទេសដោយ៖ លោក ម៉ៅ យ៉ា

លោក តេង សំណាង

លោក ប៉ែន មុនីជោតិ

លោក ជា មាន

និង លោក ហេង គឹមឆេង

រចនាក្របដោយ៖ លោក ប៉ែន មុនីជោតិ

# មាតិកា

**ទំព័រ**


មេរៀនទី១ ៖ ចំនួនគត់……………………………………………………………1

មេរៀនទី២ ៖ តួចែកនិងពហុគុណ………………………………………………..25

មេរៀនទី៣ ៖ ចំនួនគត់រ៉ឺឡាទីប…………………………………………………..38

មេរៀនទី៤ ៖ ប្រភាគ……………………………………………………………..53

មេរៀនទី៥ ៖ ចំនួនទសភាគ……………………………………………………….70

មេរៀនទី៦ ៖ ភាគរយ…………………………………………………………....86

មេរៀនទី៧ ៖ រង្វាស់រង្វាល់…………………………………………………………96

មេរៀនទី៨ ៖ កន្សោមពីជគណិត…………………………………………………105

មេរៀនទី៩ ៖ សមីការដឺក្រេទីមួយមានមួយអញ្ញាត……………………………..118

មេរៀនទី១០ ៖ វិសមភាព………………………………………………………..127

មេរៀនទី១១ ៖ ផលធៀបនិងសមាមាត្រ……………………………………………..131

មេរៀនទី១២ ៖ សញ្ញាណដំបូងនៃរូបធរណីមាត្រ…………………………………..140

មេរៀនទី១៣ ៖ មុំ ……………………………………………………………..157

មេរៀនទី១៤ ៖ បន្ទាត់ស្រប បន្ទាត់កែង…………………………………………….170

មេរៀនទី១៥ ៖ រូបធរណីមាត្រដែលមានវិមាត្រពីរ…………………………………186

មេរៀនទី១៦ ៖ បរិមាត្រនិងផ្ទៃក្រឡាពហុកោណ…………………………………..208

មេរៀនទី១៧ ៖ រង្វង់…………………………………………………………....216

មេរៀនទី១៨ ៖ មាឌនិងផ្ទៃក្រឡាខាងនៃសូលីត……………………………………..225

មេរៀនទី១៩ ៖ ភាពឆ្លុះ…………………………………………………………..234

មេរៀនទី២០ ៖ ប្រូបាប……………………………………………………………..238

មេរៀនទី២១ ៖ ក្រាបសរសេរ……………………………………………………..251

មេរៀនទី២២ ៖ ក្រាបផ្លិត………………………………………………………..257

# អារម្ភកថា

សួរស្តីមិត្តអ្នកអានជាទីរាប់អាន ! **សៀវភៅកិច្ចតែងការបង្រៀនគណិតវិទ្យាថ្នាក់ទី៧** ដែលលោក អ្នកកំពុងកាន់ក្នុងដៃនេះ ជាស្នាដៃថ្មីមួយរបស់ក្រុមគរុនិស្សិតកម្រិតឧត្តម បរិញ្ញា+១ ជំនាន់ទី១៧ ឯកទេស គណិតវិទ្យា- រូបវិទ្យា ក្រុមទី៥ ក្រោមគំនិតផ្តួចផ្តើមរបស់លោកសាស្ត្រាចារ្យ **ថៃ ហេង** ដែលជាសាស្ត្រាចារ្យនៃ វិទ្យាស្ថានជាតិអប់រំ។

ដោយពុំទាន់មានសៀវភៅគ្រូគណិតវិទ្យាថ្នាក់ទី៧ សមាជិកក្រុមយើងខ្ញុំបានបែងចែកចំនួនម៉ោងដើម្បីធ្វើកិច្ចតែងការបង្រៀនទៅតាមការយល់ឃើញរបស់សមាជិកម្នាក់ៗដែលទទួលខុសត្រូវតាមមេរៀននីមួយៗរៀងៗខ្លួន។ យើងខ្ញុំសង្ឃឹមថា ស្នាដៃនេះអាចទុកជាឯកសារពិគ្រោះរបស់លោកគ្រូ-អ្នកគ្រូ សម្រាប់ធ្វើកិច្ចតែងការបង្រៀនផ្ទាល់របស់ខ្លួន ដើម្បីបង្រៀនសិស្ស។

កិច្ចតែងការបង្រៀនទាំងនេះ ពុំសុទ្ធតែមានលក្ខណៈល្អឥតខ្ចោះនោះទេ វាគ្រាន់តែជាគំនិតមួយតែប៉ុណ្ណោះ។ ម្យ៉ាងទៀត ដោយបទពិសោធន៍មានកម្រិត យើងខ្ញុំជឿជាក់ថាកំហុស និងការខ្វះចន្លោះ ទាំងខ្លឹមសារក៏ដូចជាបច្ចេកទេសក្នុងការរៀបរៀងប្រាកដជាកើតមាន។ ដូច្នេះ យើងខ្ញុំសូមអភ័យទោសរាល់កំហុសឆ្គង និងការខ្វះចន្លោះទាំងនោះដែលកើតមានឡើងដោយអចេតនា។

យើងខ្ញុំសូមជូនពរដល់មិត្តអ្នកអាន ជាពិសេសលោកគ្រូ អ្នកគ្រូ ឲ្យមានសុខភាពល្អ ប្រាជ្ញាវាងវៃ ចាកផុតពីជម្ងឺបៀតបៀនទាំងឡាយ ដើម្បីក្លាយជាសរសរដ៏រឹងមាំ ជួយក្នុងកិច្ចអភិវឌ្ឍប្រាជ្ញាស្មារតី កុលបុត្រកុលធីតាខ្មែរ ឲ្យក្លាយទៅជាពលរដ្ឋល្អ ពេញសមត្ថភាព ចូលរួមក្នុងការអភិវឌ្ឍសង្គមកម្ពុជាឲ្យរុងរឿងតទៅអនាគត់។

ភ្នំពេញ ខែមិថុនា ឆ្នាំ២០១២

តំណាងអ្នករៀបរៀង

# កិច្ចតែងការបង្រៀន

**ថ្នាក់ទី** ៖ ៧
**មុខវិជ្ជា** ៖ **គណិតវិទ្យា**
**មេរៀនទី១** ៖ **ចំនួនគត់**(ម៉ោងសរុប ៨ ម៉ោង)
**រយៈពេល** ៖ **១ម៉ោង**(ម៉ោងទី១)

**I.វត្ថុបំណង**

- ចំណេះដឹង ៖ ស្គាល់ប្រព័ន្ធរាប់ដែលគេប្រើប្រាស់រាល់ថ្ងៃតាមរយៈអានមេរៀន
- បំណិន ៖ រៀបលំដាប់នៃចំនួនគត់ត្រូវទៅតាមទីតាំង
- ឥរិយាបទ ៖ សហការគ្នាដើម្បីធ្វើកិច្ចការ

**II.សម្ភារៈ**

- សៀវភៅសិស្ស ទំព័រទី១-២ បោះពុម្ពឆ្នាំ២០០៩

**III.ដំណើរការបង្រៀន**

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| | ជំហានទី១ | |
| -ពិនិត្យអវត្តមាន<br>-ពិនិត្យអនាម័យថ្នាក់រៀន<br>-ពិនិត្យសណ្តាប់ធ្នាប់ | រដ្ឋបាលថ្នាក់<br>-អវត្តមាន<br>-អនាម័យថ្នាក់រៀន<br>-សណ្តាប់ធ្នាប់និងវិន័យ | -ប្រធានថ្នាក់រាយការណ៍ |
| | ជំហានទី២ | |
| +តើលេខដែលយើងប្រើរាល់ថ្ងៃមានអ្វីខ្លះ?ជាប្រព័ន្ធរាប់អ្វី<br>+ថ្ងៃនេះយើងនិងសិក្សាលេខទាំងអស់នេះ | រំលឹកមេរៀន | +មានលេខ.........<br>+មិនដឹងប្រព័ន្ធរាប់អ្វី? |
| | ជំហានទី៣ | |
| +អោយសិស្សអានមេរៀនចំណងជើងទី១ | មេរៀនថ្មី<br>ចំនួនគត់<br>I សញ្ញាណចំនួនគត់ | +សិស្សអានមេរៀនតាមការណែនាំ |

| | | |
|---|---|---|
| +តើប្រព័ន្ធរបាប់ដែលគេប្រើសព្វថ្ងៃ ហៅថាប្រព័ន្ធរបាប់ អ្វី? | +ប្រព័ន្ធរបាប់ដែលគេប្រើសព្វថ្ងៃ ហៅថា ប្រព័ន្ធរបាប់ ហិនឌូអារ៉ាប់ | +សិស្សឆ្លើយ |
| +ប្រព័ន្ធរបាប់នេះមានប៉ុន្មានលេខ? លេខអ្វីខ្លះ? | + ប្រព័ន្ធរបាប់នេះមាន ១០ លេខ គឺពីលេខ ០ដល់លេខ ៩ | +សិស្សឆ្លើយ |
| +ចូរប្រើលេខទាំង១០ ដើម្បីបង្កើតជាចំនួន ។ | | +សិស្សពិភាក្សាដៃគូហើយឆ្លើយ ២៣,៩៥,២៣៩,៩៨១,...... |
| +គ្រូណែនាំ | +ចំនួនដែលបង្កើតបាន ហៅថា ចំនួនគត់<br>+ចំនួនគត់មាន 0 , 1 , 2 , 3 , ...<br>+ចំនួនគត់ដែលគ្មាន ០ ហៅថា ចំនួនគត់ធម្មជាតិ។<br>+គេតាងចំនួនគត់ ដោយចំណុចនៅលើបន្ទាត់មួយ ហៅថា បន្ទាត់ចំនួន<br><br> | +សិស្សស្តាប់និងកត់ត្រា |
| +ណែនាំសិស្ស អោយសង្កេតលើបន្ទាត់ចំនួន ដោយធ្វើការប្រៀបធៀបរវាងចំនួនខាងឆ្វេង និងចំនួននៅខាងស្តាំ<br>+គ្រប់ចំនួនគត់នៅខាងស្តាំ តូចជាង ឬធំជាងចំនួនគត់ដែលនៅខាងឆ្វេងវា ? | **II លំដាប់នៃចំនួនគត់**<br>+ចំនួនគត់មានច្រើនរាប់មិនអស់ | +សិស្សពិភាក្សា ដៃគូ ហើយឆ្លើយ និង កត់ត្រា |
| +បើគេរៀបឆ្លាស់លេខ 3 , 5 , 9<br>តើគេអាចបង្កើតចំនួនផ្សេងគ្នា | +ចំនួនគត់ដែលឋិតនៅខាងស្តាំ ធំជាងចំនួនគត់ដែលឋិតនៅខាងឆ្វេង<br>+ចំនួនគត់ដែលឋិតនៅខាងឆ្វេង តូចជាចំនួនគត់ដែលឋិតនៅខាងស្តាំ | +សិស្សពិភាក្សដៃគូ រួចឡើងរាយការ<br>-បានចំនួនផ្សេងគ្នា 6គឺ 359,395, |

| | | |
|---|---|---|
| បាន<br>ប៉ុន្មាន?តើចំនួនធំបំផុតស្មើប៉ុន្មាន? តូចបំផុត ស្មើប៉ុន្មាន? | -បានចំនួនផ្សេងគ្នា 6គឺ 359,395, 539,593,935,953<br>-ចំនួនដែលធំជាងគេគឺ 953<br>-ចំនួនដែលតូចជាងគេគឺ 359 | 539,593,935,953<br>-ចំនួនដែលធំជាងគេគឺ 953<br>-ចំនួនដែលតូចជាងគេគឺ 359 |
| | ជំហានទី៤ | |
| +តើប្រព័ន្ធរបាប់ដែលគេប្រើសព្វថ្ងៃ ហៅថាប្រព័ន្ធរបាប់ អ្វី?<br>+ប្រព័ន្ធរបាប់នេះមានប៉ុន្មានលេខ? លេខអ្វីខ្លះ?<br>+សិស្សរៀបឆ្លាស់លេខ 4 , 5, 9<br>-រកចំនួនធំបំផុត<br>-រកចំនួនតូចបំផុត | ពង្រឹងចំណេះដឹង | +សិស្សឆ្លើយ<br>+សិស្សឆ្លើយ<br>+សិស្សឆ្លើយ |
| | ជំហានទី៥ | |
| +សិស្សរៀបឆ្លាស់លេខ 7 , 5, 9<br>-រកចំនួនធំបំផុត<br>-រកចំនួនតូចបំផុត | កិច្ចការផ្ទះ | +សិស្សស្តាំការណែនាំ និង កត់ត្រាលំហាត់យកទៅធ្វើនៅផ្ទះ |

# កិច្ចតែងការបង្រៀន

**ថ្នាក់ទី** **៖ ៧**

**មុខវិជ្ជា** **៖ គណិតវិទ្យា**

**មេរៀនទី១** **៖ ចំនួនគត់**(ម៉ោងសរុប ៨ ម៉ោង)

**រយៈពេល** **៖ ១ម៉ោង**(ម៉ោងទី២)

**I.វត្ថុបំណង**

- ចំណេះដឹង ៖ ធ្វើប្រមាណវិធីបូក ដក លើចំនួនគត់តាមរយៈការពិភាក្សា
- បំណិន ៖ញែកចំនួនគត់គូ និងចំនួនគត់សេស,រៀបលេខឆ្លាស់
- ឥរិយាបទ ៖សហការ ពិភាក្សា ដោះស្រាយបញ្ហាដោយធ្វើប្រមាណវិធីបូក ដក

**II.សម្ភារ**

- សៀវភៅសិស្ស ទំព័រទី២-៨ បោះពុម្ពឆ្នាំ២០០៩

**III.ដំណើរការនាំមេរៀន**

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| ជំហានទី១ | | |
| -ពិនិត្យអវត្តមាន<br>-ពិនិត្យអនាម័យថ្នាក់រៀន<br>-ពិនិត្យសណ្តាប់ធ្នាប់ | រដ្ឋបាលថ្នាក់<br>-អវត្តមាន<br>-អនាម័យថ្នាក់រៀន<br>-សណ្តាប់ធ្នាប់និងវិន័យ | -ប្រធានថ្នាក់រាយការណ៍ |
| ជំហានទី២ | | |
| +ប្រព័ន្ធរាប់ដែលគេប្រើប្រាស់រាល់ថ្ងៃ ហៅថា ប្រព័ន្ធរាប់អ្វី?<br>+ប្រព័ន្ធរាប់នេះមានប៉ុន្មានលេខ? មានលេខអ្វីខ្លះ?<br>+ដូចម្តេចដែលហៅថា ចំនួនគត់ ធម្មជាតិ ? | រំលឹកមេរៀន | +សិស្សឆ្លើយ<br>+សិស្សឆ្លើយ<br>+សិស្សឆ្លើយ |
| ជំហានទី៣ | | |
| +សិស្សអានសៀវភៅត្រង់ចំណុច៣ | IIIចំនួនគត់គូ ចំនួនគត់សេស<br>ជាទូទៅ | +សិស្សអានមេរៀនតាមការណែនាំ |

| | | |
|---|---|---|
| +ដូចម្តេចដែលហៅថា ចំនួនគត់គូ? | +ចំនួនគត់គូជាចំនួនគត់ដែល ចែកដាច់និង២។ | +សិស្សឆ្លើយ |
| +ដូចម្តេចដែលហៅថាចំនួនគត់សេស?<br>+ចូររកគ្រប់ចំនួនគត់គូដែលនៅចន្លោះពី 20 ទៅ 35<br>+ចូររកគ្រប់ចំនួនគត់សេសដែលនៅ ចន្លោះពី 20 ទៅ 35 | +ចំនួនគត់សេសជាចំនួនគត់ដែល ចែកមិនដាច់និង២<br>+គឺ 22, 24, 26, 28, 30, 32, 34<br>+គឺ 21, 23, 25, 27, 29, 31, 33<br>**IV ប្រមាណវិធីលើចំនួនគត់**<br>**១.វិធីបូកនិងវិធីដកចំនួនគត់** | +សិស្សឆ្លើយ<br>+សិស្សពិភាក្សាដៃគូរួចរាយការ<br>+សិស្សពិភាក្សាដៃគូរួចរាយការ |
| +អោយសិស្សធ្វើប្រមាណវិធី<br>▪ 735+196<br>▪ $931-735$ | $735+196=931$<br>$931-735=196$ | +សិស្សពិភាក្សាដៃគូ<br>$+\begin{array}{r}735\\196\\\hline 931\end{array}$ $-\begin{array}{r}931\\735\\\hline 196\end{array}$ |
| +អោយសិស្សទាញជាលក្ខណៈទូទៅ | ជាទូទៅ<br>$a+b=c$ នោះ<br>$a=c-b$ ឬ $b=c-a$<br>$a-b=c$ នោះ<br>$a=b+c$ ឬ $b=a-c$ | +សិស្សពិភាក្សារួចរាយការ ហើយកត់ត្រា |
| +អោយសិស្សអានលំហាត់គំរូ<br>+ដើម្បីរកចំនួនភ្ញៀវសរុប ត្រូវធ្វើដូចម្តេច? | | +សិស្សអានតាមការណែនាំ<br>+ត្រូវធ្វើប្រមាណវិធីបូក |
| | ជំហានទី៤ | |
| | ពង្រឹងចំណេះដឹង | |
| +ដូចម្តេចដែលហៅថាចំនួនគត់គូ?<br>+ដូចម្តេចដែលហៅថាចំនួនគត់ | | +សិស្សឆ្លើយ<br>+សិស្សឆ្លើយ |

| | | |
|---|---|---|
| សេស?<br>+រកគ្រប់ចំនួនគត់គូ និង ចំនួនគត់ សេស នៅចន្លោះពី 7 ដល់ 17 | | +សិស្សឆ្លើយ |
| ជំហានទី៥ | | |
| +រៀបឆ្លាស់លេខ 3, 5 ,8<br>• គេបានចំនួន..............<br>• ចំនួនគត់គូមាន............<br>• ចំនួនគត់សេសមាន......<br>• ចំនួនដែលតូចជាងគេគឺ..<br>• ចំនួនដែលធំជាងគេគឺ...| កិច្ចការផ្ទះ | +សិស្សកត់ត្រា |

# កិច្ចតែងការបង្រៀន

**ថ្នាក់ទី** ៖ ៧

**មុខវិជ្ជា** ៖ **គណិតវិទ្យា**

**មេរៀនទី១** ៖ **ចំនួនគត់** (ម៉ោងសរុប ៨ ម៉ោង)

**រយៈពេល** ៖ **១ម៉ោង**(ម៉ោងទី៣)

**I.ទិន្នបំណង**

- ចំណេះដឹង ៖ស្គាល់តំណាងចែក,តួចែក,ផលចែកនិងសំណល់តាមរយៈការធ្វើប្រមាណវិធី
- បំណិន ៖ ធ្វើប្រមាណវិធីគុណ ចែកចំនួនគត់បានរហ័ស
- ឥរិយាបទ ៖ សហការ ក្នុងការធ្វើប្រមាណវិធីគុណ ចែកចំនួនគត់

**II.សម្ភារៈ**

- សៀវភៅសិស្ស ទំព័រទី៤-៦ បោះពុម្ពឆ្នាំ២០០៩

**III.ដំណើរការបង្រៀន**

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| ជំហានទី១ | | |
| -ពិនិត្យអវត្តមាន<br>-ពិនិត្យអនាម័យថ្នាក់រៀន<br>-ពិនិត្យសណ្តាប់ធ្នាប់ | រដ្ឋបាលថ្នាក់<br>-អវត្តមាន<br>-អនាម័យថ្នាក់រៀន<br>-សណ្តាប់ធ្នាប់និងវិន័យ | -ប្រធានថ្នាក់រាយការណ៍ |
| ជំហានទី២ | | |
| +គ្រូតពិនិត្យកិច្ចការផ្ទះ<br>+គណនា<br>$1/345+456=?$<br>$2/789-345=?$ | រំលឹកមេរៀន | +សិស្សយកកិច្ចការផ្ទះអោយគ្រូ គ្រូតពិនិត្យ<br>+សិស្សឡើងធ្វើប្រមាណវិធីលើក្តាខៀន |
| ជំហានទី៣ | | |
| +សិស្សធ្វើប្រមាណវិធីខាងក្រោម | **IV ២.វិធីគុណ និងវិធីចែកចំនួនគត់**<br>$1/\ 428\times 64=27392$ | +សិស្សពិភាក្សាដៃគូរួចឡើងកែលើក្តាខៀន<br>+សិស្សពិភាក្សាដៃគូរួចឡើងកែ |

| | | |
|---|---|---|
| $1/\ 428\times 64$<br><br>$2/27394\div 428$<br><br>$3/27394\div 64$<br><br>+អោយសិស្សទាញជាទូទៅ<br>-បើ $a\times b=c$ នោះ $a=.....?$<br>នោះ $b=.......?$ | $2/27392\div 428=64$<br><br>$3/27394\div 64=428$ | លើក្តាខៀន<br>+សិស្សពិភាក្សាដៃគូរួចឡើងកែលើក្តាខៀន |
| ជំហានទី៤ | | |
| +គណនា<br>$1/355+567+789$<br>$2/5406\div 128$ | | +សិស្សពិភាក្សដៃគូ រួចធ្វើប្រមាណវិធីលើក្តាខៀន |
| ជំហានទី៥ | | |
| +ធ្វើប្រមាណវិធី<br>$1/669292\div 122$<br>$2/7769\times 324\times 189$ | កិច្ចការផ្ទះ | +សិស្សកត់ត្រា |

# កិច្ចតែងការបង្រៀន

**ថ្នាក់ទី** ៖ ៧
**មុខវិជ្ជា** ៖ **គណិតវិទ្យា**
**មេរៀនទី១** ៖ **ចំនួនគត់** (ម៉ោងសរុប ៨ ម៉ោង)
**រយៈពេល** ៖ **១ម៉ោង**(ម៉ោងទី៨)

**I.វត្ថុបំណង**

- ចំណេះដឹង ៖ ស្គាល់លក្ខណៈគ្រឡប់ចំពោះប្រមាណវិធីបូក និងគុណ ព្រមទាំងស្គាល់ធាតុណឺត របស់ប្រមាណវិធីទាំងនេះ
- បំណិន ៖ ផ្តុំ និង ពន្លាតនៃប្រមាណវិធីបូក និងគុណ
- ឥរិយាបទ ៖ សហការ ក្នុងការធ្វើប្រមាណវិធីដោយការផ្តុំ និង ពន្លាត

**II.សម្ភារៈ**

- សៀវភៅសិស្ស ទំព័រទី៦-៩ បោះពុម្ពឆ្នាំ២០០៩

**III.ដំណើរការបង្រៀន**

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| | ជំហានទី១ | |
| -ពិនិត្យអវត្តមាន<br>-ពិនិត្យអនាម័យថ្នាក់រៀន<br>-ពិនិត្យសណ្តាប់ធ្នាប់ | រដ្ឋបាលថ្នាក់<br>-អវត្តមាន<br>-អនាម័យថ្នាក់រៀន<br>-សណ្តាប់ធ្នាប់និងវិន័យ | -ប្រធានថ្នាក់រាយការណ៍ |
| | ជំហានទី២ | |
| +ត្រួតពិនិត្យកិច្ចការផ្ទះ<br>+គណនា<br>$1/\ 234\times 34=$<br>$2/\ 44184\div 56=$ | រំលឹកមេរៀន | +សិស្សយកកិច្ចការផ្ទះអោយគ្រូត្រួតពិនិត្យ<br>+សិស្សឡើងធ្វើប្រមាណវិធីលើក្តារខៀន |
| | ជំហានទី៣ | |
| អោយសិស្សគណនា<br>+ក្រុមទី១ | **V លក្ខណៈនៃប្រមាណវិធី**<br>**១.លក្ខណៈនៃវិធីបូក**<br>+ក្រុមទី១ | +សិស្សពិភាក្សាតាមក្រុមរួចឡើងកែ |

| | | |
|---|---|---|
| $1/4+5=$<br>$2/2+(3+5)=$<br>$3/3+0=$<br>+ក្រុមទី២<br>$1/5+4=$<br>$2/(2+3)+5=$<br>$3/0+3=$<br>អោយសិស្សសង្កេតលទ្ធផល រួចទាញជាលក្ខណៈទូទៅ<br>$a+b=?$<br>$a+(b+c)=?$<br>$a+0$ និង $0+a$ ស្មើគ្នាឬទេ?<br>0 ជាអ្វីចំពោះប្រមាណវិធីបូក? | $1/4+5=9$<br>$2/2+(3+5)=10$<br>$3/3+0=3$<br>+ក្រុមទី២<br>$1/5+4=9$<br>$2/(2+3)+5=10$<br>$3/0+3=3$<br>ជាទូទៅ<br>$a+b=b+a$<br>$a+(b+c)=(a+b)+c$<br>$a+0=0+a$<br>0 ហៅថាធាតុណឺតចំពោះវិធីបូក | លើក្ដាខៀន<br>+សិស្សឆ្លើយរាងខ្លួនឬពិភាក្សាក្រុម រួចឆ្លើយ |
| | **២.លក្ខណៈនៃវិធីគុណ**<br>**អោយសិស្សគុណនា** | +សិស្សពិភាក្សាតាមក្រុមរួចឡើងកែ លើក្ដាខៀន |
| +ក្រុមទី១<br>$1/4\times5=$<br>$2/2\times(3\times5)=$<br>$3/(3+4)\times5=$<br>$4/3\times1=$<br>+ក្រុមទី២<br>$1/5\times4=$<br>$2/(2\times3)\times5=$<br>$3/3\times5+4\times5=$<br>$4/1\times3=$<br>អោយសិស្សសង្កេតលទ្ធផល រួចទាញជាលក្ខណៈទូទៅ<br>$a\times b=?$<br>$a\times(b\times c)=?$<br>$(a+b)\times c=?$<br>$a\times1$ និង $1\times a$ ស្មើគ្នាឬទេ?<br>1 ជាអ្វីចំពោះប្រមាណវិធីគុណ? | +ក្រុមទី១<br>$1/4\times5=20$<br>$2/2\times(3\times5)=30$<br>$3/(3+4)\times5=35$<br>$4/3\times1=3$<br>+ក្រុមទី២<br>$1/5\times4=20$<br>$2/(2\times3)\times5=30$<br>$3/3\times5+4\times5=35$<br>$4/1\times3=3$<br>ជាទូទៅ<br>$a\times b=b\times a$ លក្ខណៈត្រឡប់<br>$a\times(b\times c)=(a\times b)\times c$ លក្ខណៈផ្ដុំ<br>$(a+b)\times c=a\times c+b\times c$ លក្ខណៈពន្លាត<br>$a\times1=1\times a$ ,1 ជាធាតុណឺតនៃវិធីគុណ | +សិស្សអាចឆ្លើយរៀងខ្លួន ឬពិភាក្សា ដៃគូរួចឆ្លើយ<br>+សិស្សចែកជា ៣ឬ៤ ក្រុមពិភាក្សារក |

| | | |
|---|---|---|
| លំហាត់គំរូ<br>+ចានមួយមានគ្រាប់ឃ្លីច្រើនជាង ៨០ ប៉ុន្តែតិចជាង ៩០ ហើយស្មើ និង ៧ ដងនៃផលបូកតួលេខនៃចំនួនឃ្លីទាំងអស់។<br>តើគ្រាប់ឃ្លីក្នុងចានមានប៉ុន្មានគ្រាប់? | +គ្រាប់ឃ្លីមាន៨៤គ្រាប់ព្រោះ<br>$80 < 84 < 90$<br>ដោយដោយសា $(8+4)\times 7 = 84$ | ចំលើយ |
| ជំហានទី៤ | | |
| គណនា<br>$1/\ 123+45=$<br>$2/\ (65+23)\times 5=$<br>$3/ 7\times 8\times 9=$ | $1/\ 123+45=5535$<br>$2/\ (65+23)\times 5 = 88\times 5 = 440$<br>$3/ 7\times 8\times 9 = 504$ | +សិស្សពិភាក្សាដៃគូរួចរាយការ |
| ជំហានទី៥ | | |
| +គេដាក់ផ្លែក្រូចក្នុងកេះធំបីដែលក្នុងមួយកេះផ្ទុកក្រូច ៩៨ ផ្លែ និងដាក់ក្នុងកេះតូចពីរ ដែលក្នុងមួយកេះផ្ទុកផ្លែក្រូច ២៤ផ្លែ ។ តើក្រូចមានប៉ុន្មានផ្លែ? | កិច្ចការផ្ទះ | +សិស្សកត់ត្រា |

# កិច្ចតែងការបង្រៀន

**ថ្នាក់ទី** : ៧

**មុខវិជ្ជា** : **គណិតវិទ្យា**

**មេរៀនទី១** : **ចំនួនគត់** (ម៉ោងសរុប ៨ ម៉ោង)

**រយៈពេល** : **១ម៉ោង**(ម៉ោងទី៥)

## I.វត្ថុបំណង

- ចំណេះដឹង : ធ្វើប្រមាណវិធីទាំង៤នៃចំនួនគត់ដែលមានដង្កៀប រង់ក្រចក
- បំណិន : ធ្វើប្រមាណវិធីបានរហ័សនូវកន្សោមដែលមានដង្កៀប
- ឥរិយាបទ : ចូលរួមសហការដោះស្រាយលំហាត់

## II.សម្ភារ

- សៀវភៅសិស្ស ទំព័រទី៩-១០ បោះពុម្ពឆ្នាំ២០០៩

## III.ដំណើរការនាំមេរៀន

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| ជំហានទី១ | | |
| -ពិនិត្យអវត្តមាន<br>-ពិនិត្យអនាម័យថ្នាក់រៀន<br>-ពិនិត្យសណ្តាប់ធ្នាប់ | រដ្ឋបាលថ្នាក់<br>-អវត្តមាន<br>-អនាម័យថ្នាក់រៀន<br>-សណ្តាប់ធ្នាប់និងវិន័យ | -ប្រធានថ្នាក់រាយការណ៍ |
| ជំហានទី២ | | |
| +គ្រូតពិនិត្យកិច្ចការផ្ទះ<br>+គណនា<br>$1/345\times 456=?$<br>$2/(12+23)\times 7=?$ | រំលឹកមេរៀន | +សិស្សយកកិច្ចការផ្ទះអោយគ្រូ គ្រូតពិនិត្យ<br>+សិស្សឡើងធ្វើប្រមាណវិធីលើក្តាខៀន |
| ជំហានទី៣ | | |
| <u>គណនា</u><br>$1/\ 3+5-2=$<br>$2/12-2+10-3=$<br>+ចំពោះកន្សោមដែលមានតែវិធី បូក និងវិធីដក | **VI លំដាប់នៃប្រមាណវិធី**<br>គណនា<br>$1/\ 3+5-2=8-2=6$<br>$2/12-2+10-3=10+7=17$<br>ជាទូទៅ<br>ចំពោះកន្សោមដែលមានតែវិធីបូក | +សិស្សឆ្លើយ<br>+ចំពោះកន្សោមដែលមានតែវិធី បូក និងវិធីដក គេត្រូវធ្វើប្រមាណ |

| | | |
|---|---|---|
| គេត្រូវធ្វើប្រមាណវិធីខាងណាទៅខាងណា?<br><u>គណនា</u><br>$1/6\times 12\div 4=$<br>$2/125\div 5\times 15=$<br><br>+ចំពោះកន្សោមដែលមានតែវិធី គុណ និងវិធីចែកគេត្រូវធ្វើប្រមាណវិធីដូចម្តេច?<br><u>គណនា</u><br>$52-4\times 12+18\div 6\times 3=$<br><br>+ចំពោះកន្សោមមានប្រមាណវិធី ទាំង៤ គេត្រូវធ្វើប្រមាណវិធីដូច ម្តេច?<br><u>គណនា</u><br>$12-(4\times 3-2)+9=$<br><br>+ចំពោះកន្សោមមនវង់ក្រចក គេត្រូវធ្វើប្រមាណវិធីដូចម្តេច?<br><br><u>គណនា</u><br>$[(3+6)\div(5-2)+8]\times(19-3)$ | និងវិធី ដកគេត្រូវធ្វើប្រមាណវិធីពីឆ្វេង ទៅស្តាំ។<br>គណនា<br>$1/6\times 12\div 4=72\div 4=18$<br>$2/125\div 5\times 15=25\times 15=375$<br>ជាទូទៅ<br>ចំពោះកន្សោមដែលមានតែវិធីគុណនិង វិធីចែកគេត្រូវធ្វើប្រមាណវិធីពីឆ្វេងទៅ ស្តាំ<br>គណនា<br>$52-4\times 12+18\div 6\times 3$<br>$=52-48+3\times 3$<br>$=4+9$<br>$=13$<br>ជាទូទៅ<br>ចំពោះកន្សោមមានប្រមាណវិធីទាំង៤ គេ ត្រូវធ្វើប្រមាណវិធីគុណឬចែកមុនវិធីបូក ដក ពីឆ្វេងទៅស្តាំ។<br><u>គណនា</u><br>$12-(4\times 3-2)+9$<br>$=12-(12-2)+9$<br>$=12-10+9$<br>$=2+9$<br>$=11$<br>ជាទូទៅ<br>ចំពោះកន្សោមវង់ក្រចក គេត្រូវធ្វើប្រមាណវិធីក្នុងវង់ក្រចកជាមុនសិន<br><br><u>គណនា</u> | វិធីពីឆ្វេង ទៅស្តាំ។<br><br>+សិស្សគិតរៀងខ្លួនរួចឡើងកែ<br><br>+សិស្សពិភាក្សាដៃគូរួចឆ្លើយ<br><br>+សិស្សគិតទាំងអស់គ្នា រួចអោយសិស្សពានាក់ឡើងកែលើលំហាត់តែ១<br><br>+សិស្សពិភាក្សាជាក្រុមរួចឆ្លើយ<br><br>+សិស្សគិតរួចឡើងកែពនាក់<br><br>+សិស្សគិតរួចឆ្លើយ<br><br>+សិស្សពិភាក្សាដៃគូរួចឆ្លើយ |

| | | |
|---|---|---|
| +ចំពោះកន្សោមមានដង្កៀបនិងវង់ ក្រចក គេត្រូវធ្វើដូចម្ដេច? | $[(3+6)\div(5-2)+8]\times(19-13)$<br>$=[9\div3+8]\times6$<br>$=[3+8]\times6$<br>$=11\times6$<br>$=66$<br>ជាទូទៅ<br>កន្សោមមួយមានវង់ក្រចកនិងដង្កៀប គេ ត្រូវធ្វើប្រមាណវិធីក្នុងវង់ក្រចក ដែល នៅក្នុងដង្កៀប ជាមុន។ | +សិស្សពិភាក្សារួចឆ្លើយ |
| ជំហានទី៤ | | |
| គណនា<br>$1/\ 15-4+2=$<br>$2/6\times3\div2=$<br>$3/4+(5-2)\times3=$<br>$4/[6+(5-2)\times4]\div(7-4)=$ | $1/\ 15-4+2=11+2=13$<br>$2/6\times3\div2=18\div2=9$<br>$3/4+(5-2)\times3=4+3\times3=13$<br>$4/[6+(5-2)\times4]\div(7-4)$<br>$=[6+3\times4]\div3$<br>$=18\div3=6$ | +សិស្សឡើងកែលើក្ដាខៀន |
| ជំហានទី៥ | | |
| +អោយសិស្សធ្វើលំហាត់នៅទំព័រទី១៤លំហាត់លេខ ២ | កិច្ចការផ្ទះ | +សិស្សកត់ត្រា |

# កិច្ចតែងការបង្រៀន

**ថ្នាក់ទី** ៖ ៧

**មុខវិជ្ជា** ៖ **គណិតវិទ្យា**

**មេរៀនទី១** ៖ **ចំនួនគត់** (ម៉ោងសរុប ៨ ម៉ោង)

**រយៈពេល** ៖ **១ម៉ោង**(ម៉ោងទី៦)

**I.វត្ថុបំណង**

- ចំណេះដឹង ៖ ប្រាប់បានពីលំដាប់នៃប្រមាណវិធី
- បំណិន ៖ គណនាកន្សោមលេខតាមលំដាប់នៃប្រមាណវិធី
- ឥរិយាបទ ៖ ទម្លាប់សិស្ស មានបម្រុងប្រយ័ត្នក្នុងការសិក្សា

**II.សម្ភារ**

- សៀវភៅសិស្ស ទំព័រទី៩-១០ បោះពុម្ពឆ្នាំ២០០៩

**III.ដំណើរនាំមេរៀន**

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| | ជំហានទី១ | |
| -ពិនិត្យអវត្តមាន<br>-ពិនិត្យអនាម័យថ្នាក់រៀន<br>-ពិនិត្យសណ្តាប់ធ្នាប់ | រដ្ឋបាលថ្នាក់<br>-អវត្តមាន<br>-អនាម័យថ្នាក់រៀន<br>-សណ្តាប់ធ្នាប់និងវិន័យ | -ប្រធានថ្នាក់រាយការណ៍ |
| | ជំហានទី២ | |
| +ត្រួតពិនិត្យកិច្ចការផ្ទះ<br>+គណនា<br>$1/345\times 456=?$<br>$2/(12+23)\times 7=?$ | រំលឹកមេរៀន | +សិស្សយកកិច្ចការផ្ទះអោយគ្រូត្រួតពិនិត្យ<br>+សិស្សឡើងធ្វើប្រមាណវិធីលើក្តាខៀន |
| | ជំហានទី៣ | |
| <u>គណនា</u><br>$1/\ 3+5-2=$<br>$2/12-2+10-3=$<br>+ចំពោះកន្សោមដែលមានតែវិធី បូក និងវិធីដក | **VI លំដាប់នៃប្រមាណវិធី**<br>គណនា<br>$1/\ 3+5-2=8-2=6$<br>$2/12-2+10-3=10+7=17$<br>ជាទូទៅ<br>ចំពោះកន្សោមដែលមានតែវិធីបូក | +សិស្សឆ្លើយ<br>+ចំពោះកន្សោមដែលមានតែវិធី បូក និងវិធីដក គេត្រូវធ្វើប្រមាណ |

| | | |
|---|---|---|
| គេត្រូវធ្វើប្រមាណវិធីខាងណាទៅខាងណា?<br>គណនា<br>$1/6\times12\div4=$<br>$2/125\div5\times15=$<br><br>+ចំពោះកន្សោមដែលមានតែវិធី គុណ និងវិធីចែកគេត្រូវធ្វើប្រមាណវិធីដូចម្តេច?<br>គណនា<br>$52-4\times12+18\div6\times3=$<br><br>+ចំពោះកន្សោមមានប្រមាណវិធី ទាំង៤ គេត្រូវធ្វើប្រមាណវិធីដូច ម្តេច?<br>គណនា<br>$12-(4\times3-2)+9=$<br><br>+ចំពោះកន្សោមមនវង់ក្រចក គេត្រូវធ្វើប្រមាណវិធីដូចម្តេច?<br>គណនា<br>$[(3+6)\div(5-2)+8]\times(19-3)$ | និងវិធី ដកគេត្រូវធ្វើប្រមាណវិធីពីឆ្វេង ទៅស្តាំ។<br>គណនា<br>$1/6\times12\div4=72\div4=18$<br>$2/125\div5\times15=25\times15=375$<br>ជាទូទៅ<br>ចំពោះកន្សោមដែលមានតែវិធីគុណនិង វិធីចែកគេត្រូវធ្វើប្រមាណវិធីពីឆ្វេងទៅ ស្តាំ<br>គណនា<br>$52-4\times12+18\div6\times3$<br>$=52-48+3\times3$<br>$=4+9$<br>$=13$<br>ជាទូទៅ<br>ចំពោះកន្សោមមានប្រមាណវិធីទាំង៤ គេ<br>ត្រូវធ្វើប្រមាណវិធីគុណឬចែកមុនវិធី បូក ដក ពីឆ្វេងទៅស្តាំ។<br>គណនា<br>$12-(4\times3-2)+9$<br>$=12-(12-2)+9$<br>$=12-10+9$<br>$=2+9$<br>$=11$<br>ជាទូទៅ<br>ចំពោះកន្សោមវង់ក្រចក គេត្រូវធ្វើប្រមាណវិធីក្នុងវង់ក្រចកជាមុនសិន<br><br>គណនា | វិធីពីឆ្វេង ទៅស្តាំ។<br><br>+សិស្សគិតរៀងខ្លួនរួចឡើងកែ<br><br>+សិស្សពិភាក្សាដៃគូរួចឆ្លើយ<br><br>+សិស្សគិតទាំងអស់គ្នា រួចអោយសិស្សពនាក់ឡើងកែលើលំហាត់តែ១<br><br>+សិស្សពិភាក្សាជាក្រុមរួចឆ្លើយ<br><br>+សិស្សគិតរួចឡើងកែពនាក់<br><br>+សិស្សគិតរួចឆ្លើយ<br><br>+សិស្សពិភាក្សាដៃគូរួចឆ្លើយ |

| | | |
|---|---|---|
| +ចំពោះកន្សោមមានដង្កៀបនិងវង់ ក្រចក គេត្រូវធ្វើដូចម្តេច? | $[(3+6)\div(5-2)+8]\times(19-13)$<br>$=[9\div 3+8]\times 6$<br>$=[3+8]\times 6$<br>$=11\times 6$<br>$=66$<br>ជាទូទៅ<br>កន្សោមមួយមានវង់ក្រចកនិងដង្កៀប គេ ត្រូវធ្វើប្រមាណវិធីក្នុងវង់ក្រចកដែល នៅក្នុងដង្កៀប ជាមុន។ | +សិស្សពិភាក្សារួចឆ្លើយ |
| ជំហានទី៤ | | |
| គណនា<br>1/ $15-4+2=$<br>2/ $6\times 3\div 2=$<br>3/ $4+(5-2)\times 3=$<br>4/ $[6+(5-2)\times 4]\div(7-4)=$ | 1/ $15-4+2=11+2=13$<br>2/ $6\times 3\div 2=18\div 2=9$<br>3/ $4+(5-2)\times 3=4+3\times 3=13$<br>4/ $[6+(5-2)\times 4]\div(7-4)$<br>$=[6+3\times 4]\div 3$<br>$=18\div 3=6$ | +សិស្សឡើងកែលើក្តាខៀន |
| ជំហានទី៥ | | |
| +អោយសិស្សធ្វើលំហាត់ នៅទំព័រទី១៤លំហាត់លេខ ២ | កិច្ចការផ្ទះ | +សិស្សកត់ត្រា |

# កិច្ចតែងការបង្រៀន

*មុខវិជ្ជា: គណិតវិទ្យា ថ្នាក់ទី៧*

*ថ្ងៃ............ទី........ខែ.........ឆ្នាំ............*

I.*ចំណងជើងមេរៀន:* មេរៀនទី១ **ចំនួនគត់** ( **ត** )

*ចំណងជើងរង:* ៧. ការបង្គត់ចំនួនគត់

II.*វត្ថុបំណង:*ក្រោយពីរៀនចប់មេរៀននេះចប់សិស្សអាច

-ចំណេះដឹង:ប្រាប់ពីការបង្គត់ចំនួន។

-បំណិន:ចេះបង្គត់ចំនួនគត់។

-ឥរិយាបថ:មានទំនាក់ទំនងល្អរវាងសិស្សនិងសិស្សព្រមទាំងរវាងគ្រូនិងសិស្ស។

III.*ពេលវេលា* ១ ម៉ោង ( ម៉ោងទី៧ )

IV.សម្ភារ:ឧបទេស

-បន្ទាត់ក្រឹត។

V. *ដំណើរការនៃមេរៀន:*

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាព |
|---|---|---|
| គ្រូតពិនិត្យអវត្តមានអនាម័យនិងសណ្តាប់ធ្នាប់វិន័យ | ជំហានទី១ (រដ្ឋបាលថ្នាក់) | តំនាងថ្នាក់ឡើងរាយការណ៍ |
| -តើកន្សោមមួយមានវង់ក្រចកគេត្រូវធ្វើដូចម្តេច ?<br>-គណនាកន្សោម:<br>$A=56\div 8+(47-17)\div 5-13$ | ជំហានទី២ (រំលឹកមេរៀនចាស់) | -បើកន្សោមមួយមានវង់ក្រចកគេត្រូវធ្វើប្រមាណវិធី ក្នុងវង់ក្រចកជាមុនសិន។<br>គណនា<br>$A=56\div 8+(47-17)\div 5-13$<br>គេបាន<br>$A=7+30\div 5-13$<br>$=7+6-13=13-13=0$<br>$A=0$ |

<table>
<tr>
<td>គ្រូសរសេរចំណងជើងមេរៀនដាក់លើក្តាខៀន<br><br>-ដាក់ឧទាហរណ៏ទី១ឲ្យសិស្សសង្កេត និងបង្គត់ចំនួនយកត្រឹមខ្ទង់ដប<br>+តើ 647 នៅជិត 650 ជាងឬនៅជិត 640 ជាង? រួចដៅបង្ហាញលើអក្ស<br>+តើ 2931 នៅជិត 2900 ជាងឬនៅជិត 3000 ជាង? រួចដៅបង្ហាញលើអក្ស<br><br><br>ឲ្យសិស្សទាញជាទូទៅដោយពឹងផ្អែកលើកាសិក្សាឧទាហរណ៏ខាងលើ</td>
<td><u>ជំហានទី៣</u> (មេរៀនប្រចាំថ្ងៃ)<br>មេរៀនទី១ ចំនួនគត់<br>៧.ការបង្គត់ចំនួនគត់<br>Exបង្គត់ចំនួនខាងក្រោម<br>ក) 647 យកត្រឹមខ្ទង់ដប់<br>ខ) 2931 យកត្រឹមខ្ទង់រយ<br><br><br><br><br><br><br><br><br>ជាទូទៅ:<br>+ដើម្បីបង្គត់ចំនួនគត់យកត្រឹមខ្ទង់ដប់ គេពិនិត្យលេខខ្ទងរាយ។ បើវាតូចជាង 5 គេជំនួសដោយលេខ 0 ។បើវាធំជាងឬស្មើនឹង 5 គេបន្ថែម 1 ទៅលើខ្ទង់ដប់ហើយជំនួសខ្ទង់រាយដោយសូន្យ ។<br>+ដើម្បីបង្គត់ចំនួនគត់យកត្រឹមខ្ទង់រយ គេពិនិត្យលេខខ្ទង់ដប់ ។បើវាតូចជាង 5 គេជំនួសលេខខ្ទង់ដប់និងខ្ទង់រាយដោយ 0 ។បើវាធំជាងឬស្មើនឹង 5 គេបន្ថែម 1 ទៅលើខ្ទង់រយ ហើយជំនួសលេខខ្ទង់ដប់ និងខ្ទង់រាយដោយ 0 ។</td>
<td><br><br><br>-បង្គត់ចំនួនខាងក្រោម:<br>ក) 647 យកត្រឹមខ្ទង់ដប់ដោយ 647 នៅជិតជាង 650 ជាងជាង 640 ។ដូចនេះ $647 \approx 650$<br><br><br>បង្គត់ឡើង<br>ខ) 2931 យកត្រឹមខ្ទង់រយ 2931 នៅជិត 2900 ជាង 3000 ។<br>ដូចនេះ $2931 \approx 2900$<br><br><br><br>ជាទូទៅ:<br>+ដើម្បីបង្គត់ចំនួនគត់យកត្រឹមខ្ទង់ដប់គេពិនិត្យលេខខ្ទង់រាយ។<br>បើវាតូចជាង 5 គេជំនួសដោយលេខ<br>0 ។បើវាធំជាងឬស្មើនឹង 5 គេបន្ថែម 1 ទៅលើខ្ទង់ដប់ហើយជំនួសខ្ទង់រាយដោយសូន្យ ។<br>+ដើម្បីបង្គត់ចំនួនគត់យកត្រឹមខ្ទង់រយ គេពិនិត្យលេខខ្ទង់ដប់ ។បើវាតូចជាង 5 គេជំនួសលេខខ្ទង់ដប់និងខ្ទង់រាយដោយ 0 ។បើវាធំជាងឬស្មើ</td>
</tr>
</table>

| | | |
|---|---|---|
| +ដាក់ឧទាហរណ៍ទី២ឲ្យសិស្សសង្កេត និងបង្គត់ចំនួនយកត្រឹមខ្ទង់រយ រួចហើយយកត្រឹមខ្ទង់ពាន់។<br><br>+ឲ្យសិស្សពិនិត្យមើលខ្ទង់រយនៃចំនួន15824គឺត្រូវនឹងលេខប៉ុន្មាន? បន្ថែមដូចម្ដេច? | ឧទាហរណ៍:<br>បង្គត់ចំនួន15824យកត្រឹមខ្ទង់រយ រួចហើយយកត្រឹមខ្ទង់ពាន់។ | នឹង 5គេបន្ថែម1ទៅលើខ្ទង់រយ ហើយជំនួសលេខខ្ទង់ដប់និងខ្ទង់រាយដោយ 0។<br>+បង្គត់ចំនួន 15824យកត្រឹមខ្ទង់រយ យើងមាន15824 ដោយខ្ទង់ដប់គឺលេខ 2គឺតូចជាង 5នោះគេជំនួសខ្ទង់ដប់ និងខ្ទង់រាយដោយ 0<br>ដូចនេះ15824 = 15800<br>បង្គត់ចំនួន 15824យកត្រឹមខ្ទង់ពាន់ដោយចំនួន15824 មានលេខ8នៅខ្ទង់រយធំជាង 5គេបន្ថែម1លើខ្ទង់ពាន់ហើយជំនួសលេខ 0លើខ្ទង់រាយ ខ្ទង់ដប់ និងខ្ទង់រាយ។<br>ដូចនេះ 15824 = 16000 |
| -ដើម្បីបង្គត់ចំនួនគត់យកត្រឹមខ្ទង់ដប់ តើគេត្រូវធ្វើដូចម្ដេច?<br><br>-ដើម្បីបង្គត់ចំនួនគត់យកត្រឹមខ្ទង់រយ តើគេត្រូវធ្វើដូចម្ដេច? | <u>ជំហានទី៤</u> (ពង្រឹងចំនេះដឹង) | + ដើម្បីបង្គត់ចំនួនគត់យកត្រឹមខ្ទង់ដប់ គេពិនិត្យលេខខ្ទងរាយ។បើវាតូចជាង 5គេជំនួសដោយលេខ 0។បើវាធំជាងឬស្មើនឹង5គេបន្ថែម 1ទៅលើខ្ទង់ដប់ហើយជំនួសខ្ទង់រាយដោយសូន្យ ។<br>+ ដើម្បីបង្គត់ចំនួនគត់យកត្រឹមខ្ទង់រយ គេពិនិត្យលេខខ្ទង់ដប់ ។បើវាតូចជាង5គេជំនួសលេខខ្ទង់ដប់និងខ្ទង់រាយដោយ 0។បើវាធំជាងឬស្មើនឹង 5 គេបន្ថែម1ទៅលើខ្ទង់រយ ហើយជំនួសលេខខ្ទង់ដប់ និងខ្ទង់រាយដោយ 0។ |

| | | |
|---|---|---|
| | | |
| គ្រូដាក់លំហាត់ឲ្យសិស្សធ្វើនៅផ្ទះ<br>លំហាត់:បង្គត់ចំនួនខាងក្រោមយកត្រឹមខ្ទង់ដប់ ខ្ទង់រយ និងខ្ទង់ពាន់<br>ក) 7663692<br>ខ) 996972<br>អោយសិស្សធ្វើនៅផ្ទះនិងណែនាំសិស្សឲ្យគោរពវិន័យនិងច្បាប់ចរាចរណ៍។ | ជំហានទី៥ (កិច្ចការផ្ទះ)<br>លំហាត់ទី១/២/៣ទំព័រ៥០ | សិស្សកត់ត្រាលំហាត់និងស្តាប់ដំបូន្មានគ្រូ |

## កិច្ចតែងការបង្រៀន

*មុខវិជ្ជា:* *គណិតវិទ្យា ថ្នាក់ទី៧*

*ថ្ងៃ*............*ទី*........*ខែ*.........*ឆ្នាំ*............

I.*ចំណងជើងមេរៀន:* មេរៀនទី១ **ចំនួនគត់** ( **គចប់** )

*ចំណងជើងរង:* ៨.ការេនិងគូប

៨.១.ការេនិងគូប

៨.២.ឬសការេនិងឬសគូប

៨.៣.ការគណនាដោយប្រើម៉ាស៊ីនគិតលេខ

II.*វត្ថុបំណង:*ក្រោយពីរៀនចប់មេរៀននេះចប់សិស្សអាច

-ចំណេះដឹង:សិស្សស្គាល់ការេ គូប និងឬសការេ ឬសគូបតាមរយ:ខ្លឹមសារមេរៀន។

-បំណិន:គណនាការេ គូប និងឬសការេ ឬសគូបតាមរយ:ពន្យល់និងក្រុមពិភាក្សា។

-ឥរិយាបថ:មានទំនាក់ទំនងល្អរវាងសិស្សនិងសិស្សព្រមទាំងរវាងគ្រូនិងសិស្ស។

III.*ពេលវេលា*០១ម៉ោង (ម៉ោងទី៨)

IV.សម្ភារ:ឧបទេស

-បន្ទាត់ក្រឹត។

V. *ដំណើកនាំមេរៀន:*

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាព |
|---|---|---|
| គ្រូតពិនិត្យអវត្តមានអនាម័យនិងសណ្តាប់ធ្នាប់វិន័យ | <u>ជំហានទី</u>១ (រដ្ឋបាលថ្នាក់) | តំនាងថ្នាក់ឡើងរាយការណ៍ |
| -សរសេរលំហាត់លើក្តាខៀនឲ្យសិស្សគណនា:<br>+ចូរបង្គត់ចំនួនខាងក្រោមយកត្រឹមខ្ទង់ដប់ រយ ពាន់<br>ក) 7663692 | <u>ជំហានទី</u>២ (រំលឹកមេរៀនចាស់) | -ត្រៀមធ្វើលំហាត់<br>+បង្គត់ចំនួនខាងក្រោម:<br>ខ្ទង់ដប់ 7663690<br>ខ្ទង់រយ 7663700<br>ខ្ទង់ពាន់ 7664000 |

| | | |
|---|---|---|
| | <u>ជំហានទី៣</u> (មេរៀនប្រចាំថ្ងៃ) | |
| +សំណួរបំផុស: | មេរៀនទី១ ចំនួនគត់ | |
| +ដើម្បីគណនាក្រឡាផ្ទៃការេ គេត្រូវធ្វើដូចម្តេច? | ៨.ការេ គូប និងឫសការេ ឫសគូប<br>៨.១. ការេ និងគូប | +ស្តាប់សំនួរ |
| +ដើម្បីគណនាមាឌប្រលេពីប៉ែតកែង គេត្រូវធ្វើដូចម្តេច ? | | +ដើម្បីគណនាក្រឡាផ្ទៃការេ គេត្រូវយកជ្រុងគុណនឹងជ្រុង |
| +គ្រូដាក់ឧទាហរណ៍ឲ្យសិស្សគណនា | Ex គណនាក្រឡាផ្ទៃការេ និងមាឌគូបនៃរូបខាងក្រោម:<br> | +ដើម្បីគណនាមាឌប្រលេពីប៉ែតកែងគេត្រូវយកបណ្តោយគុណនឹងទទឹងគុណនឹងកំពស់<br>+គណនាក្រឡាផ្ទៃការេ គេបាន<br>$S=5\times5=25cm^2$<br>+មាឌគូបគេបាន<br>$V=5\times5\times5=125cm^3$ |
| +ណែនាំសិស្សឲ្យស្គាល់ការេនិងគូប<br>$+5\times5=5^2$ អានថា 5 ការេ<br>$+5\times5\times5=5^3$ អានថា 5 គូប | $+5\times5=5^2$ អានថា 5 ការេ<br>$+5\times5\times5=5^3$ អានថា 5 គូប<br>៨.២.ឫសការេនិងឫសគូប | +សង្កេតការណែនាំរបស់គ្រូដោយយកចិត្តទុកដាក់ |
| ណែនាំសិស្សឲ្យស្គាល់ពីឫសការេ និងឫសគូប | | សង្កេតការណែនាំ |
| +គេមាន $5\times5=5^2=25$, 5 ហៅថាឫសការេនៃ 25<br>+គេមាន $2\times2\times2=2^3=8$, 2 ហៅថាឫសគូបនៃ 8<br>+ឲ្យសិស្សទាញជាទូទៅ | +គេមាន $5\times5=5^2=25$, 5 ហៅថាឫសការេនៃ 25<br>+គេមាន $2\times2\times2=2^3=8$, 2 ហៅថាឫសគូបនៃ 8<br>**ជាទូទៅ:**<br>+បើ $x^2=a$ គេបាន $x=\sqrt{a}, a\geq0$<br>+បើ $x^3=a$ គេបាន $x=\sqrt[3]{a}$ | ពិនិត្យរួចកត់ត្រា |
| ធ្វើកំណត់ស្គាល់ឲ្យសិស្ស | **សំគាល់:** $\sqrt{a},\sqrt[3]{b}, a\geq0$<br>+សញ្ញា $\sqrt{\ }, \sqrt[3]{\ }$ ហៅថារ៉ាឌីកាល់<br>$+a,b$ ហៅថារ៉ាឌីកង់<br>៨.៣.ការគណនាដោយប្រើម៉ាស៊ីនគិតលេខ | សង្កេតនិងស្តាប់ |
| +ដាក់ឧទាហរណ៍:ដោយប្រើម៉ាស៊ីន | | |

| | | |
|---|---|---|
| គិតលេខគណនា:<br>$+\sqrt{625}$ គេបាន:ចុច 625រួចចុច ញ្ញា $\sqrt{\ }$ បានលទ្ធផល 25<br>$+9^2$ គេបាន: ចុច $9\times9$ លទ្ធផល 81 | $+\sqrt{625}=\sqrt{25^2}=25$<br>$+9^2=9\times9=81$ | គណនាដោយប្រើម៉ាស៊ីនគិតលេខ<br>$+\sqrt{625}$ គេបាន:ចុច 625រួចចុច ញ្ញា $\sqrt{\ }$ បានលទ្ធផល 25<br>$+9^2$ គេបាន: ចុច $9\times9$ លទ្ធផល 81 |
| -គណនាការេ គូប និងឫសការេ ឫសគូបខាងក្រោម:<br>$+4^2$<br>$+3^3$<br>$+\sqrt{25}$<br>$+\sqrt[3]{64}$ | <u>ជំហានទី៤</u> (ពង្រឹងចំនេះដឹង)<br>$+4^2=4\times4=16$<br>$+3^3=3\times3\times3=27$<br>$+\sqrt{25}=\sqrt{5^2}=5$<br>$+\sqrt[3]{64}=\sqrt[3]{4^3}=4$ | + គណនា<br>$+4^2=4\times4=16$<br>$+3^3=3\times3\times3=27$<br>$+\sqrt{25}=\sqrt{5^2}=5$<br>$+\sqrt[3]{64}=\sqrt[3]{4^3}=4$ |
| ពេលទៅផ្ទះធ្វើលំហាត់លេខ 8 និង 9 ។ | <u>ជំហានទី៥</u> (កិច្ចការផ្ទះ)<br>ធ្វើលំហាត់លេខ 8 និង 9 ។ | សិស្សកត់ត្រាលំហាត់និងស្តាប់ដំបូន្មានគ្រូ |

# កិច្ចតែងការបង្រៀន

មុខវិជ្ជា: គណិតវិទ្យា

ថ្នាក់ទី7

I. ចំណងជើងមេរៀន មេរៀនទី2 តួចែកនិងពហុគុណ

ចំណងជើងរង 1 លក្ខណ:ចែកដាច់នៃចំនួនគត់

II. វត្ថុបំណង ក្រោយពីរៀនចប់សិស្សអាច

- ចំណេះដឹង: សិស្សចេះពីភាពចែកដាច់នឹង2, នឹង5 ភាពចែកដាច់នឹង3,នឹង9,
- ចំនេះធ្វើ: សិស្សអាចធ្វើលំហាត់បានយ៉ាងងាយ តាមរយ:ឧទាហរណ៍
- ឥរិយាបទ: សិស្សសហកាពណ៌ដោះស្រាយលំហាត់បានដោយមានភាពជឿជាក់

III រយ:ពេល: 100 នាទ

IV សម្ភារ:ឧបទេស: សៀវភៅសិស្ស ទំព័រ 15

V តំណើរការនៃការបង្រៀន:

| សកម្មភាពគ្រូ | ខ្លឹមសាសំខាន់ៗ | សកម្មភាពសិស្ស |
|---|---|---|
| ពិនិត្យអវត្តមាន សណ្តាប់ធ្នាប់ និង អនាម័យថ្នាក់រៀន | ជំហានទី 1 (3នាទី)<br>ថ្នាក់រដ្ឋបាល | សិស្សច្បងរាយការណ៍ |
| -<br>សួរសិស្សអំពីរូបមន្តរៀនពីថ្ងៃមុន<br>-បើ a+b=c នោះ<br>a =? និង b =?<br>-បើ a –b=c នោះ<br>a =? និង b =?<br>-ចំពោះចំនួនគត់ a,bនិងc<br>• a x b=?<br>• a x (b x c)=?<br>• a (b+c)=?<br>a x 1=? | ជំហានទី2 (10នាទី)<br>(រំលឹកមេរៀនចាស់) | -បើ a+b=c នោះ<br>a =c - b និង b =c - a<br>-បើ a –b=c នោះ<br>a =c + b និង b =a - c<br>-ចំពោះចំនួនគត់ a,bនិងc<br>• a x b=b x a<br>• a x (b x c)=(a x b)x c<br>• a (b + c)=(a xb)+(a x c)<br>• a x 1=1 x a<br>1 ជាធាតុណឺតចំពោះវិធីគុណ៕ |
| ឧទាហរណ៍1<br>42 ÷ 2=21<br>56 ÷ 2=28<br>198 ÷ 2=99 | ជំហានទី3 (65នាទី)<br>មេរៀនប្រចាំថ្ងៃ<br>មេរៀនទី2តួចែកនិងពហុគុណ<br>1-លក្ខណ:ចែកដាច់នៃចំនួនគត់ | -សិស្សកត់ត្រា<br>42 ÷ 2=21<br>56 ÷ 2=28<br>198 ÷ 2=99 |

| | | |
|---|---|---|
| ឧទាហរណ៍:2<br>70 ៖ 5=14<br>95 ៖ 5=19<br>160 ៖ 5=32<br><br><u>លំហាត់គំរូ</u> ឱ្យសិស្សឡើងធ្វើ)<br>1-គេឱ្យផលបូក9018+1457<br>=91575 ចែកដាច់នឹង 5<br>ព្រោះផលបូកមានលេខចុង5។<br>2-គេឱ្យផលបូក 1995+1329<br>=3324ចែកដាច់នឹង2<br>ព្រោះផលបូកជាចំនួនគត់គូ៕<br><u>ឧទាហរណ៍:</u>1<br>-195 ៖ 3=65ចែកដាច់នឹង 3<br>ព្រោះ 1+9+5=15 ៕<br>- 1005 ៖ 9 =335 ចែកដាច់នឹង 3<br>ព្រោះ1+0+0+5=6 ៕<br>ឧទាហរណ៍:2<br>- 216 ៖ 9 =24ចែកដាច់នឹង9<br>ព្រោះ2+1+6=9<br>-2106 ៖ 9=234<br>ព្រោះ 2+1+0+6=9 | 1-1<u>ភាពចែកដាច់</u><br>ក <u>ភាពចែកដាច់2និង5</u><br><u>ជាទៅ:</u><br>-មួយចំនួនគត់ចែកដាច់នឹង2 កាលណាវាជាចំនួនគត់គូ។<br>-មួយចំនួនគត់ចែកដាច់នឹង5 កាលណាវាមានលេខខាងចុង0 ឬ 5 ។<br><br>2-ភាពចែកដាច់ 3នឹង 9<br><u>ជាទូទៅ៖</u><br>-មួយចំនួនចែកដាច់នឹង 3 កាលណាមានផលបូកលេខ តាមខ្ទង់នោះចែកដាច់នឹង3<br>-មួយចំនួនចែកដាច់នឹង 9កាលណា មានផលបូកលេខតាមខ្ទង់នោះចែក ដាច់នឹង 9៕ | 70 ៖ 5=14<br>95 ៖ 5=19<br>160 ៖ 5=32<br>-សិស្សកត់ត្រាផលបូក 9018+1457=91575ចែកដាច់នឹង 5<br>ព្រោះផលបូកមានលេខខាងចុង 5៕<br>-ផលបូក1995+1329 =3324ចែកដាច់នឹង 2<br>ព្រោះផលបូកជាចំនួនគត់គូ៕<br>-សិស្សកត់ត្រា និង សង្កេតចម្លើយដែលគ្រូធ្វើឱ្យ ៕ |
| គ្រូដាក់ឧទាហរណ៍ឱ្យសិស្សធ្វើ<br>1 គេឱ្យចំនួនមានលេខបួនខ្ទង់ 200□ ៕<br>បំពេញលេខក្នុងប្រអប់ដើម្បី | <u>ជំហានទី4</u> (20នាទី)<br>(ពង្រឹងចំនេះដឹង) | 1- ផលបូកលេខ2+0+0+7=9 ចែកដាច់ នឹង 3ផងនិង 9ផង៕<br>ដូចនេះលេខក្នុងប្រអប់គឺលេខ 7 |

| | | |
|---|---|---|
| ឱ្យបានចំនួនចែកដាច់នឹង3 ផង នឹង 9ផង ។<br>2<br>គេមានមួយចំនួនដែលមានលេខបីខ្ទង់<br>7□8<br>។បំពេញលេខក្នុងប្រអប់ដើម្បីឱ្យចំនួននោះចែកដាច់នឹង 3ផងនិង 9ផង ។ | | 2- ផលបូកលេខ7+3+8=18 ចែកដាច់នឹង3ផង និង 9ផង ។ |
| ឱ្យសិស្សធ្វើលំហាត់លេខ2(ក)ក្នុងសៀ | ជំហានទី5 (5នាទី)បណ្តាំផ្ញើរ | សិស្សកត់លំហាត់យកទៅធ្វើនៅផ្ទះ |

# កិច្ចតែងការបង្រៀន
# មុខវិជ្ជាគណិតវិទ្យា
# ថ្នាក់ទី 7

I. **ចំណងជើងមេរៀន: មេរៀនទី 2 (គ) តួចែកនិងពហុគុណ**

ចំណងជើងរង: 1. លក្ខណៈចែកដាច់នៃចំនួនគត់

II. វត្ថុបំណង: ក្រោយពីរៀនចប់សិស្សអាច

ចំណេះដឹង: សិស្សអាចស្គាល់ភាពចែកដាច់នឹង 2 នឹង 8

លក្ខណៈចេកដាច់ផលបូក និងផលដក និង តួចែកនៃពហុគុណ

I.ចំនេះធ្វើ: សិស្សអាចធ្វើលំហាត់បានតាមរយៈឧទាហរណ៍

ឥរិយាបទ: សិស្សសហការណ៍ដោះស្រាយលំហាត់បានយ៉ាងល្អ

III. រយៈពេល: 100 នាទី

IV. សម្ភារៈឧបទេសៈ សៀវភៅសិស្សទំព័រ 17

V. តំណើរការនៃការបង្រៀន

| សកម្មភាពគ្រូ | ខ្លឹមសារសំខាន់ | សកម្មភាពសិស្ស |
|---|---|---|
| ពិនិត្យអវត្តមាន សណ្តាប់ធ្នាប់ និង អនាម័យថ្នាក់រៀន។ | ជំហាន1(3នាទី)<br>(រដ្ឋបាលថ្នាក់) | ប្រធានថ្នាក់ឡើងរាយការណ៍ |
| • ធ្វើលំហាត់ ដែលដាក់ឱ្យសិស្សថ្ងៃមុន<br>• ប្រាំខ្ទង់ 734 □ 0<br>បំពេញលេខក្នុងប្រអប់ដើម្បីអោយចំនួននោះចែកដាច់<br>ក/ 2ផង និង 5 ផង | ជំហាន់ទី 2 (10នាទី)<br>(រំលឹកមេរៀនចាស់) | លេខ 7+3+4+6+0=20<br>ចែកដាច់នឹង 2ផង នឹង 5ផង |

| | | |
|---|---|---|
| ឧទាហរណ៍1<br>124៖4=31<br>ព្រោះ24 ចែកដាច់នឹង 4<br>832៖4=208<br>ព្រោះ 32 ចែកដាច់នឹង 4<br>ឧទាហរណ៍2<br>3128៖8=391<br>ព្រោះ128ចែកដាច់នឹង 8<br>7120៖8=120<br>ព្រោះ120ចែកដាច់នឹង 8<br>• គ្រូធ្វើលំហាត់ឱ្យសិស្សមើលគេមានលេខ6ខ្ទង់ 11223 □ គ្រូដាក់លំហាត់អោយសិស្សធ្វើ<br>• គេមានចំនួន:12,16,28,32,41,96 , 104,126,144 ។ ក/ 8ជាតួចែកនៃចំនួនណាខ្លះ? ខ/តើចំនួនណាខ្លះជាពហុគុណនៃ 16 ?<br>• បំពេញលីខក្នុងប្រអប់ឱ្យចំនួននោះចែកដាច់នឹង4 ផង នឹង8 ផង ។<br>• គ្រូដាក់លំហាត់ឱ្យសិស្សធ្វើម្តងពីឆ្នាំ 1999 ដល់ឆ្នាំ2010 តើឆ្នាំណាខ្លំចែកដាច់នឹង 4ផង ហើយចែកដាច់នឹង8ផង ។ គ្រូធ្វើឧទាហរណ៍ ឱ្យសិស្សមើល<br>• គេមាន 512 ចែកដាច់នឹង 2 នឹង | ជំហានទី3 (65 នាទី)<br>មេរៀនទី2 (ត)<br>គ. ភាពចែកដាច់នឹង 4 នឹង 8<br>ជាទូទៅ:<br>• មួយចំនួនចែកដាច់នឹង4 គឺវាមានលេខខាងចុងពីរខ្ទង់ចែកដាច់នឹង 4 ។<br>• មួយចំនួនចែកដាច់ 8គឺវាមានលេខចុង3ខ្ទង់ចែកដាច់នឹង 8 ។<br><br>1.2 លក្ខណៈចែកដាច់នៃផលបូកនិងផលដក<br>ជាទូទៅ<br>បើតួនីមួយនៃផលបូក ឬផលដកចែកដាច់នឹងចំនួនតែមួយដូចគ្នា នោះផលដករបស់វាក៏ចែកដាច់នឹងចំនួននោះដែរ ។ | ចំលើយឧទាហរណ៍<br>• 124៖4=31 ព្រោះ14 ចែកដាច់នឹ4<br>• 832៖4=208 ព្រោះ32 ចែកដាច់នឹង4<br>• 3128៖8=391 ព្រោះ128 ចែកដាច់8 7120៖8=120 ព្រោះ120ចែកដាច់នឹង8<br>• សិស្សកត់ត្រាលេខក្នុងប្រអប់នោះគឺ 112232 ចែកដាច់មឹង 4 ព្រោះ 32ចែកដាច់នឹង 4ផងនឹង 8ផង ។<br>• សិស្សឡើងធ្វើនិងកត់ត្រា<br>• គឺ ឆ្នាំ 2008 ព្រោះ 8ចែកដាច់ 4ផង នឹង 8ផង ។ សិស្សកត់ត្រា<br>សិស្សធ្វើលំហាត់និងកត់ត្រាទុក<br>• គេបាន a+a+1+a+2=3a+3 |

| | | |
|---|---|---|
| • 326 ចែកដាច់នឹង 2<br>512+326=838ចែកដាច់នឹង 2<br>512-326=186ចែកដាច់នឹង 2ដែរ ៕<br>ឱ្យសិស្សឡើងធ្វើលំហាត់<br>1. គេមាន 3ចំនួនគឺ<br>a, a+1 , a+2 ៕<br>បង្ហាញថាផលបូកចំនួនបីនេះចែកដាច់នឹង 3 ៕<br><br>ឧទាហរណ៍<br>• តួចែកនៃ 100 គឺ<br>1,2,4,5,10,20,25,50 និង 100<br>ហើយ 100 ជាពហុគុណនៃ<br>1,2,4,5,10,20,25,50 និង 100<br>. គ្រូដាក់លំហាត់អោយសិស្សធ្វើ | | ដោយ 3aចែកដាច់នឹង 3ហើយ 3ចែកដាច់នឹង3 នោះ 3+3ចែកដាច់នឹង 3<br>សិស្សកត់ត្រាទុក<br>សិស្សធ្វើលៅហាត់និងកត់ត្រា<br><br>ក/ 8ជតួចែកនៃចំនួន 16,32,96,104,និង 144 ៕<br>ខ/ ពហុគុណនៃ 16គឺ 16,32,96,144 ៕ |

| | | |
|---|---|---|
| . គេមានចំនួន 12, 16, 28, 32, 41, 96, 104, 126, 144.<br>ក/ 8ជាតួចែកនៃចំនួនណាខ្លះ?<br>ខ/ តើចំនួនណាខ្លះជាពហុគុណនៃ 16?<br>. | | |
| ដាក់លំហាត់អោយសិស្សធ្វើជាក្រុម:<br>ក/ គេមាន 26,30,48,66,106តើចំនួនណាខ្លះជាពហុគុណនៃ 6 ?<br>ខ/ រកគ្រប់ចំនួនដែលជាតួចែកនៃ 15,24,68 និង 120 | ២. តួចែកនិងពហុគុណ<br><br>ជំហានទី4 (20នាទី)<br>(ពង្រឹងចំណេះដឹង) | សិស្សរកត់ត្រា<br>ក/ ចំនួនដែលជាពហុគុណនៃ 6មាន 30,48,66 ។<br>ខ/តួចែកនៃ 15គឺ៖ 1,3,15<br>-តួចែកនៃ 24គឺ៖ 1,3,8,12,24<br>-តួចែកនៃ 68គឺ៖ 1,2,4,34,68<br>-តួចែកនៃ 120គឺ៖ 1,2,3,4,5,6,8,10,12,15,20,60 និង 120សស |
| ឱ្យសិស្សខំប្រឹងធ្វើលំហាត់នៅក្នុងសៀវភៅឱ្យបានច្រើន ។ | ជំហានទី5 (5នាទី)<br>(បណ្តាំផ្ញើរ) | សិស្សស្តាប់ការទូន្មាន និងខិតខំរៀនសូត្រ |

# កិច្ចតែងការបង្រៀន
# មុខវិជ្ជា:គណិតវិទ្យា

ថ្នាក់ទី7

I .ចំណងជើងមេរៀន មេរៀនទី2(ត) **ចែក និងពហុគុណ**

ចំណងជើងរង 3 ចំនួនបឋម

II. វត្ថុបំណង ក្រោយពីរៀនចប់សិស្សអាច

-ចំនេះដឹង សិស្សអាចស្គាល់ភាពចែកដាច់នឹង 2 និង 8លក្ខណៈចែកដាច់ផលបូក និងផលដកនិងតួចែក នៃពហុគុណ

-ចំនេះធ្វើ សិស្សអាចធ្វើលំហាត់បានតាមរយៈឧទាហរណ៍

-ឥរិយាបថ សិស្សសហការណ៍ដោះស្រាយលំហាត់បានយ៉ាងល្អ

III. រយៈពេល 100នាទី

IV.សម្ភារៈឧបទេស សៀវភៅសិស្សទំព័រ 17

v. ដំណើរការនៃការបង្រៀន

| សកម្មភាពគ្រូ | ខ្លឹមសារសំខាន់ | សកម្មភាពសិស្ស |
|---|---|---|
| ពិនិត្យវត្តមាន សណ្តាប់ធ្នាប់ និងអនាម័យថ្នាក់រៀន | ជំហានទី១ (៥ នាទី)<br>រដ្ឋបាលថ្នាក់ | ប្រធានថ្នាក់ឡើងរាយការណ៍ |
| មួយចំនួនចែកដាច់និង ៤ កាលណាវាមានលេខខាងចុងប៉ុន្មានខ្ទង់?<br>មួយចំនួនចែកដាច់និង៨ កាលណាវាមានលេខខាងចុងប៉ុន្មានខ្ទង់? | ជំហានទី២(១០នាទី)<br>រំលឹកមេរៀន | មួយចំនួនចែកដាច់និង ៤ កាលណាវាមានលេខខាងចុងពីរខ្ទង់ចែកដាច់និង៤។<br>មួយចំនួនចែកដាច់និង៨ កាលណាវាមានលេខខាងចុងបីខ្ទង់ចែកដាច់និង ៨។ |
| គ្រូស្រាយឧទាហរណ៍ឱ្យសិស្សមើល<br>តួចែកនៃ 5គឺ:1 និង 5។ | ជំហានទី3 (65នាទី)<br>(មេរៀនប្រចាំថ្ងៃ)<br>មេរៀនទី2 (ត)<br>3 ចំនួនបឋម<br>ជាទូទៅ:<br>-ចំនួនបឋមជាចំនួនគត់ដែលមានតួចែកតែពីរគឺ 1 និងខ្លួនឯង | សិស្សសង្កេតមើលនិងកត់ត្រា |

| | | |
|---|---|---|
| តួចែកនៃ 14គឺ:1,2,7 និង 14 ។<br>តួចែកនៃ 15គឺ:1,3,5 និង 15 ។<br>តួចែកនៃ 23គឺ:1 និង 23 ។<br>តាមឧទាហរណ៍ខាងលើគេឃើញថា<br>5និង 23 មានតួចែកតែពីរគត់គឺ 1និងខ្លួនឯង។<br>ចំនួន 5 និង23 ហៅថាចំនួនបឋម ។<br>ចំពោះ 14 និង15 មានតួចែកច្រើនជាងពីរ ហៅថាចំនួនមិនបឋម ។<br>គ្រូដាក់លំហាត់ឱ្យសិស្សធ្វើ<br>ក) រកចំនួនបឋមនៅចន្លោះ 1 និង 20 ។<br>ខ) រកចំនួនមិនបឋមដែលជាចំនួនគត់ សេសនៅចន្លោះ 1 និង 30។<br><br>គ្រូស្រាយឧទាហរណ៍ឱ្យសិស្សមើល<br><u>ឧទាហរណ៍:</u> បំបែកចំនួន 30ជាផលគុណនៃកត្តាបឋម ។<br>30 \| 2<br>15 \| 3<br>5 \| 5<br>ដូចនេះ  30=2 x 3 x 5<br>ចំនួន 2,3 និង5ជាកត្តាបឋមនៃ 30 ។ | -ចំនួនមិនបឋមជាចំនួនដែលមានតួចែកច្រើនជាងពីរ<br><u>សំគាល់:</u> តាមនិយមន័យខាងលើ "1" មិនមែនជាចំនួនបឋម ហើយក៏មិនមែនជាចំនួនមិនបឋមដែរ ។<br><br>4 <u>ការបំបែកមួយចំនួនជាផលគុណកត្តាបឋម</u> | សិស្សឡើងបកស្រាយនិងកត់ត្រាទុក<br><br>ក/ ចំនួនបឋមនៅចន្លោះ 1និង 20គឺ:2,3,5,7,11,13,17,19<br>ខ/ ចំនួនមិនបឋមដែលជាចំនួនគត់សេសនៅចន្លោះ 1 និង 30គឺ: 9,15,21,25,27<br>សិស្សសង្កេតមើលគ្រូនិងកត់<br><br>ឧទាហរណ៍<br>សិស្សឡើងធ្វើនិងកត់ចម្លើយទុក<br><br>180 \| 2<br>90 \| 2<br>45 \| 3<br>15 \| 3<br>5 \| 5<br>1 \|<br><br>360 \| 2<br>180 \| 2<br>90 \| 2<br>45 \| 3<br>15 \| 3<br>5 \| 5<br>1 \| |

| | | |
|---|---|---|
| គ្រូដាក់ឧទាហរណ៍ឱ្យសិស្សឡើងធ្វើ<br>បំបែកចំនួន x=180 និងy=360 ជាផល<br>គុណកត្តាបឋម ។ | | |
| ចែកសិស្សជាក្រុមហើយបំបែកចំនួនទាំងនេះជាកត្តាបឋម គឺ 100,1980<br><br>I. គ្រូសួររំលឹកចំនួនបឋមជាអ្វី? | <u>ជំហានទី៤</u>(២០នាទី)<br>ពង្រឹងចំនេះដឹង | សិស្សឡើងកែរនិងកត្រាទុក<br>100 \| 2     1980 \| 2<br>50 \| 2     990 \| 2<br>25 \| 5     495 \| 3<br>50 \| 5     165 \| 3<br>1 \|     55 \| 5<br>11 \| 11<br>1 \|<br>គេបាន $100=2^2x5^2$<br>ហើយ $1980=2^2x3^2x11$<br>• ចំនួនបឋមជាចំនួនគត់ដែលមានមានតួចែកតែពីរ គឺ 1និងខ្លួនឯង។<br>• ចំនួនមិនបឋមជាចំនួនដែលមានតួរចែកច្រើនជាង 2 ។ |
| ដាក់កិច្ចការផ្ទះ | <u>ជំហានទី៥</u>(៥នាទី)<br>បណ្ដាំផ្ញើ<br>លំហាត់ ៧ ៨ និង៩ | សិស្សកត់កិច្ចការផ្ទះ |

# កិច្ចតែងការបង្រៀន

មុខវិជ្ជា:គណិតវិទ្យា

ថ្នាក់ទី7

I. ចំណងជើងរងមេរៀន: មេរៀនទី2(តចប់) តួចែកនិង ពហុគុណ

ចំណងជើងរង: 5 តួចែករួមធំបំផុត

II. វត្ថុបំណង: ក្រោយពេលរៀនចប់សិស្សអាច

- ចំនេះដឹង: សិស្សអាចស្គាល់ តួចែករួមធំបំផុត និងតូចបំផុត
- ចំនេះធ្វើ: សិស្សអាចធ្វើលំហាត់បាន តាមរយ:ឧទាហរណ៍
- ឥរិយាបថ: សិស្សចេះសហការណ៍ដោះស្រាយលំហាត់បាន

III. រយ:ពេល(100នាទី)

IV. សំភារ:ឧបទេស:សៀវភៅសិស្សទំព័រ 21

V. ដំណើរការណ៍នៃការបង្រៀន

| សកម្មភាពគ្រូ | ខ្លឹមសារបង្រៀន | សកម្មភាពសិស្ស |
|---|---|---|
| គ្រូពិនិត្យអវត្តមានសណ្តាប់ធ្នាប់ និង វិន័យ។ | ជំហានទី1 (5នាទី)<br>(រដ្ឋបាលថ្នាក់) | ប្រធានថ្នាក់ឡើងរាយការណ៍ |
| គ្រូសួរសិស្សចំនួនបឋមជាអ្វី? | ជំហានទី2 (10នាទី)<br>(រំលឹកមេរៀនចាស់) | សិស្សឆ្លើយចំនួនបឋមជាចំនួនគត់ដែលមានតួចែកតែពីរគឺ1និងខ្លួនឯង ៕ចំនួនមិនបឋមជាចំនួនដែលមានតួចែកច្រើនជាងពីរ៕ |
| គ្រូស្រាយឧទាហរណ៍ឱ្យសិស្សមើលរកតួចែករួមធំបំផុតនៃ30 និង36<br>30=2<br>$30=2^2$<br>កត្តារួម⇨2x3<br>ដូចនេះ PGCD(30,36)<br>=2x3x5=30<br>• គ្រូឱ្យសិស្សឡើងធ្វើរកតួចែករួមធំបំផុតនៃ | ជំហានទី3 (66នាទី)<br>មេរៀនថ្មី (ប្រចាំថ្ងៃ)<br>5. តួចែករួមធំបំផុត<br>ជាទូទៅ:<br>ដើម្បីរកតួចែករួមធំបំផុតនៃពីរ រឺច្រើនគេបំបែកចំនួននីមួយៗជាផលគុណកត្តាបឋមរួមមេគុណកត្តារួមទាំងអស់ដែលមាននិទស្សន្តតូចជាងគេ៕ | សិស្សសង្កេតមើល និងកត់ត្រា<br>តួចែករួមធំបំផុតនៃ 60, 180, 210 គឺ:<br>$60 = 2^2 \times 3 \times 5$<br>$180 = 2^2 \times 3^2 \times 5$<br>$120 = 2 \times 3 \times 5 \times 7$<br>កត្តារួម 2x 3 x5 = 30<br>ដូចនេះ PGCD = 30 |

| | | |
|---|---|---|
| 60,180,210 | 6 <u>ពហុគុណរួមតូចបំផុត</u><br>(PPCM ឬ LCM)<br><u>ជាទូទៅ:</u><br>ដើម្បីរកតួចែករួមពហុគុណរួមតូចបំផុតនៃពីរ ឬច្រើនចំនួនគេត្រូវបំបែកចំនួននីមួយៗជាផលគុណកត្តាបឋមរួមមេគុណកត្តារួមដែលមាននិទស្សន្តធំជាងគេជាមួយនិងកត្តាមិនរួមដែលមាននៅក្នុង ចំនួនទាំងនោះ | សិស្សសង្កេតមើល និងកត់ត្រាពហុគុណរួមតូចនៃ 18, 24, 36 គឺ<br>$18 = 2 \times 3^2$<br>$24 = 2^3 \times 3$<br>$36 = 2^2 \times 3^2$<br>$2^3 \times 32$<br>PPCM (18, 24, 36) $=2^3 \times 3^2 = 72$ |
| គ្រូសួរនិយមនីឡើវិញ<br>-ដើម្បីរកតួចែករួមធំបំផុតនៃពីរ ឬ ច្រើនចំនួនគេត្រូវធ្វើអ្វីខ្លះ?<br>- ដើម្បីរកពហុគុណរួមតូចបំផុតនៃពីរ ឬច្រើនចំនួនគេត្រូវធ្វើអ្វីខ្លះ? | ជំហានទី4 (20នាទី)<br>(ពង្រឹងចំនេះដឹង) | សិស្សឡើងឆ្លើង<br>_ដើម្បីរកតួចែកធំបំផុតគេបំបែកចំនួននីមួយៗ ជាផលគុណកត្តាបឋមរួចគេគុណកត្តារួមទាំងអស់ដែលមាននិទស្សន្តតូចជាងគេ។<br>_ដើម្បីរកតួចែកតូចបំផុតគេត្រូវបំបែកចំនួននីមួយៗ ជាផលគុណកត្តាបឋម រួចគេគុណកត្តារួមធំជាងគេជាមួយកត្តាមិនរួម<br>ដែលមាននៅក្នុងចំនួនទាំងនោះ។ |

| | | |
|---|---|---|
| អោយសិស្សធ្វើលំហាត់ទំព័រ24 សៀវភៅសិស្សគឺលេខ 7 ៕ | ជំហានទី5 (5នាទី) (បណ្តាំផ្ញើ) | សិស្សយកចិត្តទុកដាក់ស្តាប់និងកត់លំហាត់យកទៅធ្វើនៅផ្ទះ ៕ |

# កិច្ចតែងការបង្រៀន
# គណិតវិទ្យា ថ្នាក់ទី ៧
# ថ្ងៃ ទី ខែ ឆ្នាំ

I. រយះពេលបង្រៀន ២ ម៉ោង

II. សម្ភារះឧបទេស

III. ចំណេះដឹងមេរៀន : **មេរៀនទី៣: ចំនួនគត់រ៉ឺឡាទីប**

- ចំណេះដឹងរង

**១ សញ្ញាណចំនួនគត់រ៉ឺឡាទីប**

**២ តំលៃដាច់ខាត នឹង លំដាប់នៃចំនួនគត់រ៉ឺឡាទីប**

IV. វត្ថុបំណង : ក្រោយពេលរៀនចប់សិស្សអាច

- **ចំណេះដឹង**: អោយ សិស្សស្គាល់ចំនួនគត់រ៉ឺឡាទីបស្គាល់តំលៃដាច់ខាតនឹងលំដាប់នៃចំនួនគត់រ៉ឺឡាទីប
- **ចំណេះធ្វើ** : សិស្ស រកចំនួន វិជ្ជមាន នឹង ចំនួនអវិជ្ជមាន ចេះគណនា តំលៃដាច់ខាត នឹង ចេះរក លំដាប់ នៃ ចំនួនគត់រ៉ឺឡាទីប
- **ឥរិយាបថ** : សិស្ស យក ចិត្តទុកដាក់រៀនសូត្រ នឹង ធ្វើលំហាត់

V. ដំណើកនាំមេរៀន : ២ ម៉ោង

| សកម្មភាពគ្រូ | ខ្លឹមសារបង្រៀន | សកម្មភាពសិស្ស |
|---|---|---|
| ពិនិត្យវត្តមានសិស្ស | **ជំហានទី១ : រដ្ឋបាលថ្នាក់** | ប្រធានថ្នាក់ឡើងរាយការណ៍ |
| រកPPCM(20;45)<br>PGCD(45;60) | **ជំហានទី២ : រំលឹកមេរៀនចាស់** | $PPCM(20;45)=2^2*3^2*5=180$<br>$PGCD(45;60)=3*5=15$<br>$45=3^2*5$ ;$60=2^2*3*5$ |

| | | |
|---|---|---|
| ដាក់ឧទាហរណ៍អោយសិស្សធ្វើ<br>7-5;7-6;7-7;7-8<br>បើគេមានតែចំនួនគត់វិធីដកមិនអាចប្រព្រឹត្តបានគ្រប់ករណី<br>ទេកាលណាតួទី១តូចជាងតួទី២ដើម្បីអោយវិធីដកបាន គ្រប់ករណីគេត្រូវបង្កើតចំនួនដែល មានសញ្ញា(-) នៅពីមុខហៅថា ចំនួនគត់រ៉ឺឡាទីប<br>ឧទាហរណ៍២<br>អ្នកឧត្តុនិយមម្នាក់នៅរដ្ឋអាឡាស្កានៃសហរដ្ឋអាមេរិកបានកត់ ត្រាឃើញថាសីតុណ្ហភាពដែលត្រជាក់បំផុតក្នុងសហរដ្ឋអាមេរិក កើតឡើង នៅខែ មករា ១៩៧១ គឺ ៦០$^{0}$c។<br>សីតុណ្ហភាព៦០$^{0}$c តាងដោយ -៦០$^{0}$cចំនួនអវិជ្ជមាន-៦០ជា ចំ នួន គត់រ៉ឺឡាទីប<br>ណែនាំ សិស្ស ពីរបៀបប្រើ ចំនួនវិជ្ជមាននឹងចំនួនអវិជ្ជមាន<br>➢បន្ទាត់មួយដែលមានទិសដៅ នៅលើ បន្ទាត់នេះគេក្រិតយកឯកតាស្មើរៗគ្នាហៅថាបន្ទាត់ចំនួន<br>-3 -2 -1 0 1 2 3 4<br> | **ជំហានទី៣ : មេរៀនថ្មី**<br>**មេរៀនទី ៣: ចំនួនគត់រ៉ឺឡាទីប**<br>**1 សញ្ញាណចំនួនគត់រ៉ឺឡាទីប**<br>ជាទូទៅ: -3 -2 -1 0 1 2 3 ហៅថាចំនួនគត់រ៉ឺឡាទីប<br>សំគាល់:គេសរសេរចំនួនគត់រ៉ឺឡាទីបវិជ្ជមានមានដោយ គ្មាន សញ្ញា(+) នៅពីមុខក៏បាន១ ២ ៣.......0 ជាចំនួនមិនវិជ្ជមាននឹងមិនអវិជ្ជមានក្នុង ការអនុវត្ត<br>➢គេប្រើចំនួនគត់រ៉ឺឡាទីបវិជ្ជមានសំ រាប់ការសំគាល់ប្រាក់ចំណេញសីតុណ្ហភាពលើសូន្យអង្សាកាលបរិច្ឆេទខាងមុខឬ ទីតាំងខាងស្តាំ...<br>➢គេប្រើចំនួនគត់រ៉ឺឡាទីបអវិជ្ជមានសំរាប់ការសំគាល់ប្រាក់ខាតសីតុណ្ហភាពក្រោមសូន្យអង្សាកាលបរិច្ឆេទកន្លងទៅឬទីតាំងខាងឆ្វេង.... | 7-5=2; 7-6=1; 7-7=0; 7-8=?<br>ជាទូទៅ: -3 -2 -1 0 1 2 3 ហៅថាចំនួនគត់រ៉ឺឡាទីប<br>សំគាល់:គេសរសេរចំនួនគត់រ៉ឺឡាទីបវិជ្ជមានមានដោយគ្មាន សញ្ញា(+) នៅពីមុខ ក៏បាន១ ២ ៣.......0 ជា ចំនួន មិន វិជ្ជ មាន នឹងមិនអវិជ្ជមាន ក្នុងការ អនុវត្ត<br>➢គេប្រើចំនួនគត់រ៉ឺឡាទីបវិជ្ជមានសំរាប់ការសំគាល់ប្រាក់ចំណេញសីតុណ្ហភាពលើសូន្យអង្សាកាលបរិច្ឆេទខាងមុខឬទីតាំងខាងស្តាំ...<br>➢គេប្រើចំនួនគត់រ៉ឺឡាទីបអវិជ្ជមានសំរាប់ការសំគាល់ប្រាក់ខាតសីតុណ្ហភាពក្រោមសូន្យអង្សាកាលបរិច្ឆេទកន្លងទៅឬទីតាំងខាងឆ្វេង ....<br>ចំនួនគត់ រ៉ឺឡាទីបវិជ្ជមាន 0.4 ½ +1.2 0 3 5 46<br>ចំនួនគត់ រ៉ឺឡាទីបអវិជ្ជមាន -5 -9 -1 |

<table>
<tr>
<td>ប្រតិបត្តិ<br>0.4 ½ -5 +1.2 -9 -1 0 3<br>5 នឹង 46 តើចំនួនណាជាចំនួនគត់រ៉ឺឡាទីបវិជ្ជមាន នឹងចំនួនគត់រ៉ឺឡាទីប អវិជ្ជមាន<br><br>-3 -2 -1 0 1 2 3 4<br><br>ឧទាហរណ៍១ នៅលើបន្ទាត់ចំនួន ពី៣ ទៅ 0 ស្មើរនឹង៣ចំនួន ពី-៣ ទៅ 0 ស្មើរនឹង៣ឯកតាដែរ<br>ឧទាហរណ៍២<br>|-3|=3;|3|=3;|0|=0<br>គ្រូដាក់ការសន្និដ្ឋានអោយសិស្ស<br><br><u>លំហាត់គំរូ:</u> ចូរគណនាតំលៃ ដាច់ខាតនៃចំនួនខាងក្រោម<br>-25; -13; +10<br><br>ប្រតិបត្តិ គណនា<br>|-5|; |7|; |+34|<br><br>គ្រូដាក់ឧទាហរណ៍អោយសិស្សសង្កេត<br>ឧទាហរណ៍<br>3 -2 -1 0 1 2 3 4<br><br>$2<4$ ; $-4<-2$<br>គ្រូបញ្ជាក់តំលៃអោយសិស្សកាន់តែច្បាស់</td>
<td><u>2 .តំលៃដាច់ខាត នឹង លំដាប់ចំនួន គត់ រ៉ឺឡាទីប</u><br><u>2.1.តំលៃដាច់ខាតចំនួនគត់រ៉ឺឡាទីប</u><br><br><u>សន្និដ្ឋាន</u> តំលៃដាច់ខាតនៃមួយចំនួនគឺចំងាយពីចំនួននោះទៅគល់ 0 តំលៃដាច់ខាតគេកំណត់សរសេរ<br>|a|={ a ;បើ a≥0 ;-a បើ a <0 }<br><br>2.2 <u>លំដាប់ចំនួនគត់រ៉ឺឡាទីប</u><br><br>ចំពោះចំនួនវិជ្ជមាន ចំនួនដែលមាន តំលៃដាច់ខាតធំជាចំនួនធំជាង<br>-ចំនួនអវិជ្ជមាន ចំនួនដែលមានតំលៃដាច់ខាត តូចជាចំនួនធំជាង<br>-ចំនួន ដែលនៅ ខាងស្តាំ ធំជាងចំនួន ដែលនៅ ខាងឆ្វេង<br><br>ប្រតិបត្តិ</td>
<td><u>សន្និដ្ឋាន</u> តំលៃដាច់ខាតនៃមួយចំនួនគឺចំងាយពីចំនួននោះទៅគល់ 0តំលៃដាច់ខាតគេកំណត់សរសេរ<br>|a|={ a ;បើ a≥0 ;-a បើ a <0 }<br><br>|-25| =25<br>|13| =13<br>|+10| =10<br><br>|-5|=5; |7|=7; |+34|=34<br><br>ឧទាហរណ៍<br>3 -2 -1 0 1 2 3 4<br><br>$2<4$ ; $-4<-2$<br><br>ចំពោះចំនួនវិជ្ជមាន ចំនួនដែលមាន តំលៃ ដាច់ខាត ធំជា ចំនួនធំជាង<br>-ចំនួនអវិជ្ជមាន ចំនួនដែលមានតំលៃដាច់ខាត តូចជាចំនួនធំជាង<br>-ចំនួន ដែលនៅ ខាងស្តាំ ធំជាងចំនួន ដែលនៅ ខាងឆ្វេង<br><br>ក/ តាមលំដាប់ឡើង</td>
</tr>
</table>

| | | |
|---|---|---|
| ប្រតិបត្តិ<br>សរសេរចំនួនគត់រ៉ឺឡាទីប<br>-10; -20; 3.7; -1, -40,9, 4,0,2<br>ក/ តាមលំដាប់ឡើង<br>ខ/ តាមលំដាប់ចុះ | សរសេរចំនួនគត់រ៉ឺឡាទីប<br>-10; -20; 3.7; -1, -40,9, 4,0,2<br>ក/ តាមលំដាប់ឡើង<br>ខ/ តាមលំដាប់ចុះ | -40 -20 -10 -1 0 2 3 4 7 9<br>ខ/ តាមលំដាប់ចុះ<br>9 7 4 3 2 0 -1 -10 -20 -40 |
| ចូរគណនា តំលៃ<br>ដាច់ខាតនៃចំនួន ខាងក្រោម<br>\|-4\|, \|+8\|, \|-12\| | **ជំហានទី៤:ពង្រឹងពុទ្ធិ** | \|-4\|=4, \|+8\|=8, \|-12\|=12 |
| អោយសិស្សធ្វើ លំហាត់ទី១<br>ទំព័រ ៣៨ | **ជំហានទី៥:បណ្តាំផ្ញើរ** | សិស្សកត់ត្រាលំហាត់ទុកធ្វើ |

# កិច្ចតែងការបង្រៀន
# គណិតវិទ្យា ថ្នាក់ទី ៧
## ថ្ងៃ ទី ខែ ឆ្នាំ

I. រយៈពេលបង្រៀន ២ ម៉ោង

II. សម្ភារៈឧបទេស

III. ចំណងជើងមេរៀន : **ចំនួនគត់រ៉ឺឡាទីប(ត)**

- ចំណងជើងរង

**៣ ចំនួនផ្ទុយនឹងការដៅចំនុចនៅលើបន្ទាត់ចំនួន**

**៤ វិធីបូក នឹង ដកចំនួនគត់រ៉ឺឡាទីប**

IV. វត្ថុបំណង : ក្រោយពេលរៀនចប់សិស្សអាច

- **ចំណេះដឹង**: អោយ សិស្សស្គាល់ចំនួនផ្ទុយ ការដៅចំនុចនៅលើបន្ទាត់ចំនួន ស្គាល់ពីវិធីបូក នឹង ដកចំនួនគត់រ៉ឺឡាទីប
- **ចំណេះធ្វើ** : សិស្សចេះរកចំនួនផ្ទុយ ចេះដៅចំនុចនៅលើបន្ទាត់ចំនួន ចេះគណនា វិធីបូក នឹង ដកចំនួនគត់រ៉ឺឡាទីប
- **ឥរិយាបថ** : សិស្ស យក ចិត្តទុកដាក់រៀនសូត្រ នឹង ធ្វើលំហាត់

V. ដំណើកនាំមេរៀន : ២ ម៉ោង

| សកម្មភាពគ្រូ | ខ្លឹមសារបង្រៀន | សកម្មភាពសិស្ស |
|---|---|---|
| ពិនិត្យវត្តមានសិស្ស | **ជំហានទី១ : រដ្ឋបាលថ្នាក់** | ប្រធានថ្នាក់ឡើងរាយការណ៍ |
| គណនា តំលៃខាងក្រោម<br>\|-10\|, \|+30\|, \|-5\|,\|+6\| | **ជំហានទី២ : រំលឹកមេរៀនចាស់** | \|-10\|=10, \|+30\|=30, \|-5\|=5,\|+6\|=6 |

| | | |
|---|---|---|
| គ្រូដាក់ឧទាហរណ៍ហើយសួរសិស្ស<br>ចូររកចំនួនផ្ទុយពី២គឺប៉ុន្មាន នឹង ចូររកចំនួនផ្ទុយពី៣គឺប៉ុន្មាន?<br>គេប្រើសញ្ញា(-)នៅពីមុខចំនួនមួយដើម្បី សំគាល់ ចំនួនផ្ទុយនៃចំនួន នោះ<br>-២ ជាចំនួនផ្ទុយនៃ២<br>ដូចនេះ:-(២)=-២<br>-(-២) ជាចំនួនផ្ទុយនៃ-២<br>-(-២)=២ | **ជំហានទី៣ : មេរៀនថ្មី**<br>**<u>មេរៀនទី ៣: ចំនួនគត់រ៉ឺឡាទីប(ត)</u>**<br>**<u>៣. ចំនួនផ្ទុយ នឹង ការដៅចំនុចនៅលើបន្ទាត់ចំនួន</u>**<br>**<u>៣.១ ចំនួនផ្ទុយ</u>**<br><br>ចូររកចំនួនផ្ទុយពី ២គឺប៉ុន្មាន នឹង ចូររកចំនួនផ្ទុយពី ៣គឺប៉ុន្មាន?<br>គេប្រើ សញ្ញា(-)នៅ ពីមុខ ចំនួនមួយ ដើម្បី សំគាល់ ចំនួនផ្ទុយនៃចំនួន នោះ | ចំនួនផ្ទុយពី ២គឺ-២<br>ចំនួនផ្ទុយពី ៣គឺ-៣ |
| គ្រូដាក់ការសន្និដ្ឋាន<br><br>លំហាត់គំរូ ដៅចំនួន-(-1) ,-4, នឹង-[-(-3)] នៅលើបន្ទាត់ចំនួន<br>-(-1)=1,-4,នឹង-[-(-3)]=-3<br><br><br>ប្រតិបត្តិ<br>ចូរបំពេញចន្លោះក្នុងប្រអប់<br>ក/-(-15)=<br>ខ/-[(+8)]= | សន្និដ្ឋាន:<br>បើគេមានចំនួនa នោះគេបាន<br>**-(a)=-a, -(-a)=a**<br>លំហាត់ ដៅចំនួន-(-1),-4, នឹង -[-(-3)] នៅលើបន្ទាត់ចំនួន<br>-(-1)=1,-4,នឹង-[-(-3)]=-3<br><br> | សន្និដ្ឋាន:<br>បើគេមានចំនួនa នោះគេបាន<br>**-(a)=-a, -(-a)=a**<br>ដៅចំនួន-(-1),-4,នឹង-[-(-3)] នៅលើបន្ទាត់ចំនួន<br>-(-1)=1,-4,នឹង-[-(-3)]=-3<br><br><br>ក/-(-15)=15<br>ខ/-[(+8)]=-8 |
| នៅលើបន្ទាត់ចំនួនគេតាងដោយ x'x **A**ជា ចំនុចកន្លះ បន្ទាត់ox | **<u>៣.២ការដៅចំនុចនៅលើបន្ទាត់ចំនួន</u>**<br><br>នៅលើបន្ទាត់ចំនួនគេតាងដោយ x'x **A**ជា ចំនុចកន្លះ បន្ទាត់ox | |

ដែលOA=៤ **B**ជាចំនុចកន្លះបន្ទាត់ox’ដែលOB=៣

-4 -3 -2 -1 0 1 2 3 4 5

x‘ x

**B** **A**

-ចំនុចA នៅត្រង់ចំនួនគត់វិជ្ជមាន +4 គេថា+4 ជាអាប់ស៊ីស នៃA គេសរសេរA(4)

-ចំនុចB នៅត្រង់ចំនួនគត់អវិជ្ជមាន -3 គេថា-3ជាអាប់ស៊ីស នៃA គេសរសេរB (-3)

**__លំហាត់គំរូ:__** ដៅចំនុច A(2) B(-3) C(5) នៅលើបន្ទាត់x’x រួចគណនាABនឹងAC

-3 -2 -1 0 1 2 3 4 5

B A C

AB=OA+OB ; AC=|OC|-|OA|

=|2|+|-3| =|5|-|2|

=2+3 =5-2

=5 =3

**__ប្រតិបត្តិ__** នៅលើបន្ទាត់ចំនួនដែលមានគល់O

ក/ ដៅចំនុច A(-3) B(-1) ដៅចំនុច C(4) D(2)

-3 -2 -1 0 1 2 3 4

A B D C

ខ/គណនាABនឹង AD

AB=OA-OB ; AD=|OB|+|OD|

=|-3|-|-1| =|-1|+|2|

=3-1 =1+2

=2 =3

ដែលOA=៤ **B**ជាចំនុចកន្លះបន្ទាត់ox’ដែលOB=៣

-4 -3 -2 -1 0 1 2 3 4 5

x‘ x

**B** **A**

**__លំហាត់គំរូ:__** ដៅចំនុច A(2) B(-3) C(5) នៅលើបន្ទាត់x’x រួចគណនាABនឹងAC

-3 -2 -1 0 1 2 3 4 5

B A C

**__ប្រតិបត្តិ__** នៅលើបន្ទាត់ចំនួនដែលមានគល់O

ក/ ដៅចំនុច A(-3) B(-1) ដៅចំនុច C(4) D(2)

-3 -2 -1 0 1 2 3 4 5

A B D C

ខ/គណនាABនឹង AD

-4 -3 -2 -1 0 1 2 3 4 5

x‘ x

**B** **A**

-ចំនុចA នៅត្រង់ចំនួនគត់វិជ្ជមាន +4 គេថា+4 ជាអាប់ស៊ីស នៃA គេសរសេរA(4)

-ចំនុចB នៅត្រង់ចំនួនគត់អវិជ្ជមាន -3 គេថា-3ជាអាប់ស៊ីស នៃA គេសរសេរB (-3)

ដៅចំនុច A(2) B(-3) C(5) នៅលើបន្ទាត់x’x រួចគណនាABនឹងAC

-3 -2 -1 0 1 2 3 4 5

B A C

AB=OA+OB ; AC=|OC|-|OA|

=|2|+|-3| =|5|-|2|

=2+3 =5-2

=5 =3

ក/ ដៅចំនុច A(-3) B(-1) ដៅចំនុច C(4) D(2)

-3 -2 -1 0 1 2 3 4 5

| | | |
|---|---|---|
| គ្រូដាក់ឧទាហរណ៍អោយសិស្ស<br>3+4=?<br>បកស្រាយលើបន្ទាត់ចំនួន<br>0 1 2 3 4 5 6 7 8<br><br>តែបើ (-4)+ (-1) =?<br>គ្រូពន្យល់បែបឧទាហរណ៍ជាក់ស្តែងក្នុងជីវភាពប្រចាំថ្ងៃ<br>ឧទាហរណ៍១<br>យើងជំពាក់គេ១០០ ហើយបន្ទាប់មកខ្ចី៣០០ទៀតតើជំពាក់គេប៉ុន្មាន?<br>គ្រូអោយសិស្សទាញវិធាន<br>ឧទាហរណ៍២<br>\|-3\|=3;\|3\|=3;\|0\|=0<br>គ្រូដាក់ការសន្និដ្ឋានអោយសិស្ស<br><br><u>លំហាត់គំរូ:</u> ចូរគណនា ចំនួនខាងក្រោម<br>(-7)+4=?<br>(-2)- (-9) =?<br>15+ (-10) =? | **<u>៤. វិធីបូក នឹង ដកចំនួនគត់រ៉ឺឡាទីប</u>**<br>**៤.១ <u>វិធីបូកចំនួនគត់រ៉ឺឡាទីប</u>**<br><br>**<u>វិធាន</u>**<br>1.ផលបូកពីរចំនួនគត់ រ៉ឺឡាទីបវិជ្ជមានជាចំនួនវិជ្ជមាន ហើយមានផលបូកស្មើនឹងតំលៃដាច់ខាតនៃចំនួនទាំង2<br>2.ផលបូកពីរចំនួនគត់រ៉ឺឡាទីបអវិជ្ជមានជាចំនួន អវិជ្ជមាន ហើយមានផលបូកស្មើនឹងតំលៃដាច់ខាត នៃចំនួនទាំង2<br>3.ផលបូកនៃពីរចំនួនគត់រ៉ឺឡាទីបមានសញ្ញាផ្ទុយញគ្នាមានសញ្ញា ដូចតួដែលមានតំលៃដាច់ខាតធំជាងគេហើយមានផលបូកស្មើនឹងផលដកតំលៃដាច់ខាតនៃចំនួនទាំង2 | <br>A B D C<br>ខ/គណនាABនឹង AD<br>AB=OA-OB ;<br>AD=\|OB\|+\|OD\|<br>=\|-3\|-\|-1\| =\|-1\|+\|2\|<br>=3-1 =1+2<br>=2 =3<br><br>3+4=7<br>ជំពាក់៤០០<br>**<u>វិធាន</u>**<br>1.ផលបូកពីរចំនួនគត់រ៉ឺឡាទីបវិជ្ជមានជាចំនួនវិជ្ជមានហើយមានផលបូកស្មើនឹងតំលៃដាច់ខាតនៃចំនួនទាំង2<br>2.ផលបូកពីរចំនួនគត់រ៉ឺឡាទីបអវិជ្ជ មានជាចំនួន អវិជ្ជមាន ហើយមាន ផលបូកស្មើនឹងតំលៃដាច់ខាតនៃចំ នួនទាំង2<br>3.ផលបូកនៃពីរចំនួនគត់រ៉ឺឡាទីប មានសញ្ញាផ្ទុយញគ្នាមានសញ្ញាដូចតួដែលមានតំលៃដាច់ខាតធំជាងគេ ហើយមានផលបូកស្មើនឹ ផលដក តំលៃដាច់ខាតនៃចំនួនទាំង2 |

| | | |
|---|---|---|
| គ្រូដាក់ឧទាហរណ៍អោយសិស្ស ឧទាហរណ៍<br>4-2=? នឹង (-8)- (2) =?<br>គណនា តំលៃខាងក្រោម<br>6-(-3) =?<br>គ្រូផ្តល់ឧទាហរណ៍អោយសិស្សកាន់តែច្បាស់<br>បើយើងមានឃ្លីចំនួន6គ្រាប់ ហើយយើងដកឃ្លី3គ្រាប់មកដាក់ ចូលខាងឃ្លីចំនួន6គ្រាប់តើវាមាន ឃ្លីប៉ុន្មាន?<br>គ្រូដាក់វិធានអោយសិស្ស<br>ប្រតិបត្តិ គណនា<br>(-3)- (7) =?<br>(-11)- (-5) =? | **៤.២ <u>វិធីដកចំនួនគត់រ៉ឺឡាទីប</u>**<br>ឧទាហរណ៍<br>4-2=? ;(-8)-(2) =?<br>គេអាចសរសេរ<br>6-(-3) =6-(-3) +(-3) +(-3)=9<br>**<u>វិធាន</u>** ដើម្បីដកចំនួនគត់រ៉ឺឡាទីប គេត្រូវបូកចំនួនផ្ទុយរបស់វា<br>**+(+a)=a**<br>**-(-a)=a**<br>**+(-a)=-a**<br>**-(+a)=-a** | (-7)+4=-3<br>(-2)- (-9) =-11<br>15+ (-10) =5<br>4-2=2 ;(-8)- (2)=-10<br>មានឃ្លីចំនួន9គ្រាប់<br>គេអាចសរសេរ<br>6-(-3) =6-(-3) +(-3) +(-3)=9<br>**<u>វិធាន</u>**<br>ដើម្បីដកចំនួនគត់រ៉ឺឡាទីប គេត្រូវបូកចំនួនផ្ទុយរបស់វា<br>**+(+a)=a**<br>**-(-a)=a**<br>**+(-a)=-a**<br>**-(+a)=-a**<br>(-3)- (7) =(-3)+(-7) =-10<br>(-11)- (-5) =(-11)+ (5) =-6 |
| ចូរ គណនា តំលៃ នៃចំនួន ខាងក្រោម<br>10+ (-2) =?<br>(-12)+ (-2) =?<br>(-10)- (-2) =? | **ជំហានទី៤:ពង្រឹងពុទ្ធិ** | 10+ (-2) =8<br>(-12)+ (-2) =-14<br>(-10)- (-2) =-12 |
| អោយសិស្សធ្វើ លំហាត់ទី6 នឹង លំហាត់ទី7 ទំព័រ 38 | **ជំហានទី៥:បណ្តាំផ្ញើរ** | សិស្សកត់ត្រាលំហាត់ទុកធ្វើនៅផ្ទះ |

# កិច្ចតែងការបង្រៀន
# គណិតវិទ្យា ថ្នាក់ទី ៧
## ថ្ងៃ ទី ខែ ឆ្នាំ

I. រយះពេលបង្រៀន ២ ម៉ោង

II. សម្ភារះឧបទេស

III. ចំណងជើងមេរៀន : **ចំនួនគត់រ៉ឺឡាទីប(តចប់)**

- ចំណងជើងរង

**៤ វិធីគុណ នឹង ចែកចំនួនគត់រ៉ឺឡាទីប**

**៤.១ វិធីគុណចំនួនគត់រ៉ឺឡាទីប**

**៤.២ វិធីចែកចំនួនគត់រ៉ឺឡាទីប**

**៦ លំដាប់ប្រមាណវិធី**

**៦.១ប្រមាណវិធីដែលមានតួបូកនឹងដក**

**៦.២ប្រមាណវិធីដែលមានតួគុណនឹងចែក**

**៦.៣ប្រមាណវិធីចម្រុះ**

IV. វត្ថុបំណង : ក្រោយពេលរៀនចប់សិស្សអាច

- **ចំណេះដឹង**: អោយសិស្សស្គាល់ពីវិធីគុណ នឹង ចែកចំនួនគត់រ៉ឺឡាទីប ស្គាល់ពីប្រមាណវិធី បូក ដក គុណ ចែក នឹង ប្រមាណវិធីចម្រុះ
- **ចំណេះធ្វើ** : សិស្សចេះគណនា វិធីគុណ នឹង ចែកចំនួនគត់រ៉ឺឡាទីប ប្រមាណវិធីចម្រុះ ដោយ ដាក់ជាកត្តា
- **ឥរិយាបថ** : សិស្ស យក ចិត្តទុកដាក់រៀនសូត្រ នឹង ធ្វើលំហាត់

V. ដំណើរការនាំមេរៀន : ២ ម៉ោង

| សកម្មភាពគ្រូ | ខ្លឹមសារបង្រៀន | សកម្មភាពសិស្ស |
|---|---|---|
| ពិនិត្យវត្តមានសិស្ស<br>អនាម័យ បរិស្ថាន | **ជំហានទី១ : រដ្ឋបាលថ្នាក់** | ប្រធានថ្នាក់ឡើងរាយការណ៍ |

| | | |
|---|---|---|
| គណនា<br>តំលៃនៃចំនួនខាងក្រោម<br>8+ (-2) =?<br>(-15)+ (+4) =?<br>(+10)- (-9) =?<br>(-8) – (+4) =? | **ជំហានទី២ : រំលឹកមេរៀនចាស់** | 8+ (-2) =6<br>(-15)+ (+4) =-11<br>(+10)- (-9) =19<br>(-8) – (+4) =-12 |
| គ្រូដាក់ឧទាហរណ៍ជាលំហាត់អោយសិស្សគណនា<br>**<u>លំហាត់</u>**<br>x +x +x =?<br>អោយសិស្សសង្កេត មើលចំនួនខាងក្រោម<br>4 x 3= 3+3+3+3=12 (4តួ)<br>4 x(-3)= (-3)+(-3)+(-3)+(-3)=-12 (4តួ)<br><br>គ្រូអោយសិស្សសង្កេតនឹងទាញការសន្និដ្ឋាន<br><br>បើយើងមាន(-4) x (-3) តើស្មើប៉ុន្មាន?<br>គ្រូរំលឹកពីរការសន្និដ្ឋានខាងលើ | **<u>ជំហានទី៣ : មេរៀនថ្មី</u>**<br>**<u>មេរៀនទី៣:</u>**<br>**<u>ចំនួនគត់រ៉ឺឡាទីប(តចប់)</u>**<br>**<u>៥ វិធីគុណ</u>**<br>**<u>នឹងចែកគត់ចំនួនរ៉ឺឡាទីប</u>**<br>**<u>៥.១ វិធីគុណគត់ចំនួនរ៉ឺឡាទីប</u>**<br><br>4 x 3= 3+3+3+3=12 (4តួ)<br>4 x(-3)= (-3)+(-3)+(-3)+(-3)=-12 (4តួ)<br><br>គេអាចផ្លាស់ប្តូរលំដាប់ហើយផល គុណនៅដដែល(4) x(-3)= -12<br>សន្និដ្ឋាន:<br>-ផលគុណជាចំនួន វិជ្ជមានកាលណា តួទាំងពីរមានសញ្ញាដូចគ្នា<br>-ផលគុណជាចំនួន អវិជ្ជមានកាល ណា<br>តួទាំងពីរមានសញ្ញាផ្ទុយគ្នា | ស្មើ នឹង3x<br><br>4 x 3= 3+3+3+3=12 (4តួ)<br>4 x(-3)= (-3)+(-3)+(-3)+(-3)=-12 (4តួ)<br><br>សន្និដ្ឋាន:<br>-ផលគុណជាចំនួន វិជ្ជមានកាលណា តួទាំងពីរមានសញ្ញាដូចគ្នា<br>-ផលគុណជាចំនួន អវិជ្ជមានកាល ណា<br>តួទាំងពីរមានសញ្ញាផ្ទុយគ្នា |

| | | |
|---|---|---|
| តើផលគុណជាចំនួនវិជ្ជមានលុះត្រាតួទាំងពីរមានសញ្ញាដូចម្តេច?<br>តើ(-4) នឹង(-3)មានសញ្ញាដូចម្តេច?<br>តើផលគុណវាស្មើរប៉ុន្មាន?<br>គ្រូបញ្ជាក់ពីប្រមាណវិធី<br>ផលគុណជាចំនួន វិជ្ជមានកាលណា តួទាំងពីរជាចំនួនអវិជ្ជមាន<br><br>មួយចំនួនគុណសូន្យស្មើសូន្យ<br>**ប្រតិបត្តិ**<br>គណនានៃចំនួនខាងក្រោម:<br>(-20) x(3) =?<br>(-6) x(-6) =?<br>(-89) x0=?<br><br>គ្រូដាក់ឧទាហរណ៍អោយសិស្សសង្កេត<br><br>គ្រូបញ្ជាក់ពីលក្ខណ:ដូចគ្នារវាង វិធីគុណ នឹងចែក<br><br>គ្រូផ្តល់វិធាន | ឧទាហរណ៍<br>(-4) x (-3) =?<br><br>ផលគុណជាចំនួន វិជ្ជមានកាលណា តួទាំងពីរជាចំនួនអវិជ្ជមាន<br>(+) x (+) =+<br>(-) x (+) =-<br>(+) x (-) =-<br>(-) x (-) =+<br><br>មួយចំនួនគុណសូន្យស្មើសូន្យ<br>**ប្រតិបត្តិ**<br>គណនានៃចំនួនខាងក្រោម:<br>(-20) x(3) =?<br>(-6) x(-6) =?<br>(-89) x0=?<br><br>**៥.២ វិធីចែកចំនួនគត់រ៉ឺឡាទីប**<br>6/3=2នោះយើងអាចដឹងថា3 x2=6<br>6/(-3)=-2នោះយើងអាចដឹងថា (-)3 x(2)=-6<br>(-6)/3=-2នោះយើងអាចដឹងថា (3) x(-)2=6<br>(-6)/(-3)=2នោះយើងអាចដឹងថា (-3) x(-2)=6<br><br>-ផលចែកជាចំនួន វិជ្ជមានកាលណា តួទាំងពីរមានសញ្ញាដូចគ្នា<br>-ផលចែកជាចំនួន អវិជ្ជមានកាលណា តួទាំងពីរមានសញ្ញាផ្ទុយគ្នា | លុះត្រាតួទាំងពីរមានសញ្ញាដូចគ្នា<br><br>តួលេខទាំងពីរមានសញ្ញាដូចគ្នា<br><br>ស្មើ 12<br><br>ផលគុណជាចំនួន វិជ្ជមានកាលណា តួទាំងពីរជាចំនួនអវិជ្ជមាន<br>(+) x (+) =+<br>(-) x (+) =-<br>(+) x (-) =-<br>(-) x (-) =+<br><br>មួយចំនួនគុណសូន្យស្មើសូន្យ<br><br>(-20) x(3) =-60<br>(-6) x(-6) =36<br>(-89) x0=0<br><br>ផលចែកជាចំនួន វិជ្ជមានកាលណា តួទាំងពីរមានសញ្ញាដូចគ្នា<br>-ផលចែកជាចំនួន អវិជ្ជមានកាលណា<br>តួទាំងពីរមានសញ្ញាផ្ទុយគ្នា |

| | | |
|---|---|---|
| លំហាត់គំរូ:<br>ចូរគណនាផលចែក ខាងក្រោម<br>ក. $\frac{-20+4}{2}$<br>ខ. $\frac{-10}{3-5}$<br>គ. $\frac{[4-(-10)]}{-7}$ | (+) /(+) =+<br>(-) / (+) =-<br>(+) / (-) =-<br>(-) / (-) =+<br>**ចំណាំ**<br>- សូន្យចែកនឹងមួយចំនួនមិនសូន្យ បានផលចែកសូន្យ<br>- គេមិនអាចយកមួយចំនួនចែកនឹង សូន្យ បានទេ<br>លំហាត់គំរូ:<br>ចូរគណនាផលចែក ខាងក្រោម<br>ក. $\frac{-20+4}{2}$<br>ខ. $\frac{-10}{3-5}$<br>គ. $\frac{[4-(-10)]}{-7}$ | (+) / (+) =+<br>(-) / (+) =-<br>(+) / (-) =-<br>(-) / (-) =+<br>**ចំណាំ**<br>- សូន្យចែកនឹងមួយចំនួនមិនសូន្យ បានផលចែកសូន្យ<br>- គេមិនអាចយកមួយចំនួនចែកនឹង សូន្យ បានទេ<br>ក. $\frac{-20+4}{2}=\frac{-16}{2}$= -8<br>ខ. $\frac{-10}{3-5}=\frac{-10}{-2}=5$<br>គ. $\frac{[4-(-10)]}{-7}=\frac{4+10}{-7}=\frac{14}{-7}$=-2 |
| **ប្រតិបត្តិ** គណនា<br>ក.$\frac{-40416}{-165-256}$<br>ខ. $\frac{-2729+583}{-29}$ | | ក.$\frac{-40416}{-165-256}=\frac{-40416}{-421}=96$<br>ខ. $\frac{-2729+583}{-29}=\frac{-2146}{-29}=74$ |
| គ្រូដាក់ឧទាហរណ៍ អោយសិស្សគណនាកន្សោមខាងក្រោម<br>ក.30+17-20; ខ. 21-7+3;<br>គ.8-14+(-5)-(-2)<br>ឃ.32-(10+5)នឹង-18+[15-(-4)] | **៦ លំដាប់ប្រមាណវិធី**<br>**៦.១ប្រមាណវិធីដែលមានតួបូកនឹង ដក**<br>គណនាកន្សោមខាងក្រោម<br>ក.30+17-20=47-20=27<br>ខ. 21-7+3=14+3=17<br>គ.8-14+(-5)-(-2)=-6-5+2=-11+2=-9<br>ឃ.32-(10+5)=32-(15)=32-15=17<br>-18+[15-(-4)]=-18+[15+4] =-18+19=1 | គណនាកន្សោមខាងក្រោម<br>ក.30+17-20=47-20=27<br>ខ. 21-7+3=14+3=17<br>គ.8-14+(-5)-(-2)=-6-5+2=-11+2=-9<br>ឃ.32-(10+5)=32-(15)=32-15=17<br>-18+[15-(-4)]=-18+[15+4] =-18+19=1 |
| គ្រូអោយសិស្សទាញលក្ខណ:ជាទូទៅ | **ជាទូទៅ**<br>បើកន្សោមមានលេខតែវិធីបូកនឹង ដក(គ្មានវង់ក្រចក)នោះប្រមាណវិធី | **ជាទូទៅ**<br>បើកន្សោមមានលេខតែវិធីបូកនឹង ដក(គ្មានវង់ក្រចក)នោះប្រមាណ |
| ប្រតិបត្តិ គណនា<br>ក.13-4+7 =?<br>ខ.13-(4+7) =?<br>គ.12+ (5+8) =? | | |

| | | |
|---|---|---|
| ឃ. (12+5)+8=?<br><br>គ្រូដាក់ឧទាហរណ៍ អោយសិស្ស<br>គណនាកន្សោមខាងក្រោម<br>ក. 5x (-3) x 2=?<br>ខ. 30÷ 5 x 2=?<br>គ. 800÷ 100 x (-4) =?<br>ឃ.10 x 14 ÷ 7=?<br>គ្រូអោយសិស្សទាញលក្ខណៈ:ជា<br>ទូទៅ<br><br>ប្រតិបត្តិ គណនា<br>ក. [5 x (-3)] x 2=?<br>ខ. [5 x (-3) x 2]=?<br>គ. 1000÷100÷10=?<br><br>គ្រូដាក់ឧទាហរណ៍ អោយសិស្ស<br>គណនាកន្សោមខាងក្រោម<br>ក. 6+5 x 2=?<br>ខ. 25-5x 5=?<br>គ. 18-10 ÷ 2 =?<br>ឃ.20 ÷ 4+6=?<br>គ្រូអោយសិស្សទាញលក្ខណៈ:ជា<br>ទូទៅ | ត្រូវធ្វើពីឆ្វេងទៅស្តាំតែបើមានវង់<br>ក្រ<br>ចកត្រូវធ្វើប្រមាណវិធីក្នុងវង់ក្រច<br>ក ជាមុន។<br>**ប្រតិបត្តិ** គណនា<br>ក.13-4+7 =?<br>ខ.13-(4+7) =?<br>គ.12+ (5+8) =?<br>ឃ. (12+5)+8=?<br><br>**<u>៦.២ ប្រមាណវិធីដែល</u>**<br>**<u>មានតួគុណ នឹងចែក</u>**<br><br>គណនាកន្សោមខាងក្រោម<br>ក. 5x (-3) x 2=(-15) x 2=-30<br>ខ. 30÷ 5 x 2=6 x 2=12<br>គ. 800÷ 100 x (-4) =8 x (-4)=-400<br>ឃ.10 x 14 ÷ 7=140÷7=20<br>**ជាទូទៅ**<br><br>បើកន្សោមមានលេខតែវិធីគុណ<br>នឹងចែក (គ្មានវង់ក្រចក)<br>នោះប្រមាណ<br>វិធីត្រូវធ្វើពីឆ្វេងទៅស្តាំតែបើ<br>មានវង់ ក្រចកត្រូវធ្វើប្រមាណ<br>វិធីក្នុងវង់ ក្រ ចកជាមុន។<br>គណនា<br>ក. [5 x (-3)] x 2=?<br>ខ. [5 x (-3) x 2]=?<br>គ. 1000÷100÷10=?<br>**<u>៦.៣ប្រមាណវិធីចម្រុះ</u>**<br><br>គណនាកន្សោមខាងក្រោម | វិធី ត្រូវធ្វើពីឆ្វេងទៅស្តាំតែ<br>បើមាន<br>វង់ក្រចកត្រូវធ្វើប្រមាណវិធីក្នុងវ<br>ង់ ក្រចក ជាមុន។<br>គណនា<br>ក.13-4+7 =9+7=16<br>ខ.13-(4+7) =13-(11)=13-11=2<br>គ.12+ (5+8) =12+(13)-12+13=25<br>ឃ.(12+5)+8=(17)+8=17+8=25<br><br>គណនាកន្សោមខាងក្រោម<br>ក. 5x (-3) x 2=(-15) x 2=-30<br>ខ. 30÷ 5 x 2=6 x 2=12<br>គ. 800÷ 100 x (-4) =8 x (-4)=-400<br>ឃ.10 x 14 ÷ 7=140÷7=20<br>**ជាទូទៅ**<br>បើកន្សោមមានលេខតែវិធីគុណ<br>នឹងចែក (គ្មានវង់ក្រចក)<br>នោះប្រមាណ<br>វិធីត្រូវធ្វើពីឆ្វេងទៅស្តាំតែបើ<br>មាន វង់ក្រចកត្រូវធ្វើប្រមាណ<br>វិធីក្នុងវង់ ក្រចកជាមុន។<br>គណនា<br>ក. [5 x (-3)] x 2=(-15)x 2=-30<br>ខ. [5 x (-3) x 2]=[(-15) x 2]=-30<br>គ. 1000÷100÷10=10÷10=1<br><br>គណនាកន្សោមខាងក្រោម |

| | | |
|---|---|---|
| | ក. 6+5 x 2=6+10=16<br>ខ. 25-5x 5=25-25=0<br>គ. 18-10 ÷ 2 =8÷2=4<br>ឃ.20 ÷ 4+6=5+6=11<br><br>**ជាទូទៅ**<br>បើកន្សោមលេខមានប្រមាណវិធីចម្រុះ(គ្មានវង់ក្រចក)នោះគេត្រូវធ្វើ ប្រមាណវិធីគុណនឹងចែកមុន។ | ក. 6+5 x 2=6+10=16<br>ខ. 25-5x 5=25-25=0<br>គ. 18-10 ÷ 2 =8÷2=4<br>ឃ.20 ÷ 4+6=5+6=11<br><br>**ជាទូទៅ**<br>បើកន្សោមលេខមានប្រមាណវិធីចម្រុះ(គ្មានវង់ក្រចក)នោះគេត្រូវធ្វើ ប្រមាណវិធីគុណនឹងចែកមុន។ |
| **ប្រតិបត្តិ**<br>ចូរគណនា តំលៃកន្សោមលេខខាងក្រោម<br>ក. [2-3(5+4)]- (6+5x 2) =?<br>ខ. [4+ (4÷4)](4) =?<br>គ. [(35-7) (4+6)] ÷2=? | **ជំហានទី៤:ពង្រឹងពុទ្ធិ**<br>**ប្រតិបត្តិ**<br>ចូរគណនា តំលៃកន្សោមលេខខាងក្រោម<br>ក. [2-3(5+4)]- (6+5x 2) =?<br>ខ. [4+ (4÷4)](4) =?<br>គ. [(35-7) (4+6)] ÷2=? | ក. [2-3(5+4)]- (6+5x 2)<br>=[2-3(9)]-(6+10)<br>=(2-27)-16<br>=-25-16=-41<br>ខ. [4+ (4÷4)](4) =(4+1)(4)=5x 4=20<br>គ. [(35-7) (4+6)]÷2<br>=[(28)(10)] ÷2<br>=280 ÷2=140 |
| អោយសិស្សធ្វើលំហាត់ទី13ទំព័រ 39 | **ជំហានទី៥:បណ្តាំផ្ញើរ** | សិស្សកត់ត្រាលំហាត់ទុកធ្វើ |

# កិច្ចតែងការបង្រៀន

*មុខវិជ្ជា:* *គណិតវិទ្យា ថ្នាក់ទី ៧*

*ថ្ងៃ............ទី........ខែ.........ឆ្នាំ............*

I.*ចំណងជើងមេរៀន:* មេរៀនទី ៤ ប្រភាគ

*ចំណងជើងរង:* ១. សញ្ញាណប្រភាគ

២. ប្រភាគសមមូល

៣.ការសម្រួលប្រភាគ

II.*វត្ថុបំណង:* ក្រោយពីរៀនចប់មេរៀននេះចប់សិស្សអាច

-ចំណេះដឹង: ប្រាប់ពីសញ្ញាណប្រភាគ ប្រភាគសមមូល និងការសម្រួលប្រភាគបានត្រឹមត្រូវតាមរយ:ឧទាហរណ៍។

-បំណិន: សិស្សប្រតិបត្តិបានពីប្រភាគសមមូល និងការសម្រួលប្រភាគបានត្រឹមត្រូវតាមរយ: ឧទាហរណ៍ និងលំហាត់ប្រតិបត្តិ ។

-ឥរិយាបថ: មានទំនាក់ទំនងល្អរវាងសិស្ស និងសិស្សព្រមទាំងរវាង គ្រូ និងសិស្ស ។

III.*ពេលវេលា* ០២ ម៉ោង

IV. សម្ភារ:ឧបទេស

- ដែកឈានបន្ទាត់ក្រឹត ក្រដាសកាតុងគូសរង្វង់ជាចំណែក។

V. *ដំណើកនាំមេរៀន:*

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាព |
|---|---|---|
| គ្រូតពិនិត្យ អវត្តមាន អនាម័យ និងសណ្តាប់ធ្នាប់ វិន័យ | <u>ជំហានទី</u> ១ (រដ្ឋបាលថ្នាក់) | តំនាងថ្នាក់ឡើងរាយការណ៍ |
| -បើផលចែកជាចំនួនវិជ្ជមានកាលណាតួទាំងពីរមានសញ្ញាដូចម្តេច ?<br>-<br>បើផលចែកជាចំនួនអវិជ្ជមានកាលណាតួទាំងពីរមានសញ្ញាដូចម្តេច? | <u>ជំហានទី</u> ២ (រំលឹកចាស់) | -<br>កាលណាតួទាំងពីរមានសញ្ញាដូចគ្នា ។<br>-<br>កាលណាតួទាំងពីរមានសញ្ញាផ្ទុយគ្នា ។ |

<table>
<tr>
<td>គ្រូសរសេរចំណងជើងមេរៀនដាក់លើក្តាខៀន<br><br>-ផ្ទៃកនិមួយៗស្មើនឹងប៉ុន្មាន? ភាគនៃនំសរុប<br>-តើគេអាចសរសេរប្រភាគជាផលចែកនៃមួយចំនួន និងមួយចំនួនផ្សេងទៀតខុសពីសូន្យបានយ៉ាងដូចម្តេច ?<br>-ចូរប្អូនរកឧទាហរណ៍ប្រភាគឲ្យបានប្រាំ ?<br><br>-ដាក់ឧទាហរណ៍ឲ្យសិស្សសង្កេត<br>-បើសុខកាត់នំជាបីចំណែកស្មើៗគ្នាហើយញ៉ាំអស់ 1ចំណែក ។ តើសុខបានញ៉ាំអស់ប៉ុន្មានចំណែកនៃនំនោះ<br>-បើសៅកាត់នំជា 6 ចំនែកស្មើៗគ្នាហើយបានញ៉ាំអស់ 2 ចំណេក ។<br>តើសៅបានញ៉ាំអស់ប៉ុន្មានចំណែកនៃនំនោះ ?<br>-បើសំកាត់នំជា9ចំណែកស្មើៗគ្នាហើយញ៉ាំអស់ 3ចំណែក ។តើសំបានញ៉ាំអស់ប៉ុន្មាន?</td>
<td><u>ជំហានទី</u> ៣ (មេរៀនប្រចាំថ្ងៃ)<br>មេរៀនទី៤ ប្រភាគ<br>១. សញ្ញាណប្រភាគ<br>Ex គេដាក់នំមួយជា ៥ ផ្ទៃកស្មើៗគ្នា ចែកឲ្យក្មេង ៥ នាក់ហើយក្មេងម្នាក់ៗ នឹងទទួលបានមួយផ្ទៃក (មើលរូប )<br><br>ជាទូទៅ $\frac{a}{b}$ ជាប្រភាគដែល $a,b$ ជាចំនួនគត់រ៉ឺឡាទីប ហើយ $a$ ជាភាគយក និង $b$ ជាភាគបែងនៃប្រភាគ $(b\neq 0)$<br>២. ប្រភាគសមមូល<br>Ex សុខ សៅ និងសំមានទិញនំម្នាក់មួយមានទំហំប៉ុនគ្នា ។</td>
<td>-មួយភាគប្រាំនៃនំសរុបគេសរសេរ $\frac{1}{5}$<br>-គេអាចសរសេរប្រភាគជាផលចែកមួយចំនួន នឹងមួយចំនួនផ្សេងទៀត ខុសពីសូន្យ ។<br>-ឧទាហរណ៍ប្រភាគឲ្យបានប្រាំ $\frac{4}{5},-\frac{1}{2},\frac{3}{2},\frac{1}{4},\frac{3}{4}$<br><br>-សុខបានញ៉ាំអស់ $\frac{1}{3}$ នៃនំនោះ<br><br>-សៅបានញ៉ាំអស់ $\frac{2}{6}$ នៃនំនោះ<br><br>-សំបានញ៉ាំអស់ $\frac{3}{9}$ នៃនំនោះ</td>
</tr>
</table>

| | | |
|---|---|---|
| ចំនែកនៃនំនោះ<br>-តើសុខ សៅ និងសំ<br>បានញ៉ាំនំអស់<br>បរិមាណស្មើគ្នា ឬទេ ?<br>ជាប្រភាគអ្វី?<br>គេសរសេរដូចម្តេច ?<br><br>-ចូរប្អូនពិនិត្យប្រភាគ $-\frac{3}{4}$ និង $\frac{6}{-8}$<br>ជាប្រភាគសមមូល ឬទេ<br>?ព្រោះអ្វី?<br>គេសរសេរដូចម្តេច ?<br>- ចូរប្អូនពិនិត្យប្រភាគ $\frac{3}{7}$ និង $-\frac{4}{5}$<br>ជាប្រភាគសមមូល ឬទេ<br>?ព្រោះអ្វី?<br>គេសរសេរដូចម្តេច ?<br><br>ដើម្បីរកតម្លៃ $x$<br>យើងត្រូវធ្វើដូចម្តេច?<br><br>បែងចែកសិស្សជាក្រុមឲ្យពិភាក្សា<br>ការងារប្រតិបត្តិ<br><br>-ចូរប្អូនពិនិត្យមើល 6 និង 15 មាន<br>តួចែករួមឬទេ?បើមានស្មើនឹងប៉ុន្មា | Ex តើប្រភាគខាងក្រោមជាប្រភាគ<br>សមមូលគ្នា ឬទេ ?<br>ក) $-\frac{3}{4}$ និង $\frac{6}{-8}$<br>ខ) $\frac{3}{7}$ និង $-\frac{4}{5}$<br><br>**ជាទូទៅ**<br>កាលណាប្រភាគសមមូលគ្នា<br>ជាប្រភាគតាងឲ្យបរិមាណស្មើគ្នា។<br>បើប្រភាគ $\frac{a}{b}$ និង $\frac{c}{d}$<br>ជាប្រភាគសមមូល<br>គ្នាមានន័យថា $\frac{a}{b}=\frac{c}{d}$ លុះត្រាតែ<br>$a\times d=b\times c,(b\neq 0,d\neq 0)$ ។<br>Ex រកតម្លៃ $x$ បើគេដឹងថា $\frac{x}{4}=\frac{21}{28}$<br><br>**ប្រតិបត្តិ** ចូរបំពេញចំនួនក្នុងប្រអប់<br>ក) $\frac{2}{7}=\frac{\square}{\square}$ ខ) $-\frac{15}{25}=\frac{\square}{\square}$<br>គ) $\frac{4}{9}=\frac{28}{\square}$ | -សុខ សៅ<br>និងសំបានញ៉ាំនំអស់<br>បរិមាណស្មើគ្នា ជាប្រភាគ<br>សមមូលគ្នា ។<br>គេសរសេរ $\frac{1}{3}=\frac{2}{6}=\frac{3}{9}$<br>ក) ប្រភាគ $-\frac{3}{4}$ និង $\frac{6}{-8}$<br>ជាប្រភាគសមមូលគ្នាព្រោះ<br>$(-3)(-8)=4\times 6=24$<br>គេសេរសេរ $-\frac{3}{4}=\frac{6}{-8}$<br>ខ) ប្រភាគ $\frac{3}{7}$ និង $-\frac{4}{5}$<br>មិនមែនជា<br>ប្រភាគសមមូលគ្នាទេ។ពី<br>ព្រោះ<br>$3\times 5\neq(-4)\times 7$ គេសរសេរ<br>$\frac{3}{7}\neq-\frac{4}{5}$<br><br>រកតម្លៃ $x$<br>ដោយ $\frac{x}{4}=\frac{21}{28}$ នោះគេបាន<br>$x\times 28=21\times 4$ នាំឲ្យ<br>$x=\frac{4\times 21}{28}=3$ ដូចនេះ $x=3$<br>ក) $\frac{2}{7}=\frac{4}{14}$ ខ) $-\frac{15}{25}=-\frac{3}{5}$<br>គ) $\frac{4}{9}=\frac{28}{63}$ |

| | | |
|---|---|---|
| ន<br>-តើគេអាចសរសេរ $\frac{6}{15}$ បានយ៉ាងដូចម្ដេច ?<br>-តើ $\frac{2}{5}$ ហៅថាប្រភាគអ្វី ?ហើយសមមូលនឹងប្រភាគណា ?<br><br>-តើ 16 និង 40 មានតួចែករួមធំបំផុតស្មើនឹងប៉ុន្មាន?<br>តើគេអាចសរសេរបានយ៉ាងដូចម្ដេច?<br>-ដូចគ្នាចំពោះ 70 នឹង 245<br><br>មុននឹងសម្រួលប្រភាគយើងត្រូវពិនិត្យភាគយក និងភាគបែងវាមាន តួចែករួមធំបំផុតស្មើនឹងប៉ុន្មាន ? | ៣. ការសម្រួលប្រភាគ<br>Ex សម្រួលប្រភាគ $\frac{6}{15}$<br><br>**ជាទូទៅ**<br>សម្រួលប្រភាគគឺធ្វើឲ្យប្រភាគនោះទៅជាប្រភាគសម្រួលមិនបានដែលសមមូលនឹងវា។សម្រួលប្រភាគអាចចែកភាគយកនិងភាគបែង<br>នៃប្រភាគនោះ<br>នឹងតួចែករួមធំបំផុតនៃភាគយកនិងភាគបែង ។$\frac{a}{b}$ ជាប្រភាគហើយ $k$ ជាចំនួនខុសពីសូន្យគេបាន<br>$\frac{ka}{kb}=\frac{a}{b}$<br>Exសម្រួលប្រភាគ $\frac{16}{40}$ និង $\frac{70}{245}$<br><br>**ប្រតិបត្តិ**<br>**សម្រួលប្រភាគ**<br>$\frac{18}{30},\frac{-19}{57}$ និង $-\frac{10}{15}$ | - 6 និង15<br>មានតួចែករួមស្មើនឹង 3<br>គេសរសេរ $\frac{6}{15}=\frac{2\times3}{5\times3}=\frac{2}{5}$<br><br>-$\frac{2}{5}$ ហៅថាប្រភាគសម្រួលមិនបានហើយសមមូលនឹង $\frac{6}{15}$<br><br>-16 និង 40 មានតួចែករួមធំបំផុតស្មើនឹង 8<br>$\frac{16}{40}=\frac{2\times8}{5\times8}=\frac{2}{5}$<br>$\frac{70}{245}=\frac{35\times2}{35\times7}=\frac{2}{7}$<br>សម្រួលប្រភាគ<br>$\frac{18}{30}=\frac{6\times3}{6\times5}=\frac{3}{5}$<br>$\frac{-19}{57}=\frac{-19\times1}{19\times3}=-\frac{1}{3}$<br>$-\frac{10}{15}=\frac{2\times5}{3\times5}=-\frac{2}{3}$ |
| -ដូចម្ដេចដែលហៅថាប្រភាគសមមូល? | <u>ជំហានទី ៤</u> (ពង្រឹងចំនេះដឹង) | សម្រួលប្រភាគខាងក្រោម៖ |

| | | |
|---|---|---|
| -ចូរសម្រួលប្រភាគខាងក្រោម៖<br>ក) $\frac{18}{-33}$ និង $\frac{-36}{-12}$ | | ក) $\frac{18}{-33}=\frac{6\times3}{-11\times3}=-\frac{6}{11}$<br>$\frac{-36}{-12}=\frac{-12\times3}{-12\times1}=3$ |
| គ្រូដាក់លំហាត់ ទី១/២/៣ ទំព័រ៥០ អោយសិស្សធ្វើនៅផ្ទះ និងណែនាំសិស្សឲ្យគោរពវិន័យ និងច្បាប់ចរាចរណ៍ ។ | <u>ជំហានទី</u> ៥ (កិច្ចការផ្ទះ)<br>លំហាត់ទី ១/២/៣ ទំព័រ ៥០ | សិស្សកត់ត្រាលំហាត់ និងស្តាប់ ដំបូន្មានគ្រូ |

# កិច្ចតែងការបង្រៀន

*មុខវិជ្ជា:* **គណិតវិទ្យា ថ្នាក់ទី ៧**

*ថ្ងៃ..........ទី........ខែ......ឆ្នាំ......*

I.*ចំណងជើងមេរៀន:* មេរៀនទី ៤ **ប្រភាគ** (ត)

*ចំណងជើងរង* ៤.ការប្រៀបធៀបប្រភាគ និងរៀបលំដាប់ប្រភាគ

៥. វិធីបូក និង វិធីដកប្រភាគ

II.*វត្ថុបំណង:* ក្រោយពីរៀនចប់មេរៀននេះចប់សិស្សអាច

-ចំណេះដឹង: ប្រាប់បានពីរបៀបប្រៀបធៀប និងរៀបប្រភាគ ព្រមទាំងវិធីបូក ដកប្រភាគបានត្រឹមត្រូវ តាមតរយៈឧទាហរណ៍ ។

-បំណិន: អនុវត្តបានពីការប្រៀបធៀបប្រភាគ រៀបលំដាប់ប្រភាគ បូក ដកប្រភាគ តាមរយៈឧទាហរណ៍និងលំហាត់ប្រតិបត្តិ ។

-ឥរិយាបថ: មានទំនាក់ទំនងល្អរវាងសិស្ស និងសិស្សព្រមទាំងរវាង គ្រូ និងសិស្ស ។

III.*ពេលវេលា* ០២ ម៉ោង

IV. *សម្ភារ:ឧបទេស*

- ដៃកឈានបន្ទាត់ក្រឹត ក្រដាសកាតុងគូសរង្វង់ជាចំណែកៗ ។

V. *ដំណើរការមេរៀន:*

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាព |
|---|---|---|
| គ្រូតពិនិត្យ អវត្តមាន អនាម័យ និង<br>សណ្តាប់ធ្នាប់ វិន័យ | <u>ជំហានទី</u> ១ (រដ្ឋបាលថ្នាក់) | តំនាងថ្នាក់ឡើងរាយការណ៍ |
| -<br>ចូរប្អូនសម្រួលប្រភាគខាងក្រោម<br>ក) $\frac{ka}{kb}=$........<br>ខ) $\frac{18}{33}=$........<br>តើប្រភាគ $\frac{3}{2}$ និង $\frac{2}{3}$<br>មួយណាធំជាង ? | <u>ជំហានទី</u> ២ (រំលឹកចាស់) | -សម្រួលប្រភាគខាងក្រោម<br>ក) $\frac{ka}{kb}=\frac{a}{b}$<br>ខ) $\frac{18}{33}=\frac{6}{11}$<br>+ ប្រភាគ $\frac{3}{2}$ ធំជាង $\frac{2}{3}$ |

| | | |
|---|---|---|
| គ្រូសរសេរចំណងជើងមេរៀនដាក់<br>លើក្តាខៀន<br><br>+តើពហុគុណរួមតូចបំផុតនៃ 12,8,9,4 ស្មើនឹងប៉ុន្មាន ?<br>+បន្ទាប់មកគេធ្វើដូចម្តេច ?<br><br>+តើ $\frac{11}{12}=\frac{....}{72}$<br>+ តើ $\frac{5}{8}=\frac{....}{72}$<br>+ តើ $\frac{7}{9}=\frac{....}{72}$<br>+ តើ $\frac{3}{4}=\frac{....}{72}$<br><br>+ដើម្បីប្រៀបធៀបប្រភាគដែលមាន<br>ភាគបែងដូចគ្នា<br>តើគេធ្វើដូចម្តេច ?<br>+ ចូរប្អូនរៀបតាមលំដាប់ឡើងនៃប្រភាគដើម | ជំហានទី ៣ (មេរៀនប្រចាំថ្ងៃ)<br>មេរៀនទី៤ ប្រភាគ (ត)<br>៤. ការប្រៀបធៀប និងរៀបលំដាប់ប្រភាគ<br>Ex ប្រៀបធៀបប្រភាគ<br>និងរៀបលំដាប់ប្រភាគ $\frac{11}{12},\frac{5}{8},\frac{7}{9},\frac{3}{4}$<br>តាមលំដាប់ឡើង ។<br><br>**ជាទូទៅ**<br>+ ដើម្បីប្រៀបធៀបប្រភាគដែលមានភាគបែងដូចគ្នា គេប្រៀបធៀបតែភាគយក។<br>+ ដើម្បីប្រៀបធៀបប្រភាគដែលមានភាគបែងខុសគ្នា គេត្រូវតម្រូវភាគបែងរួមរួចហើយប្រៀបធៀបភាគយក នឹង ភាគយក ។ | +ពហុគុណរួមតូចបំផុតនៃ 12,8,9,4 ស្មើនឹង 72 ។<br>+បន្ទាប់មកគេប្តូរប្រភាគនីមួយៗ ទៅ<br>ជាប្រភាគសមមូលគ្នា<br>ដែលមានភាគ<br>បែងស្មើនឹង 72 ។<br>+ $\frac{11}{12}=\frac{11\times6}{12\times6}=\frac{66}{72}$<br>+ $\frac{5}{8}=\frac{5\times9}{8\times9}=\frac{45}{72}$<br>+ $\frac{7}{9}=\frac{7\times8}{9\times8}=\frac{56}{72}$<br>+ $\frac{3}{4}=\frac{3\times18}{4\times18}=\frac{54}{72}$<br>+<br>គេប្រៀបធៀបតែភាគយកគេបាន<br>$\frac{45}{72}<\frac{54}{72}<\frac{56}{72}<\frac{66}{72}$<br>+រៀបតាមលំដាប់ឡើងនៃប្រភាគដើម<br>$\frac{5}{8},\frac{3}{4},\frac{7}{9},\frac{11}{12}$ ។ |

| | | |
|---|---|---|
| + តើប្រភាគ $-\frac{3}{4}$ និង $-\frac{4}{5}$ មានភាគ<br>បែងរួមស្មើនឹងប៉ុន្មាន ?<br>+ តើ $-\frac{3}{4}=\frac{?}{20}$<br>+ តើ $-\frac{4}{5}=\frac{?}{20}$<br>+ តើប្អូនសង្កេតឃើញដូចម្តេច ? | Ex ប្រៀបធៀបប្រភាគ $-\frac{3}{4}$ និង $-\frac{4}{5}$ | ប្រភាគ $-\frac{3}{4}$ និង $-\frac{4}{5}$ មានភាគបែងរួមស្មើនឹង 20 ។<br>$-\frac{3}{4}=\frac{(-3)\times 5}{4\times 5}=-\frac{15}{20}$<br>$-\frac{4}{5}=\frac{(-4)\times 4}{4\times 5}=-\frac{16}{20}$<br>$-15>-16$ នោះ $-\frac{15}{20}>-\frac{16}{20}$<br>នាំឲ្យ $-\frac{3}{4}>-\frac{4}{5}$ |
| បែងចែកសិស្សជាក្រុមឲ្យពភាក្សា<br>លំហាត់ប្រតិបត្តិ | **ប្រតិបត្តិ**<br>ប្រៀបធៀបប្រភាគខាងក្រោម៖<br>ក) $\frac{14}{35},\frac{26}{30}$ និង $\frac{27}{45}$<br>ខ) $\frac{-11}{12},\frac{-17}{18}$ និង $\frac{-9}{25}$ | ក) $\frac{14}{35}<\frac{27}{45}<\frac{26}{30}$<br>ខ) $-\frac{17}{18}<-\frac{11}{12}<-\frac{9}{25}$ |
| +តើប្រភាគ $\frac{2}{7}$ និង $\frac{3}{7}$ មានភាគបែង<br>ដូចគ្នាឬទេ ?<br>+ តើគេធ្វើដូចម្តេច ? | ៥. វិធីបូក និងវិធីដកប្រភាគ<br>៥.១ វិធីបូកប្រភាគមានភាគបែងដូចគ្នា<br>Ex ចូរគណនា $\frac{3}{7}+\frac{2}{7}$ | +មានភាគបែងដូចគ្នា<br>+គេបូកភាគយក<br>នឹងភាគយករក្សា<br>ភាគបែងទុកនូវដដែល។<br>គេបាន $\frac{3}{7}+\frac{2}{7}=\frac{2+3}{7}=\frac{5}{7}$ |
| +តើប្រភាគ $\frac{-3}{5}$ និង $\frac{1}{5}$ មានភាគបែង<br>ដូចគ្នាឬទេ ?<br>+ តើគេធ្វើដូចម្តេច ? | Ex ចូរគណនា $\frac{-3}{5}+\frac{1}{5}$ | +មានភាគបែងដូចគ្នា<br>+គេបូកភាគយក<br>នឹងភាគយករក្សា<br>ភាគបែងទុកនូវដដែល។<br>គេបាន $\frac{-3}{5}+\frac{1}{5}=\frac{-3+1}{5}=-\frac{2}{5}$ |
| ឲ្យសិស្សទាញជាទូទៅ | **ជាទូទៅ**<br>ដើម្បីបូកប្រភាគដែលមានភាគបែងដូចគ្នាគេបូកភាគយក នឹងភាគយក | |

| | | |
|---|---|---|
| ដើម្បីបូកប្រភាគនេះបានគេធ្វើដូចម្តេច ? | រក្សាភាគបែងទុកដដែល ។ $\frac{a}{b}+\frac{c}{b}=\frac{a+c}{b}$ ដែល $a,b,c$ ជាចំនួនគត់រ៉ឺឡាទីប $b\neq 0$ ៥.២ វិធីបូកប្រភាគមានភាគបែងខុសគ្នា Ex គណនា $\frac{2}{3}+\frac{3}{5}$ | យើងត្រូវតម្រូវភាគបែងរួមតូចបំផុតដែលស្មើនឹង $PPCM\left(3,5\right)=15$ គេបាន $\frac{2}{3}+\frac{3}{5}=\frac{10}{15}+\frac{9}{15}=\frac{10+9}{15}=\frac{19}{15}$ |
| ដើម្បីបូកប្រភាគនេះបានគេធ្វើដូចម្តេច ? | Ex គណនា $\frac{1}{3}+\frac{-3}{4}$ | យើងត្រូវតម្រូវភាគបែងរួមតូចបំផុតដែលស្មើនឹង $PPCM\left(3,4\right)=12$ គេបាន $\frac{1}{3}+\frac{-3}{4}=\frac{4}{12}+\frac{-9}{12}$ $=\frac{4-9}{12}=-\frac{5}{12}$ |
| ឲ្យសិស្សទាញជាទូទៅ | **ជាទូទៅ** ដើម្បីបូកប្រភាគដែលមានភាគបែងខុសគ្នា គេត្រូវតម្រូវភាគបែងរួម (គេយក $PPCM$ នៃភាគបែងជាភាគបែងរួម) រួចបូកភាគយកនឹងភាគយករួចរក្សាភាគបែងរួមទុកដដែល **លក្ខណៈ** ក) លក្ខណៈត្រឡប់ $\frac{a}{b}+\frac{c}{d}=\frac{c}{d}+\frac{a}{b}$ ខ) លក្ខណៈផ្តុំ $\left(\frac{a}{b}+\frac{c}{d}\right)+\frac{p}{q}=\frac{a}{b}+\left(\frac{c}{d}+\frac{p}{q}\right)$ គ) $\frac{a}{b}+0=\frac{a}{b}$ | ប្រភាគ $\frac{6}{7}$ និង $-\frac{2}{7}$ មានភាគបែងស្មើគ្នា ។ ដើម្បីដកប្រភាគនេះគេធ្វើដូច |

| | | |
|---|---|---|
| តើប្អូនសង្កេតឃើញដូចម្តេច?<br>ចំពោះប្រភាគ $\frac{6}{7}$ និង $-\frac{2}{7}$<br>ដើម្បីដកប្រភាគនេះគេធ្វើដូចម្តេច?<br>+សិស្សទាញទូទៅ | ៥.៣វិធីដកប្រភាគមានភាគបែងដូចគ្នា<br>Ex គណនា $\frac{6}{7}-\frac{2}{7}$<br>**ជាទូទៅ** $\frac{a}{b}-\frac{c}{b}=\frac{a-c}{b}$ ដែល $a,b,c$ ជាចំនួនគត់រ៉ឺឡាទីប $b\neq 0$<br>**សំគាល់** ប្រភាគ $-\frac{3}{5}$ ផ្ទុយនឹងប្រភាគ $\frac{3}{5}$<br>ព្រោះ $\frac{3}{5}+\left(-\frac{3}{5}\right)=0$<br>ដូចនេះ $\frac{a}{b}$ ផ្ទុយនឹង $-\frac{a}{b}$ | គទៅ:<br>$\frac{6}{7}-\frac{2}{7}=\frac{6-2}{7}=\frac{4}{7}$ |
| ដើម្បីដកប្រភាគនេះតើគេត្រូវធ្វើដូចម្តេច ? | ៥.៤ វិធីដកប្រភាគដែលមានភាគបែងខុសគ្នា<br>Ex គណនា $\frac{7}{8}-\frac{1}{2}$ | គេត្រូវតម្រូវភាគបែងរួមតូចបំផុត $PPCM\left(8,2\right)=8$រួចដកភាគយកនឹងភាគយកហើយរក្សាភាគបែងទុកដដែល ។<br>គេបាន $\frac{7}{8}-\frac{1}{2}=\frac{7-4}{8}=\frac{3}{8}$ |
| ដើម្បីដកប្រភាគនេះតើគេត្រូវធ្វើដូចម្តេច ? | Ex គណនា $\frac{2}{7}-(-\frac{1}{4})$ | ភាគបែងរួម $PPCM\left(7,4\right)=28$<br>គេបាន $\frac{2}{7}-(-\frac{1}{4})=\frac{2}{7}+\frac{1}{4}=\frac{8}{28}+\frac{7}{28}=\frac{8+7}{28}=\frac{15}{28}$ |
| ឲ្យសិស្សទាញជាទូទៅ | **ជាទូទៅ**ដើម្បីដកប្រភាគដែលមានភាគបែងខុសគ្នាគេត្រូវតំរូវភាគបែងរួម<br>( គេយក $PPCM$ នៃភាគបែង ជាភាគបែងរួមរួចដកភាគយក នឹងភាគយកហើយរក្សាទុកភាគបែងនូវដដែល<br>Ex គណនា $x$ ដោយដឹងថា | |

| | | |
|---|---|---|
| ដើម្បីគណនាតម្លៃ $x$ នៃប្រភាគនេះ គេត្រូវធ្វើដូចម្តេច ?<br><br>ដាក់លំហាត់ប្រតិបត្តិឲ្យសិស្សពិភាក្សាជាដៃគូរួចឡើងធ្វើលើក្តាខៀន | $\frac{x}{5}=\frac{5}{6}+\frac{-19}{30}$<br><br>**ប្រតិបត្តិ** គណនាកន្សោមខាងក្រោម<br>$A=-\frac{1}{2}-\frac{1}{4}-(-\frac{9}{10})$<br>$B=\frac{3}{14}-\frac{5}{-7}-\frac{1}{2}$ | គេត្រូវតរូវភាគបែងរួម<br>$PPCM\,(30,6,5)=30$<br>គេបាន $\frac{x}{5}=\frac{5}{6}+\frac{-19}{30}$<br>$\frac{6x}{30}=\frac{25}{30}-\frac{19}{30}$<br>$6x=25-19$<br>$6x=6$<br>$x=1$<br><br>$A=\frac{3}{20}$<br>$B=\frac{3}{7}$ |
| -ដើម្បីប្រៀបធៀបប្រភាគដែលមានភាគបែងខុសគ្នាតើគេត្រូវធ្វើដូចម្តេច ?<br><br>-ដើម្បីបូក ឬដកប្រភាគដែលមានភាគបែងខុសគ្នា តើគេត្រូវធ្វើដូចម្តេច ? | <u>ជំហានទី</u> ៤ (ពង្រឹងចំនេះដឹង) | គេត្រូវតំរូវភាគបែងរួមរួចហើយប្រៀបធៀបភាគយក និងភាគយក ។ភាគបែងនឹងភាគបែង ។<br>ដើម្បីដកប្រភាគដែលមានភាគបែងខុសគ្នាគេត្រូវតំរូវភាគបែងរួម( គេយក $PPCM$ នៃភាគបែងជាភាគបែងរួម រួចដកភាគយកនឹងភាគយកហើយរក្សាទុកភាគបែងនូវដដែល ។ |

| | | |
|---|---|---|
| គ្រូដាក់លំហាត់ ទី៩ទំព័រ៥១ អោយសិស្សធ្វើនៅផ្ទះ និងណែនាំ សិស្សឲ្យគោរពវិន័យ និងច្បាប់ចរាចរណ៍ ។ | <u>ជំហានទី ៥</u> (កិច្ចការផ្ទះ)<br>លំហាត់ទី ៦ ទំព័រ ៥០ | សិស្សកត់ត្រាលំហាត់ និងស្តាប់ដំបូន្មានគ្រូ |

# កិច្ចតែងការបង្រៀន

*មុខវិជ្ជា: គណិតវិទ្យា ថ្នាក់ទី ៧*

*ថ្ងៃ............ទី..........ខែ...........ឆ្នាំ.........*

I.*ចំណងជើងមេរៀន:* មេរៀនទី ៤ ប្រភាគ (ត)

*ចំណងជើងរង:* ៦. វិធីគុណប្រភាគ

៧. វិធីចែកប្រភាគ

I.*វត្ថុបំណង:* ក្រោយពីរៀនចប់មេរៀននេះចប់សិស្សអាច

-ចំណេះដឹង: ប្រាប់បានពីវិធីគុណប្រភាគ ចែកប្រភាគបានត្រឹមត្រូវតាមរយៈឧទាហរណ៍។

-បំណិន: គណនាបានពីការគុណប្រភាគ និងចែកប្រភាគបានត្រឹមត្រូវ តាមរយៈឧទាហរណ៍និងលំហាត់ប្រតិបត្តិ ។

-ឥរិយាបថ: មានទំនាក់ទំនងល្អរវាងសិស្ស និងសិស្សព្រមទាំងរវាង គ្រូ និងសិស្ស ។

II.*ពេលវេលា* ០២ ម៉ោង

III. *សម្ភារ:ឧបទេស*

- ដែកឈានបន្ទាត់ក្រឹត ក្រដាសកាតុងគូសរង្វង់ជាចំណែកៗ ។

IV. *ដំណើកនាំមេរៀន:*

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាព |
|---|---|---|
| គ្រូតពិនិត្យ អវត្តមាន អនាម័យ និង សណ្តាប់ធ្នាប់ វិន័យ | <u>ជំហានទី</u> ១ (រដ្ឋបាលថ្នាក់) | តំនាងថ្នាក់ឡើងរាយការណ៍ |
| -ដើម្បីបូក ឬដកប្រភាគដែលមានភាគបែងដូចគ្នា តើគេត្រូវ ធ្វើដូចម្តេច?<br>- គណនា<br>ក) $A=\frac{14}{20}+\frac{7}{20}$<br>ខ) $B=\frac{8}{15}+\frac{3}{5}+\frac{1}{3}$ | <u>ជំហានទី</u> ២ (រំលឹកចាស់) | -គេត្រូវបូក ឬដកតែភាគយករក្សាភាគបែងទុកនៅដដែល ។<br>ក) $A=\frac{14}{20}+\frac{7}{20}=\frac{14+7}{20}=\frac{21}{20}$<br>ខ)<br>$B=\frac{8}{15}+\frac{3}{5}+\frac{1}{3}=\frac{8+9+5}{15}=\frac{22}{15}$ |

| | | |
|---|---|---|
| គ្រូសរសេរចំណងជើងមេរៀនដាក់<br>លើក្ដារខៀន | ជំហានទី ៣ (មេរៀនប្រចាំថ្ងៃ)<br>មេរៀនទី៤ ប្រភាគ (ត)<br>៦. វិធីគុណប្រភាគ | |
| +ដើម្បីគុណប្រភាគនោះ<br>តើគេត្រូវធ្វើដូចម្ដេច ? | Ex គណនា $\frac{1}{2}\times\frac{1}{4}$ | +គេត្រូវគុណភាគយក<br>នឹងភាគយក<br>ហើយគុណភាគបែងនឹងភាគបែង<br>។<br>គេបាន $\frac{1}{2}\times\frac{1}{4}=\frac{1\times1}{2\times4}=\frac{1}{8}$ |
| + ដើម្បីគុណប្រភាគនោះ<br>តើគេត្រូវធ្វើដូចម្ដេច ? | Ex គណនា $\frac{-3}{7}\times\frac{2}{-5}$ | គេត្រូវគុណភាគយកនឹងភាគយក<br>ហើយគុណភាគបែងនឹងភាគបែង<br>។<br>គេបាន<br>$\frac{-3}{7}\times\frac{2}{-5}=\frac{(-3)\times2}{7\times(-5)}=\frac{-6}{-35}=\frac{6}{35}$ |
| ឲ្យសិស្សទាញជាទូទៅ | **ជាទូទៅ** ដើម្បីគុណប្រភាគ $\frac{a}{b}$ និង<br>$\frac{c}{d}$ គេគុណភាគយកនឹង<br>ភាគយក ហើយភាគបែង<br>នឹងភាគបែង។គេបាន<br>$\frac{a}{b}\times\frac{c}{d}=\frac{a\times c}{b\times d}, b\neq0, d\neq0$<br>**សំគាល់**<br>ក) បើ $d=1$ នោះ $\frac{a}{b}\times c=\frac{a\times c}{b}$<br>ខ) $\frac{a}{b}\times\frac{c}{d}=\frac{c}{d}\times\frac{a}{b}$<br>គ) $\left(\frac{a}{b}\times\frac{c}{d}\right)\times\frac{p}{q}=\frac{a}{b}\left(\frac{c}{d}\times\frac{p}{q}\right)$<br>ឃ) $\frac{a}{b}\times1=1\times\frac{a}{b}=\frac{a}{b}$<br>ង) $\frac{a}{b}\left(\frac{c}{d}+\frac{p}{q}\right)=\frac{a}{b}\times\frac{c}{d}+\frac{a}{b}\times\frac{p}{q}$ | |
| -តើយើងត្រូវធ្វើដូចម្ដេច? | Ex គណនា | + យើងត្រូវធ្វើដូចតទៅ |

| | | |
|---|---|---|
| បែងចែកសិស្សជាក្រុម<br>ឲ្យពិភាក្សាលំហាត់ប្រតិបត្តិ | $A=\frac{5}{7}\times\frac{8}{15}\times\frac{14}{3}$<br>$B=\frac{-7}{15}\times\frac{5}{8}\times\frac{15}{-7}\times(-16)$ | $A=\frac{5}{7}\times\frac{8}{15}\times\frac{14}{3}=\frac{5\times8\times14}{7\times15\times3}=\frac{16}{9}$<br>$B=\frac{-7}{15}\times\frac{5}{8}\times\frac{15}{-7}\times(-16)$<br>$=\frac{(-7)\times5\times15\times(-16)}{15\times8\times(-7)}=-10$ |
| | **ប្រតិបត្តិ គណនា**<br>$A=\frac{-15}{9}\times\frac{13}{15}-\frac{13}{18}\times\frac{4}{9}$<br>$B=-3\frac{1}{4}+\frac{3}{5}\times\left(-\frac{2}{13}\right)$ | $A=-\frac{245}{252}$<br>$B=-\frac{1177}{300}$ |
| -ដើម្បីចែកប្រភាគនេះយើងត្រូវធ្វើដូចម្ដេច?<br>ស្មើគ្នាឬទេ ? គេធ្វើដូចម្ដេច? | ៧. វិធីចែកប្រភាគ<br>Ex ចូរគណនា $\frac{3}{5}\div\frac{1}{10}$ | -ដើម្បីចែកប្រភាគនេះយើងត្រូវយកប្រភាគទី ១ គុណនឹងចម្រាស់ប្រភាគទី ២ ។<br>គេបាន $\frac{3}{5}\div\frac{1}{10}=\frac{3}{5}\times\frac{10}{1}=\frac{30}{5}=6$ |
| -ដើម្បីចែកប្រភាគនេះយើងត្រូវធ្វើដូចម្ដេច?<br>ស្មើគ្នាឬទេ ? គេធ្វើដូចម្ដេច? | Ex ចូរគណនា $\frac{-3}{4}\div2$ | -ដើម្បីចែកប្រភាគនេះយើងត្រូវយកប្រភាគទី ១ គុណនឹងចម្រាស់ប្រភាគទី ២ ។<br>គេបាន $\frac{-3}{4}\div2=\frac{-3}{4}\times\frac{1}{2}=-\frac{3}{8}$ |
| | **ជាទូទៅ**<br>ដើម្បីចែកប្រភាគ នឹងប្រភាគ គេត្រូវយកប្រភាគទី ១គុណចម្រាស ប្រភាគទី ២ ។<br>**ចំពោះ**<br>$\frac{a}{b}\div\frac{c}{d}=\frac{a}{b}\times\frac{d}{c}=\frac{a\times d}{b\times c}$<br>$a\div\frac{c}{d}=\frac{a\times c}{d}$<br>ដែល $b\neq0,c\neq0,d\neq0$ | |
| -មុនចែកប្រភាគនេះតើយើងត្រូវធ្វើដូចម្ដេច ?<br>សមមូលនឹងប្រភាគណា ? | **សំគាល់** ចម្រាសនៃ 2 គឺ $\frac{1}{2}$ | -យើងត្រូវ គណនា<br>$\frac{1}{5}-\frac{1}{2}=\frac{2-5}{10}=-\frac{3}{10}$<br>$-\frac{2}{3}\times\frac{1}{8}=-\frac{2}{24}$ |

| | | |
|---|---|---|
| -បន្ទាប់មកធ្វើដូចម្តេច ?<br><br>ដាក់លំហាត់ឲ្យសិស្សពិភាក្សា<br>ក្រុមរួចឡើងធ្វើលើក្តាខៀន | ចម្រាសនៃ $\frac{a}{b}$ គឺ $\frac{b}{a}$<br>Ex គណនាកន្សោម<br>$A=\left(\frac{1}{5}-\frac{1}{2}\right)\div\left(-\frac{2}{3}\times\frac{1}{8}\right)$<br><br>**ប្រតិបត្តិ**<br>ក) គណនាកន្សោម<br>$A=\frac{3}{5}\times\left(-\frac{1}{4}-\frac{1}{6}\right)\div\left(-\frac{2}{3}+\frac{1}{4}\right)$<br>ខ) គណណនា $x$ បើគេដឹងថា<br>$\frac{3}{4}\div x=2$ | $A=\left(\frac{1}{5}-\frac{1}{2}\right)\div\left(-\frac{2}{3}\times\frac{1}{8}\right)$<br>$=\frac{3}{10}\times\frac{24}{2}=\frac{3\times24}{10\times2}=\frac{18}{5}$<br><br>គេបានក)<br>$A=\frac{3}{5}\times\left(-\frac{1}{4}-\frac{1}{6}\right)\div\left(-\frac{2}{3}+\frac{1}{4}\right)$<br>$=\frac{3}{5}\times\left(\frac{-3-2}{12}\right)\div\left(\frac{-28+15}{12}\right)$<br>$=-\frac{1}{4}\div\left(-\frac{13}{12}\right)=\frac{1}{4}\times\frac{12}{13}=\frac{3}{13}$<br>ខ) គណណនា $x$ បើគេដឹងថា<br>$\frac{3}{4}\div x=2$<br>គេបាន<br>$\frac{3}{4}\div x=2$<br>$\frac{3}{4}\times\frac{1}{x}=2$<br>$\frac{3}{4x}=2\Leftrightarrow 2\times4x=3$<br>$8x=3\Rightarrow x=\frac{3}{8}$ |
| -ដើម្បីគុណប្រភាគ និង ប្រភាគតើគេត្រូវធ្វើដូចម្តេច ?<br>-<br>ដើម្បីចែកប្រភាគនឹងប្រភាគ<br>តើគេត្រូវធ្វើដូចម្តេច ?<br>+គណនា<br>ក) $20\div\frac{4}{5}$<br>ខ) $\frac{9}{28}\div\frac{6}{7}$ | ជំហានទី ៤ (ពង្រឹងចំនេះដឹង) | -គេត្រូវគុណភាគយក<br>នឹងភាគយកហើយ<br>ភាគបែង នឹងភាគបែង ។<br>- គេត្រូវយកប្រភាគទី ១ គុណចម្រាសនឹងប្រភាគទី ២ ។<br>+គណនា<br>ក) $20\div\frac{4}{5}=20\times\frac{5}{4}=25$<br>ខ) $\frac{9}{28}\div\frac{6}{7}=\frac{9}{28}\times\frac{7}{6}=\frac{3}{8}$ |

| | | |
|---|---|---|
| គ្រូដាក់លំហាត់ ទី៩ទំព័រ៥១ អោយសិស្សធ្វើនៅផ្ទះ និងណែនាំ សិស្សឲ្យគោរពវិន័យ និងច្បាប់ចរាចរណ៍ ។ | ជំហានទី ៥ (កិច្ចការផ្ទះ)<br>លំហាត់ទី ៩ ទំព័រ ៥១ | សិស្សកត់ត្រាលំហាត់ និងស្តាប់ដំបូន្មានគ្រូ |

# កិច្ចតែងការបង្រៀន

- ថ្នាក់ទី7
- មេរៀនទី5 «ចំនួនសភាគ»
- ខ្លឹមសារមេរៀន: 1 សញ្ញាណចំនួនទសភាគ

 1.1 តម្លៃលេខតាមខ្ទង់ក្នុងចំនួនទសភាគ

 1.2 ការប្រៀបធៀបចំនួនទសភាគ

 - រយៈពេល 01 ម៉ោង

## I/**វត្ថុបំណង**

1.ចំណេះដឹង: កំណត់សញ្ញាណនៃចំនួនទសភាគ និងតម្លៃលេខតាមខ្ទង់ក្នុងចំនួនទសភាគបានត្រឹមត្រូវតាមរយៈឧទាហរណ៍។

២.បំណិន: ប្រៀបធៀប និងរៀបតាមលំដាប់ទសភាគតាមរយៈការអនុវត្ត ធ្វើលំហាត់បានត្រឹមត្រូវ។

៣.ឥរិយាបថ: មានស្មារតីប្រុងប្រយ័ត្ន ក្នុងជីវភាពរស់នៅប្រចាំថ្ងៃក្នុងការងារទាក់ទង នឹងចំនួនទសភាគ។

## II/**សម្ភារឧបទេស**

-សៀវភៅសិស្សទំព័រ 53 ដល់55 បោះពុម្ពឆ្នាំ2009

## III/**ដំណើរការបង្រៀន**

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| -ពិនិត្យអត្តមាន វិន័យ អនាម័យក្នុងថ្នាក់ | ជំហានទី1 (1-2នាទី)<br>(រដ្ឋបាលថ្នាក់) | -ប្រធានថ្នាក់រាយការណ៍ |

| | | |
|---|---|---|
| - ដូចម្តេចដែលហៅថាប្រភាគ? | ជំហានទី2 (3-5នាទី)<br>(រំលឹកមេរៀនចាស់)<br>-សញ្ញាណប្រភាគ | -ប្រភាគជាចំនួនដែលមានរាង $\frac{a}{b}$ដែលa,bជាចំនួនគត់រ៉ឺឡាទីបហើយ a ជាភាគយក b ជាភាគបែងនៃប្រភាគ(a/b) |
| -ដាក់ឧទាហរណ៍ លើក្តាខៀន រួចណែនាំ៖<br>$\frac{1}{10}$=0.1 ;$\frac{1}{១០០}$ $= \cdots ?$<br>$\frac{2}{1000}$=0,002<br>-ណែនាំប្រាប់<br>-ណែនាំសួរ: អ្វីទៅជាចំនួនទសភាគ?<br><br>-គ្រូនិងសិស្សឲ្យឧទាហរណ៍បន្ថែមពីចំនួនទសភាគ<br><br><br>-ដាក់ឧទាហរណ៍ រួចណែនាំ: ៩ ស្ថិតនៅលើភាគពាន់មាតម្លៃ | ជំហានទី 3 (25-30នាទី)<br>(មេរៀនប្រចាំថ្ងៃ)<br>**ចំនួនទសភាគ**<br>1.សញ្ញាណចំនួនទសភាគ<br>ឧទាហរណ៍ទី1<br>$\frac{1}{10}$=0.1,$\frac{1}{100}$=0.01,$\frac{2}{1000}$ $=$ 0,002។ គេថា0.1 ,0.1 ,0.2ជាចំនួនទសហើយសញ្ញាចុចហៅថាចំណុចទសភាគ។<br>*ចំនួនទសភាគជាចំនួនតាងប្រភាគដែលមានភាគបែងស្មើ 10,100,1000,….។<br>ឧទាហរណ៍ទី2 7.31,0,012,-12.5,-10.001,…ជាចំនួនទសភាគ។<br>1.1តម្លៃលេខតាមខ្ទង់ក្នុងចំនួនទសភាគ | -ស្តាប់ការណែនាំ<br><br>$\frac{1}{100}$=0.01<br><br>-ចំនួនទសភាគជាចំនួនប្រភាគដែលមានភាគមបែងស្មើ 10,100,1000,...។<br>-ឲ្យឧទាហរណ៍ខ្លះធ្វើជាបុគ្គល។<br><br><br>-សិស្សសង្កេត<br><br>-សិស្សស្តាប់ការណែនាំ |

| | | |
|---|---|---|
| ស្មើ$\frac{៩}{១០០០}$=០,០០៩ | | |
| | ឧទាហរណ៍ ៖ | |
| -ចុះ៣ស្ថិតនៅខ្ទង់អ្វី? មានតម្លៃស្មើប៉ុន្មាន? | 2 1 . 0 3 9<br>9ភាគពាន់=$\frac{9}{1000}$=0.009 | -3នៅខ្ទង់ភាគរយ។ មានតម្លៃ=$\frac{3}{100}$=0.03 |
| -ឲ្យជាឧទាហរណ៍ រួចណែនាំប្រៀបធៀប | 3ភាគរយ=$\frac{3}{100}$=0.03 | -សិស្សស្តាប់ |
| -តំរៀបចំនួនទសភាគដោយឲ្យចំណុចទសភាគត្រូវគ្នា។ រួចប្រៀបធៀបលេខតាមខ្ទង់នីមួយៗ។ | 0ភាគដប់=$\frac{0}{10}$=0.01<br>1ខ្ទង់រាយ=1x1=1<br>2ខ្ទង់ដប់=2x10=20 | -ស្តាប់និងធ្វើការប្រៀបធៀបលេខតាមខ្ទង់។ |
| -ដាក់ឧទាហេរណ៍រួចណែនាំសួ តើការរៀបតាមលំដាប់កើន ជាការរៀបពីតូចទៅធំ ឬពីធំទៅមតូច? | សរុប=21.039<br>**1.2/ ការប្រៀបធៀបចំនួនទសភាគ**<br>ឧទាហរណ៍: ប្រៀបធៀប 3.341 និង 3.342។<br>3 . 3 4 1<br>3 . 3 4 2<br>ស្មើគ្នា ស្មើគ្នា ស្មើគ្នា 2>1<br>ដូចនេះ 3.342>3.341<br>**1.3/ការរៀបលំដាប់ចំនួនទសភាគ**<br>ឧទាហរណ៍: រៀប 4.02, 4.05 និង 4.04តាមលំដាប់កើន គឺ 4.02, 4.04, 4.05។ ឬអាចសរសេរ<br>4.02<4.04<4.05 | -រៀបតាមលំដាប់កើន គឺរៀបពីតូចទៅធំ។ |

| | | |
|---|---|---|
| +ឲ្យសិស្សរៀបចំនួន -៣.០២ ,-៤.៥៦,-២.១០,៣.០០តាមលំដាប់ចុះ។ | **ជំហានទី4** (7-10នាទី)<br>(ពង្រឹងចំណេះដឹង)<br>+រៀបចំចំនួន-3.02,-4.56,-2.10,3.00តាមលំដាប់ចុះ គឺ 3.00,-2.10,-3.02,-4.56។ | -សិស្សម្នាក់ឡើងធ្វើក្តាខៀន<br>-សិស្សដទៃទៀតធ្វើនៅកន្លែងរៀងៗខ្លួន<br>+3.00>-2.10>-3.02>-4.56 |
| -ឲ្យសិស្សធ្វើលំហាត់ប្រវត្តិ ១ និង២ ទំព័រ ៥៥។ | **ជំហានទី5** (2-3 នាទី)<br>(កិច្ចការផ្ទះ)<br>-លំហាតប្រតិបត្តិទី 1 និង 2 ទំព័រ 55 | -សិស្សកត់ចំណាំទុកធ្វើនៅផ្ទះ។ |

# កិច្ចតែងការបង្រៀន

- ថ្នាក់ទី7
- មេរៀនទី5 «ចំនួនសភាគ»(ត)
- ខ្លឹមសារមេរៀន: 2. ការប្តូរប្រទៅជាចំនួនទសភាគ

  3. ការប្តូរទសភាគទៅជាប្រភាគ
- រយៈពេល 01 ម៉ោង

## I/**វត្ថុបំណង**

1.ចំណេះដឹង: កំណត់បានពីសញ្ញាណនៃចំនួនទសភាគខួបតាមរយៈការពន្យល់របស់គ្រូបានត្រឹមត្រូវ។

២.បំណិន:ប្តូរប្រភាគទៅជាចំនួនទសភាគ និងប្តូរចំនួនទសភាគទៅជាប្រភាគឲ្យបានត្រឹមត្រូវតាមរយៈ ឧទាសហរណ៍ និងការប្រតិបត្តិ។

3.ឥរិយាបថ: មានស្មារតីប្រុងប្រយ័ត្ន ក្នុងការប្តូរប្រភាគទៅជាចំនួនទសភាគ និងច្រាសមកវិញ។

## II/**សម្ភារឧបទេស**

-សៀវភៅសិស្ស ទំព័រ 55-57 បោះពុម្ពឆ្នាំ2009

III/ ដំណើកនាំមេរៀន

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| -ពិនិត្យអវត្តមានវិន័យសណ្តាប់ធ្នាប់ក្នុងថ្នាក់ | **ជំហានទី1** (១-២នាទី)<br>(រដ្ឋបាលថ្នាក់) | -ប្រធានថ្នាក់រាយការណ៍ |

| | | |
|---|---|---|
| -ចូរឲ្យនិយមន័យចំនួនទសភាគ។ | **ជំហានទី2** (1-5នាទី)<br>(រំលឹកមេរៀនចាស់)<br>-និយមន័យចំនួនទសភាគ | -ចំនួនទសភាគជាចំនួនតាងប្រភាគដែលមានភាគបែងស្មើ 10,100,1000,...។ |
| -ដាក់ឧទាហរណ៍ រួចណែនាំឲ្យសិស្សគណនា<br>-ចូរប្អូនសាកល្បងធ្វើប្រមាណវិធីចែក ។<br>-ណែនាំឲ្យធ្វើប្រមាណវិធីបន្ត<br><br>-សង្កេត 0 មានពីរនោបន្ទាប់ពីមានសញ្ញាចុចមានពីរខ្ទង់ដែរ។<br>-ណែនាំប្រាប់: បើ $\frac{2}{3}$=0.666...គឺមានលេខ 6 ជានិច្ចគ្មានទីនបញ្ចប់ ។គេមិនអាចសរសេរឲ្យគ្រប់លេខ 6 ទេ ។ ដូចនេះ គេប្រើបានដើម្បី បង្ហាញថា 6 មានច្រំដែលនោះ $\frac{2}{3}$=0.666...=0.6 ហៅថាចំនួនទសភិាគខួបដែលមាន 6 ជាខួប ។<br>-ឲ្យសិស្សប្តូរដោយចែក | **ជំហានទី3** (២៥-៣០នាទី)<br>(មេរៀនប្រចាំថ្ងៃ)<br>**ចំនួនទសភាគ** (ត)<br><br>**2. ការប្តូរប្រភាគទៅជាចំនួនទសភាគ**<br><br>ចម្លើយ<br>ក/. $\frac{9}{10}$=0.9<br>ខ/. $\frac{13}{100}$=0.13<br>គ/. $\frac{2}{100}$=-0.02<br>ឃ/. $\frac{123}{100}$= 1.$\underline{23}$ 2ខ្ទង់<br>សូន្យ2ខ្ទង់<br>ឧទាហរណ៍ទី1 នៅពេលគេចែក 2 និង 3 គេបាន $\frac{2}{3}$=0.666...=$0.\overline{6}$ ហៅថាចំនួនទសភាគខួបដែលមាន 6ខួប។<br>ឧទាហរណ៍:ទី2 ប្តូរប្រភាគ | -រៀបចំសម្ភារៈសិក្សានិងគណនា<br>-សិស្សសាកល្បងចែករៀងៗខ្លួន<br>$\frac{9}{10}$=0.9<br>$\frac{13}{100}$=0.13<br>-$\frac{2}{100}$=-0.02<br>-សង្កេតនិងកត់ត្រា<br><br>-សង្កេតសាកល្បងចែកនិងកត់ត្រា |

| | | |
|---|---|---|
| | ជាចំនួនទសភាគ $\frac{7}{5}$=1.4 ឬ $\frac{7}{5}$=$\frac{14}{10}$=1.4 | $\frac{7}{5}$=1.4<br>$\frac{7}{5}$=$\frac{7\times2}{5\times2}$=$\frac{14}{10}$=1.4 |
| -ឲ្យសិស្សប្តូរដោយបំលែងភាគបែង ជា 10,.100,1000,...<br>-ដាក់ ឧទាហរណ៍ ណែនាំ<br>- តើគេបានប្រភាគយ៉ាងដូចម្តេច ?<br>-ឲ្យសិស្សប្តូរ 19.91 ជាប្រភាគ<br>-តើគេអាចកំណត់ថាលេខ2បន្ទាប់ពីចុចមានចំនួនប៉ុន្មានបានឬទេ?<br>-បើតាង N =0.$\bar{2}$ តើគអាចសរសេរ N បានយ៉ាងដូចម្តេចដោយមិនប្រើរបា?<br>-គុណ N និង 10 តើគេបានដូចម្តេច?<br>-យក10N ដក N. | **3. ការប្តូរចំនួនទសភាគជាប្រភាគ**<br>ឧទាហរណ៍ទី3<br>ប្តូរចំនួនទសភាគជាប្រភាគ<br>ក/0.14=$\frac{14}{100}$ =$\frac{7}{50}$<br>ខ/.19.91=$\frac{1991}{100}$<br>គ/,0.$\bar{2}$<br>តាង N= 0.$\bar{2}$<br>N=0.0222<br>គេបាន 10N=2.222….<br>$\frac{N = 0.222 \ldots}{9N = 2}$<br>⇨ N=$\frac{2}{9}$<br>គេបាន N=0.$\bar{2}$=$\frac{2}{9}$ | -សិស្សស្តាប់<br>-គេបាន 0.14=$\frac{14}{100}$=$\frac{7}{50}$<br>-19.91=$\frac{1991}{100}$<br>-គេមិនអាចកំណត់បានទេ<br>-បើN=0.2<br>នោះ N=0.222…<br>-គុណ N និង10គេបាន 10N=2.222... |
| -សិស្សប្តូរប្រភាគជាចំនួនទសភាគ<br>ក/$\frac{1}{2}$ | ជំហានទី4(7- 10នាទី)<br>(ពង្រឹងចំណេះដឹង)<br>ក.$\frac{1}{2}$=0.5 | -សិស្សប្តូរ<br>ក/$\frac{1}{2}$=$\frac{1\times5}{25\times5}$=0.5 |

| | | |
|---|---|---|
| ខ/$\frac{8}{25}$<br>-ប្តូរចំនួនទសភាគជាប្រភាគ<br>ក/-1.$\bar{7}$<br>ខ/0.$\overline{345}$ | ខ.-$\frac{8}{25}$=-0.32<br><br>ក.-1.$\bar{7}$=-17$\frac{7}{9}$<br><br>ខ.0 .$\overline{345}$=$\frac{115}{333}$ | ខ/.-$\frac{8}{25}$=-$\frac{8\times4}{25\times4}$=-0.32<br>-សិស្សគណនា<br>ក/.-1.$\bar{7}$<br>តាងN =-1.777…<br>10N=-17.777…<br>$N = -1.777\ldots$<br>$9N = -16 => N = -1\frac{7}{9}$ |
| -ឲ្យសិស្សធ្វើលំហាត់លេខ 2 ទំព័រ 6 និងប្តូរ2.0$\overline{1}$2 ជាប្រភាគ រចំនួនចំរុះ។ | ជំហានទី5(2-៣នាទី)<br>(កិច្ចការផ្ទះ)<br>-លំហាត់លេខ 2 ទំព័រទី 61 និងប្តូរ2-$\overline{01}$2ជាប្រភាគឬចំនួនចំរុះ | -កត់ត្រាលេខលំហាត់ និងលំហាត់បន្ថែមទុកធ្វើនៅផ្ទះ។ |

# កិច្ចតែងការបង្រៀន

- ថ្នាក់ទី7
- មេរៀនទី5 «ចំនួនសភាគ»(ត)
- រយៈពេល 01 ម៉ោង

## I/វត្ថុបំណង

1.ចំណេះដឹង: កំណត់បានពីវីធី បូក ដក គុណចំនួនទសភាគបានត្រឹមត្រូវតាមរយៈឧទាហរណ៍។

2.បំណិន: គណនាផលបូក ដក គុណចំ នួនទសភាគបានត្រឹមត្រូវតាមរយៈឧទាហរណ៍។

3. ឥរិយាបថ: បណ្ដុះស្មារតីប្រុងប្រយ័ត្នក្នុងការគណនាប្រមាណវិធី បូក ដក គុណ

II/សម្ភារៈឧបទេស

-សៀវភៅសិស្ស-ទំព័រ57 -58បោះពុម្ភឆ្នាំ2009

III/ ដំណើកនាំមេរៀន

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| -ពិនិត្យវត្តមាន អនាម័យ | ជំហានទី1(1-2នាទី) (រដ្ឋបាលថ្នាក់) | -ប្រធានថ្នាក់រាយការណ៍ |
| -ប្តូរប្រភាគជាចំនួនទសភាគ | ជំហានទី2 (3-5នាទី) (រំលឹកមេរៀនចាស់) | -គណនា |

| | | |
|---|---|---|
| ក/-$\frac{13}{100}$<br>ខ/$\frac{407}{1000}$<br>គ/-$\frac{13786}{1000}$ | | ក/.$\frac{-13}{100}$=-0.13<br>ខ/.$\frac{407}{1000}$=0.407<br>គ/.-$\frac{13786}{1000}$=13786 |
| -ដាក់ឧទាហរណ៍រួចគណនា<br>ក.12.3+6.2?ចំណុចទសភាគត្រូវដាក់ឲ្យត្រង់ជួរឈរ<br>Type equation here.<br>-ណែនាំគណនា (ខ) និង(គ)<br>-ណែនាំ: $\begin{array}{r} -12.3 \\ 6.2 \\ \hline 6.1 \end{array}$<br>-ដាក់លំហាត់គំរូណែនាំឲ្យសិស្សគណនា<br>-ដាក់ឧទាហរណ៍ពន្យល់សិស្ស | -ជំហាហានទី3(25-30នាទី)<br>(មេរៀនប្រចាថ្ងៃ)<br>5. ចំនួនទសភាគ(ត)<br>4.វិធីបូក និងដកចំនួនទសភាគ<br>4.1 វិធីបូកចំនួនទសភាគ<br>ឧទាហរណ៍<br>ក/. 12. 3 +6.2=18.5<br>ខ/. 3.49+18.753=22.243<br>គ/. 101.51+13.31=114.82<br>-វិធីដកចំនួនទសភាគ<br>ឧទាហរណ៍:<br>គណនា 12.3-6.2=6.1<br>* លំហាត់គរូគណនា<br>ក/ -2.34+(-16.5)+3.56<br>=-56 .28<br>ខ/-8.245+5.113+0.456<br>=-2.676 | $\begin{array}{r} 3.49 \\ +\ 18.753 \\ \hline 22.243 \end{array}$<br>-8.245+5.113+0.456<br>=-8.245+5.569<br>=-2.676 |

| | | |
|---|---|---|
| | 5.វិធីគុណនិងចែកចំនួនទសភាគ<br>5.1 វិធីគុណចំនួនទសភាគ<br>ឧទាហរណ៍: គណនាផលគុណ | |
| ក/.2.56x8<br>$\frac{2.56\times 8 \leftarrow \text{ផ្នែកទសភាគមាន2ខ្ទង់}}{20.48 \leftarrow \text{ផ្នែកទសភាគមាន2ខ្ទង់}}$ | ក/. 2.56X8 =20.48 | ក/. 2.56X8 =20.48 |
| ខ/.  -1.482x2.9 | ខ/ -1.482 X2.9=-4.2978 | ខ/. $\frac{-1.482x2.9}{1.3338}+\frac{2.964}{-4.2978}$ |
| -គ្រូពន្យល់ | | -សិស្សសង្កេត ,ស្តាប់ |
| បើ0.387x10=3.87គឺរំកិលចំណុចទសភាគ 1 ខ្ទង់ទៅខហាងស្តាំ<br>-ចុះបើ0.387x100= ….? | ឧទាហរណ៍ទី២  គណនាផលគុណ<br>ក/ 0.387x10=3.87 គឺរំកិលចំនុចទសភាគ 1 ខ្ទង់ទៅខាងស្តាំ | 0.387x100=38.7 |
| 3.87x1000=....? | ខ/ 3.87X100=387 គឺរំកិលចំណុចចទសភាគ2 ទៅខាងស្តាំ។ | 3.87x100=387 |
| -ណែនាំសួរដើម្បីគុណមួយចំនួនទសភាគ នឹង10, 100 ,1000,....តើគេត្រូវធ្វើដូចម្តេច? | គ/ 0.387X1000=387 គឺរំកិលចំណុចទសភាគ3ខ្ទង់ទៅខាងស្តាំ។<br>*ជាទូទៅដើម្បីគុណជាមួយ | គឺគេរំកិលចំណុចទសភាគ1,2,3,…ខ្ទង់ទៅខាងស្តាំរៀងគ្នា។ |

| | | |
|---|---|---|
| | ចំនួនទសភាគនឹង10, 100, 1000...គេរំកិលចំណុចទសភាគ1 , 2,3 ... ខ្ទង់ទៅខាងស្តាំរៀងគ្នា។ | |
| -ដើម្បីបូកឬ ដកចំនួនទសភាគ តើគេត្រូវដាក់ចំនួន ទសភាគយ៉ាងដូចម្តេច តាមប្រមាណវិធី?<br>-ដើម្បីមួយចំនួយទសភាគនឹង 10 , 100 ,1000 ,...គេត្រូវធ្វើដូចម្តេច? | -ជំហានទី4(7-10 នាទី)<br>(ពង្រឹងចំណេះដឹង) | -ដើម្បីបូកឬដកចំណុចទសភាគគេដាក់ចំណុចទសភាគឲ្យត្រូវជួរតាមប្រមាណវិធីណា។<br>គឺរំកិលចំណុចទសភាគ 1,2,3,...ខ្ទង់ទៅខាងស្តាំរៀងគ្នា។ |
| -ឲ្យសិស្សគណនា<br>ក/.1.48+16.943<br>ខ/.31.64-17.186<br>គ/.4.27X13 | -ជំហានទី5 (2-3 នាទី)<br>(កិច្ចការផ្ទះ)<br>ក/.1.48+16.943=18.423<br>ខ/.31.64-17.186=14.454<br>គ/.4.27x13=55.51 | -កត់ត្រាលំហាត់ទុកធ្វើនៅផ្ទះ។ |

# កិច្ចតែងការបង្រៀន

❖ ថ្នាក់ទី7

❖ មេរៀនទី5 «ចំនួនសភាគ»

❖ ខ្លឹមសារមេរៀនៈ5. 2. ចែកចំនួនទសភាគ នឹងចំនួនគត់

5. 3. ការចេកចំនួនទសភាគ នឹងចំនួនទសភាគ

5.4. ការចែកចំនួនទសភាគ នឹងប្រភាគ

❖ រយៈពេល 01 ម៉ោង

## I/វត្ថុបំណង

1. ចំណេះដឹងៈ កំណត់បានពីវិធាននៃការចែកចំនួនទសភាគបានត្រឹមត្រូវតាមរយៈឧទាហរណ៍។
2. បំណិនៈ គណនាប្រមាណវិធីចែកចំនួនទសភាគបានត្រឹមត្រូវតាមរយការអនុវត្ត ប្រតិប្តិ
3. ឥរិយាបថៈ មានស្មារតីប្រុងប្រយ័ត្នក្នុងការគណនាប្រមាណវិធីចេកចំនួនទសភាគ។

## II/សម្ភារៈឧបទេស

-សស-ទំព័រ58 -60បោះពុម្ភឆ្នាំ2009

## III/ ដំណើកនាំមេរៀន

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| -ពិនិត្យអវត្តមាន វិន័យ អនាម័យ | ជំហានទី1(1-2 នាទី) (រដ្ឋបាលថ្នាក់) | -ប្រធានថ្នាក់រាយការណ៍ |

| | | |
|---|---|---|
| -ដើម្បីគុណមួយចំនួនទសភាគនឹង 10, 100, 1000…តើគេត្រូវធ្វើដូចម្តេច? | ជំហានទី2(3-5 នាទី)<br>(រំលឹកមេរៀនចាស់) | -គេត្រូវរំកិលចំណុចទសភាគ1 ,2, 3, ..ខ្ទង់ទៅខាងស្តាំរៀងគ្នា។ |
| -ដាក់ឧទាហរណ៍ណែនាំចែកសរសេរជាប្រភាគប្រភាគចែកប្រភាគ?<br>-ណែនាំ $\frac{4}{10}$=0.4<br>-ណែនាំ<br>47.3÷10 =$\frac{473}{10}$x $\frac{1}{10}$=$\frac{473}{100}$=4.73<br>-ណែនាំគណនា<br><br>-ណែនាំទាញជាទូទៅ: | ជំហានទី៣(25-30)<br>(មេរៀនប្រចាំថ្ងៃ)<br>ចំនួនទសភាគ (ត)<br>5.2 ចែកចំនួនទសភាគ នឹងចំនួនគត់<br>ឧទាហរណ៍:<br>$\frac{4}{10}$ ÷ 2=$\frac{4}{10}$X$\frac{1}{2}$=$\frac{2}{10}$=0.2<br>0.4 \| 2<br>0 \| 0.2<br>ឧទាហរណ៍ទី2 គណនា<br>47.3 ÷ 10 = 4.73<br>47.3 ÷ 10 = 4.73<br>47.3 ÷ 1000 =0. 0473<br>*ជាទូទៅ ដើម្បីចែកចំនួនទសភាគនឹង10, 100, | 2=$\frac{2}{1}$<br>$\frac{4}{10}$x$\frac{1}{2}$<br>-សិស្សសង្កេត<br>-សិស្សកត់ត្រា<br>47.3÷100=0.473<br>47.3÷1000=0.0473<br>-សិស្សទាញជាទូទៅ |

| | | |
|---|---|---|
| | 1000...គេរំកិលចំណុចទសភាគ 1, 2, 3,...ខ្ទង់ទៅខាងឆ្វេងរៀងគ្នា។ | .$\frac{1.272}{0.03}=\frac{1272}{30}=42.4$ |
| | 5.3 ការចែកចំនួនទសភាគនឹងចំនួនទសភាគ | |
| -ដាក់ឧទាហរណ៍រួចណែនាំ | ឧទាហរណ៍ទី1 គណនា<br>1.272 ÷0.03 =42.4 | -គត់ត្រា |
| *$\frac{1.272}{0.03}$ បម្លែងតំណាងចែកនិងតួចែកទៅជាចំនួនគត់<br>-ណែនាំទាញជាតទូទៅ | *ជាទូទៅ ដើម្បីចែកចំនួនទសភាគមួយនខឹងចំនួនទសភាគមួយទៀតគខេត្រូវធ្វើតំណាងចែក និងតួចែកឲ្យទៅជាចំនួនគត់ ដោយគុណតំណាងចែកនឹងតួចែក នឹង10 , 100 1000 ...បន្ទាប់មកគេប្រើវិធីតំណាងចែកនៃចំនួនួនគត់។ | $\frac{0.0796}{0.01}$<br>$=\frac{0.0796x10000}{0.01x10000}=\frac{796}{100}$<br>$= 7.96$<br>-សង្កេត<br>-កត់ត្រា<br>*2.5÷($-\frac{125}{3}$) $= 25x(-\frac{3}{125}$<br>=$-\frac{7.5}{125} = -0.6$។ |
| -ណែនាំឲ្យសង្កេតឧទាហរណ៍ទី2<br>$\frac{0.0796}{0.1}=\frac{796}{1000}=0.796$<br>-ណែនាំគណនា | ឧទាហរណ៍ទី2 គណនា<br>o.o796÷0.1=0.796<br>0.796÷ 0.01=7.96 | |

| | | |
|---|---|---|
| -ណែនាំទាញទូទៅ:<br><br>-ណែនាំគណនា<br>1.42$\div\frac{4}{5}$=1.42x= $\frac{7.10}{4}=1.75$<br>-ណែនាំឲ្យគណនា | *ជាទូទៅដើម្បីចែកចំនួនទសភាគមួយនឹង0.1 ,0.01 ,0.001,…គេរំកិលចំណុចទសភាគ1, 2, 3, …ខ្ទង់ទៅខាងស្តាំរៀងគ្នា។<br>5.4 ការចែកចំនួយទសភាគនឹងប្រភាគ<br><br>1.42$\div\frac{4}{5}$=1.75<br><br>2.5$\div$(-$\frac{125}{3}$)=-0.6 | |
| -ដើម្បីចែកចំនួនទសភាគជាមួយចំនួនទសភាគមួយទៀត តើគេត្រូវធ្វើដូចម្តេច? | ជំហានទី4(7-10 នាទី)<br>(ពង្រឹងចំណេះដឹង) | -ត្រូវធ្វើតំណាងចែកនិងតួចែកឲ្យទៅជាចំនួនគត់ ដោយគុណតំណាងចែកនិងតួចែកនឹង10, 100, 1000 ,…បន្ទាប់មកចែកចំនួនគត់នឹងចំនួនគត់។ |
| -លំហាត់ប្រតិបត្តិទំព័រ 60 | ជំហានទី5(7-10 នាទី)<br>(កិច្ចការផ្ទះ) | -កត់ត្រាទុកធ្វើនៅផ្ទះ។ |

# កិច្ចតែងការបង្រៀន(ថ្នាក់ទី៧)

មេរៀនទី៦ **ភាគរយ**

+ខ្លឹមសារមេរៀន : ១. សញ្ញាណភាគរយ

២.ការប្តូរភាគរយជាប្រភាគនិងទសភាគ

៣.ការប្តូរប្រភាគ រឺចំនួនទសភាគទៅជាភាគរយ

៤.ចំនោទភាគរយ

៤.១ការសរសេរបរិមាណមួយជាភាគរយនៃបរិមាណមួយទៀត

+រយៈពេល០២ម៉ោង

I.វត្ថុបំណងនៃមេរៀន

-ចំណេះដឹង : បកស្រាយចំណោទជាភាគរយ

ការប្តូរប្រភាគ រឺចំនួនទសភាគទៅជាភាគរយ

-បំណិន : ដោះស្រាយចំណោទដែលទាក់ទងនឹងភាគរយ

-ឥរិយាបថ : មានស្មារតីប្រុងប្រយ័ត្ន យកចិត្តទុកដាក់ស្តាប់គ្រូពន្យល់ ។

II.ពេលវេលា: ថ្ងៃ..................ទី..................ខែ...............ឆ្នាំ...........

III.សម្ភារៈឧបទេស

-សៀវភៅសិស្ស និងសៀវភៅគ្រូ

-ផ្ទាំងក្រដាសបង្ហាញរូបការផាត់ពណ៌និងមិនផាត់ពណ៌

IV.ដំណើកនាំមេរៀន

| សកម្មភាពគ្រូ | ខ្លឹមសាមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| -គ្រូត្រួតពិនិត្យវត្តមាន អនាម័យ សណ្តាប់ធ្នាប់និងវិន័យ | ជំហានទី១ (រដ្ឋបាលថ្នាក់)<br>(១-២នាទី)<br>-គ្រូពីនិត្យវត្តមាន អនាម័យ សណ្តាប់ធ្នាប់ និង វិន័យ | តំណាងសិស្សឡើងរាយការណ៍ |
| ដាក់សំនួររឺលំហាត់អោយសិស្សដើម្បីរំលឹកមេរៀនចាស់ | ជំហានទី២ (រំលឹកមេរៀនចាស់)<br>(៣-៥នាទី)<br>សរសេរប្រភាគនីមួយៗខាងក្រោមជា ចំនួនទសភាគ<br>ក) $\frac{9}{10}$ ខ) $\frac{17}{100}$ គ) $\frac{91}{1000}$ | ក) $\frac{9}{10}$ គឺ 0.9<br>ខ) $\frac{17}{100}$ គឺ 0.17<br>គ) $\frac{91}{1000}$ គឺ 0.091 |

| | | |
|---|---|---|
| ឲ្យសិស្សសង្កេតឧទាហរណ៍ និងពន្យល់បន្ថែមលើឧទាហរណ៍<br>បង្ហាញផ្ទាំងក្រដាសកាតុងរូបនៃការផោត់ពណ៌<br>គ្រូបង្ហាញរូបភាពដើម្បីជាជំនួយ<br>គ្រូអោយសិស្សទាញរកនិយមន័យនៃ ភាគរយ<br><br>បង្ហាញផ្ទាំងក្រដាសកាតុងរូបនៃការផោត់ពណ៌<br><br>បង្ហាញផ្ទាំងក្រដាសកាតុងរូបនៃការផោត់ពណ៌<br>តើ ៧០%បើយើងសរសេរទៅជាប្រភាគ រឺជាចំនួនទសភាគមានតម្លៃប៉ុន្មាន? ចូរប្អូនសង្កេតឧទាហរណ៍<br>តាមឧទាហរណ៍ខាងលើយើងអាចទាញជាទូទៅ | <u>ជំហានទី៣</u> (ដំណើកនាំមេរៀន)<br>(៣-៥នាទី)<br>មេរៀនទី៦ **ភាគរយ**<br>**១. សញ្ញាណភាគរយ**<br>**ឧទាហរណ៍** គេមានការេទាំងអស់១០០។<br>ការេផោត់ពណ៌មាន៣០។គេថាការេផោត់ពណ៌មានសាមសិបភាគរយនៃការេទាំងអស់។<br>គេសរសេរ៣០%(សាមសិបភាគរយ)។<br>បើគេសរសេរចំនួនការេផោត់ពណ៌ជាប្រភាគដោយធៀបនិងចំនួនការេទាំងអស់គឺ $\frac{30}{100}$។<br><br>**ប្រតិបត្តិ**<br>សរសេរការេផោត់ពណ៌នៃរូបនីមួយៗជាភាគរយ។<br>រូប (ក) រូប (ខ) រូប(គ)<br><br>**២.ការប្តូរភាគរយជាប្រភាគនិងទសភាគ**<br>**ឧទាហរណ៍** សរសេរ ៧០%ជាប្រភាគនិងជាចំនួនទសភាគ។<br>$70\% = \frac{7}{10} = 0.7$ | ផ្តោតអារម្មណ៍ និងយកចិត្តទុកដាក់គ្រូពន្យល់<br><br>សិស្សគូសរូបចូលក្នុងសៀវភៅ<br><br>**ភាគរយ**ជាប្រភាគដែលមានភាគបែងស្មើនឹង១០០។ គេប្រើនិមិត្តសញ្ញា % ដើម្បីតាងនិមិត្តសញ្ញាភាគរយ។<br><br>រូប (ក) គឺ ៣៩%<br>រូប (ខ) គឺ ៤៥%<br>រូប (គ) គឺ ៥៤%<br><br>យកចិត្តទុកដាក់ស្តាប់គ្រូពន្យល់និងបង្ហាញឧទាហរណ៍ |

| | | |
|---|---|---|
| ឲ្យសិស្សឡើងធ្វើប្រតិបត្តិ<br><br>បង្ហាញផ្ទាំងក្រដាសកាតុងរូបនៃការវេជាត់ពណ៌ | **ជាទូទៅ** គេអាចប្តូរប្រភាគរយទៅជាប្រភាគមួយដោយសរសេរវាជាប្រភាគមួយដែលមានភាគបែងស្មើនិង១០០%។បន្ទាប់មកសម្រួលប្រភាគនោះទៅជាទម្រង់ងាយបើអាច។<br>**ប្រតិបត្តិ** សរសេរ ៣២% , ៧១.៣% ជាប្រភាគនិងជាចំនួនទសភាគ។ | **ប្រតិបត្តិ** $32\% = \frac{32}{100} = \frac{8}{25}$<br>$32\% = 0.32$<br>$713\% = \frac{713}{100}$<br>$713\% = 7.13$ |
| តាមឧទាហរណ៍ខាងលើយើងអាចទាញជាទូទៅ<br><br>តាមឧទាហរណ៍ចូរប្អូនសង្កេតមើលតើវាមានសម្មតិកម្មអ្វីខ្លះ? | **៣ ការប្តូរប្រភាគ ឬចំនួនទសភាគទៅជាភាគរយ**<br>**ឧទាហរណ៍** សរសេរប្រភាគ $\frac{2}{25}$ ជាភាគរយ $\frac{2}{25} = 2\times100\%$<br>$= 0.08\times100\% = 8\%$<br>ដូច្នេះ $\frac{2}{25} = 8\%$<br>**ជាទូទៅ** គេប្តូរប្រភាគមួយឬចំនួនទសភាគមួយទៅជាភាគរយដោយគុណវានឹង ១០០% ។<br>**ប្រតិបត្តិ** សរសេរ $\frac{1}{5}, 0.007$ ជាភាគរយ | យកចិត្តទុកដាក់ស្តាប់គ្រូពន្យល់និងបង្ហាញឧទាហរណ៍<br><br>**ប្រតិបត្តិ** $\frac{1}{5} = \frac{1}{5}\times100\% = 20\%$<br>$0.007 = 0.007\times100\% = 0.7\%$ |
| | **៤. ចំណោទភាគរយ**<br>**៤.១ ការសរសេរបរិមាណមួយជាភាគរយនៃបរិមាណមួយទៀត**<br>**ឧទាហរណ៍** នៅក្នុងអនុវិទ្យាល័យ | តាមឧទាហរណ៍មានសម្មតិកម្ម<br>-គ្រូបង្រៀនសរុប៧០នាក់<br>- ជាអ្នកគ្រូ៥៦នាក់ |

| | | |
|---|---|---|
| | មួយមានគ្រូបង្រៀន៧០នាក់ ក្នុងនោះមាន៥៦នាក់ជាអ្នកគ្រូ។ រកភាគរយគ្រូបង្រៀនជាអ្នកគ្រូ។ រកភាគរយគ្រូបង្រៀនជាលោកគ្រូ ។<br>គេដឹងថាចំនួនអ្នកគ្រូនៅក្នុងសាលាមាន៥៦នាក់ក្នុងចំនោមគ្រូបង្រៀន៧០នាក់។<br>ចំនួនអ្នកគ្រូធៀបនិងចំនួនគ្រូសរុបគឺ $\frac{56}{70}$ គឺត្រូវស្មើនិង៨០%<br>**ដូច្នេះ** ៨០%នៃគ្រូបង្រៀននៅក្នុងសាលានេះជាអ្នកគ្រូ។<br>ភាគរយនៃលោកគ្រូនៅក្នុងសាលានេះគឺ ១០០%-៨០%=២០%។<br>**ជាទូទៅ** ដើម្បីសរសេរបរិមាណ $a$ មួយជាភាគរយនៃបរិមាណ $b$ មួយទៀត។គេត្រូវ :<br>-សរសេរជាប្រភាគ $\frac{a}{b}$<br>-គុណប្រភាគ $\frac{a}{b}$ និង ១០០% | |
| ចូរប្អូនឲ្យនិយមន័យភាគរយ<br><br>តើគេប្តូរភាគរយទៅជាប្រភាគមួយដោយរបៀបណា? | <u>ជំហានទី៤</u> (ពង្រឹងពុទ្ធិ)<br>(៧-១០នាទី) | **ភាគរយ**ជាប្រភាគដែលមានភាគបែងស្មើនឹង១០០។ គេប្រើនិមិត្តសញ្ញា % ដើម្បីតាងនិមិត្តសញ្ញាភាគរយ។<br>គេអាចប្តូរប្រភាគរយទៅជាប្រភាគមួយដោយសរសេរវាជាប្រភាគ |

| | | |
|---|---|---|
| | | មួយដែលមានភាគបែងស្មើនិង១០០%។ |
| -គ្រូដាក់លំហាត់ទី១ទី២ ទំព័រ៧១។ឲ្យសិស្សធ្វើនៅផ្ទះ និងណែនាំសិស្សឲ្យគោរពវិន័យនិងច្បាប់ចរាចរណ៍ | ជំហានទី៥ (កិច្ចការផ្ទះ) (២-៣នាទី)<br>លំហាត់ទី១ និង ទី២ ទំព័រ៧១ | សិស្សកត់ត្រាលំហាត់និងស្តាប់ដំបូន្មានគ្រូ |

# កិច្ចតែងការបង្រៀន( ថ្នាក់ទី៧ )

មេរៀនទី៦ **ភាគរយ**

+ខ្លឹមសារមេរៀន : **៤.២ ប្រាក់ចំនេញ និប្រាក់ខាត**

**៤.៣ ការបញ្ចុះតម្លៃ**

**៤.៤ កម្រៃជើងសារ**

**៤.៥ ការប្រាក់**

+រយៈពេល០២ម៉ោង

I.វត្ថុបំណងនៃមេរៀន

-ចំណេះដឹង : រកប្រាក់ចំនេញ និងប្រាក់ខាត

ដោះស្រាយចំណោទដែលទាក់ទងនឹងភាគរយ

-បំណិន : អាចដោះស្រាយចំណោទដែលទាក់ទងនឹងភាគរយ

-ឥរិយាបថ : មានស្មារតីប្រុងប្រយ័ត្ន យកចិត្តទុកដាក់ស្តាប់គ្រូពន្យល់ ។

II.ពេលវេលា: ថ្ងៃ……………..ទី……………..ខែ…………..ឆ្នាំ………..

III.សម្ភារៈឧបទេស

-សៀវភៅសិស្ស និងសៀវភៅគ្រូ

IV.ដំណើកនាំមេរៀន

| សកម្មភាពគ្រូ | ខ្លឹមសាមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| -គ្រូត្រួតពិនិត្យវត្តមាន អនាម័យ សណ្តាប់ធ្នាប់និងវិន័យ | ជំហានទី១ (រដ្ឋបាលថ្នាក់) (៥នាទី) -គ្រូពីនិត្យវត្តមាន អនាម័យ សណ្តាប់ធ្នាប់ និង វិន័យ | តំណាងសិស្សឡើងរាយការណ៍ |
| ដាក់សំនួររំលឹកលំហាត់អោយសិស្សដើម្បីរំលឹកមេរៀនចាស់។ | ជំហានទី២ (រំលឹកមេរៀនចាស់) (៥នាទី) តើគេអាចប្តូរប្រភាគមួយឬចំនួនទសភាគមួយទៅជាភាគរយបានដោយរបៀបណា? | គេអាចប្តូរប្រភាគមួយឬចំនួនទសភាគមួយទៅជាភាគរយបានដោយ |
| | ជំហានទី៣ (ដំណើកនាំមេរៀន) (៥នាទី) មេរៀនទី៦ **ភាគរយ** | |

| | | |
|---|---|---|
| លើកឧទាហរណ៍ ១និង២ មកបកស្រាយបញ្ជាក់ប្រាប់សិស្ស<br>តាមឧទាហរណ៍១និង២ តើប្អូនអាចរកប្រាក់ចំនេញ ឬ ប្រាក់ខាតបានរឺទេ? ដោយរបៀបណា?<br>ដាក់លំហាត់គំរូដើម្បីឲ្យសិស្សកាន់តែច្បាស់នូវខ្លឹមសារមេរៀន<br><br>តើយើងមានសម្មតិកម្មអ្វីខ្លះ?<br><br>តាមឧទាហរណ៍ចូរប្អូនសង្កេតមើលតើវាមានសម្មតិកម្មអ្វីខ្លះ?<br>ជាដំបូងរកប្រាក់នៃការបញ្ចុះតម្លៃ ហើយយកប្រាក់បញ្ចុះតម្លៃមកធៀបនិងប្រាក់ដាក់ | **៤.២ ប្រាក់ចំនេញ និងប្រាក់ខាត**<br>**ឧទាហរណ៍ ១**<br>**ឧទាហរណ៍ ២**<br><br>ប្រាក់ចំនេញ=ប្រាក់ថ្លៃលក់−ប្រាក់ថ្លៃដើម<br>ប្រាក់ខាត=ប្រាក់ថ្លៃដើម−ប្រាក់ថ្លៃលក់<br><br>**លំហាត់គំរូ ១** ហ៊ាតុងលក់នាឡិកាមួយគ្រឿងថ្លៃ ២៦០០០៛ គាត់ចំនេញបាន ៣០%។ រកថ្លៃដើមនៃនាឡិកា<br>**ចម្លើយ**<br>ប្រាក់ចំនេញ=ប្រាក់ថ្លៃលក់−ប្រាក់ថ្លៃដើម<br>បើប្រាក់ថ្លៃដើម=១០០%<br>នោះប្រាក់ថ្លៃលក់=(១០០%+៣០%)នៃ<br>ប្រាក់ដើម<br><br>=១៣០%នៃប្រាក់ថ្លៃដើម<br>គេបានប្រាក់ថ្លៃលក់=១៣០%×ប្រាក់ថ្លៃដើម<br>នាំឲ្យប្រាក់ថ្លៃដើម=ប្រាក់ថ្លៃលក់÷១៣០%<br>=ប្រាក់ថ្លៃលក់×$\frac{100}{130}$<br>=២៦០០០×$\frac{100}{130}$<br>=២០០០០៛<br>ដូច្នេះ ប្រាក់ថ្លៃដើមនៃនាឡិកាដែលមួយគ្រឿងគឺ ២០០០០៛<br>**៤.៣ ការបញ្ចុះតម្លៃ**<br>**ឧទាហរណ៍** ទូរទស្សន៍មួយគ្រឿង | សិស្សយកចិត្តទុកដាក់ស្តាប់គ្រូពន្យល់ឧទាហរណ៍១និង២<br><br>តាមឧទាហរណ៍១និង២ យើងអាចរកប្រាក់ចំនេញ ឬប្រាក់ខាតបានដោយ :<br>ប្រាក់ចំនេញ=ប្រាក់ថ្លៃលក់-ប្រាក់ថ្លៃដើម<br>ប្រាក់ខាត=ប្រាក់ថ្លៃដើម-<br><br>នាឡិកាមួយមានតម្លៃ ២៦០០០៛ គាត់ចំនេញបាន៣០%<br><br>តាមឧទាហរណ៍មានសម្មតិកម្ម<br>-ទូរទស្សន៍មួយគ្រឿងបានដាក់លក់តម្លៃ 640000 ៛<br>-គេបញ្ចុះនៅត្រឹមតែ 560000 ៛ |

| | | |
|---|---|---|
| លក់គុណនិង១០០%ដើម្បីរកភាគរយនៃការបញ្ចុះតម្លៃ។ បន្ទាប់ពីសង្កេត និងអនុវត្តនិឧទាហរណ៍ចូរប្អូនទាញជាទូទៅ<br><br>ពន្យល់សិស្សនូវពាក្យកម្រៃជើងសារឲ្យងាយយល់ តាមឧទាហរណ៍ចូរប្អូនសង្កេតមើលតើវាមានសម្មតិកម្មអ្វីខ្លះ?<br><br>បន្យល់សិស្សនូវពាក្យ **ការប្រាក់ ប្រាក់ដើម អត្រា** ឲ្យបានច្បាស់ និងយល់បានត្រឹមត្រូវ<br><br>តាមឧទាហរណ៍ចូរប្អូនសង្កេតមើលតើវាមានសម្មតិកម្មអ្វីខ្លះ? | បានដាក់លក់តម្លៃ 640000៛។ ក្នុងថ្ងៃអាទិត្យនេះគេបានដាក់លក់វាក្នុងតម្លៃតែ 560000៛។ រកការបញ្ចុះថ្លៃជាភាគរយ។<br>**ចម្លើយ** ការបញ្ចុះតម្លៃគឺ<br>$640000-560000=80000$៛<br>ការបញ្ចុះតម្លៃជាភាគរយគឺ<br>$\frac{80000}{640000}\times100\%=12.5\%$<br><br>**៤.៤ កម្រៃជើងសារ**<br>**ឧទាហរណ៍** ពូភាពបានជួយលក់ដីស្រែរបស់មីងសំមួយកន្លែងតម្លៃ 8800000៛ ដោយទទួលបានប្រាក់កម្រៃជើងសារ៣% ។តើពូភាពទទួលបានប្រាក់កម្រៃជើងសារប៉ុន្មានរៀល?<br>3% នៃ 8800000៛ $=\frac{3}{100}\times8800000$៛<br>$=264000$៛<br>ដូច្នេះ ពូភាពទទួលបានប្រាក់កម្រៃជើងសារ 264000៛ ។<br>**៤.៥ ការប្រាក់**<br>• **ការប្រាក់** ជាប្រាក់ចំនេញ ឬប្រាក់ខាតបានមកពីទឹកប្រាក់ដែលឲ្យគេខ្ចី ឬខ្ចីគេ ក្នុងរយះពេលមានកំណត់<br>• **ប្រាក់ដើម** ជាទឹកប្រាក់ខ្ចីគេ ឬឲ្យគេខ្ចី | **ទូទៅ** ការបញ្ចុះតម្លៃជាផលរវាងថ្លៃលក់ខាងដើម និងថ្លៃដែលត្រូវលក់ ។<br>ការបញ្ចុះតម្លៃជាញឹកញាប់គេឲ្យជាភាគរយនៃថ្លៃលក់ខាងដើម។<br><br>សិស្សយកចិត្តទុកដាក់រៀនសូត្យ សង្កេតឧទាហរណ៍ និងស្តាប់ការពន្យល់របស់លោកគ្រូ<br>តាមឧទាហរណ៍មានសម្មតិកម្ម<br>-ដីស្រែរបស់មីងសំមួយកន្លែងតម្លៃ 8800000៛<br>-ប្រាក់កម្រៃជើងសារ៣%<br><br>រកអត្ថន័យនៃពាក្យ **ការប្រាក់ ប្រាក់ដើម** និង**អត្រា** ដោយខ្លួនឯងបន្ទាប់មកស្តាប់គ្រូពន្យល់<br><br>តាមឧទាហរណ៍មានសម្មតិកម្ម<br>- ពូលីខ្ចីប្រាក់ 400000៛<br>-អត្រា 6% |

| | | |
|---|---|---|
| សួរសិស្សតើយើងគួរធ្វើយ៉ាងណាដើម្បីឲ្យរកបានចម្លើយ? | • **អត្រា** ជាការប្រាក់គិតជាភាគរយក្នុងពេលកំណត់មួយខែ ឬមួយឆ្នាំ។ ជាទូទៅធនាគារគិតអត្រាការប្រាក់ក្នុង ១ឆ្នាំ<br>**ឧទាហរណ៍** ពូលីខ្ចីប្រាក់ $400\,000$៛ ពីធានាគារមួយក្នុងអត្រា $6\%$ ។បើគាត់ខ្ចីក្នុងរយៈពេលបីឆ្នាំតើគាត់ត្រូវបង់ការប្រាក់អស់ប៉ុន្មានរៀល?<br>ប្រាក់ដើមគឺ $400\,000$៛<br>ការប្រាក់លើប្រាក់ $400\,000$៛ក្នុងរយៈពេលមួយឆ្នាំគឺ $\frac{6}{100}\times 400\,000$៛ $=24000$៛<br>ការប្រាក់លើប្រាក់ $400\,000$៛ក្នុងរយៈពេលបីឆ្នាំគឺ $3\times 24000$៛$=72\,000$៛<br>ដូច្នេះ គាត់ត្រូវបង់ការប្រាក់ $72\,000$៛។<br>គេទាញបានរូបមន្ត<br>**ការប្រាក់=ប្រាក់ដើម×អត្រា×រយៈពេល**<br>**ឬ** $I=\frac{PRT}{100}$<br>ដែល $I$ ជាការប្រាក់<br>$T$ ជារយៈពេលជាឆ្នាំ<br>$P$ ជាប្រាក់ដើម<br><br>$R\%$ ជាអត្រាការប្រាក់ក្នុងមួយឆ្នាំ | -រយៈពេលបីឆ្នាំ |

| | | |
|---|---|---|
| ចូរប្អូនកំណត់និយមន័យនៃការប្រាក់? | <u>ជំហានទី៤</u> (ពង្រឹងពុទ្ធិ)<br>(៥នាទី) | **ការប្រាក់=ប្រាក់ដើម×អត្រា×រយៈពេល**<br>ឬ $I=\frac{PRT}{100}$<br>ដែល $I$ ជាការប្រាក់<br>$T$ ជារយៈពេលជាឆ្នាំ<br>$P$ ជាប្រាក់ដើម<br>$R$% ជាអត្រាការប្រាក់ក្នុងមួយឆ្នាំ |
| -គ្រូដាក់លំហាត់ទី៧ទី៨ ទំព័រ៧១។ឲ្យសិស្សធ្វើនៅផ្ទះ និងណែនាំសិស្សឲ្យគោរពវិន័យនិងច្បាប់ចរាចរណ៍ | <u>ជំហានទី៥</u> (កិច្ចការផ្ទះ)<br>(៥នាទី)<br><br>លំហាត់ទី៧ និង ទី៨ ទំព័រ៧១ | សិស្សកត់ត្រាលំហាត់និងស្តាប់ដំបូន្មានគ្រូ |

# កិច្ចតែងការបង្រៀន

- ការបរិច្ឆេទ : ថ្ងៃ ទី ខែ ឆ្នាំ
- មុខវិជ្ជា : គណិតវិទ្យា
- បង្រៀនថ្នាក់ទី : 7
- មេរៀនទី 7 : រង្វាស់រង្វាល់
- រយៈពេល : ពីរម៉ោង ( 2ម៉ោង )

I. វត្ថុបំណង :

-ចំណេះដឹង : កំណត់បានពីខ្នាតស្តង់ដា រង្វាស់ប្រវែង និងខ្នាតផ្សេងៗទៀតតាមរយៈខ្លឹមសារមេរៀនបានត្រឹមត្រូវ

-ចំណេះធ្វើ : ពន្យលបានពីខ្នាតស្តង់ដា និងបំបែកខ្នាតស្តង់ដាតាមរយៈក្រុមពិភាក្សានិងលំហាត់អនុវត្តបានត្រឹមត្រូវ

-ឥរិយាបថ : មានបំរុងប្រយ័ត្នខ្ពស់ក្នុងការបំបែកខ្នាតតាមរយៈជីវភាពរស់នៅបានត្រឹមត្រូវ ។

II. ខ្លឹមសារមេរៀន :

1. ខ្នាតស្តង់ដា

1.1រង្វាស់ប្រវែង

1.2 ខ្នាតផ្សេងៗ

1.3 ម៉ាស

1.4 ចំណុះ

III. សម្ភារៈឧបទ្ទេស :

-សៀវភៅសិស្ស+គ្រូទំព័រទី 73 - 77 បោះពុម្ភឆ្នាំ 2009

-ផ្ទាំងរូប . ប័ណ្ណសំនួរ

IV. ដំណើរការបង្រៀន :

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| -គ្រូពិនិត្យ :<br>• អវត្តមាន . វិន័យ<br>• អនាម័យ . សណ្តាប់ធ្នាប់ | ជំហានទី 1<br>( រដ្ឋបាលថ្នាក់ ) | -ប្រធាន ឬ តំណាងថ្នាក់ឡើងរាយការណ៍ |

| | | |
|---|---|---|
| | | |
| -គ្រូសួរ :<br>• ភាគរយជាអ្វី ? តើគេប្រើនិមិត្តសញ្ញាអ្វីសម្រាប់តាង?<br>• ដើម្បីប្តូរប្រភាគ រឺចំនួនទសភាគទៅជាភាគរយគេត្រូវធ្វើដូចម្តេច ? | <u>ជំហានទី 2</u><br>( រំលឹកមេរៀនចាស់ )<br>• សញ្ញាណភាគរយ<br>• ការប្តូរប្រភាគ រឺ ទសភាគជាភាគរយ | -ស្តាប់សំនួរ<br>• ភាគរយជាប្រភាគដែលមានភាគបែងស្មើនិង100គេប្រើនិមិត្តសញ្ញា %ដើម្បីតាងភាគរយ<br>• ដើម្បីប្តូរប្រភាគ រឺ ចំនួនទសភាគទៅជាភាគរយគេត្រូវគុណវា និង 100% ។ |
| -ដើម្បីវាស់ប្រវែងក្តារខៀនគេប្រើឧបករណ៍អ្វី ?<br>-តើខ្នាតប្រវែងគឺអ្វី ?<br>-បញ្ជាក់ប្រាប់សិស្សពីប្រភេទផ្សេងទៀតនៃខ្នាតប្រវែង<br>• ឯកតាដែលតូចជាងម៉ែត្រមាន<br>ដេស៊ីម៉ែត្រ 1dm = 0.1m<br>សង់ទីម៉ែត្រ 1cm = 0.01m<br>មីលីម៉ែត្រ 1mm =0.001m | <u>ជំហានទី 3</u><br>( មេរៀនប្រចាំថ្ងៃ )<br><u>មេរៀនទី 7</u> រង្វាស់រង្វាល់<br>1.<u>ខ្នាតស្តង់ដា</u><br>1.1 <u>រង្វាស់ប្រវែង</u><br>-គេប្រើម៉ែត<br>-គឺម៉ែត្រ ( m )<br>• 1dm = 0.1m<br>1cm = 0.01m<br>1mm = 0.001m | -ដើម្បីវាស់ប្រវែងក្តារខៀនគេប្រើម៉ែត្រ<br>-ខ្នាតប្រវែងគឺ ម៉ែត្រ ( m )<br>-សង្កេតការបង្ហាញ<br>• សង្កេតការបំបែកខ្នាតដែលតូចជាងម៉ែតទៅជាម៉ែត្រ<br>• ពិនិត្យនិងចងចាំការ |

| | | |
|---|---|---|
| • ឯកតាដែលធំជាងម៉ែត្រមាន<br>ដេកាម៉ែត្រ 1dam = 10m<br>ហិចតូម៉ែត្រ 1hm =100m<br>គីឡូម៉ែត 1km = 1000m<br>-ដាក់លំហាត់គំរូអោយសិស្សឡើងធ្វើ<br>-សំគាល់ :<br>បញ្ជាក់ពីការបំបែកខ្នាត | • 1dam = 10m<br>1hm = 100m<br>1km = 1000m<br>-ចូរបំបែកខ្នាតខាងក្រោម<br>• 5cm = 0.05 m<br>0.1km = 100 m<br>-សំគាល់ :<br>+ ដើម្បីប្តូរឯកតាមួយទៅឯកតាតូចបន្ទាប់រៀងគ្នា គេត្រូវរំកិលចំណុចក្បៀសទៅខាងស្តាំ ម្តងមួយខ្ទង់ៗ<br>+ដើម្បីប្តូរឯកតាមួយទៅឯកតាធំបន្ទាប់រៀងគ្នា គេត្រូវរំកិលចំណុចក្បៀសទៅខាងឆ្វេងម្តងមួយខ្ទង់ៗ | បំបែកខ្នាតដែលធំជាងម៉ែត្រទៅម៉ែត្រ<br>-ឡើងដោះស្រាយលំហាត់<br>V. 5cm = 0.05m<br>0.1km = 100m<br>-កត់ត្រាដោយយកចិត្តទុកដាក់ |
| -ដាក់ឧទាហរណ៍ធ្វើការពន្យល់<br>• នៅលើផ្ទៃសមុទ្រគេនិយមប្រើខ្នាត មីល<br>1mill = 1 852m<br>-តើខ្នាតដែលគេនិយមប្រើនៅប្រទេសអង់គ្លេសមានអ្វីខ្លះ ? | 1.2 <u>ខ្នាតផ្សេងៗ</u><br>• 1mill = 1852m<br>-ខ្នាតនិយមប្រើរួមមាន<br>អ៊ីញ 1inch ≈2.54cm<br>ភុត 1foot ≈30.48cm<br>យ៉ា 1yard =3foot ≈0.9114m | -ពិនិត្យឧទាហរណ៍<br>VI. 1mill = 1852m<br>-ខ្នាតគេនិយមប្រើរួមមា<br>អ៊ីញ 1inch ≈2.54cm<br>ភុត 1foot ≈30.48cm<br>យ៉ា 1yard =3foot ≈0.9114m<br>ម៉ាយ 1mile ≈1609.344m |

| | | |
|---|---|---|
| -តើរង្វាស់ខ្នាតរបស់ខ្មែរបុរាណមានអ្វីខ្លះ ?<br><br>-ម៉ាសជាអ្វី ? ឯកតាសំខាន់ៗនៃម៉ាសគឺអ្វី ?<br><br>-តើចំណុះជាអ្វី ?<br>ឯកតាសំខាន់នៃរង្វាស់ចំណុះគឺអ្វី ?<br>-បង្ហាញពី របៀបបំបែកខ្នាត<br>ហិចតូលីត 1hL = 100L<br>ដេកាលីត 1daL = 10L<br>លីត L<br>ដេស៊ីលីត 1dL = 0.1L | ម៉ាយ 1mile = 1760yd<br>≈1609.344m<br>-មាន 1ចំអាម = 0.20m<br>1ព្យាម = 4ហត្ថ = 2m<br>1ហត្ថ = 0.50m<br>1សិន = 20ព្យាម = 40m<br>1 ការ៉ុត = 100សិន<br>1យោជន៍ =400សិន = 16km<br><br>1.3<u>ម៉ាស</u><br>-ម៉ាសជាទំហំប្រដូចគ្នាបាន ឬទំហំប្រមាណបាន ។ ឯកតាម៉ាស គឺ គីឡូក្រាម ( kg )<br>●គីឡូក្រាម 1kg = 1000g<br>●ហិចតូក្រាម 1hg = 100g<br>●ដេកាក្រាម 1dag = 10g<br>●ក្រាម 1g = 0.001kg<br>●ដេស៊ីក្រាម 1dg = 0.1g<br>●សង់ទីក្រាម 1cg = 0.01g<br>●មីលីក្រាម 1mg = 0.001g<br>1.4 <u>ចំណុះ</u><br>-ចំណុះជាទំហំប្រមាណបានព្រោះវាមានមាឌ<br>ឯកតាសំខាន់នៃរង្វាស់<br>ចំណុះគឺ លីត្រ ( L ) 1L = $1dm^3$<br>-ការបំបែកខ្នាត | -មាន 1ចំអាម = 0.20m<br>1ព្យាម = 4ហត្ថ = 2m<br>1ហត្ថ = 0.50m<br>1សិន = 20ព្យាម = 40m<br>1 ការ៉ុត = 100សិន<br>1យោជន៍ =400សិន = 16km<br><br>-ម៉ាសជាទំហំប្រដូចគ្នា ឬទំហំប្រមាណបាន ឯកតាម៉ាសគឺ ( kg )<br>●គីឡូក្រាម 1kg = 1000g<br>●ហិចតូក្រាម 1hg = 100g<br>●ដេកាក្រាម 1dag = 10g<br>●ក្រាម 1g = 0.001kg<br>●ដេស៊ីក្រាម 1dg = 0.1g<br>●សង់ទីក្រាម 1cg = 0.01g<br>●មីលីក្រាម 1mg = 0.001g<br><br>-ចំណុះជាទំហំប្រមាណបានព្រោះវាមានមាឌ ឯកតាសំខាន់នៃរង្វាស់ចំណុះគឺ លីត្រ ( L ) 1L = $1dm^3$<br>-សង្កេតការបំបែកខ្នាតដោយយកចិត្តទុកដាក់ |

| | | |
|---|---|---|
| សង់ទីលីត 1cL = 0.01L<br>មីលីលីត 1mL = 0.001L<br>-តាមរយៈការបំបែកខ្នាតគេអាចសំគាល់ដូចម្តេច ? | 1hL = 100L<br>1daL = 10L<br>1dL = 0.1L<br>1cL = 0.01L<br>1mL = 0.001L<br>-សំគាល់ : ដើម្បីផ្លាស់ប្តូរឯកតា<br>•គេត្រូវរំកិលចំណុចក្បៀសទៅខាងស្តាំម្តងមួយខ្ទង់ កាលណាគេប្តូរឯកតាតូចបន្ទាប់ ។<br>•គេត្រូវរំកិលចំណុចក្បៀសទៅខាងឆ្វេងម្តងមួយខ្ទង់ កាលណាគេប្តូរឯកតាធំបន្ទាប់ ។ | -សំគាល់ : ដើម្បីផ្លាស់ប្តូរឯកតា<br>•គេត្រូវរំកិលចំណុចក្បៀសទៅខាងស្តាំម្តងមួយខ្ទង់ កាលណាគេប្តូរឯកតាតូចបន្ទាប់ ។<br>•គេត្រូវរំកិលចំណុចក្បៀសទៅខាងឆ្វេងម្តងមួយខ្ទង់ កាលណាគេប្តូរឯកតាធំបន្ទាប់ ។ |
| -ចូរបំបែកខ្នាតខាងក្រោម<br>1.បំបែកខ្នាតទៅជាម៉ែត្រ<br>• 10cm = m<br>•0.01km = m<br>•2000mm = m<br>2.បំបែកខ្នាតទៅជា kg<br>• 100g =0.1kg<br>•500g = 0.5kg<br>•2000g = 2kg | <u>ជំហានទី 4</u><br>( ពង្រឹងពុទ្ធិ )<br>1.បំបែកទៅម៉ែត្រ<br>• 10cm = 0.1m<br>• 0.01km = 10m<br>• 2000mm = 2m<br>2. បំបែកទៅជាគីឡូក្រាម<br>• 100g =0.1kg<br>•500g = 0.5kg<br>•2000g = 2kg | -ឡើងគណនាតាមក្រុម<br>1.បំបែកទៅម៉ែត្រ<br>• 10cm = 0.1m<br>• 0.01km = 10m<br>• 2000mm = 2m<br>2. បំបែកទៅជាគីឡូក្រាម<br>• 100g =0.1kg<br>•500g = 0.5kg<br>•2000g = 2kg |
| -ពេលទៅផ្ទះត្រូវមើលមេរៀនបន្តនិងជួយធ្វើការងារឪពុកម្តាយ | <u>ជំហានទី5</u><br>( កិច្ចការផ្ទះ ) | -ត្រងត្រាប់ស្តាប់ការណែនាំ |

# កិច្ចតែងការបង្រៀន

- ថ្នាក់ទី 7
- មេរៀន : << រង្វាស់រង្វាល់ >>
- ខ្លឹមសារមេរៀន : 2.ពេលវេលា
  - 2.1 សញ្ញាណរយៈពេល
  - 2.2 ឯកតាពេល
  - 2.3 ប្រមាណវិធីលើថេរវេលា
- រយៈពេល 1ម៉ោង

I. វត្ថុបំណង

1.ចំណេះដឹង : កំណត់បានពីសញ្ញាណរយៈពេល ឯកតាពេលបានត្រឹមត្រូវ តាមរយៈឧទាហរណ៍ ។

2.បំណិន : គណនាប្រមាណវិធីលើថេរវេលា និង បំបែកខ្នាតពេលបានត្រឹមត្រូវតាមរយៈការអនុវត្តលំហាត់គំរូ

3.ឥរិយាបថ : មានស្មារតីប្រុងប្រយ័ត្នក្នុងការធ្វើការងារ តាមរយៈការកំណត់ពេលវេលាប្រចាំថ្ងៃបានល្អ

II. សម្ភារៈឧបទេស

-សៀវភៅសិស្សទំព័រ 78 é 80 បោះពុម្ពឆ្នាំ 2009

-ផ្ទាំងក្រដាសសរសេរឧទារហណ៍ សញ្ញាណរយៈពេល

III. ដំណើកនាំមេរៀន

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| .ពិនិត្យ ,អវត្តមាន ,វិន័យ សណ្តាប់ធ្នាប់ក្នុងថ្នាក់ | .ជំហានទី 1 ( 1→2mn )<br>( រដ្ឋបាលថ្នាក់ ) | . ប្រធានថ្នាក់រាយការណ៍ |
| -ចូរបំពេញ :<br>1អ៊ីញ =...........cm<br>1ម៉ាយ =.............m<br>1យោជន៍ =..........km<br>1kg =.................g<br>1dg =.................g | .ជំហានទី2 ( 3→5mn )<br>រំលឹកមេរៀនចាស់<br>-ខ្នាតប្រវែង<br>-ខ្នាតម៉ាស | -សិស្សឡើងបំពេញ<br>1អ៊ីន =2.54cm<br>1ម៉ាយ =1 609.344m<br>1យោជន៍ =16km<br>1kg =1 000g<br>1dg =0.1g |

| | | |
|---|---|---|
| | | |
| -សរសេរចំណងជើងលើក្តារខៀន:<br>-ឲ្យសិស្សម្នាក់ឡើងអានឧទាហរណ៍ 1 និង 2ទំព័រ 78 និងពន្យល់ណែនាំ ។<br>-បិទផ្ទាំងក្រដាសឧទាហរណ៍ឲ្យសិស្សអាន និងណែនាំ ។<br><br><br><br><br><br><br><br><br>-ណែនាំ : តាមប្អូនធ្លាប់បានរៀន តើឯកតានៃពេលមានអ្វីខ្លះ ?<br>-ចុះ1h=...........?<br><br>-តើ1ថ្ងៃស្មើប៉ុន្មានម៉ោង?<br><br>-ដាក់Ex$_1$:រួចណែនាំ<br>តើគ្រូចាប់ផ្តើមបង្រៀននៅម៉ោង | .ជំហានទី3 ( 25$\rightarrow$30mn )<br>( មេរៀនប្រចាំថ្ងៃ )<br>7. <u>រង្វាស់រង្វា</u> (តចប់)<br><br>2.<u>ពេលវេលា</u><br>2.1.<u>សញ្ញាណរយៈពេល</u><br>Ex:បើគេដាំបាយមួយឆ្នាំងឆ្អិនដំណាក្នានិងរយៈពេលធ្វើលំហាត់គណិតវិទ្យា រួចបន្តធ្វើលំហាត់រូបវិទ្យាមួយទៀតចប់សព្វគ្រប់ នោះគេថារយៈពេលនៃការដាំបាយមួយឆ្នាំងឆ្អិនជាផលបូកនៃរយៈពេលធ្វើលំហាត់ទាំងពីរមុខវិជ្ជា ។<br>2.2 <u>ឯកតាពេល</u><br>ឯកតាសំខាន់ៗនៃរយៈពេលគឺៈ<br>-វិនាទី ($\delta$)<br>-ម៉ោង( h )=60mn=3600$\delta$<br>-នាទី (mn) =60$\delta$<br>-ថ្ងៃ ( j )=24h=86 400$\delta$<br>2.3.<u>ប្រមាណវិធីលើថេរវេលា</u><br>Ex$_1$:អ្នកគ្រូចាប់ផ្តើមបង្រៀននៅម៉ោង 9h 5mn10$\delta$ ។ | -រៀបចំសំភារៈសិស្ស<br><br>-សិស្សម្នាក់ឡើងរកឧទាហរណ៍ 1 និង 2<br>-ស្តាប់ការពន្យល់<br>-សិស្សអាន<br>-កត់ត្រា<br><br><br><br><br><br><br><br>-មានៈ<br>-វិនាទី ($\delta$)<br>-ម៉ោង ( h ) ; 1h=60mn<br>-នាទី ( mn )=60$\delta$<br>-1ថ្ងៃ = 24h<br><br>-អាន Ex:<br>-ចាប់ផ្តើម : 9h 5mn10$\delta$ |

| | | |
|---|---|---|
| ប៉ុន្មាន ?<br>-ដើម្បីរករយៈពេលនៃការបង្រៀន តើគេត្រូវធ្វើដូចម្តេច ?<br>-ណែនាំវិធីគណនា :<br>-ដាក់$Ex_2$រួចណែនាំ :<br>-ប្តូរថ្ងៃឲ្យទៅជាវិនាទី<br>-តើ 1j =..............$\delta$ | គាតបង្រៀនចប់នៅម៉ោង 9h 55mn 11$\delta$ ។<br>រយៈពេលនៃការបង្រៀនគឺ :<br>   9h 55mn 11$\delta$<br>— 9h 5mn 10$\delta$<br>____________<br>   0h 50mn 01$\delta$<br>$Ex_2$:ប្តូរ 1j 3h 27mn 15$\delta$ ជាវិនាទី | -ចប់ = 9h 55mn 11$\delta$<br><br>-យកម៉ោងបញ្ចប់ ដកម៉ោងចាប់ផ្តើម ។<br><br>-សង្កេត -ស្តាប់ការពន្យល់ |
| -ចុះ 3h =................$\delta$ ។<br>ចូរគិតដូចគ្នាដែរ 27mn =......$\delta$<br><br><br><br>-ជាសរុប 1j3h 27mn 15$\delta$ =....................$\delta$<br>-ដាក់លំហាត់គំរូ រួចណែនាំ :<br>បើយកវិនាទី ចែកនឹង60 តើគេបានថ្ងៃ , នាទី ,ឬ h ?<br>-ណែនាំរបៀបធ្វើ :<br><br>-បំបែក mn ទៅជា h តើចែកនឹងប៉ុន្មាន ?<br>-បំបែក h ទៅជា j តើចែកនឹងប៉ុន្មាន ? | 1j =86 400$\delta$<br>3h = 3x3600 =10 800$\delta$<br>27mn =27x60 =1 620$\delta$<br>15$\delta$ = 15$\delta$<br>____________<br>1j3h 27mn 15$\delta$ = 98 835$\delta$<br><br>លំហាត់គំរូ 1<br>សុខធ្វើដំណើរអស់រយៈពេល 210391$\delta$ ។ ររករយៈពេលដែលសុខធ្វើដំណើរគិតជាថ្ងៃ ម៉ោងនាទី និងវិនាទី ។<br>210391 \| 60<br>303 \| 3506mn \| 60<br>391 \| 506 \| 58h \| 24<br>31$\delta$ \| 26mn \| 10h \| 2j<br><br>ដូចនេះរយៈពេលដែលសុខធ្វើដំណើរគឺ 2j10h26mn31$\delta$ ។ | -គិត<br>-1j =86 400$\delta$<br>-គិត<br>- 27mn = 27x60<br>= 1 620$\delta$<br><br><br><br><br>-វិនាទីចែកនឹង 60 គេបាន mn ។<br>-ស្តាប់<br>-ចែក និង 60<br><br>-ចែកនិង 24 |

| | | |
|---|---|---|
| | លំហាត់គំរូ 2 :<br>គណនា 7h40mn18$\delta$x11<br>7h 40mn 18$\delta$<br>11<br>77h 44mn 198$\delta$<br>ឬ 3j 12h 23mn 18$\delta$ | |
| -តើ 1h =..............$\delta$ ?<br>3j =..............$\delta$ ?<br>10h =..............mn ? | .ជំហានទី 4 ( 7$\rightarrow$10mn )<br>( ពង្រឹងចំនេះដឹង ) | -1h = 3600 $\delta$<br>-3j = 259200 $\delta$<br>-10h = 600 mn |
| -ឲ្យធ្វើលំហាត់ទី 5 ;6 ទំព័រ 80 ។ | .ជំហានទី5 ( 2$\rightarrow$3mn )<br>(កិច្ចការផ្ទះ)<br>.លំហាត់ទី 5 ;6 ទំព័រ 80 ។ | -កត់ត្រាទុក ធ្វើនៅផ្ទះ ។ |

# កិច្ចតែងការបង្រៀន
# គណិតវិទ្យាថ្នាក់ទី ៧

មេរៀនទី៨ "កន្សោមពីជគណិត"

១ សញ្ញាណកន្សោមពីជគណិត

រយៈពេល ១ ម៉ោង( ម៉ោងទី១)

**I .វត្ថុបំណង**

១ ចំណេះដឹងៈ កំនត់បានអំពីសញ្ញាណកន្សោមពីជគណិត បានត្រឹមត្រូវតាមរយៈឧទាហរណ៍ ។

២ បំណិន ៈ សរសេរកន្សោមពីជគណិតបានត្រឹមត្រូវ តាមរយៈលំហាត់ ។

៣ ឥរិយាបថ ៈ តាមរយៈការសិក្សាសិស្សមានស្មារតីប្រុងប្រយ័ត្នក្នុងការអនុវត្តជាក់ស្តែង ។

**II . សម្ភារៈឧបទេស**

សៀវភៅសិស្សទំព័រ ៨១.៨២ បោះពុម្ពឆ្នាំ ២០០៩

**III. ដំណើរការបង្រៀន**

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| ពិនិត្យ អនាម័យ វិន័យ អវត្តមាន | ជំហានទី១ (១-២ នាទី ) (រដ្ឋបាលថ្នាក់) | តំណាងថ្នាក់ឡើងរាយការណ៍ |
| តើឯកតាពេលមានអ្វីខ្លះ? <br> តើ១ថ្ងៃមានប៉ុន្មានម៉ោង ? <br> ១ម៉ោង=...................នាទី <br> ១នាទី=....................វិនាទី | ជំហានទី២ (៣-៥ នាទី) (រំលឹកមេរៀន) | ឯកតាពេលមាន វិនាទី(s) នាទី(mn) ម៉ោង (h) <br> ១ថ្ងៃ=២៤ម៉ោង <br> ១ម៉ោង=៦០ នាទី <br> ១នាទី=៦០វិនាទី |
| គ្រូដាក់ឧទាហរណ៍ពន្យល់ ណែនាំ រួចសួរ <br> -បើ $x$ ជំនួសឲ្យ7 ហើយ $y$ ជំនួសឲ្យ5 តើកន្សោមនេះអាចសរសេរបានដូចម្តេច ? <br> -សិស្សអានឧទាហរណ៍ទី២ | ជំហានទី៣ (២៥-៣០ នាទី) (មេរៀនថ្មី) <br> កន្សោមពីជគណិត <br> ១ សញ្ញាណកន្សោមពីជគណិត <br> EX-១ គេមានកន្សោមលេខ $5-3\times7$ ហើយគេប្រើអក្សរ $x$ និង $y$ ជំនួសឲ្យ 7 និង 5 គេបាន $y-3x$ ហៅថាកន្សោមពីជគណិតដែលមានពីរអថេរគឺ $x$ និង $y$ <br> EX២ ដីមួយកន្លែងរាងចតុកោណកែងដែលមាន បណ្តោយស្មើនឹង | + ស្តាប់ សង្កេត ការណែនាំ រួចឆ្លើយ <br> -គេបានៈ $y-3x$ <br> -សិស្សឡើងអាន២ ឬ៣ នាក់ |

<table>
<tr>
<td>តើដីមានរាងជាអ្វី?<br>ចុះដឹងអ្វីខ្លះ?<br>បណ្តោយស្មើប៉ុន្មាន?<br>ទទឹងស្មើប៉ុន្មាន?<br>-តើគេអោយរកអ្វី?<br>ដោយដីនោះមានរាង<br>ចតុកោណកែងតើរូបមន្ត<br>បរិមាត្រស្មើអ្វី?<br>តើកន្សោម $2a+26$ ជាកន្សោម<br>ណាអ្វី?មានអថេរអ្វី?<br>-ណែនាំសម្គាល់<br><u>សំគាល់</u><br>$2a$ មានន័យថា $2\times a$<br>$3x$ មានន័យថា $3\times x$<br>$x\ y$ មានន័យថា $x\times y$ $x\times y$<br>-ដាក់ EX-3 ណែនាំសិស្សពីអថេរ<br>និងចំនួនតួ</td>
<td>១៣ ម៉ែត្រ និងទទឹងស្មើ a ម៉ែត្រ<br>កំណត់បរិមាត្រដីនោះ ។<br>ចម្លើយ<br>កំណត់បរិមាត្រ<br>តាមរូបមន្ត<br>បរិមាត្រ=(ប+ទ)×2<br>$=(a+13)\times 2$<br>$=2a+26$<br>កន្សោម $2a+26$ ជាកន្សោម<br>ពីជគណិតដែល $a$ ជាអថេរ<br><br>EX-3 បង្ហាញពីចំនួនតួ និងចំនួន<br>អថេរនៃកន្សោមពីជគណិត<br>
<table>
<tr><th>កន្សោមពីជគណិត</th><th>អថេរ</th><th>ចំនួនតួ</th></tr>
<tr><td>$8x$</td><td>$x$</td><td>1</td></tr>
<tr><td>$\frac{5}{3}a+2b$</td><td>$a\ b$</td><td>2</td></tr>
<tr><td>$7n^2+n+1$</td><td>$n$</td><td>3</td></tr>
<tr><td>$18x^3-x^2+6z-3$</td><td>$x\ y\ z$</td><td>4</td></tr>
</table>
</td>
<td>ចតុកោណកែង<br>បណ្តោយ =១៣ ម៉ែត្រ<br><br>ទទឹង=a<br>-កំនត់បរិមាត្រ<br><br>បរិមាត្រ=(ប+ទ)×2<br><br>ជាកន្សោមពីជគណិត<br>$a$ ជាអថេរ<br>-សង្កេត និងកត់ត្រា</td>
</tr>
<tr>
<td>ឲ្យសិស្សធ្វើលំហាត់ជា<br>បុគ្គល<br>សរសេរល្បះខាងក្រោមជា<br>កន្សោមពីជគណិត<br>ក: $2n$ បូក $3m$<br>ខ: $27p$ ដក $q$ រួចចែកនិង $z$</td>
<td><u>ជំហាន៤</u> (៧-១០នាទី)<br>(ពង្រឹងចំណេះដឹង)</td>
<td>សិស្សធ្វើលំហាត់<br>សរសេរល្បះជាកន្សោមពីជគណិត<br>ក/ $2n+3m$<br>ខ/ $\frac{27p-q}{z}$</td>
</tr>
<tr>
<td>អោយសិស្សមើលមេរៀន<br>បន្តនិងធ្វើលំហាត់ប្រតិបត្តិ<br>នៅទំព័រ ៨២</td>
<td><u>ជំហានទី៥</u> (២-៣នាទី)<br>(បណ្តាំផ្ញើ កិច្ចការផ្ទះ)</td>
<td>ស្តាប់ការណែនាំ</td>
</tr>
</table>

# កិច្ចតែងការបង្រៀន
# គណិតវិទ្យា ថ្នាក់ទី ៧

មេរៀនទី៨ « **កន្សោមពីជគណិត**» (ត)

ខ្លឹមសារមេរៀន៖ ២. តម្លៃកន្សោមពីជគណិត

រយៈពេល ១ ម៉ោង(ម៉ោងទី២)

I. **វត្ថុបំណង**

១ .ចំនេះដឹង : ប្រាប់បានអំពីវិធីរកតម្លៃនៃកន្សោមពីជគណិត តាមរយះឧទាហរណ៍បាន ត្រឹមត្រូវ

២.បំណិន : គណនាតម្លៃនៃកន្សោមពីជគណិតបានត្រឹមត្រូវតាមរយះការប្រតិបត្តិ ។

៣.ឥរិយាបថ : មានស្មារតីប្រុងប្រយ័ត្នពេលគណនាតម្លៃនៃ កន្សោមពីជគណិតបានខ្ពស់ ។

II. **សម្ភារឧបទេស**

-សៀវភៅសិស្សទំព័រ ៨២ .៨៣ បោះពុម្ពឆ្នាំ ២០០៩

-កន្សោមពីជគណិតធ្វើពីក្រដាសពណ៌ សំរាប់បង្ហាញជំនួស

-ផ្ទាំងក្រដាសលំហាត់ប្រតិបត្តិ

III.**ដំណើរកនាំមេរៀន**

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| -ពិនិត្យអវត្តមាន វិន័យ អនាម័យនៅក្នុងថ្នាក់ | ជំហានទី១ (១.២ នាទី)<br>(រដ្ឋបាលថ្នាក់) | .<br>ប្រធានថ្នាក់រាយការណ៍ |
| តើ $-\frac{3}{4}x-2y^{10}+5z-3$ មានប៉ុន្មានតួ?អថេរអ្វីខ្លះ:? | ជំហានទី២(៣.៥នាទី)<br>(រំលឹកមេរៀនចាស់) | $-\frac{3}{4}x-2y^{10}+5z-3$ មាន៤តួ និងមានបីអថេរគឺx , y , z ។ |
| បិទផ្ទាំងកន្សោមពីជគណិតរួចណែនាំវិធីជំនួស $x$ ដោយ 4<br>$y$ ដោយ 8 គេបានដូចម្តេច ?<br>ក/ $a(b+c)=$...........?<br>$ab+ac=$.........?<br>សន្និដ្ឋាន?<br>ចុះ $a(b-c)$ និង $ab-ac$ ? | ជំហានទី៣(២៥.៣០ នាទី)<br>(មេរៀនប្រចាំថ្ងៃ)<br>២.តម្លៃកន្សោមពីជគណិត<br>EX1,គណនាតម្លៃកន្សោមពីជគណិត<br>$3x+2y$ បើ $x=4$ , $y=8$<br>នោះ $3x+2y=3\times4+2\times8=28$<br>EX.2 រកតម្លៃនៃកន្សោមរួចប្រៀបធៀប<br>ក. $a(b+c)$ និង $ab+ac$<br>ខ. $a(b-c)$ និង $ab-ac$ ចំពោះ<br>$a=-1, b=5, c=3$ | បើ $x=4$ , $y=8$ នោះ<br>$3x+2y=3\times4+2\times8=12+16$<br>$=28$<br><br>$a(b+c)=-1(5+3)$<br>$=-8$<br>$ab+ac=-1\times5-1\times3$<br>$=-8$<br>សន្និដ្ឋាន $a(b+c)=ab+ac$ |

| | | |
|---|---|---|
| បិទផ្ទាំងក្រដាសលំហាត់<br>ប្រតិបត្តិ រួចណែនាំគណនា<br>.ឲ្យសិស្សឡើងគណនា<br>លំហាត់ទី១<br>ណែនាំសរសេរ<br>ណែនាំគណនា<br><br>ប្រភាគមួយមិនអាច<br>កំនត់បានកាលណាវា<br>មានលក្ខណៈដូចម្តេច?<br>.នោះតើ $\frac{x-4}{x+12}$ មានន័យ<br>គេបានដូចម្តេច? | ចម្លើយ<br>ក/ $a(b+c)=ab+ac=-8$<br>ខ/ $a(b-c)=ab-ac=-2$<br><br>.ប្រតិបត្តិ<br>១/គណនាតម្លៃនៃកន្សោមបើ<br>$a=2\ ,b=6\ ,c=4,d=5$<br>ក/ $(b-c)+a$<br>ខ/ $(ab+c)d$<br>២/សុភាពនិង ណារីទាំងពីរនាក់<br>មាន៥០០០ រៀល។<br>ប៉ុន្តែគេដឹងថាសុភាពមាន<br>ប្រាក់ $y$ រៀល។<br>ក/សរសេរចំនួនប្រាក់របស់ណារី<br>ជាកន្សោមពីជគណិត<br>ខ/រកចំនួនប្រាក់របស់ណារីបើសុ<br>ភាព មានប្រាក់ ៤០០០ រៀល<br>៣/គណនាតម្លៃកន្សោម $\frac{2m}{-4-n}$<br>ចំពោះ $m=\frac{1}{2}\ ,n=-3$<br><br>៤/គណនាតម្លៃនៃអថេរដែលនាំ<br>ឲ្យកន្សោម $\frac{x-4}{x+12}$ មិនអាច<br>កំណត់បាន(ឬគ្មានន័យ)។ | $a(b-c)=-1(5-3)=-2$<br>$ab-ac=-5+3=-2$<br>$\Rightarrow a(b-c)=ab-ac$<br>កត់ត្រា<br>សិស្សឡើងគណនា<br>ចម្លើយ<br>១/ក. $(b-c)+a=(6-4)+2=4$<br>ខ. $(ab+c)d=(2\times 6+4)\times 5=80$<br>២/ក. $5000-y$<br>ខ.បើ $y=4000$ រៀល<br>$\Rightarrow 5000-y=1000$ រៀល<br><br>៣/ $\frac{2m}{-4-n}=\frac{2\times\frac{1}{2}}{-4-(-3)}=\frac{1}{-1}=-1$<br><br>ប្រភាគ $\frac{a}{b}$ ដែល $b=0$ ជាប្រភាគ<br>មិនអាចកំនត់បាន<br>៤/ $\frac{x-4}{x+12}$ គ្មានន័យកាលណា<br>$x+12=0$<br>.គេបាន $x=-12$ |
| គណនាតម្លៃកន្សោម<br>$\frac{t+2}{-3+4q}$ បើ<br>ក/ $t=-2\ \ ,q=1$<br>ខ/ $t=-2\ ,q=\frac{3}{4}$ | <u>ជំហានទី៤</u>(៧.១០ នាទី)<br>(ពង្រឹងចំណេះដឹង)<br>.កន្សោម $\frac{t+2}{-3+4q}$<br>ក/ $\frac{t+2}{-3+4q}=0$<br>ខ/ $\frac{t+2}{-3+4q}$ គ្មានន័យ | គណនាតម្លៃកន្សោម<br>ក/ $t=-2\ \ ,q=1$ គេបាន<br>$\frac{t+2}{-3+4q}=\frac{-2+2}{-3+4}=0$<br>ខ/ $t=-2\ ,q=\frac{3}{4}$ គេបាន<br>$\frac{t+2}{-3+4q}=\frac{-2+2}{-3+4\times\frac{3}{4}}=\frac{0}{0}$ គ្មានន័យ |
| ឲ្យសិស្សធ្វើលំហាត់<br>ទី៣ ទំព័រ ៤០ | <u>ជំហានទី៥</u> (២.៣ នាទី)<br>(កិច្ចការផ្ទះ)លំហាត់ទី៣ ទំព័រ ៤០ | កត់ត្រាទុកធ្វើនៅផ្ទះ |

# កិច្ចតែងការបង្រៀន
# គណិតវិទ្យាថ្នាក់ទី៧

**មេរៀនទី៨** "**កន្សោមពីជគណិត**"(**ត**)

ខ្លឹមសារមេរៀន៖ ៣/វិធីបូក និង ដក កន្សោមពីជគណិត
៣.១ ផលបូកនិងផលដកដែលមានតួដូចគ្នា
៣.២ ការគណនាផលបូកនិង ផលដកកន្សោមពីជគណិត ដោយប្រើវិធីដាក់ជាកត្តា

(រយះពេល ១ ម៉ោង) (ម៉ោងទី៣)

## I **វត្ថុបំណង**

១.ចំណេះដឹង: កំណត់បានពីវិធីបូកនិងដកកន្សោមពីជគណិតបានត្រឹមត្រូវ តាមរយះឧទាហរណ៍។

២.បំណិន: គណនាប្រមាណវិធីបូកនិង ដកកន្សោមពីជគណិតបានត្រឹមត្រូវ តាមរយះការប្រតិបត្តិ ។

៣.ឥរិយាបថ: មានស្មារតីប្រុងប្រយ័ត្ន ពេលគណនាប្រមាណវិធីបូកដកកន្សោម ពីជគណិត បានខ្ពស់ ។

## II **សម្ភារឧបទេស**

.សៀវភៅសិស្ស ទំព័រ៨៥.៨៦ បោះពុម្ពឆ្នាំ ២០០៩

## III **ដំណើរការមេរៀន**

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| .ពិនិត្យ អវត្តមាន វិន័យ អនាម័យ | ជំហានទី១ (១.២ នាទី)<br>(រដ្ឋបាលថ្នាក់) | ប្រធានថ្នាក់រាយការណ៍ |
| គណនាតម្លៃនៃកន្សោម<br>$5a-2b+c$ ចំពោះ<br>$a=b=1$ , $c=-1$ | ជំហានទី២ (៣.៥ នាទី )<br>(រំលឹកមេរៀនចាស់) | សិស្សគណនា<br>$5a-2b+c=$<br>$5\times1-2\times1+(-1)=2$ |
| សរសេរចំណងជើងដាក់លើក្តារខៀន | ជំហានទី៣ (២៥.៣០ នាទី)<br>(មេរៀនប្រចាំថ្ងៃ)<br>កន្សោមពីជគណិត (ត)<br>៣/វិធីបូកនិងដកន្សោមពីជគណិត | សរសេរចំណងជើង |

| | | |
|---|---|---|
| ដាក់ឧទាហរណ៍និង<br>ណែនាំ $x+x=2x$<br>$x+x+x+x=4x$<br>ណែនាំតួដូចគ្នានិង<br>ខុសគ្នា<br>តួ $2x$ និង $4x$ មានអថេរដូចគ្នា<br>ហៅថាតួដូចគ្នា ។<br>តួ $3t$ និង $4s$ ហៅថាតួខុសគ្នា<br>ព្រោះ $3t$ និង $4s$ មានអថេរខុសគ្នា ។ | ៣.១/ផលបូកនិងផលដកដែលមានតួដូចគ្នា<br>EX1.គណនា $x+x=2x$<br>$x+x+x+x=4x$<br>$t+t+t=3t$<br>$s+s+s+s=4s$ | ស្តាប់ការណែនាំនិងកត់ត្រា<br><br>ស្តាប់ និង កត់ត្រា |
| ណែនាំគណនា<br>$5x+(-2x)=5x-2x=3x$ ណែនាំគណនា | EX2.គណនា $5x+(-2x)=3x$<br>លំហាត់គំរូ<br>គណនាផលបូកកន្សោម<br>$3x+2-5x+1=-2x+3$ | ស្តាប់ និង កត់ត្រា |
| ណែនាំយកឧទាហរណ៍<br>ខាងលើមកគណនា | ៣.២/ការគណនាផលបូកនិងផលដកកន្សោមពីជគណិតដោយប្រើដាក់ជាកត្តា<br>EX $5x+(-2x)=3x$<br>$=(5-2)x$<br>និង $t+t+t=3t=(1+1+1)t$<br>-ជាទូទៅ $ax\pm bx=(a\pm b)x$<br>ក្នុងការគណនាដោយខ្លី<br>$3x+2x=5x$<br>$3x-2x=x$ | $ax\pm bx=(a\pm b)x$<br><br>កត់ត្រា |
| ដាក់លំហាត់គំរូនិងលំហាត់ | លំហាត់គំរូ | |

| | | |
|---|---|---|
| ប្រតិបត្តិ ឲ្យសិស្សធ្វើ | គណនាកន្សោម<br>$2x+(-7x)=(2-7)x=-5x$<br>$4x-4x=(4-4)x=0x=0$<br>.ប្រតិបត្តិគណនាកន្សោម<br>ក/$8x+(-7x)=x$<br>ខ/$10x+23x=33x$ | ចម្លើយ<br>$2x+(-7x)=(2-7)x=-5x$<br>$4x-4x=(4-4)x=0x=0$<br>ក/.$8x+(-7x)=8x-7x=x$<br>ខ/.$10x+23x=33x$ |
| ឲ្យសិស្សគណនា<br>ក/$4x-5x+2x$<br>ខ/$t-3t+4t$ | ជំហានទី៤ (៧.១០ នាទី)<br>(ពង្រឹងចំណេះដឹង) | គណនា<br>ក/$4x-5x+2x=x$<br>ខ/$t-3t+4t=2t$ |
| ឲ្យសិស្សធ្វើលំហាត់ លេខ៦<br>ក.ខ.ទំព័រ ៩០ | ជំហានទី៥(២.៣នាទី)<br>លំហាត់លេខ៦<br>ចំណុច ក.ខ.ទំព័រ ៩០ | កត់ត្រាទុកធ្វើនៅផ្ទះ |

# កិច្ចតែងការបង្រៀន
# គណិតវិទ្យាថ្នាក់ទី៧

មេរៀនទី៨ "**កន្សោមពីជគណិត**"(ត)

ខ្លឹមសារមេរៀន ៖៣.៣/គណនាផលបូកនិងផលដកដោយប្រើលក្ខណៈផ្តុំ

(រយៈពេល ១ ម៉ោង) (ម៉ោងទី៤)

I **វត្ថុបំណង**

១/ចំណេះដឹង : កំណត់បានពីវិធីបូក ដក កន្សោមពីជគណិតដោយប្រើលក្ខណៈផ្តុំបានត្រឹមត្រូវ តាមរយៈឧទាហរណ៍ ។

២/បំណិន : គណនាផលបូក ដក កន្សោមពីជគណិតដោយប្រើលក្ខណៈផ្តុំបានត្រឹមត្រូវ តាមរយៈការប្រតិបត្តិ។

៣/ឥរិយាបថ : មានស្មារតីប្រុងប្រយ័ត្នក្នុងការគណនាផលបូកដកដោយប្រើលក្ខណៈផ្តុំខ្ពស់ ។

II **សម្ភារឧបទេស**

សៀវភៅសិស្ស ទំព័រ ៨៦.៨៧ បោះពុម្ពឆ្នាំ២០០៩

III **ដំណើរការនាំមេរៀន**

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| ពិនិត្យ អវត្តមាន វិន័យ<br>អនាម័យ | ជំហានទី១ (១.២ នាទី)<br>(រដ្ឋបាលថ្នាក់) | ប្រធានថ្នាក់រាយការណ៍ |
| ឲ្យសិស្សគណនា<br>$8x+(-7x)$<br>$10x+23x$<br>$-2a+(-4a)$<br>$b-5b+15b$ | ជំហានទី២(៣.៥ នាទី)<br>(រំលឹកមេរៀនចាស់) | $8x+(-7x)=8x-7x=x$<br>$10x+23x=33x$<br>$-2a+(-4a)-2a-4a=-6a$<br>$b-5b+15b=11b$ |
| ដាក់ឧទាហរណ៍ ណែនាំ<br>$A=(4x-1)+(-3x+6)$<br>$=4x-1-3x+6$(លុបវង់ក្រចក)<br>$=(4x-3x)+(-1+6)$ | ជំហានទី៣ (២៥.៣០ នាទី)<br>(មេរៀនប្រចាំថ្ងៃ)<br>៣.៣គណនាផលបូក ដក កន្សោម ពីជគណិតដោយប្រើលក្ខណៈផ្តុំ<br>EX :ណនា $A=(4x-1)+(-3x+6)$<br>និង $B=(3x-4)-(x-7)$ | កត់ត្រា<br>សង្កេត |

| | | |
|---|---|---|
| (ផ្តុំតួដូចគ្នា)<br>$A = x+5$<br>$B=(3x-4)-(x-7)$<br>$=3x-4-x+7$<br><br>ណែនាំផ្តុំតួដូចគ្នា<br>គណនាផលបូកនិង<br>ផលដកតួដូចគ្នា<br>ណែនាំ សម្គាល់<br><br>សរសេរលំហាត់គំរូ<br>លើក្តាខៀន ។<br><br>តើបរិមាត្រចតុកោណ<br>កែងមានរូបមន្តដូច<br>ម្តេច?<br>ណែនាំគណនា<br><br>ដាក់ប្រតិបត្តិណែនាំ<br>អោយសិស្សគណនា | $A=(4x-1)+(-3x+6)$<br>$A=x+5$<br>$B=(3x-4)-(x-7)$<br>$B=2x+3$<br><br>EX2.គណនា<br>$5x-y-2y+2z^2-8x-z+4y$<br>$5x-8x-y-2y+4y+2z^2-z$<br>$=-3x+y+2z^2-z$<br>.សម្គាល់ តួ $2z^2$<br>និ $z$ ជាតួមិនដូចគ្នាហេតុនេះ<br>មិនអាចបូកចូលគ្នាបានទេ។<br>.លំហាត់គំរូ បន្ទប់រៀនមួយមាន<br>រាងចតុកោណកែងដែលមាន<br>បណ្តោយស្មើ $2x+7$ និងទទឹង<br>ស្មើ $x+5$ ។រកបរិមាត្រ<br>បន្ទប់រៀននោះ ។<br><br><br>.ប្រតិបត្តិ បង្រួមកន្សោម<br>$2a+5b+7a+9b$ រួចគណនា<br>តម្លៃកន្សោមចំពោះ<br>$a=-2\ ,\ b=7$ | $5x-8x-y-2y+4y+2z^2-z$<br>$=-3x+y+2z^2-z$<br><br>កត់ត្រា<br>អានប្រធានលំហាត់<br><br>P=(ប+ទ).2<br>$P=(2x+7+x+5)\times 2$<br>$=(3x+12)2$<br>$=6x+24$<br><br>សិស្សគណនា<br>$2a+5b+7a+9b$<br>$=2a+7a+5b+9b$<br>$=9a+14b$<br>ចំពោះ $a=-2\ ,\ b=7$<br>នោះ $9a+14b=9\times(-2)+14\times 7$<br>$=-18+98=80$ |
| | <u>ជំហានទី៤</u> (៧.១០ នាទី) | សិស្សគណនា |

| | | |
|---|---|---|
| ឲ្យសិស្សគណនា<br>$y-z+5x-y+z-5x$<br>$a-2b+7a-3b+5$ | (ពង្រឹងចំណេះដឹង)<br>$y-z+5x-y+z-5x=0$<br>$a-2b+7a-3b+5=8a-5b+5$ | $y-y-z+z+5x-5x$<br>$=0-0+0=0$<br>$a-2b+7a-3b+5$<br>$=a+7a-2b-3b+5$<br>$=8a-5b+5$ |
| ឲ្យសិស្សធ្វើលំហាត់<br>ទី៣ ទំព័រ ៩០ | <u>ជំហានទី៥</u>(២.៣នាទី)<br>(កិច្ចការផ្ទះ)<br>លំហាត់ទី៣ ទំព័រ ៩០ | កត់ត្រាទុកធ្វើនៅផ្ទះ |

# កិច្ចតែងការបង្រៀន
# គណិតវិទ្យា ថ្នាក់ទី ៧

មេរៀនទី៨ «**កន្សោមពីជគណិត**»(**តចប់**)

ខ្លឹមសាមេរៀន ៥.ការដាក់ជាផលគុណកត្តា

(រយះពេល ១ ម៉ោង)(ម៉ោងទី៦)

## I **វត្ថុបំណង**

១/ចំណេះដឹង : បង្ហាញបានពីវិធីដាក់ជាផលគុណកត្តាបានត្រឹមត្រូវតាមរយះឧទាហរណ៍ ។

២/បំណិន : សរសេរកន្សោមជាផលគុណកត្តាបានត្រឹមត្រូវ តាមរយះការប្រតិបត្តិ ។

៣/ឥរិយាបថ : មានស្មារតីប្រុងប្រយ័ត្នពេលដោះស្រាយលំហាត់ ។

## II **សម្ភារឧបទេស**

.សៀវភៅសិស្សទំព័រ៨៩ បោះពុម្ពឆ្នាំ ២០០៩

## III **ដំណើរនាំមេរៀន**

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| ពិនិត្យ អវត្តមាន អនាម័យ វិន័យ | ជំហានទី១(១.២នាទី)<br>(រដ្ឋបាលថ្នាក់) | ប្រធានថ្នាក់រាយការណ៍ |
| ឲ្យសិស្សឡើងបំពេញ<br>$a(b+c)=........?$<br>$(a+b)(c+d)=..........?$ | ជំហានទី២(៣.៥នាទី)<br>(រំលឹកមេរៀនចាស់) | សិស្សឡើងបំពេញ<br>$a(b+c)=ab+ac$<br>$(a+b)(c+d)=$<br>$a(c+d)+b(c+d)$<br>$=ac+ad+bc+bd$ |
| ណែនាំ:គេដឹងថា $a(b+c)$ និង $ab+ac$ មានតម្លៃស្មើគ្នា | ជំហានទី៣ (២៥.៣០ នាទី)<br>(មេរៀនប្រចាំថ្ងៃ)<br>៥/ការដាក់ជាផលគុណកត្តា<br>គេដឹងថា $a(b+c)$ និង $ab+ac$ មានតម្លៃស្មើគ្នា<br>.កាលណាគេសរសេរ<br>$a(b+c)=ab+ac$ | ស្តាប់និងកត់ត្រា<br>ស្តាប់ |

| | | |
|---|---|---|
| ណែនាំអត្ថន័យនៃការសរសេរ | មានន័យថាគេពន្លាតផលគុណ<br>$a(b+c)$ ជាផលបូក $ab+ac$<br>.កាលណាគេសរសេរ<br>$ab+ac=a(b+c)$<br>មានន័យថាគេដាក់<br>ផលបូក $ab+ac$ ជាផលគុណកត្តា<br>$a(b+c)$ ។ | សង្កេត កត់ត្រា |
| ដាក់ឧទាហរណ៍និងណែនាំ<br>យកអ្វីដែលដូចគ្នាក្នុងតួនីមួយៗ ដាក់ជាកត្តា<br>$12x=6x\times 2$<br>ណែនាំយក $PGCD(4.6)$<br>ជាកត្តា | EX.ដាក់ជាផលគុណកត្តា<br>ក/ $yz-3y=y(z-3)$<br>ខ/ $12x+6xy=6x(2+y)$<br>គ/ $4xy-6yz=2y\times 2x-2y\times 3z$<br>$=2y(2x-3z)$ | $y$ ដូចគ្នាក្នុងតួនីមួយៗ<br>សង្កេត |
| ផ្តុំតួ $ax-ay$ មាន $a$ ដូចគ្នា<br>នោះយក $a$ ជាកត្តា | .លំហាត់គំរូដាក់ជាផលគុណកត្តា<br>ក/ $ax-ay+bx-by$<br>$=(ax-ay)+(bx-by)$ (ផ្តុំតួ)<br>$=a(x-y)+b(x-y)$<br>(ដាក់ $a$ , $b$ ជាកត្តា)<br>$=(x-y)(a+b)$<br>យក $(x-y)$ ជាកត្តា<br>ខ/ $mn+3m-4n-12$<br>$=(mn+3m)-(4n+12)$<br>$=m(n+3)-4(n+3)$ | សង្កេត<br>ស្តាប់<br>កត់ត្រា<br>ស្តាប់ការណែនាំ |
| ណែនាំដាក់ជាកត្តា<br>ឲ្យសិស្សដាក់ជាផលគុណកត្តា | .ប្រតិបត្តិ:ដាក់ជាផលគុណកត្តា<br>ក/ $ab+a+b+1$<br>$=(b+1)(a+1)$ | សិស្សធ្វើ<br>ក $ab+a+b+1$<br>$=(ab+a)+(b+1)$ |

| | | |
|---|---|---|
| | ខ/ $xz+2z+2y+xy$<br>$=(x+2)(z+y)$<br><br>គ/ $(x-5)(x+2)-(3x+1)(x-5)$<br>$=(x-5)(-2x+1)$ | $=a(b+1)+(b+1)$<br>$=(b+1)(a+1)$<br>ខ/ $xz+2z+2y+xy$<br>$=(xz+2z)+(2y+xy)$<br>$=z(x+2)+y(2+x)$<br>$=(x+2)(z+y)$<br>គ/.<br>$(x-5)(x+2)-$<br>$(3x+1)(x-5)$<br>$=(x-5)(x+2-3x-1)$<br>$=(x-5)(-2x+1)$ |
| សួរ តើការសរសេរ<br>$a(b+c)=ab+ac$ មានន័យ<br>ដូចម្តេច?<br>ចុះបើ $ab+ac=a(b+c)$ វិញ ? | <u>ជំហានទី៤</u>(៧.១០ នាទី)<br>(ពង្រឹងចំណេះដឹង) | មានន័យថាពន្លាតផល<br>គុណ $a(b+c)$ ជាផលបូក<br>$ab+ac$ ។<br>មានន័យដាក់ផលបូក<br>$ab+ac$ ជាផលគុណ<br>$a(b+c)$ ។ |
| អោយសិស្សធ្វើ<br>លំហាត់ទី៨ ទំព័រ ៩០ | <u>ជំហានទី៥</u>(២.៥ នាទី)<br>(កិច្ចការផ្ទះ)<br>លំហាត់ទី៨ ទំព័រ ៩០ | កត់ត្រាទុកធ្វើនៅផ្ទះ |

# កិច្ចតែងការបង្រៀន
# គណិតវិទ្យា ថ្នាក់ទី ៧
# ថ្ងៃ ទី ខែ ឆ្នាំ

I. រយៈពេលបង្រៀន ២ ម៉ោង

II. សម្ភារៈឧបទេស

III. ចំណងជើងមេរៀន : **សមីការដឺក្រេទីមួយមានមួយអញ្ញាត**

- ចំណងជើងរង

1) សញ្ញាណសមីការដឺក្រេទីមួយមានមួយអញ្ញាត

2) ឫសនៃសមីការដឺក្រេទីមួយមានមួយអញ្ញាត

3) ដោះស្រាយសមីការដឺក្រេទី១មានមួយអញ្ញាត

3.1ដោះស្រាយសមីការដឺក្រេទី១ដោយប្រើវិធីបូកឬដក

IV. វត្ថុបំណង : ក្រោយពេលរៀនចប់សិស្សអាច

\+ ចំណេះដឹង:

– ប្រាប់បានពីសញ្ញាណសមីការដឺក្រេទី១មាន១អញ្ញាត

– ពន្យល់ឬប្រាប់បានពីរបៀបដោះស្រាយសមីការដឺក្រេទី១មាន១អញ្ញតឬ រក ឫសនៃ សមីការ

\+ បំនិន(ចំណេះធ្វើ) ៖

– ដោះស្រាយសមីការសមីការដឺក្រេទី១មាន១អញ្ញាត

– ដោះស្រាយសមីការសមីការដឺក្រេទី១មាន១អញ្ញាតដែលមានប្រមាណវិធីបូកឬដក។

\+ ឥរិយាបទ:

– សិស្សមានទំនាក់ទំនងល្អរវាងគ្រូនិងមិត្តរួមថ្នាក់បានត្រឹមត្រូវតាមរយ:មេរៀននិងឧទាហរណ៍

– សិស្សមានបំរុងប្រយ័ត្នក្នុងការស្តាប់គ្រូពន្យល់យ៉ាងយកចិត្តទុកដាក់និងសៀមស្ទាត់អាចធ្វើលំហាត់បានត្រឹមត្រូវ

V. ដំណើកនាំមេរៀន : ២ ម៉ោង

| សកម្មភាពគ្រូ | ខ្លឹមសារបង្រៀន | សកម្មភាពសិស្ស |
|---|---|---|
| គ្រូតពិនិត្យអនាម័យអវត្តមាន<br>-សណ្តាប់ធ្នាប់និង វិន័យ | ជំហានទី១<br>(រដ្ឋបាលថ្នាក់) | តំណាងថ្នាក់ឡើងរាយការណ៍ |

| | | |
|---|---|---|
| គេអោយកន្សោម5-3x7<br>បើគេប្រើអក្សរ $x$ និង $y$<br>ជំនួសដោយ7និង5 នោះគេ<br>បានកន្សោមយ៉ាង ដូចម្តេច?<br>តើ $x$ និង $y$ ហៅថាអ្វី?<br>តើន្សោមនេះហៅថាអ្វី | <u>ជំហានទី២</u><br>(រំលឹកមេរៀនចាស់) | +កន្សោមទៅជា $y-3x$<br>+ $x$ និង $y$ ហៅថាអថេរ<br>+កន្សោមនេះហៅថា<br>កន្សោមពិជគណិត |
| គ្រូដាក់ឧទាហរណ៍អោយសិស្ស គេអាចសរសេរកន្សោមពិជ<br>គណិតនៃសមីការនោះដោយ<br>ដូចម្តេច?<br><br>គ្រូអោយសិស្សទាញជាទូទៅ<br><br>គ្រូអោយសិស្សទាញជាតំលៃ | <u>ជំហានទី៣</u><br>(មេរៀនប្រចាំថ្ងៃ)<br><u>1.សញ្ញាណសមីការដឺក្រេទីមួយ</u><br><u>មានមួយអញ្ញាត</u><br><br><u>ឧទាហរណ៍</u>:<br>ឧបមាថានៅក្នុងស្រុក មួយមាន<br>សាលាបឋមចំនួន5នៅឆ្នាំ2005លុះ<br>មកដល់ឆ្នាំ2008សាលាបឋម<br>សិក្សាកើនឡើងដល់8សាលាគេ<br>ចង់ដឹងថាតើចំនួនសាលាដែល<br>គេបានសាសង់នៅចន្លោះឆ្នាំ<br>2005-2008មានចំនួនប៉ុន្មាន?<br><br>ជាទូទៅះ<br>កន្សោមពិជគណិតមានទម្រង់<br>$ax+b=c$ ដែល $a,b$ និង $c$<br>ជាចំនួនថេរហើយ $a\neq 0$ ហៅថា<br>សមីការដឺក្រេទី1មានអញ្ញាត្តិ ។<br>2.<u>ឫសនៃសមីការដឺក្រេទីមួយមាន</u><br><u>មួយអញ្ញាត</u><br>គេមានសមីការ $x+4=7$<br>តើមានតំលៃ $x$ ណាដែល នាំឲ្យអង្គ | តាង $x$ ជាចំនួនសាលាបឋម<br>សិក្សា ដែលគបានសាងសង់<br>ចន្លោះឆ្នាំ2005ដល់2008នោះ<br>គេបានកន្សោមពិជគណិត<br>នៃសមីការដោយះ<br>$5+x=8$ ជាសមីការដឺ<br>ក្រេទី1មាន1អញ្ញាត្តិ។<br>ជាទូទៅះ<br>កន្សោមពិជគណិតមានទម្រ<br>ង់ $ax+b=c$ ដែល $a,b$ និង $c$<br>ជាចំនួនថេរហើយ $a\neq 0$<br>ហៅថា<br>សមីការដឺក្រេទី1មានអញ្ញាត្តិ<br>។ |

| | | |
|---|---|---|
| ដាក់ប្រតិបត្តិឲ្យសិស្សធ្វើ<br>ប្រតិបត្តិ<br>គេមានតម្លៃ $x$ ស្មើនឹង 52 ; 24។<br>តើតម្លៃ $x$ ណាដែលជា<br>ឫសនៃសមីការ $x-14=38$ ។<br><br>ដាក់ឧទារណ៍ណែនាំឲ្យ<br>សិស្សសង្កេត<br><br>តាមរយៈឧទាហរណ៍តើយើងស<br>ង្កេតឃើញជាទូទៅយ៉ាងដូចម្ដេច<br>កាលណាគេដកឬថែម<br>ចំនួនដូចគ្នាពីអង្គទាំងពីរនៃ<br>សមភាពនិងសមីការ? | ទាំងពីរនៃសមីការ<br>មានតម្លៃស្មើគ្នា?<br><br>ប្រតិបត្តិ<br>គេមានតម្លៃ $x$ ស្មើនឹង 52 ; 24។<br>តើតម្លៃ $x$ ណាដែលជា<br>ឫសនៃសមីការ $x-14=38$ ។<br><br>3.ដោះស្រាយសមីការដឺក្រេទី១មានមួយអញ្ញាត្តិ<br>*3.1ដោះស្រាយសមីការដឺក្រេទី១ ដោយប្រើវិធីបូកឬដក*<br>Ex1: គេមានសមភាព $5=5$<br>គេបាន $5+2=5+2$<br>(ថែម2លើអង្គទាំងពីរ)<br>$7=7$<br>Ex2:គេមានសមភាព $5=5$<br>គេបាន $5-2=5-2$<br>(ដក2ពីអង្គទាំងពីរ)<br>$3=3$ | បើ $x=1$ គេបាន $1+4<7$<br>បើ $x=2$ គេបាន $2+4<7$<br>បើ $x=3$ គេបាន $3+4=7$<br>បើ $x=4$ គេបាន $4+4>7$<br>នាំឲ្យ $x=3$<br>ជាឫសនៃសមីការ<br>ឬជាចម្លើយនៃសមីការ។<br><br>+បើ $x=52$<br>គេបាន $52-14=38$<br>+បើ $x=42$ គេបាន<br>$42-14=28<38$<br>បើ $x=24$ គេបាន<br>$24-14=10<38$<br>ដូច្នេះឫសនៃសមីការគឺ $x=52$<br><br>ឃើញថាអង្គទាំងពីរស្មើគ្នាព<br>ល់<br>ពេលថែមរឺថយចំនួនលេខ |

| | | |
|---|---|---|
| គ្រូអោយសិស្សទាញជាសំគាល់ពីឧទាហរណ៍ខាងលើ | សំគាល់៖<br>ក្នុងការអនុវត្តន៍គេលើកតួពីអង្គម្ខាងទៅអង្គម្ខាងទៀតដោយប្តូរសញ្ញា។<br>ជាទូទៅ៖<br>បើគេថែមឬដកចំនួនដូចគ្នាពីអង្គទាំងពីរនៃសមភាពនៅតែស្មើគ្នាដដែល។ | សំគាល់៖<br>ក្នុងការអនុវត្តន៍គេលើកតួពីអង្គម្ខាងទៅអង្គម្ខាងទៀតដោយប្តូរសញ្ញា។<br>ជាទូទៅ៖<br>បើគេថែមឬដកចំនួនដូចគ្នាពីអង្គ<br>ទាំងពីរនៃសមភាពនៅតែស្មើគ្នាដដែល។ |
| ដោះស្រាយសមីការ៖<br>$x-2013=3x-1$<br>$x-18=5x-20$ | <u>ជំហានទី៤</u><br>(ពង្រឹងពុទ្ធិ)<br>ដោះស្រាយសមីការ៖<br>$x-2013=3x-1$ $x-18=5x-20$ | $x-2013=3x-1$<br>$x-3x=2013-1$<br>$-2x=2012$<br>$x=-1006$<br>$x-18=5x-20$<br>$-4x=2$<br>$x=-1/2$ |
| ដោះស្រាយសមីការខាក្រោម<br>$1./\ x-3=2011-4x$<br>$2./\ 2012-x=20-x$ | <u>ជំហានទី៥</u><br>(បណ្តាំផ្ញើ)<br>ដោះស្រាយសមីការខាក្រោម<br>$1./\ x-3=2011-4x$<br>$2./\ 2012-x=20-x$ | សិស្សកត់ត្រាទុកធ្វើផ្ទះ។ |

# កិច្ចតែងការបង្រៀន
# គណិតវិទ្យា ថ្នាក់ទី ៧
# ថ្ងៃ ទី ខែ ឆ្នាំ

I. រយៈពេលបង្រៀន ២ ម៉ោង

II. សម្ភារៈឧបទេស

III. ចំណងជើងមេរៀន : **សមីការដឺក្រេទីមួយមានមួយអញ្ញាត**

- ចំណងជើងរង

3.2.<u>ការដោះស្រាយសមីការដោយប្រើវិធីចែកឬគុណ</u>

3.3<u>ដោះស្រាយសមីការដោយប្រើវិធីចំរុះ</u>

3.4<u>ចំណោទសមីការដឺក្រេទី1មាន1អញ្ញាត្តិ</u>

IV. វត្ថុបំណង : ក្រោយពេលរៀនចប់សិស្សអាច

➢ ចំណេះដឹង៖

+ ប្រាប់បានពីរបៀបឬវិធីដោះស្រាយសមីការក្នុងវិធីគុណឬចែករហូតដល់ដោះស្រាយដោយប្រើវិធីចំរុះ

+ បង្ហាញឬពន្យល់បានពីរបៀបដោះស្រាយចំណោទសមីការដឺក្រេទី1មាន1អញ្ញាតបានត្រឹមត្រូវតាមរយៈមេរៀននិងឧទាហរណ៍

➢ ចំណេះធ្វើ(បំណិន)៖

+ ដោះស្រាយសមីការដោយប្រើវិធីវិធីចំរុះបានត្រឹមត្រូវតាមរយៈលំហាត់ឧទាហរណ៍បនិងមេរៀន។

+ ដោះស្រាយចំណោទសមីការបានត្រឹមត្រូវលើលំហាត់ប្រតិបត្តិ

➢ ឥរិយាបទ៖

+សិស្សមានទំនាក់ទំនងល្អរវាងគ្រូនិងមិត្តរួមថ្នាក់បានត្រឹមត្រូវតាមរយៈមេរៀននិង ឧទាហរណ៍

+ សិស្សមានបំរុងប្រយ័ត្នក្នុងការធ្វើលំហាត់និងស្តាប់គ្រូពន្យល់

V. ដំណើកនាំមេរៀន : ២ ម៉ោង

| សកម្មភាពគ្រូ | ខ្លឹមសារបង្រៀន | សកម្មភាពសិស្ស |
|---|---|---|
| -ត្រួតពិនិត្យអនាម័យ<br>-អវត្តមាន<br>-សណ្តាប់ធ្នាប់និង វិន័យ | <u>ជំហានទី១</u><br>(រដ្ឋបាលថ្នាក់) | តំណាងថ្នាក់ឡើងរាយការណ៍ |
| ដោះស្រាយសមីការខាងក្រោម<br>$1./\ x-3=2011-4x$<br>$2./\ 2012-x=20-x$ | <u>ជំហានទី២</u><br>(រំលឹកមេរៀនចាស់)<br>ដោះស្រាយសមីការខាងក្រោម<br>$1./\ x-3=2011-4x$<br>$2./\ 2012-x=20-x$ | $1./\ x-3=2011-4x$<br>$\Leftrightarrow x+4x=2011+3$<br>$\Leftrightarrow 5x=2014 \Leftrightarrow x=\frac{2014}{5}$<br>ដូច្នេះឫសរបស់សមីការគឺ<br>$x=\frac{2014}{5}$<br>$2./\ 2012-x=20+x$<br>$\Leftrightarrow -x-x=20-2012$<br>$\Leftrightarrow -2x=1992$<br>$\Rightarrow x=\frac{1992}{2}=996$<br>ដូច្នេះឫសរបស់សមីការគឺ<br>$x=996$ |

| | | |
|---|---|---|
| ដាក់ឧទាហរណ៍មួយដើម្បីបង្ហាញពីអត្ថន័យនៃសមីការ។ | <u>ជំហានទី៣</u>(មេរៀនប្រចាំថ្ងៃ)<br>មេរៀនទី9៖សមីការដឺក្រេទីមួយមានមួយអញ្ញាត<br>3.2.<u>ការដោះស្រាយសមីការដោយប្រើវិធីចែកឬគុណ</u><br>Ex1.ដោះស្រាយសមីការ $2x=-4$<br><br>Ex$_2$: ដោះស្រាយសមីការ<br>$\frac{x}{4}=9$ ។ | <br>2x = −4<br><br>$\frac{2x}{2}=-\frac{4}{2}$<br>$x=-2$<br><br>យើងមាន $\frac{x}{4}=9$<br>(គុណទាំងពីរនឹង4)<br>គេបាន $4\times\frac{x}{4}=9\times4$<br>$\Leftrightarrow x=36$<br>ផ្ទៀងផ្ទាត់ $\frac{x}{4}=9$<br>$\frac{36}{4}=9$<br>$9=9$ |
| គ្រូអោយសិស្សទាញជាទូទៅ | ជាទូទៅគេអាចដោះស្រាយសមីការតាមវិធីគុណឬចែកអង្គទាំងពីរនឹង<br>មួយចំនួនដូចគ្នាយ៉ាងម្តេច?<br>3.3<u>ដោះស្រាយសមីការដោយប្រើវិធី ចម្រុះ</u><br>Ex$_1$ ដោះស្រាយសមីការ | ជាទូទៅគេអាចដោះស្រាយសមីការតាមវិធីគុណឬចែកអង្គទាំងពីរនឹងមួយចំនួនដូចគ្នាខុសពីសូន្យ<br><br>គេមាន $2x=10+50$<br>$2x=60$<br>$\Rightarrow x=30$ |

| | | |
|---|---|---|
| ដាក់លំហាត់ប្រតិបត្តិឲ្យសិស្ស<br><br>ដាក់ឧទាហរណ៍ រួចណែនាំសិស្សធ្វើតាមជំហ៊ាន<br><br>– ជ្រើសរើសអញ្ញាត្តិ: តាងចំនួននោះដោយអក្សរ $x$<br>– សរសេរសមីការគេបាន<br>$3x = 93$<br>– ដោះស្រាយសមីការ<br>$3x = 93$<br>$\Leftrightarrow x = \frac{93}{3} = 31$<br>ដូចនេះឫសរបស់សមីការគឺ<br>$x = 31$<br><br>គ្រូអោយសិស្សពីរបៀបនៃការដោះស្រាយលំហាត់ | $2x - 50 = 10$<br><br>ប្រតិបត្តិ<br>ដោះស្រាយសមីការ<br>$5x - (7x - 4) = 2$<br><br>3.4.<u>ចំណោទសមីការដឺក្រេទី1មាន 1 អញ្ញាត្តិ</u><br>Ex1:រកចំនួនមួយដែលបីដងចំនួននោះស្មើនឹង 93។<br><br>– ជ្រើសរើសអញ្ញាត្តិ: តាងចំនួននោះដោយអក្សរ $x$<br>– សរសេរសមីការគេបាន<br>$3x = 93$<br>– ដោះស្រាយសមីការ<br>$3x = 93$<br>$\Leftrightarrow x = \frac{93}{3} = 31$<br>ដូចនេះឫសរបស់សមីការគឺ<br>$x = 31$<br><br>ជាទូទៅ៖<br>ដើម្បីដោះស្រាយសមីការចំណោទសមីការដឺក្រេទី1មាន1អញ្ញាត្តិគេត្រូវ៖<br>– សិក្សាប្រធាន | ដូចនេះឫសរបស់សមីការគឺ<br>$\boxed{x = 30}$<br>គេបាន<br>$5x - (7x - 4) = 2$<br>$5x - 7x + 4 = 2$<br>$5x - 7x = 2 - 4$<br>$-2x = -2$<br>$\Leftrightarrow x = 1$<br><br>សិក្សាប្រធាន:<br>គេប្រាប់:បីដងចំនួននោះស្មើនឹង 93<br>គេសួររកចំនួននោះ<br><br>– ជ្រើសរើសអញ្ញាត្តិ: តាងចំនួននោះដោយអក្សរ $x$<br>– សរសេរសមីការគេបាន<br>$3x = 93$<br>– ដោះស្រាយសមីការ<br>$3x = 93$<br>$\Leftrightarrow x = \frac{93}{3} = 31$<br>ដូចនេះឫសរបស់សមីការគឺ<br>$x = 31$<br><br>ជាទូទៅ៖<br>ដើម្បីដោះស្រាយសមីការចំណោទសមីការដឺក្រេទី1មាន1អញ្ញាត្តិគេត្រូវ៖<br>– សិក្សាប្រធាន<br>(គេប្រាប់អ្វី?គេសួររកអ្វី?)<br>– ជ្រើសរើសអញ្ញាត្តិ |

| | | |
|---|---|---|
| | (គេប្រាប់អ្វី?គេសួររកអ្វី?)<br>– ជ្រើសរើសអញ្ញាត្តិ<br>– សរសេរសមិការ<br>– ដោះស្រាយសមីការ<br>– ផ្ទៀងផ្ទាត់ចម្លើយ | – សរសេរសមិការ<br>– ដោះស្រាយសមីការ<br>– ផ្ទៀងផ្ទាត់ចម្លើយ |
| ចំការមួយរាងចតុកោណកែងមានបរិមាត្រស្មើ 376m។ គណនាប្រវែងទទឹងនិងប្រវែងបណ្ដោយ មានបើគេដឹងថាបណ្ដោយមានប្រវែង 28m លើសទទឹង។ | ជំហានទី៤<br>(ពង្រឹងពុទ្ធិ) | គេប្រាប់:បរិមាត្រចតុកោណស្មើនឹង376mនិងណ្ដោយមាន ប្រវែង $28m$ លើសទទឹង។<br>គេសួរ:<br>រកទទឹងនិងបណ្ដោយ<br>– ជ្រើសរើសអញ្ញាត្តិ:<br>– តាងជា $x$ ទទឹងរបស់ ចតុកោណកែងនោះគេបាន ជាប្រវែងបណ្ដោយ<br>– សរសេរសមីការគេបាន<br>$376 = x(28+x)$<br>– ដោះស្រាយសមីការ<br>$376 = 2\times\left[x+(28+x)\right]$<br>$376 = 2(2x+28)$<br>$376 = 4x+28$<br>$4x = 376-64$<br>$x = \frac{376-64}{4} = \frac{312}{4} = 78$<br>ដូចនេះប្រវែងទទឹងគឺ78mនិងប្រវែងបណ្ដោយគឺ106m |
| ជំហានទី៥<br>គ្រូអោយសិស្សធ្វើលំហាត់ប្រតិបត្តិ 2 ទំព័រ98 | ជំហានទី៥<br>(បណ្ដាំផ្ញើ)<br>ធ្វើលំហាត់ប្រតិបត្តិ 2 ទំព័រ98 | សិស្សកត់ត្រាទុកធ្វើផ្ទះ។ |

# កិច្ចតែងការបង្រៀន (គណិតវិទ្យថ្នាក់ទី៧)

មេរៀនទី១០

## វិសមភាព

+ខ្លឹមសារមេរៀន : ១ សញ្ញាណវិសមភាព

ក បន្ទាត់បំនួន

២ លក្ខណៈវិសមភាព

ក ការបូកដកអង្គទាំងពីរនៃវិសមភាពមួយចំនួន

ខ ការប្តូរតួពីរអង្គម្ខាងទៅអង្គម្ខាងទៀតនៃវិសមភាព

៣ ការគុណចែកអង្គទាំងពីរនៃវិសមភាពនិងមួយចំនួន

+រយៈពេល០២ម៉ោង

I.វត្ថុបំណងនៃមេរៀន

-ចំណេះដឹង : ប្រាប់ពីលក្ខណៈវិសមភាព ប្តូរតួពីអង្គម្ខាងទៅអង្គម្ខាង ការគុណរឺចែកអង្គ ទាំងពីរនៃវិសមភាពនឹងមួយចំនួនបានត្រឹមត្រូវ។

-បំណិន : បកស្រាយពីការប្តូរតួពីអង្គម្ខាងទៅអង្គម្ខាងទៀត និងការគុណចែកអង្គ ទាំងពីនឹងមួយចំនួនតាមរយៈឧទាហរណ៍។

-ឥរិយាបថ : មានស្មារតីប្រុងប្រយ័ត្ន យកចិត្តទុកដាក់ស្តាប់គ្រូពន្យល់ ។

II.ពេលវេលា: ថ្ងៃ……………..ទី……………..ខែ…………..ឆ្នាំ………..

III.សម្ភារៈឧបទេស

-សៀវភៅសិស្ស និងសៀវភភៅគ្រូ

-ផ្ទាំងក្រដាសបង្ហាញរូបការេជាត់ពណ៌និងមិនជាត់ពណ៌

IV.ដំណើកនាំមេរៀន

| សកម្មភាពគ្រូ | ខ្លឹមសាមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| -គ្រូត្រួតពិនិត្យវត្តមាន អនាម័យ សណ្តាប់ធ្នាប់និងវិន័យ | ជំហានទី១ (រដ្ឋបាលថ្នាក់)<br>(៥នាទី)<br>-គ្រូពីនិត្យវត្តមាន អនាម័យ សណ្តាប់ធ្នាប់ និង វិន័យ | តំណាងសិស្សឡើងរាយការណ៍ |
| ដាក់សំនួររឺលំហាត់អោយសិស្សដើម្បីរំលឹកមេរៀនចាស់។ | ជំហានទី២ (រំលឹកមេរៀនចាស់)<br>(៥នាទី)<br>ដោះស្រាយសមីការ<br>$(1).\ 5x+2=17$<br>$(2).\ 10x-3=22$ | |

| | | |
|---|---|---|
| | | $(1).\ 5x+2=17$<br>$5x=17-2$<br>$5x=15$<br>$x=15/5=3$<br>$(2).\ 10x-3=22$<br>$x=\frac{22+3}{10}=\frac{5}{2}$ |
| ឲ្យសិស្សសង្កេតឧទាហរណ៍និងពន្យល់បន្ថែមលើឧទាហរណ៍អាចទាញជាទូទៅ<br>– តើ $2>1, -3>-5, -2<1$ គេហៅថាអ្វី?<br><br>**ឧទាហរណ៍** គេមានវិសមភាព<br>$\begin{array}{c}25>10\\ +\\ 5\quad 5\\ \hline 30>15\end{array}$<br><br>$\begin{array}{c}25>10\\ +\\ 5\quad 5\\ \hline 20>5\end{array}$<br><br>– បើចំនួនធំជាង $b$ តើគេអាចសរសេរបានដូចម្តេច?<br>– បើ $c$ តូចជាងរឺស្មើ $d$ តើគេអាចសរសេរបានដូចម្តេច? | <u>ជំហានទី៣</u> (ដំណឹកនាំមេរៀន)<br>(៨០នាទី)<br>មេរៀនទី១០ **វិសមភាព**<br>**១ សញ្ញាណវិសមភាព**<br>**ក បន្ទាត់ចំនួន**<br><br>$2>1; -3>-5\ ; -2<1$ ហៅថាវិសមភាព។<br><br>**២ លក្ខណៈវិសមភាព**<br>**ក ការបូកដកអង្គទាំងពីរនៃវិសមភាពនិងមួយចំនួន**<br><br>-បើ $a$ ធំជាង $b$ នោះគេសរសេរ $a>b$ ឬ $b<a$<br>– បើ $c$ តូចជាងរឺស្មើ $d$ គេសរសេរ $c\le d$ រឺ $d\ge c$ | ផ្តោតអារម្មណ៍ និងយកចិត្តទុកដាក់គ្រូពន្យល់<br>សិស្សគូសរូបចូលក្នុងសៀវភៅ<br>$2>1, -3>-5, -2<1$ គេហៅថាវិសមភាព។<br><br>**ជាទូទៅ** បើគេបូករឺដកអង្គទាំងពីរនៃវិសមភាពគេបានវិសមភាពថ្មីមានទិសដៅដូចវិសមភាពដើម។<br><br>– គេសរសេរ<br>$a>b$ រឺ $b<a$<br>– គេសរសេរ<br>$c\le d\ ,d\ge c$ |

| | | |
|---|---|---|
| | **ជាទូទៅ** កន្សោមលេខពីរដែលនៅសងខាងសញ្ញា $>,<,\geq,\leq$ ហៅថាវិសមភាព។<br>**សំគាល់**<br>$-\ a>b$ និង $c>d$ ជាវិសមភាពមានទិសដៅដូចគ្នា<br>$-a>b\ \&\ c<d$ ជាវិសមភាពមានទិសដៅផ្ទុយគ្នា។<br>**២ ការប្តូរពីអង្គម្ខាងទៅអង្គម្ខាងទៀតនៃវិសមភាព** | **ជាទូទៅ** គេនិយាយថាកន្សោមលេខពីរនៅសងខាងសញ្ញា $>;\geq;<;\leq$ គេហៅថាវិសមភាព។ |
| − គេមាន $a+b>c-d$ បើគេថែម $d-b$ លើអង្គទាំងពីរនៃវិសមភាពគេបានដូចម្តេច?<br>− តើតាមការបកស្រាយខាងលើគេអាចទាញបានយ៉ាងដូចម្តេច? | $a+b>c-d$<br>$a+b+d-b>c-d+d+b$<br>$a+d>c-b$ | $-a+b>c-d$ គេបាន<br>$a+b+d-b>c-d+d-b$<br>$a+d>c-b$<br>តាមការស្រាយបញ្ជាក់ខាងលើគេទាញបាន: ចំពោះវិសមភាពមួយគេអាចលើកតួពីអង្គម្ខាងទៅអង្គម្ខាងទៀតដោយប្តូរសញ្ញា។ |
| **ឧទាហរណ៍** គេមានវិសមភាព $10<20$ បើគេគុណរឺកំចែកអង្គទាំងពីរនឹង $5$ រឺ $-2$ គេបាន លទ្ធផលដូចម្តេច? | **៣ ការគុណចែកអង្គទាំងពីរនៃវិសមភាពមួយចំនួន:**<br>**ជាទូទៅ** បើគេគុណរឺចែកអង្គទាំងពីរនៃវិសមភាពនឹងមួយចំនួនវិជ្ជមានគេបានវិសមភាពថ្មីមានទិសដៅដូចវិសមភាពដើម។<br>$a>b;c>0$ នោះ $a.c>b.c$ រឺ $\frac{a}{c}>\frac{b}{c}$<br>បើគេគុណរឺចែកអង្គទាំងពីរនិងមួយចំនួនអវិជ្ជមានគេបានវិសមភាពថ្មីមានទឹសដៅផ្ទុយពីវិសមភាពដើម។<br>$a>b\ ,c<0$<br>$a.c<b.c$<br>$\frac{a}{c}<\frac{b}{c}$ | គេមាន $10<20$<br>គុណនិង $5$ $10\times5<20\times5$<br>$50<100$<br>ចែកនិង $5$ $\frac{10}{5}<\frac{20}{5}$<br>$2<4$<br>គុណនិង $-2$ $10(-2)>20(-2)$<br>$-20>-40$<br>ចែកនិង $-2$ $\frac{10}{-2}>\frac{20}{-2}$<br>$-5>-10$ |

| | | |
|---|---|---|
| | | |
| ជំនួសតំលៃ $a,b\&c$ រួចបំពេញសញ្ញា $>,<$ ក្នុងប្រអប់<br>ក. $a\square b$ នោះ $a.c\square b.c$<br>បើ $a=-8\,;b=5\,,c=-1$<br>ខ. $a\square b$ នោះ $\frac{a}{c}\square\frac{b}{c}$<br>បើ $a=15\,,b=-5\,,c=5$ | ជំហានទី៤ (ពង្រឹងពុទ្ធិ)<br>(៥នាទី) | ចម្លើយ<br>ក. $a\boxed{<}b$ , $a.c\boxed{>}b.c$<br>ខ. $a\boxed{>}b$ , $\frac{a}{c}\boxed{>}\frac{b}{c}$ |
| -គ្រូដាក់លំហាត់ទទំព័រ១០៦។ ឲ្យសិស្សធ្វើនៅផ្ទះនិងណែនាំសិស្សឲ្យគោរពវិន័យនិងច្បាប់ចរាចរណ៍ | ជំហានទី៥ (កិច្ចការផ្ទះ)<br>(៥នាទី)<br>លំហាត់ទំព័រ១០៦ | សិស្សកត់ត្រាលំហាត់និងស្តាប់ដំបូន្មានគ្រូ |

## កិច្ចតែងការបង្រៀន

១. សម្រាប់បង្រៀនសិស្សថ្នាក់ទី៧

២. មេរៀន: ផលធៀប និងសមាមាត្រ

៣. រយះពេល: ២ម៉ោង

៤. វត្ថុបំណង សិស្សអាច:

-បកស្រាយបរិមាណពីរដោយប្រើផលធៀប។

-ដោះស្រាយចំណោទដោយប្រើផលធៀបសមាមាត្របានត្រឹមត្រូវ។

-អនុវត្តក្នុងការដោះដូរវត្ថុផ្សេងក្នុងជីវភាពរស់នៅ។

៥. សម្ភារះ ក្រដាសកម្រងលំហាត់ បន្ទាត់ ។

៦. ដំណើរការបង្រៀន

| សកម្មភាពគ្រូ | ខ្លឹមសារ | សកម្មភាពសិស្ស |
|---|---|---|
| ពិនិត្យវត្តមានសិស្ស | **រដ្ឋបាលថ្នាក់** | តំណាងសិស្សឡើងរាយការណ៍ |
| តើគេតាងបរិមាណពីរដែលមានឯកតាដូចគ្នាយ៉ាងដូចម្តេច? | **រំលឹកមេរៀន**<br>$a:b$ រឺ $\frac{a}{b}$ | $a:b$ រឺ $\frac{a}{b}$ |

| | | |
|---|---|---|
| អោយសិស្សសង្កេតឧទាហរណ៍ រួចតាងផលធៀប។<br><br>អោយសិស្សដោះស្រាយលំហាត់គំរូ | **មេរៀនថ្មី**<br>**១ ផលធៀបនៃបរិមាណពីរ**<br>ឧទាហរណ៍ គេប្រៀបធៀបកម្ពស់សត្វឆ្កែ និងខ្លា។ការប្រៀបធៀបបរិមាណទាំងពីរនេះ 2cm លើ3cm អាចសរសេរជាទម្រង់ 2:3 អានថា"ពីរលើបី"។<br>ផលធៀបនេះគេអាចសរសេរជាប្រភាគ $\frac{2}{3}$ ។<br>ដូចនេះ គេអាចប្រៀបធៀបបរិមាណពីដែលមានឯកតាដូចគ្នា។<br>ជាទូទៅ ផលធៀបនៃ a និង b ដែល a,bជាចំនួនគត់(b#0) ហើយតាងបរិមាណពីរដែលមានឯកតាដូចគ្នា គេអាចសរសេរជាទម្រង់ $a:b$ រឺ $\frac{a}{b}$<br>លំហាត់គំរូ នៅក្នុងថ្នាក់ទី 7 មានសិស្ស45នាក់ ក្នុងនោះមានស្រី 15 នាក់។រកផលធៀបសិស្សប្រុស និងសិស្សស្រី។ | សិស្សសង្កេត រួចទាញជាទូទៅ<br><br>ជាទូទៅ ផលធៀបនៃ a និង b ដែល a,bជាចំនួនគត់(b#0) ហើយតាងបរិមាណពីរដែលមានឯកតាដូចគ្នា គេអាចសរសេរជាទម្រង់ $a:b$ រឺ $\frac{a}{b}$<br><br>ចម្លើយ 30:15 រឺ $\frac{30}{15}=\frac{2}{1}$ |

| | | |
|---|---|---|
| ដើម្បីអោយដឹងថាផលធៀបណាខ្លះសមាមូលគ្នា គេត្រូវធ្វើដូចម្តេច?<br><br>អោយសិស្សដោះស្រាយលំហាត់ឧទាហរណ៍ | ចម្លើយ 30:15 រឺ $\frac{30}{15}=\frac{2}{1}$<br><br>**២ ផលធៀបសមាមូល**<br><br>ដើម្បីអោយដឹងថាផលធៀបណាខ្លះសមាមូលគ្នា គេត្រូវសរសេរផលធៀបទាំងនោះជាទម្រង់ $\frac{a}{b}$ បន្ទាប់មកជ្រើសរើសយកប្រភាគណាដែលសមាមូលគ្នា។<br><br>សម្គាល់<br><br>. លំដាប់ក្នុងការសរសេរផលធៀបមានសារៈសំខាន់ណាស់។<br><br>.ផលធៀបគ្មានខ្នាតទេ។<br><br>.ផលធៀបអាចប្រើដើម្បីធ្វើការប្រៀបធៀបបរិមាណច្រើនជាងពីរ។<br><br>ឧទាហរណ៍ បុរសបីនាក់ A, B និងC បានចែកប្រាក់ចំនេញគ្នាក្នុងការរកស៊ីហ៊ុនគ្នាមួយ។ពួកគេទទួលបានប្រាក់ $4000, $3000 និង$1000 រៀងគ្នា។<br><br>ផលធៀបចំណែកប្រាក់ចំនេញ | ដើម្បីអោយដឹងថាផលធៀបណាខ្លះសមាមូលគ្នា គេត្រូវសរសេរផលធៀបទាំងនោះជាទម្រង់ $\frac{a}{b}$ បន្ទាប់មកជ្រើសរើសយកប្រភាគណាដែលសមាមូលគ្នា។<br><br>ផលធៀបចំណែកប្រាក់ចំនេញរបស់ពួកគេគឺ : |

| | | |
|---|---|---|
| តើអត្រាជាអ្វី? | របស់ពួកគេគឺ : 4000:3000:1000<br>រឺ 4:3:1<br>**៣ អត្រានិងល្បឿនមធ្យម**<br>**៣១ អត្រា**<br>ប្រភាគនីមួយៗ ខុសគ្នាពីផល ធៀបដោយវាទាក់ទងនិង បរិមាណពីរប្រភេទដែលមានឯក តាខុសគ្នា។ប្រភាគនីមួយៗនេះ ហៅថា អត្រា។<br>សម្គាល់ គេប្រើនិម្មិតសញ្ញា"/" ដើម្បីបញ្ជាក់ពីអត្រា។<br>**៣២ ល្បឿនមធ្យម**<br>ជាទូទៅ<br>ល្បឿនមធ្យម=ចម្ងាយចរ/រយះពេល<br>រឺ $V=\frac{d}{t}$ ដែល V ជាល្បឿនមធ្យម<br>d ជាចម្ងាយចរ | 4000:3000:1000<br>រឺ 4:3:1<br>ប្រភាគនីមួយៗ ខុសគ្នាពីផល ធៀបដោយវាទាក់ទងនិង បរិមាណពីរប្រភេទដែលមានឯក តាខុសគ្នា។ប្រភាគនីមួយៗនេះ ហៅថា អត្រា។<br>ជាទូទៅ<br>ល្បឿនមធ្យម=ចម្ងាយចរ/រយះពេល<br>រឺ $V=\frac{d}{t}$ ដែល V ជាល្បឿនមធ្យម<br>d ជាចម្ងាយចរ<br>t ជារយះពេល |

| | | |
|---|---|---|
| អោយសិស្សដោះស្រាយលំហាត់គំរូ | t ជារយៈពេល<br><br>ជាទូទៅ<br><br>ចម្ងាយចរ=ល្បឿនមធ្យម ×រយៈពេលចរ រឺ $d = v \times t$<br><br>លំហាត់គំរូ រថភ្លើងមួយធ្វើដំនើរដោយល្បឿនមធ្យម 15m/s។<br><br>ក រករយៈពេលដែលរថភ្លើងចរក្នុងចម្ងាយផ្លូវ 750m។<br><br>ខ បើរថភ្លើងនោះធ្វើដំណើរពីស្ថានីយ A នៅម៉ោង៨ព្រឹក។តើរថភ្លើងនោះ ទៅដល់ស្ថានីយ B នៅម៉ោងប៉ុន្មាន? បើពី A ទៅ B មានចម្ងាយឃ្លាតពីគ្នា 36km។<br><br>ចម្លើយ<br><br>ក $t = \frac{d}{v} = \frac{750}{15} = 50$<br><br>ខ<br>$t = \frac{d}{v} = \frac{36000}{15} = 2400s = 40mn$ | ជាទូទៅ<br><br>ចម្ងាយចរ=ល្បឿនមធ្យម ×រយៈពេលចរ រឺ $d = v \times t$<br><br>ចម្លើយ<br><br>ក $t = \frac{d}{v} = \frac{750}{15} = 50$<br><br>ខ<br>$t = \frac{d}{v} = \frac{36000}{15} = 2400s = 40mn$ |

| | | |
|---|---|---|
| រករូបមន្តល្បឿនមធ្យម?<br>រករូបមន្តចម្ងាយចរ? | **ពង្រឹងពុទ្ធិ** | $V=\frac{d}{t}$<br>$d=v\times t$ |
| ដាក់កិច្ចការផ្ទះ | **បណ្ដាំផ្ញើ**<br>លំហាត់ 11, 12, និង13 ទំព័រ ១១៦ សៀវភៅសិស្ស | សិស្សកត់កិច្ចការផ្ទះ |

## កិច្ចតែងការបង្រៀន

១. សម្រាប់បង្រៀនសិស្សថ្នាក់ទី៧

២. មេរៀន: ផលធៀប និងសមាមាត្រ

៣. រយះពេល: ២ម៉ោង

៤. វត្ថុបំណង សិស្សអាច:

-បកស្រាយសមាមាត្រស្រប និងសមាមាត្រច្រាសបានត្រឹមត្រូវ។

-ដោះស្រាយចំណោទដោយប្រើផលធៀបសមាមាត្រច្រាស និងសមាមាត្រស្របបានត្រឹមត្រូវ។

-សហាការដោះស្រាយលំហាត់ដោយស្មារតីយោគយល់។

៥. សម្ភារះ ក្រដាសកម្រងលំហាត់ បន្ទាត់ ។

៦ ដំណើរការបង្រៀន

| សកម្មភាពគ្រូ | ខ្លឹមសារ | សកម្មភាពសិស្ស |
|---|---|---|
| ពិនិត្យវត្តមានសិស្ស | **រដ្ឋបាលថ្នាក់** | តំណាងសិស្សឡើងរាយការណ៍ |
| តើផលធៀបសមាមាត្រជាអ្វី? | **រំលឹកមេរៀន**<br>ជាការប្រៀបធៀបបរិមាណពីរដែលមានបរិមាណពីរស្មើគ្នា។ | ជាការប្រៀបធៀបបរិមាណពីរដែលមានបរិមាណពីរស្មើគ្នា។ |
| អោយបញ្ញាត្តិជាទូទៅ | **មេរៀនថ្មី**<br>៤ សមាមាត្រ<br>៤ ១ សមាមាត្រស្រប<br>ជាទូទៅ $a_1$ និង $a_2$ ជាពីរចំនួន | ជាទូទៅ $a_1$ និង $a_2$ ជាពីរចំនួនខុសពីសូន្យដែល $a_1+a_2 \neq 0$ |

| | | |
|---|---|---|
| | ខុសពីសូន្យដែល $a_1+a_2 \neq 0$<br>បើ $\frac{b_1}{a_1}=\frac{b_2}{a_2}$ នោះគេបាន<br>$\frac{b_1}{a_1}=\frac{b_2}{a_2}=\frac{b_1+b_2}{a_1+a_2}$ ។<br>ដូចគ្នាដែរ $a_1, a_2, a_3$ ជាបីចំនួនខុសពីសូន្យដែល $a_1+a_2+a_3 \neq 0$<br>បើ $\frac{b_1}{a_1}=\frac{b_2}{a_2}=\frac{b_3}{a_3}$ នោះគេបាន<br>$\frac{b_1}{a_1}=\frac{b_2}{a_2}=\frac{b_3}{a_3}=\frac{b_1+b_2+b_3}{a_1+a_2+a_3}$ ។ | បើ $\frac{b_1}{a_1}=\frac{b_2}{a_2}$ នោះគេបាន<br>$\frac{b_1}{a_1}=\frac{b_2}{a_2}=\frac{b_1+b_2}{a_1+a_2}$ ។<br>ដូចគ្នាដែរ $a_1, a_2, a_3$ ជាបីចំនួនខុសពីសូន្យដែល $a_1+a_2+a_3 \neq 0$<br>បើ $\frac{b_1}{a_1}=\frac{b_2}{a_2}=\frac{b_3}{a_3}$ នោះគេបាន<br>$\frac{b_1}{a_1}=\frac{b_2}{a_2}=\frac{b_3}{a_3}=\frac{b_1+b_2+b_3}{a_1+a_2+a_3}$ ។ |
| អោយសិស្សដោះស្រាយលំហាត់គំរូ | លំហាត់គំរូ រកថ្លៃនំ 13kg បើនំ6kg ថ្លៃ 90 000 រៀល។<br>ចម្លើយ<br>នំ 13kg ថ្លៃ 195 000រៀល។ | នំ 13kg ថ្លៃ 195 000រៀល។ |
| សិស្សសង្កេតលំហាត់គំរូ | ៤ ២ សមាមាត្រច្រាស<br>លំហាត់គំរូ បុរស 10 នាក់អាចជីកលាណដ្ឋានមួយហើយក្នុងរយៈពេល 4 ម៉ោង។បើបុរស 5 នាក់ជីកលេណដ្ឋានដដែលនេះតើត្រូវប្រើពេលប៉ុន្មានទើបហើយ។<br>ចម្លើយ | |

| | | |
|---|---|---|
| | បុរស 5 នាក់ប្រើរយៈពេល 8 ម៉ោងទើបជីកលេណដ្ឋានហើយ។ | បុរស 5 នាក់ប្រើរយៈពេល 8 ម៉ោងទើបជីកលេណដ្ឋានហើយ។ |
| សិស្សឡើងដោះស្រាយលំហាត់ | **ពង្រឹងពុទ្ធិ**<br>លំហាត់ គេអោយ a:b:c=3:5:9 និង c-a=72។រកតម្លៃនៃ a+b+c ។ | a+b+c=204 |
| ដាក់កិច្ចការផ្ទះ | **បណ្តាំផ្ញើ**<br>លំហាត់ 14, 15, 16 និង17 ទំព័រ 116 សៀវភៅសិស្ស | សិស្សកត់ត្រាកិច្ចការផ្ទះ |

# កិច្ចតែងការបង្រៀន

*មុខវិជ្ជា: គណិតវិទ្យា ថ្នាក់ទី ៧*

*ថ្ងៃ............ទី...........ខែ............ឆ្នាំ..........*

I.*ចំណងជើងមេរៀន:* មេរៀនទី ១២ សញ្ញាណដំបូងនៃរូបធរណីមាត្រ

*ចំណងជើងរង:* ១. សញ្ញាណរូបធរណីមាត្រ

១.១ សញ្ញាណទូទៅនៃរូបធរណីមាត្រ

១.២ ចំណុច

១.៣ បន្ទាត់

II.*វត្ថុបំណង:* ក្រោយពីរៀនចប់មេរៀននេះចប់សិស្សអាច

-ចំណេះដឹង: សិស្សប្រាប់ពីសញ្ញាណរូបធរណីមាត្រ ចំណុច និងបន្ទាត់បានតាមរយៈ ឧទាហរណ៍បានត្រឹមត្រូវ ។

-បំណិន: សិស្សកំណត់បានពីសញ្ញាណរូបធរណីមាត្រ ចំនុច និងបន្ទាត់តាមរយៈ ប្រតិបត្តិបានត្រឹមត្រូវ ។

-ឥរិយាបថ: សិស្សមានស្មារតីចូលរួមចែករំលែកការលំបាករវាងគ្នា និងគ្នា ។

III.*ពេលវេលា* ០២ ម៉ោង

IV. *សម្ភារ:ឧបទេស*

- រូបប្រលេពីប៉ែតកែង ស៊ីឡាំង ពីរ៉ាមីត និងបន្ទាត់ ។
- ស.ស ទំព័រទី ១១៧ ដល់ទំព័រទី ១១៩ បោះពុម្ពឆ្នាំ.............

V. *ដំណើរការមេរៀន:*

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាព |
|---|---|---|
| គ្រូតពិនិត្យ អវត្តមាន អនាម័យ និង<br>សណ្តាប់ធ្នាប់ វិន័យ | <u>ជំហានទី</u> ១ (រដ្ឋបាលថ្នាក់) | តំនាងថ្នាក់ឡើងរាយការណ៍ |
| តើធុងសាំងមានជាអ្វី?<br>តើប្រអប់ដីសមានរាងជាអ្វី? | <u>ជំហានទី</u> ២ (រំលឹកចាស់) | ធុងសាំងមានរាងជាស៊ីឡាំង<br>ប្រអប់ដីសមានជាងជាគូប |

| | | |
|---|---|---|
| គ្រូសរសេរចំណងជើងមេរៀនដាក់លើក្ដាខៀន<br>.គ្រូលើកឧទាហរណ៍ដោយគូសរូបធរណីមាត្រឲ្យសិស្សសង្កេតហើយប្រាប់ឈ្មោះនៃរូបធរណីមាត្រនោះ<br><br>-គ្រូប្រាប់សិស្សពីចំណុច<br>-បើយើងយកបិចទៅចុចលើក្រដាសនោះគេបានស្នាមមូលមួយខ្សាច់មួយគ្រាប់ ។រូបភាពទាំងនោះហៅថាចំនុច ។<br>គ្រូដាក់ឧទាហរណ៍ពីការតាងចំនុច:<br>. A គេហៅថាចំនុច A<br>+ B គេហៅថាចំនុច B<br> ចំនុច C | <u>ជំហានទី</u> ៣ (មេរៀនប្រចាំថ្ងៃ)<br>មេរៀនទី១២<br>សញ្ញាណរូបធរណីមាត្រ<br>១. សញ្ញាណរូបធរណីមាត្រ<br>១.១<br>សញ្ញាណទូទៅនៃរូបធរណីមាត្រ<br>ក) <br>ប្រលេពីប៉ែតកែង<br>ខ) <br>ស៊ីឡាំង<br>១.២ ចំណុចសំគាល់<br>-ចំណុច គ្មានវិមាត្រ គ្មានទទឹង គ្មានបណ្ដោយ គ្មានកំពស់ទេ ។<br>-ចំណុចជារូបធាតុតូចបំផុត គេហៅថា ភាវៈធរណីមាត្រងាយជាងគេ ។<br>. A គេហៅថាចំនុច A<br>+ B គេហៅថាចំនុច B<br> ចំនុច C<br> | <br>សិស្សសង្កេតមើលរួចឆ្លើយ<br><br>ក) ហៅថា ប្រលេពីប៉ែតកែង<br><br>ខ) ហៅថាស៊ីឡាំង<br><br>សិស្សសង្កេតស្ដាប់គ្រូពន្យល់<br><br>សិស្សដៅចំនុច<br>. A គេហៅថាចំនុច A<br>+ B គេហៅថាចំនុច B<br> ចំនុច C<br> |

| | | |
|---|---|---|
| Exលោកគ្រូបានឲ្យសិស្សយកដើមផ្កាចំនួន ៦ដើមទៅដាំឲ្យបាន ៤ ជួរដែលក្នុងមួយជួរ ៗមាន៣ ដើម ។តើត្រូវដាំរបៀបណា ?<br>ដៅចំនុចដែលត្រូវ ដាំ ?<br>បើគេរំកិលចុងប៊ិចនៅលើក្រដាស គេបានរូបភាពមួយហៅថាអ្វី ?<br><br>Ex តាមពីរចំនុចផ្សេងគ្នា A និង B គេអាចគូសបន្ទាត់បានតែមួយគត់ ។<br>គេកំណត់សរសេរបន្ទាត់ AB ។គេអាចបន្លាយ ABបានទាំងសងខាងព្រោះបន្ទាត់គ្មានព្រំដែន ។<br>Ex<br>រូបខាងក្រោមតាងអោយបន្ទាត់ $d$ និងចំនុច $A,B,C,E,H$ ។<br>តើចំនុចណាខ្លះជារបស់បន្ទាត់ $d$ និងមិនមែនជារបស់បន្ទាត់ $d$ ?<br><br> | ១.៣ បន្ទាត់<br>-បន្ទាត់$(d)$<br>$(d)$<br>សំគាល់: បន្ទាត់គ្មានកំពស់ គ្មានទទឹងតែគេអាចនិយាយពីបណ្តោយបាន ។<br>បន្ទាត់ជាភាវៈធរណីមាត្រដែលមានវិមាត្រមួយ ។<br>ស្វ័យសត្យ:<br>តាមចំនុចមួយគេអាចគូសបន្ទាត់បានច្រើនរាប់មិនអស់ ។<br>-តាមពីរចំនុចផ្សេងគ្នា គេអាចគូសបាន<br>បន្ទាត់តែមួយគត់ ឬ បន្ទាត់ច្រើនរាប់មិនអស់តែត្រួតស៊ីគ្នា ។<br><br><br>ចំនុច $A,B,C,E$ ស្ថិតនៅលើបន្ទាត់ $d$<br>តែមួយ គេថា $A,B,C,E$ រត់ត្រង់គ្នា ។<br>ចំនុច $H$ មិនស្ថិតនៅលើបន្ទាត់ $d$ ទេ ។ | ហៅថាបន្ទាត់$(d)$<br>$(d)$<br><br>សិស្សសង្កេត និងស្តាប់គ្រូពន្យលដោយយកចិត្តទុកដាក់<br><br><br>ចំនុច $A,B,C,E$ ស្ថិតនៅលើបន្ទាត់ $d$ តែមួយ គេថា $A,B,C,E$ រត់ត្រង់គ្នា ។<br>គេសរសេរ<br>$A\in d, B\in d, C\in d, E\in d$<br>។ចំនុច $H$<br>មិនស្ថិតនៅលើបន្ទាត់ $d$ ទេ ។គេសរសេរ $H\notin d$ ។ |
| -ដើម្បីកំនត់កន្លះបន្ទាត់មួយ តើគេត្រូវធ្វើដូចម្តេច ? | ជំហានទី ៤ (ពង្រឹងចំនេះដឹង)<br>-សរសេរគល់មុន | -ដើម្បីកំនត់កន្លះបន្ទាត់មួយ គេត្រូវសរសេរ គល់ មុន ។ |

| | | |
|---|---|---|
| -បើបន្ទាត់ $d$ មួយស្ថិតនៅក្នុងប្លង់ $(p)$ តើគ្រប់ចំនុចនៃបន្ទាត់ $d$ ស្ថិតនៅក្នុងប្លង់ $(p)$ ដែរ ឬ ទេ ? | -គ្រប់ចំនុចនៃបន្ទាត់ $d$ ស្ថិតនៅក្នុងប្លង់តែមួយ ។ | -បើបន្ទាត់ $d$ មួយស្ថិតនៅក្នុងប្លង់ $(p)$ គ្រប់ចំនុចនៃបន្ទាត់ $d$ ស្ថិតនៅក្នុងប្លង់ $(p)$ ដែរ ។ |
| គ្រូដាក់លំហាត់ ទី៣ ទំព័រ ១២៦ អោយសិស្សធ្វើនៅផ្ទះ និងណែនាំសិស្សឲ្យគោរពវិន័យ និងច្បាប់ចរាចរណ៍ ។ | <u>ជំហានទី</u> ៥ (កិច្ចការផ្ទះ) លំហាត់ទី ៣ ទំព័រ ១២៦ | សិស្សកត់ត្រាលំហាត់ និងស្តាប់ ដំបូន្មានគ្រូ |

# កិច្ចតែងការបង្រៀន

*មុខវិជ្ជា: គណិតវិទ្យា ថ្នាក់ទី ៧*

I.*ចំណងជើងមេរៀន:* មេរៀនទី ១២ សញ្ញាណដំបូងនៃរូបធរណីមាត្រ (ត)

*ចំណងជើងរង:* ១.៤ កន្លះបន្ទាត់

១.៥ ប្លង់

II.*វត្ថុបំណង:* ក្រោយពីរៀនចប់មេរៀននេះចប់សិស្សអាច

-ចំណេះដឹង: សិស្សប្រាប់ពីកន្លះបន្ទាត់ និង ប្លង់ តាមរយៈ ឧទាហរណ៍បានត្រឹមត្រូវ ។

-បំណិន: សិស្សកំណត់បានពីកន្លះបន្ទាត់

និងប្លង់តាមរយៈឧទាហរណ៍លំហាត់ប្រតិបត្តិបានត្រឹមត្រូវ ។

-ឥរិយាបថ: សិស្សមានស្មារតីចូលរួមចែករំលែកការលំបាករវាងគ្នា និងគ្នា ។

III.*ពេលវេលា* ០២ ម៉ោង ថ្ងៃ..........ទី..........ខែ...........ឆ្នាំ២០......

IV. *សម្ភារៈឧបទេស*

- បន្ទាត់ក្រិត និងបន្ទាត់ ។
- ស.ស ទំព័រទី ១១៧ ដល់ទំព័រទី ១១៩ បោះពុម្ពឆ្នាំ.............

V. *ដំណើកនាំមេរៀន:*

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាព |
|---|---|---|
| គ្រូតពិនិត្យ អវត្តមាន អនាម័យ និង សណ្តាប់ធ្នាប់ វិន័យ | <u>ជំហានទី</u> ១ (រដ្ឋបាលថ្នាក់) | តំនាងថ្នាក់ឡើងរាយការណ៍ |
| -តាមពីរចំនុចគេអាចគូសបន្ទាត់បានប៉ុន្មាន ?<br>-ដូចម្តេចដែលហៅថា ចំនុច ? | <u>ជំហានទី</u> ២ (រំលឹកចាស់)<br>-បានតែមួយគត់ ឬច្រើនរាប់មិនអស់តែត្រូតស៊ីគ្នា ។<br>-ចំនុចជាធាតុតូចបំផុត គេហៅថាភាវៈធរណីមាត្រតូចជាងគេ ។ | -បានតែមួយគត់ ឬច្រើនរាប់មិនអស់តែត្រូតស៊ីគ្នា ។<br>-ចំនុចជាធាតុតូចបំផុតគេហៅថាភាវៈធរណីមាត្រតូចជាងគេ ។ |
| គ្រូសរសេរចំណាងជើងមេរៀនដាក់ | <u>ជំហានទី</u> ៣ (មេរៀនប្រចាំថ្ងៃ)<br>មេរៀនទី១២ | |

| | | |
|---|---|---|
| លើក្តាខៀន<br>.គ្រូលើកឧទាហរណ៍អោយសិស្សសង្កេត និងឆ្លើយ<br>ឧទាហរណ៍: គេមានបន្ទាត់ $xy$ មួយមានចំនុច $M$ មួយដែល<br>$M \in xy$<br>$x$ ——— M ——— $y$<br>-តើចំនុច $M$ ចែកបន្ទាត់ $xy$ ជាប៉ុន្មានផ្នែក ?<br>-ផ្នែកនិមួយ ៗហៅថាអ្វី ? ហើយគេសរសេរដូចម្តេច ?<br>-ចំនុច $M$ ហៅថាអ្វីនៃកន្លះបន្ទាត់ ? | សញ្ញាណរូបធរណីមាត្រ<br>១.៤កន្លះបន្ទាត់<br>-ចំនុច $M$ ចែកបន្ទាត់បន្ទាត់ $xy$ ជាពីរផ្នែកគឺ $Mx$ និង $My$ ។<br>-ផ្នែកនិមួយ ៗហៅថាកន្លះបន្ទាត់ហើយគេសរសេរកន្លះបន្ទាត់ $Mx$ និង $My$<br>-ចំនុច $M$ ហៅថាគល់នៃកន្លះបន្ទាត់<br>សំគាល់<br>-ដើម្បីកំនត់កន្លះបន្ទាត់មួយគេត្រូវសរសេរ (គល់) មុន ។<br>-កន្លះបន្ទាត់ $Mx$ និង $My$ ហៅថាកន្លះបន្ទាត់ឈមគ្នា ។<br>-កន្លះបន្ទាត់មានព្រំដែនតែម្ខាងទេ ។ | $x$ ——— M ——— $E$<br>-ចំនុច $M$ ចែកបន្ទាត់បន្ទាត់ $xy$ ជាពីរផ្នែកគឺ $Mx$ និង $My$ ។<br>-ផ្នែកនិមួយៗហៅថាកន្លះបន្ទាត់ហើយគេសរសេរកន្លះបន្ទាត់ $Mx$ និង $My$<br>-ចំនុច $M$ ហៅថាគល់នៃកន្លះបន្ទាត់។ |
| Ex សរសេរកន្លះបន្ទាត់តាមរូបខាងក្រោម ៖<br>$x$ ——— $A$ ——— $D$ ——— $y$<br>Exគេមានបន្ទាត់ $AB$ និង $EF$ ប្រសព្វគ្នាត្រង់ចំនុច $O$ ។ គូសរូប និងសរសេរឈ្មោះកន្លះទាំងនោះ ? | | សរសេរកន្លះបន្ទាត់តាមរូប<br>$x$ ——— $A$ ——— $D$ ——— $y$<br>កន្លះបន្ទាត់ $Ax, Ay, Dx$ និង $Dy$<br>-គូសរូប និងសរសេរកន្លះបន្ទាត់ |

| | | |
|---|---|---|
| គ្រូដាក់លំហាត់ប្រតិបត្តិអោយសិស្សធ្វើជាដៃគូ<br>ប្រតិបត្តិ ពិនិត្យមើលរូបខាងក្រោម<br><br>-តាមរូបខាងលើតើមានកន្លះបន្ទាត់ប៉ុន្មាន ?សរសេរឈ្មោះកន្លះបន្ទាត់ទាំងនោះ ?<br>គ្រូប្រាប់សិស្ស<br>គេឃើញថាផ្ទៃរាបស្មើនៅជុំវិញខ្លួនយើងដូចជាផ្ទៃជញ្ជាំង ផ្ទៃតុ ឬក្រដាសមួយសន្លឹកជាសញ្ញាណនៃប្លង់ ។<br>ឧទាហរណ៍: បើគេមានបន្ទាត់ $xy$ ចែកប្លង់ $p$ ជាពីរផ្នែកគឺ I និង II ដូចរូបខាងក្រោម:<br>-តើផ្នែក (I) និង (II) ហៅថាអ្វី ?<br>-តើបន្ទាត់ $xy$ ហៅថាអ្វី ?<br>ឧទាហរណ៍២ ចូរប្អូនរកឧទាហរណ៍នៅជុំវិញខ្លួនដែលឲ្យរូបភាពប្លង់?<br>ឧទាហរណ៍៣ បើគេរំកិលផ្ទាំងគំរូមួយលើតុ តើគេសង្កេតឃើញផ្ទៃទាំងពីរនោះយ៉ាងដូចម្តេច ? | មានកន្លះបន្ទាត់ ៨ គឺ $Ax, Ay, Bx, By, Cx, Cy, Dx$ និង $Dy$ ។<br>១.៥ ប្លង់<br>សំគាល់ បើបន្ទាត់ $d$ នៅក្នុងប្លង់( $p$ )<br>មានន័យថា គ្រប់ចំនុចទាំងអស់នៃបន្ទាត់ $d$ ក៏ស្ថិតនៅក្នុងប្លង់( $p$ ) ដែរ ។<br><br><br><br> | <br><br>កន្លះបន្ទាត់ $OA, OB, OE$ និង $OE$<br><br>មានកន្លះបន្ទាត់ ៨ គឺ $Ax, Ay, Bx, By, Cx, Cy, Dx$ និង $Dy$ ។<br>សិស្សសង្កេត និងស្តាប់ដោយយកចិត្តទុកដាក់ ។<br>-ផ្ទៃក (I) និង (II) ហៅថាកន្លះបន្ទាត់<br>-បន្ទាត់ $xy$ ជាព្រំដែនរួមនៃកន្លះប្លង់ទាំងពីរ<br>-រូបភាពប្លង់នៅជុំវិញខ្លួនមានដូចផ្ទៃទឹកនៅនឹងថ្កល់ ផ្ទៃក្តាខៀន |

| | | |
|---|---|---|
| ចូរធ្វើការសន្និដ្ឋាន ?<br>-ដាក់ប្រតិបត្តិឲ្យសិស្សពិភាក្សា<br>ជំនួស...............ខាងក្រោម<br>ដោយសញ្ញា $\in$ ឬ $\notin$<br><br><br>ក. $A........(d)$ ខ. $F........(d)$<br>គ. $D........(d)$ ឃ. $B........(d)$<br>ង. $E........(d)$ ច. $C........(d)$ | ក. $A.....\in...(d)$ ខ.<br>$F.....\notin...(d)$<br>គ. $D....\notin....(d)$ ឃ.<br>$B.....\in...(d)$<br>ង. $E....\in....(d)$ ច.<br>$C...\in.....(d)$ | ផ្ទៀតផ្ទាត់.........<br>-គេឃើញវាត្រូវគ្នាជានិច្ច<br>-<br>ដូចនេះប្លង់អាចរំកិលលើខ្លួនឯង<br><br><br>ក. $A.....\in...(d)$ ខ<br>$F.....\notin...(d)$<br>គ. $D....\notin....(d)$ ឃ<br>$B.....\in...(d)$<br>ង. $E....\in....(d)$ ច<br>$C...\in.....(d)$ |
| ជំនួស...............ខាងក្រោម<br>ដោយសញ្ញា $\in$ ឬ $\notin$<br><br><br>ក. $a........(d)$ ខ. $f........(d)$<br>គ. $b........(d)$ ឃ. $c........(d)$ | <u>ជំហានទី ៤</u> (ពង្រឹងចំណេះដឹង)<br>- ក. $a....\in....(d)$ ខ<br>$f....\notin....(d)$<br>គ. $b.....\in...(d)$ ឃ. $c...\in.....(d)$ | ក. $a....\in....(d)$ ខ<br>$f....\notin....(d)$<br>គ. $b.....\in...(d)$ ឃ.<br>$c...\in.....(d)$ |
| ពេលប្អូនទៅដល់ផ្ទះវិញធ្វើលំហាត់ទី១ និង ទី២ នៅទំព័រទី១២៦ និងជួយធ្វើការឪពុកម្តាយផង ។ | <u>ជំហានទី ៥</u> (កិច្ចការផ្ទះ)<br>លំហាត់ទី ១ និងទី ២ទំព័រ ១២៦ | សិស្សកត់ត្រាលំហាត់ និងស្តាប់ដំបូន្មានគ្រូ |

# កិច្ចតែងការបង្រៀន

*មុខវិជ្ជា: គណិតវិទ្យា ថ្នាក់ទី៧*

*ថ្ងៃ..............ទី........ខែ.......ឆ្នាំ..........*

I.*ចំណងជើងមេរៀន:* មេរៀនទី ១២ សញ្ញាណដំបូងនៃរូបធរណីមាត្រ

*ចំណងជើងទេ:* ២.អង្កត់

២.១ សំណង់អង្កត់

២.២ ប្រៀបធៀបអង្កត់ពីរ

II.*វត្ថុបំណង:* ក្រោយពីរៀនចប់មេរៀននេះចប់សិស្សអាច

-ចំណេះដឹង: សិស្សប្រាប់ពីរបៀបសង់អង្កត់ និងប្រៀបធៀបអង្កត់ពីរ បានតាមរយ:ឧទាហរណ៍គំរូ ។

-បំណិន: សិស្សប្រតិបត្តិបានពីការសង់អង្កត់ និងប្រៀបធៀបអង្កត់ពីរបាន តាមរយ:លំហាត់ប្រតិបត្តិ

-ឥរិយាបថ: សិស្សមានស្មារតីចូលរួមចែករំលែកការលំបាករវាងគ្នា និងគ្នា ។

III.*ពេលវេលា* ០២ ម៉ោង

IV. *សម្ភារ:ឧបទេស:*

- បន្ទាត់ បន្ទាត់ក្រិត ដែកឈាន និងផ្ទាំងរូបភាព ។

V. *ដំណើកនាំមេរៀន:*

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាព |
|---|---|---|
| គ្រូតពិនិត្យ អវត្តមាន អនាម័យ និងសណ្តាប់ធ្នាប់ វិន័យ | ជំហានទី ១ (រដ្ឋបាលថ្នាក់) | តំនាងថ្នាក់ឡើងរាយការណ៍ |
| -ដើម្បីកំណត់កន្លះបន្ទាត់មួយ តើគេត្រូវធ្វើដូចម្តេច ?<br>ចូរប្អូនរកឧទាហរណ៍នៅជុំវិញខ្លួនដែលឲ្យរូបភាពប្លង់ ? | ជំហានទី ២ (រំលឹកចាស់) | -គេត្រូវសរសេរ គល់ ជាមុន ។<br>-រូបភាពប្លង់ដែលនៅជុំវិញខ្លួនយើងមាន: ផ្ទៃក្តារខៀន ផ្ទៃកញ្ចក់ផ្ទៃជញ្ជាំង ។ |

| | ជំហានទី ៣ (មេរៀនប្រចាំថ្ងៃ) | សិស្សសង្កេត និងកត់ត្រា |
|---|---|---|
| គ្រូសរសេរចំណងជើងមេរៀនដាក់លើក្តាខៀន<br>.គ្រូដាក់ឧទាហរណ៍រួចសួរ តើផ្នែកមួយដែលខណ្ឌដោយចំនុច $M$ និង $N$ ហៅថាអ្វី ?<br>-គេសរសេរដូចម្តេច ?<br>-តើចំនុច $M$ និង $N$ ហៅថាអ្វី? និងបន្ទាត់ $l$ ហៅថាអ្វីនៃអង្កត់ $MN$ ? | មេរៀនទី១២<br>សញ្ញាណរូបធរណីមាត្រ<br>២.អង្កត់<br>២.១ សំណង់អង្កត់<br>ឧទាហរណ៍៖ គេមានបន្ទាត់ $l$ និង $M \in l$ ដែលចំនុច $M$ មិនត្រួតលើ $N$ ។<br><br> | ផ្នែកមួយដែលខណ្ឌដោយចំនុច $M$ និង $N$ ហៅថាអង្កត់<br>-គេសរសេរ $[MN]$<br>-ចំនុច $M$ និង $N$ ហៅថាចុងអង្កត់<br>និងបន្ទាត់ $l$ ហៅថាទម្រងនៃអង្កត់ $MN$ ។ |
| ឧទាហរណ៍២<br>-តើអង្កត់ $AB$ មានប្រវែងប៉ុន្មាន ?គេកំណត់សរសេរដូចម្តេច ? | ឧទាហរណ៍២<br>គេដឹងប្រវែងអង្កត់មួយ កាលណាគេយកបន្ទាត់ក្រិតទៅវាស់វា(គិតជា $cm$) ។ | -អង្កត់ $AB$ មានប្រវែង $4cm$ ។<br>គេកំណត់សរសេរ $AB = 4cm$ ។ |
| លំហាត់គំរូ: នៅលើបន្ទាត់ $xy$ មួយគេគូសអង្កត់ $A'B'$ ឲ្យមានប្រវែងស្មើនឹងអង្កត់ $AB$ ។<br>-ដើម្បីគូសអង្កត់ $A'B'$ នៅលើបន្ទាត់ $xy$ ឲ្យមានប្រវែងស្មើនឹងអង្កត់ $AB$ យើងត្រូវធ្វើដូចម្តេច?<br>Ex៩ គេមានអង្កត់ $AB$ និង $CD$ ។នៅលើបន្ទាត់ $xy$ មួយ គេដាក់ចំនុច | <br><br>២.២ប្រៀបធៀបអង្កត់ពីរ | -បើករង្វះដែកឈានដើម្បីវាស់ប្រវែង $AB$<br>-ដៅចំនុច $A' \in xy$<br>-រក្សារង្វះដែកឈានអោយនូវដដែលរួចដាក់ម្ខាងត្រង់ចំនុច $A'$ |

| | | |
|---|---|---|
| $A$ និង $C$ ឲ្យត្រួតស៊ីគ្នា បើចំនុច $B$ និង $D$ ត្រួតស៊ីគ្នាលើ $xy$ ។<br>-តើអង្កត់ $AB$ និង អង្កត់ $CD$ ដូចម្តេចនឹងគ្នាហើយមានប្រវែងស្មើគ្នាឬទេ ?<br>-គេកំណត់សរសេរដូចម្តេច ?<br>Ex$_{២}$ គេមានអង្កត់ $AB$ និងអង្កត់ $CD$ ។ គេដាក់ចំនុច $A$ និង $C$ នៅលើបន្ទាត់ $xy$ មួយលៃយ៉ាងណាឲ្យ $A$ និង $C$ ត្រួតស៊ីគ្នា ហើយដាក់ $B$ និង $D$ នៅលើ $xy$ ផ្នែកខាង $y$<br>-បើ $D$ នៅចន្លោះ $A$ និង $B$ នោះអង្កត់ $AB$ និង $CD$ មួយណាធំជាង?<br>-គេកំណត់សរសេរដូចម្តេច ? | <br><br><br> | និងចុងម្ខាងទៀតគូសលើបន្ទាត់ $xy$ ត្រង់ $B^{\vert}$ គេបាន $A^{\vert}B^{\vert}$ ដែល $AB = A^{\vert}B^{\vert}$<br>ដូចនេះ $AB = A^{\vert}B^{\vert}$ តាមបម្រាប់ ។<br>- អង្កត់ $AB$ និង អង្កត់ $CD$ ត្រួតស៊ីគ្នា ហើយមានប្រវែងស្មើគ្នា ។<br>-គេកំនត់សរសេរ $AB = CD$<br>-បើ $D$ នៅចន្លោះ $A$ និង $B$ នោះ អង្កត់ ធំជាង ហើយអង្កត់ តូចជាង ។<br>-គេកំណត់សរសេរ $AB \succ CD$ និង $CD \prec AB$ |
| | ប្រតិបត្តិ គេមានចំនុចបួន $A, B, C, D$ នៅលើបន្ទាត់ $xy$ ដូចរូបខាងក្រោម៖<br><br><br>ក) ដោយប្រើដែកឈានប្រៀបធៀបអង្កត់ $AB$ និង $CD$?<br>ខ)តើគេអាចសន្និដ្ឋានយ៉ាងដូចម្តេ | ក)ដោយប្រើចុងទាំងពីរនៃដែកឈានមកដៅចំ ចំនុច $A$ និង $B$ ។ ដោយរក្សារង្វះនៃដែកឈាននេះ គេឃើញចុចទាំងពីរនៃដែកឈាននៅលើចំនុច $C$ និង $D$ ។<br>ដូចនេះ $AB = CD$<br>ខ)អង្កត់ និង មានផ្នែករួម គឺអង្កត់ $BC$ ដោយ $AB = CD$ នោះ $AC = BD$ ។ |

| | | |
|---|---|---|
| | ច<br>ចំពោះអង្កត់ និង ? | |
| គេដឹងប្រវែងនៃអង្កត់មួយគិតជា ($cm$) គេត្រូវធ្វើដូចម្តេច ?<br>ដាក់លំហាត់ប្រតិបត្តិនៅក្នុងសៀវភៅទំព័រ ១២៣<br>ឲ្យសិស្សឡើងធ្វើ<br>ជាបុគ្គល ។ | ជំហានទី ៤ (ពង្រឹងចំនេះដឹង) | គេត្រូវយកបន្ទាត់ក្រឹតទៅវាស់វា ។<br>ក)ដោយប្រើដៃកឈានគេបាន $AB \prec BC$<br>ខ)ដោយប្រើដៃកឈាន<br>គេបាន $CD = BC$<br>គ)គេសន្និដ្ឋានបានថា $AC \succ CD$ |
| គ្រូដាក់លំហាត់ ទី៧ ទំព័រ ១២៦ អោយសិស្សធ្វើនៅផ្ទះ<br>និងណែនាំសិស្សឲ្យគោរពវិន័យ<br>និងច្បាប់ចរាចរណ៍ ។ | ជំហានទី ៥ (កិច្ចការផ្ទះ)<br>លំហាត់ទី ៧ទំព័រ ១២៦ | សិស្សកត់ត្រាលំហាត់ និងស្តាប់ដំបូន្មានគ្រូ |

# កិច្ចតែងការបង្រៀន

*មុខវិជ្ជា: គណិតវិទ្យា ថ្នាក់ទី៧*

*ថ្ងៃ........ទី......ខែ........ឆ្នាំ........*

I.*ចំណងជើងមេរៀន:* មេរៀនទី ១២ សញ្ញាណដំបូងនៃរូបធរណីមាត្រ

*ចំណងជើងទេ:* ២.៣ វិធីបូក និងដកអង្កត់

២.៤ គុណចែកអង្កត់ នឹងមួយចំនួន

II.*វត្ថុបំណង:* ក្រោយពីរៀនចប់មេរៀននេះចប់សិស្សអាច

-ចំណេះដឹង: សិស្សប្រាប់ពីរបៀប បូក ដកអង្កត់ និងគុណចែកអង្កត់នឹងមួយចំនួនពិតបានតាមរយៈ

ឧទាហរណ៍គំរូ ។

-បំណិន: សិស្សគណនាបានពីវិធីបូក ដកអង្កត់ និងគុណចែកអង្កត់នឹងមួយចំនួនពិតបានត្រឹមត្រូវ

តាមរយៈឧទាហរណ៍ និងលំហាត់ប្រតិបត្តិបានត្រឹមត្រូវ ។

-ឥរិយាបថ: សិស្សមានស្មារតីចូលរួមចែករំលែកការលំបាកវាងគ្នា និងគ្នា ។

III.*ពេលវេលា* ០២ ម៉ោង

IV. *សម្ភារៈឧបទេស:*

- បន្ទាត់ បន្ទាត់ក្រិត ដែកឈាន និងផ្ទាំងរូបភាព ។

V. *ដំណើកនាំមេរៀន:*

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាព |
|---|---|---|
| គ្រូតពិនិត្យ អវត្តមាន អនាម័យ និងសណ្តាប់ធ្នាប់ វិន័យ | <u>ជំហានទី</u> ១ (រដ្ឋបាលថ្នាក់) | តំនាងថ្នាក់ឡើងរាយការណ៍ |
| -ដាក់លំហាត់ឲ្យសិស្សឡើងធ្វើ<br>-លំហាត់: គេមានចំនុច $A, B, C$ និង $D$ រៀបតាមលំដាប់នៅលើបន្ទាត់ $(\Delta)$ មួយដោយដឹងថា<br>$AB = CD = 3cm, BC = 5cm$ | <u>ជំហានទី</u> <u>២</u> (រំលឹកចាស់) | បៀបធៀបអង្កត់ $AC$ និង $BD$<br>$AC = AB + BC = 3 + 5 = 8cm$<br>$BD = BC + CD = 5 + 3 = 8cm$ |

| | | |
|---|---|---|
| ប្រៀបធៀបអង្កត់ $AC$ និង $BD$? | | ដូចនេះ $AC = BD$ |
| គ្រូសរសេរចំណងជើងមេរៀនដាក់លើក្តាខៀន<br>.គ្រូដាក់ឧទាហរណ៍រួចសួរ<br>-Ex១ គណនាផលបូកអង្កត់ $AB, CD$ និង $EF$ ។<br>-តើអក្ស $AF$ ហៅថាអ្វីនៃអង្កត់ $AB, CD$ និង $EF$ ។<br>-តើគេសរសេរដូចម្តេច ?<br>Ex២ គណនាផលដកនៃអង្កត់ $AB$ និង $CD$ ។<br>-តើអង្កត់ $DB$ ហៅថាអ្វីនៃអង្កត់ $AB$ និង $CD$ ។<br>-គេសរសេរដូចម្តេច?<br><br>រកប្រវែងផ្លូវដែលកីឡាករបីនាក់ $A, B$ និង $C$ រត់បណ្តាក់គ្នាតាមរូបខាងក្រោម:<br><br><br>-គ្រូដាក់លំហាត់ឲ្យសិស្សពិភាក្សាគ្នាជាដៃគូ<br>-**ប្រតិបត្តិ** នៅលើបន្ទាត់ $d$ គេដៅ | <u>ជំហានទី ៣</u> (មេរៀនប្រចាំថ្ងៃ)<br>មេរៀនទី១២<br>សញ្ញាណរូបធរណីមាត្រ<br>២.៣ វិធីបូក និងដកអង្កត់<br><br><br><br><br>**ចំណាំ:**ដើម្បីធ្វើប្រមាណវិធីបូក ឬដក<br>លើអង្កត់បានលុះត្រាតែដាក់អង្កត់ទាំងពីរឲ្យនៅលើបន្ទាត់តែមួយ<br>-ដាក់ឲ្យបានជាអង្កត់តគ្នា<br><br>$MN = 29Cm$<br><br>**ប្រតិបត្តិ** នៅលើបន្ទាត់ $d$ គេដៅចំនុច $A, B$ និង $C$ ដែល $AB = 12cm$ និង $BC = 46cm$ ។ | សិស្សសង្កេត និងកត់ត្រា<br><br>- $AF$ ហៅថាផលបូកនៃអង្កត់ $AB, CD$ និង $EF$ ។គេសរសេរ<br>$AF = AB + BD + DF$<br><br>- $DB$ ហៅថាផលដកនៃអង្កត់ $AB$ និង $CD$ ។<br>-គេសរសេរ $DB = AB - CD$<br><br>រកប្រវែងផ្លូវ<br>$AD = AB + BC + CD$<br>$AD = 576 + 648 + 835 = 2059m$<br>ដូចនេះប្រវែងផ្លូវ $AD = 2059m$<br><br>គណនាប្រវែង $MN$<br><br> |

| | | |
|---|---|---|
| ចំនុច $A,B$ និង $C$ ដែល $AB=12cm$ និង $BC=46cm$ ។ គណនាប្រវែង $MN$ បើចំនុច $M,N$ ជាចំនុចកណ្ដាល់នៃអង្គត់ $AB$ និង $BC$ ។ | គណនាប្រវែង $MN$ បើចំនុច $M,N$ ជាចំនុចកណ្ដាល់នៃអង្គត់ $AB$ និង $BC$ ។ | $MN=MB+BN$<br>តែ $MB=\frac{AB}{2}=\frac{12}{2}=6cm$<br>$BN=\frac{BC}{2}=\frac{46}{2}=23cm$<br>យើងបាន $MN=6+23=29cm$ |
| -គ្រូដាក់ឧទាហរណ៍រូចសួរ<br>Ex៣គេមានអង្គត់ដូចខាងក្រោម<br><br><br>ចូរប្អូនគណនាអង្គត់ $AF$ ? | ២.៤គុណចែកអង្គត់នឹងមួយចំនួនពិត<br>$AF=5AB$ | គណនាអង្គត់ $AF$<br>$AF=AB+BC+CD+DE+EF$<br>ដោ $AB=BC=CD=DE=EF$<br>គេបាន $AF=5AB$<br>គេថា $AF$ ជាផលគុណរវាងអង្គត់ $AB$ និង 5 |
| គ្រូដាំឧទាហរណ៍ និងចោទជាសំនួរ<br>Ex៥គេមាន $I$ ជាចំនុចកណ្ដាល នៃអង្គត់ $AB, J$ កណ្ដាល់នៃ អង្គត់ $AI$ និង $K$ កណ្ដាល $IB$ ។<br>ក)តើអង្គត់ $AB$ ស្មើនឹងប៉ុន្មានដង $AI$ និង $AJ$ ?<br>ខ)តើអង្គត់ $JK$ ស្មើនឹងប៉ុន្មានដង? | Ex៤បើគេមានសមភាព $PQ=4AB$ ដូចរូប<br><br><br><br><br>មានន័យថាអង្គត់ $AB$ ត្រូវគុណនឹង 4 ដើម្បីឲ្យបានអង្គត់ $PQ$ ។គេថា $AB$ ជាផលចែកអង្គត់ $PQ$ នឹង 4 ។<br>គេបាន<br>$AB=\frac{PQ}{4}$ | -សិស្សសង្កេត និងស្ដាប់គ្រូពន្យលដោយយកចិត្តទុកដាក់<br>ក) $AB=2AI$<br>$AB=4AJ$<br>ខ) $JK=JI+IK=\frac{AI}{2}+\frac{IB}{2}$<br>$JK=\frac{1}{2}AB$ |
| -ផ្លូវពីភូមិ $A$ ទៅភូមិ $B$ មានចម្ងាយ $24.6Km$ ។មនុស្សម្នាក់ជិះកង់ចេញពីភូមិ $A$ ទៅភូមិ $B$ ហើយជួបអ្នកជិះម៉ូតូចេញពីភូមិ $B$ ទៅភូមិ $A$ ។ បើគេដឹងថាចម្ងាយពីភូមិ $B$ មកកន្លែងជួបស្មើនឹងបីដងនៃចម្ងាយពីភូមិ $A$ មកទីជួបគ្នា។ រកចម្ងាយផ្លូវដែលអ្នកទាំងពីរបានធ្វើដំណើរ? | <br><br>ក) $AB=2AI$<br>$AB=4AJ$ | -រកចម្ងាយផ្លូវដែលអ្នកទាំងពីរបានធ្វើដំណើរ<br>តាង $x$ ជាចម្ងាយផ្លូវដែលអ្នកជិះកង់បានធ្វើដំណើរ<br>តាង $3x$ ជាចម្ងាយផ្លូវដែលអ្នកជិះម៉ូតូបានធ្វើដំណើរ<br>គេបាន |

| | | |
|---|---|---|
| | ខ) $JK=\frac{1}{2}AB$<br><br>-អ្នកជិះកង់ធ្វើដំនើរបាន $6.15Km$<br>-អ្នកជិះម៉ូតូធ្វើដំណើរបា$18.45Km$ | $x+3x=24.6$<br>$4x=24.6$<br>$x=\frac{24.6}{4}=6.15Km$<br>$3x=3\times 6.15=18.45Km$<br>ដូចនេះ អ្នកជិះកង់ធ្វើដំណើរបាន $6.15Km$ អ្នកជិះម៉ូតូធ្វើដំណើរបា$18.45Km$ |
| ដើម្បីធ្វើប្រមាណវិធីបូកឬដកលើអង្កត់បានគេត្រូវធ្វើដូចម្តេច? | <u>ជំហានទី</u> ៤ (ពង្រឹងចំនេះដឹង)<br><br>**ប្រតិបត្តិ:**គេមានបីចំនុច $x,y,z$ នៅលើបន្ទាត់$(\Delta)$ ហើយ $S$ ជាចំនុចកណ្តាល $yz$ ។<br>ក) គណនាប្រវែង $xs$ ដោយដឹងថា<br>$xy=8cm, xz=20cm$<br>ខ) បង្ហាញថា $xs=\frac{xy+xz}{2}$<br> | +គេត្រូវធ្វើដូចតទៅ<br>-ដាក់អង្កត់ទាំងពីរឲ្យនៅលើអង្កត់តែមួយ។<br>-ដាក់ឲ្យបានជាអង្កត់តគ្នា។<br><br>ក) គណនាប្រវែង $xs$<br>$xs=xy+ys$ ដោយ<br>$ys=\frac{yz}{2}=\frac{20}{2}=10cm, xy=8cm$<br><br>នាំឲ្យ $xs=8+10=18cm$<br>ខ) បង្ហាញថា $xs=\frac{xy+xz}{2}$<br>$xy=8cm$<br>ដោយ $xz=xy+yz$<br>$xz=8+20=28cm$<br><br>យើងបាន<br>$xy+xz=8+28=36cm$<br>$\frac{xy+xz}{2}=\frac{36}{2}=18cm=xs$<br>ដូចនេះ: $xs=\frac{xy+xz}{2}$ |

| | | |
|---|---|---|
| គ្រូដាក់លំហាត់ ទី១០ ទំព័រ ១២៦ អោយសិស្សធ្វើនៅផ្ទះ និងណែនាំ សិស្សឲ្យគោរពវិន័យ និងច្បាប់ចរាចរណ៍ ។ | ជំហានទី ៥ (កិច្ចការផ្ទះ)<br>លំហាត់ទី ១០ ទំព័រ ១២៦ | សិស្សកត់ត្រាលំហាត់ និងស្តាប់ដំបូន្មានគ្រូ |

# កិច្ចតែងការបង្រៀន

គណិតវិទ្យាថ្នាក់ទី: ៧

## មេរៀនទី ១៣ : មុំ

## I.វត្ថុបំណងនៃមេរៀន:

ពេលរៀនចប់សិស្សអាច:

**ចំណេះដឹង:** - បញ្ជាក់ប្រភេទមុំ និង វង្វាស់មុំបានត្រឹមត្រូវតាមខ្លឹមសារមេរៀន

**ចំណេះធ្វើ:** - វាស់មុំដោយប្រើរ៉ាប៉័ទ័រ ធ្វើប្រមាណវិធីទាំងបួនលើមុំ និងសង់កន្លះបន្ទាត់ពុះមុំបានត្រឹមត្រូវ

**ឥរិយាបថ :** - សិស្សយកចំណេះដឹងដែលគេបានរៀនក្នុងមេរៀននេះទៅប្រើប្រាស់ក្នុងជីវភាពប្រចាំថ្ងៃបាន

## II. រយះពេល : ២ ម៉ោង ថ្ងៃ.....................ទី..............ខែ...................ឆ្នាំ២០១...

## III. ខ្លឹមសារមេរៀន :

1. សញ្ញាណមុំ

1.1 សញ្ញាណទូទៅនៃមុំ

1.2 ប្រភេទមុំ

1.3 ឯកតាមុំ

## IV. សម្ភារឧបទេស

-សៀវភៅសិស្ស ទំព័រទី១២៧-១២៩

-សៀវភៅសិស្ស ទំព័រទី១២៧-១២៩

- បន្ទាត់ក្រិត រ៉ាប៉័ទ័រ ដៃកឈាន

-ក្រដាសកាតុង..............

## IV.ដំណើរការបង្រៀន:

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| -ពិនិត្យអានាម័យ សណ្តាប់ធ្នាប់ អវត្តមានសិស្សនៅក្នុងថ្នាក់ | <u>ជំហានទី១</u><br>"រដ្ឋបាលថ្នាក់" | -ប្រធានថ្នាក់រាយការណ៍ |

| | | |
|---|---|---|
| | | |
| -តើប្អូនធ្លាប់លឺពាក្យថាមុំទេ?<br>តើមុំដែលប្អូនស្គាល់មានមុំអ្វីខ្លះ? | <u>ជំហានទី២</u><br>"រំលឹកមេរៀនចាស់" | -ធ្លាប់លឺ<br>-មាន មុំ កែង មុំស្រួច មុំទាល |
| **<u>ឧទាហរណ៍១:</u>**គេមានកន្លះមុំពីរ ox និងoyដែលមានគល់រួម o ហើយ ចែកប្លង់ជាពីរផ្នែកគឺផ្នែកទី(I)និងផ្នែកទី(II) ដែលផ្នែក នីមួយៗហៅថាអ្វី?<br><br>**<u>ឧទាហរណ៍២:</u>**គេមានកន្លះបន្ទាត់ពុះ OA &OB ដែល O ជាគល់រួម។ គេបានមុំ AOB ឬ BOA ឬ យ៉ាងងាយមុំ O កន្លះបន្ទាត់ ទាំង ពីរហៅថាជ្រុងនៃមុំ គល់រួមO ហៅថាកំពូលនៃមុំ។<br><br>-ដូចម្តេចដែលហៅថាមុំ?<br>មិត្តសញ្ញា ជ្រុង និង កំពូល ។<br><br><u>លំហាត់:</u>គូសមុំxoyប្រាប់ឈ្មោះនិ មិត្តសញ្ញា ជ្រុង និង កំពូល ។ | <u>ជំហានទី៣</u><br>"មេរៀនប្រចាំថ្ងៃ"<br>**<u>មេរៀនទី១៣</u>:មុំ**<br>**1.សញ្ញាណមុំ**<br>**1.1.សញ្ញាណទូទៅនៃមុំ**<br><br>-ផ្នែកទី(I): ហៅថាមុំលយ<br>-ផ្នែកទី(II): ហៅថាមុំឆក<br><br>-គេបានមុំ AOB ដែលកំណត់បាន<br>∠AOB ឬ∠BOA ឬ ∠O<br>**<u>និយមន័យ</u>**<br>មុំជាផ្នែកមួយនៃប្លង់កំណត់ដោយកន្លះបន្ទាត់ពីរដែលមានគល់រួម។<br> | <br>-ផ្នែកទី(I): ហៅថាមុំលយ<br>-ផ្នែកទី(II): ហៅថាមុំឆក<br><br>-គេបានមុំ AOB ដែលកំណត់បាន<br>∠AOB or∠BOA or ∠O<br>**<u>និយមន័យ</u>**<br>មុំជាផ្នែកមួយនៃប្លង់កំណត់ដោយកន្លះបន្ទាត់ពីរដែលមានគល់រួម។<br> |

| | | |
|---|---|---|
| -គ្រូពន្យល់នៃនាំសិស្សអំពីប្រភេទមុំហើយឪ្យសិស្ស ទាញនិយម ន័យពីមុំទាំងនេះ។<br><br>**ឧទាហរណ៍**:តាមរូបនេះ<br>សូមប្រាប់ឈ្មោះនិងប្រភេទ | -មុំ ∠xoy or ∠yox or∠o<br>-ជ្រុង ox , oy<br>-កំពូល o<br>**1.2.<u>ប្រភេទមុំ</u>**<br><br>-មុំស្រួចជាមុំដែលតូចជាងមុំកែង<br><br>-មុំកែងគឺជ្រុងទាំងពីរកែងគ្នា ox┴oy<br><br>- មុំទាលជាមុំធំជាងមុំកែង តែតូចជាងមុំរាប<br>**សម្គាល់**:<br><br>-មុំរាបជ្រុង ox &oy ជាបន្លាយគ្នា<br><br>-មុំសូន្យ ជ្រុង ox &oyត្រួតស៊ីគ្នា<br><br>-មុំពេញ ជ្រុង ox&oyត្រួតស៊ីគ្នា<br> | -មុំ ∠xoy or ∠yox or∠o<br>-ជ្រុង ox , oy<br>-កំពូល o<br>**1.2.<u>ប្រភេទមុំ</u>**<br><br>-មុំស្រួចជាមុំដែលតូចជាងមុំកែង<br><br>-មុំកែងគឺជ្រុងទាំងពីរកែងគ្នា ox┴oy<br><br>- មុំទាលជាមុំធំជាងមុំកែង តែតូចជាងមុំរាប<br>**សម្គាល់**:<br><br>-មុំរាបជ្រុង ox &oyជាបន្លាយគ្នា<br><br>-មុំសូន្យ ជ្រុង ox &oyត្រួតស៊ីគ្នា<br><br>-មុំពេញ ជ្រុង ox&oyត្រួតស៊ីគ្នា<br><br>**<u>ចម្លើយ</u>**<br>-∠toxជាមុំស្រួច<br>-∠toy ជាមុំកែង |

| | | |
|---|---|---|
| មុំនីមួយៗ ។<br><br>-តើឯកតាមុំដែលគេនិយមប្រើជាងគេមានអ្វីខ្លះ?<br><br>**លំហាត់គំរូ**: សរសេរ $8°18'20"$ ជាសឹកុងនិង $42750"$ ជាដឺក្រេ មីនុត សឹកុង។ | **1.3.ឯកតាមុំ**<br>-ឯកតាមុំដែលគេនិយមប្រើគឺ:<br>**ក. មុំកែង** :ស្មើកន្លះមុំរាប (គេតាងដោយD)<br>-ដឺក្រេ ( °)= $\frac{1}{90}D$ ឬ 1D = 90°<br>**ខ. ឯកតាបន្ទាប់នៃដឺក្រេគឺ:**<br>-មីនុត(')= $\frac{1°}{60}$<br>-សឹកុង (″)= $\frac{1'}{60}$<br>1មុំរាប=2D , 1D=90°<br>$1° = 60', 1' = 60"$<br>គ. ក្រាត (gr)= $\frac{1}{100}D$ ឬ 1D=100gr<br>**ចម្លើយ:**<br>-សរសេរ $8°18'20"$ ជាសឹកុង:<br>$8° = 8\times 60' = 480'$<br>$480'+18' = 498'$<br>$498' = 498\times 60" = 29880"$<br>ដូចនេះ $8°18'20" = 29880"+20"$<br>$= 29900"$<br>-សរសេរ $42750"$ ជាដឺក្រេ មីនុត សឹកុង:<br>$42750" = \frac{1'\times 42750}{60} = 712'30"$<br>$712' = \frac{1'\times 712}{60} = 11°52'$ | -$\angle$ yozជាមុំទាល<br>-$\angle$ zoxជាមុំរាប-<br>-$\angle$ tot ជាមុំសូន្យ<br><br>**1.3.ឯកតាមុំ**<br>-ឯកតាមុំដែលគេនិយមប្រើគឺ:<br>**ក. មុំកែង** :ស្មើកន្លះមុំរាប (គេតាងដោយD)<br>-ដឺក្រេ ( °)= $\frac{1}{90}D$ ឬ 1D = 90°<br>**ខ. ឯកតាបន្ទាប់នៃដឺក្រេគឺ:**<br>-មីនុត(')= $\frac{1°}{60}$<br>-សឹកុង (″)= $\frac{1'}{60}$<br>1មុំរាប=2D , 1D=90°<br>$1° = 60', 1' = 60"$<br>គ. ក្រាត (gr)= $\frac{1}{100}D$ ឬ 1D=100gr<br>**ចម្លើយ:**<br>-សរសេរ $8°18'20"$ ជាសឹកុង:<br>$8° = 8\times 60' = 480'$<br>$480'+18' = 498'$<br>$498' = 498\times 60" = 29880"$<br>ដូចនេះ $8°18'20" = 29880"+20"$<br>$= 29900"$<br>-សរសេរ $42750"$ ជាដឺក្រេ មីនុត សឹកុង:<br>$42750" = \frac{1'\times 42750}{60} = 712'30"$<br>$712' = \frac{1'\times 712}{60} = 11°52'$ |

| | | |
|---|---|---|
| | ដូចនេះ 42750" =11°52'30" | ដូចនេះ 42750" =11°52'30" |
| -ដូចម្តេចដែលហៅថាមុំ?<br>-ចូរអោយនិយមន័យ មុំស្រួច មុំកែងនិងមុំទាល។ | <u>ជំហានទី៤</u><br>"ពង្រឹងពុទ្ធិ" | - មុំជាផ្នែកមួយនៃប្លង់កំណត់ដោយកន្លះបន្ទាត់ពីរដែលមានគល់រួម<br>-មុំស្រួចជាមុំដែលតូចជាងមុំកែង<br>-មុំកែងគឺជ្រុងទាំងពីរកែងគ្នា<br>- មុំទាលជាមុំធំជាងមុំកែង តែតូចជាងមុំរាប |
| -សូមប្អូនៗទាំងអស់ទៅផ្ទះវិញធ្វើប្រតិបត្តិនៅទំព័រទី១២៩ផង។<br>-ត្រូវនិយាយថាទេចំពោះគ្រឿងញៀន។ | <u>ជំហានទី៥</u><br>"បណ្តាំផ្ញើ" | -សិស្សកត់ទំព័រទុក |

# កិច្ចតែងការបង្រៀន

គណិតវិទ្យាថ្នាក់ទី: ៧

មេរៀនទី ១៣ : មុំ

## I.វត្ថុបំណងនៃមេរៀន:

ពេលរៀនចប់សិស្សអាច:

**ចំណេះដឹង** : -សិស្សស្គាល់ពីឧបករណ៍សំរាប់វាស់មុំដូចជា កែង , រ៉ាប៉ទ័រ , បន្ទាត់ និង ដែកឈានដែលនៅក្នុងមេរៀនបានបង្ហាញ

**ចំណេះធ្វើ** : -សិស្សអាចវាស់មុំដោយប្រើឧបករណ៍ កែង , រ៉ាប៉ទ័រ , បន្ទាត់ និង ដែក ឈាន ដែលនៅក្នុងមេរៀនបានបង្ហាញបានយ៉ាងត្រឹមត្រូវ

**ឥរិយាបថ** : - សិស្សយកចំណេះដឹងដែលគេបានរៀនក្នុងមេរៀននេះទៅប្រើប្រាស់ ក្នុងជីវភាពប្រចាំថ្ងៃបាន

## II. រយៈពេល :២ ម៉ោង ថ្ងៃ ..................ទី...........ខែ...................ឆ្នាំ.................

## III.ខ្លឹមសារមេរៀន:

2. ឧបករណ៍សម្រាប់វាស់មុំ

2.1.វាស់និងសង់មុំដោយប្រើរ៉ាប៉ទ័រ

2.2 សងមុំដោយប្រើដែកឈាន

3. ប្រមាណវិធីលើមុំ

3.1.មុំជាប់

3.2.ប្រមាណវិធីលើមុំ

4. សងកន្លះបន្ទាត់ពុះមុំដោយប្រើបន្ទាត់ និងដែកឈាន

4.1 មុំផ្ទុំ

## IV. សម្ភារឧបទេស:

-បន្ទាត់ក្រិត កែង រ៉ាប៉ទ័រ ដែកឈាន - ក្រាដាសកាតុង

## V. ដំណើរនៃការបង្រៀន:

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| -គ្រូពិនិត្យអានាម័យ សណ្តាប់ធ្នាប់ អវត្តមានសិស្សក្នុងថ្នាក់ | ជំហានទី១<br>" រដ្ឋបាលថ្នាក់" | -ប្រធានថ្នាក់រាយការណ៍ |
| -ដូចម្តេចដែលហៅថាមុំ?<br>-តើគេប្រើឧបករណ៍អ្វីខ្លះសម្រាប់វាស់មុំ? | ជំហានទី២<br>"រំលឹកមេរៀនចាស់" | -មុំជាផ្នែកមួយនៃប្លង់កំណត់ដោយកន្លះបន្ទាត់ពីរដែលមានគល់រួម។<br>-ឧបករណ៍សំរាប់វាស់មុំដូចជា កែង , រ៉ាប៉័រ , បន្ទាត់ និង ដែកឈាន |
| -តើឧបករណ៍សម្រាប់វាស់មុំមានអ្វីខ្លះ?<br><br>ឧទាហរណ៍: គូសវាស់ xoyដូចរូបនេះ? តើមុំ xoyមានរង្វាស់ ស្មើប៉ុន្មាន? | ជំហានទី៣<br>"មេរៀនប្រចាំថ្ងៃ"<br>**មេរៀនទី១៣ :មុំ**<br>**2.ឧបករណ៍សម្រាប់វាស់មុំ**<br>**-កែង:**ជាឧបករណ៍សម្រាប់គូសបន្ទាត់កែង។គេធ្វើពីឈើ ឬ ជ័រ......<br>**-រ៉ាប៉័រ:**មានរាងជាកន្លះរង្វង់មានជាក់រង្វាស់ពី $0°$ ទៅ$180°$ ដោយមានលេខ $90°$ នៅកណ្តាល។<br>**2.1.វាស់និងសង់មុំដោយប្រើរ៉ាប៉័រ**<br><br>**2.2.សង់មុំដោយប្រើដែកឈាន** | **-កែង:**ជាឧបករណ៍សម្រាប់គូសបន្ទាត់កែង។គេធ្វើពីឈើ ឬ ជ័រ...<br>**-រ៉ាប៉័រ:**មានរាងជាកន្លះរង្វង់មានជាក់ង្វាស់ពី $0°$ ទៅ$180°$ ដោយមានលេខ $90°$ នៅកណ្តាល។<br><br>**ចំម្លើយ**<br>-xoyមានរង្វាស់ $50°$ គេសរសេរ xoy= $50°$ |

| | | |
|---|---|---|
| **ឧទាហរណ៍:**<br>មុំxoy&yoxមានកំពូលរួម oមានជ្រុងរួមoyហើយនៅសងខាងជ្រុង oyគេថា xoy&yoxជាមុំជាប់គ្នា<br><br>-គ្រូទាញទំនាក់ទំនងនៃមុំ $\angle AOB$ និង $\angle CXE$ ដែលមុំ $\angle CXE$ បានពីការបូក $\angle AOB$ ពីរដងឬ $\angle AOB$ គុណ២ ។ | **<u>និយមន័យ:</u>**មុំពីរប៉ុនគ្នាត្រួតស៊ីគ្នាឬមានរង្វាស់ស្មើគ្នា។<br>**3.<u>ប្រមាណវិធីលើមុំ</u>**<br>**3.1 <u>មុំជាប់</u>**<br><br>-មុំxoy&yoxមានកំពូលរួម O មានជ្រុងរួមoyហើយនៅសងខាងជ្រុង oyគេថា xoy&yoxជាមុំជាប់គ្នា<br>**3.2.<u>ប្រមាណវិធីលើមុំ</u>**<br>**ក.<u>វិធីបូក ដកមុំ</u>**<br>**<u>ឧទាហរណ៍ :</u>**<br><br>$\angle zot = \angle xoy + \angle BNA$<br>$\angle BNA = \angle toz - \angle xoy$<br>$\angle xoy = \angle toz - \angle BNA$<br>**ខ.<u>វិធីគុណ ចែកមុំនិងមួយចំនួន</u>**<br>**<u>ឧទាហរណ៍:</u>**<br><br> | **<u>និយមន័យ:</u>**មុំពីរប៉ុនគ្នាត្រួតស៊ីគ្នាឬមានរង្វាស់ស្មើគ្នា។<br><br>-មុំxoy&yoxមានកំពូលរួមO មានជ្រុងរួមoyហើយនៅសងខាងជ្រុង oyគេថា xoy&yoxជាមុំជាប់គ្នា<br>**<u>ឧទាហរណ៍ :</u>**<br><br>$\angle zot = \angle xoy + \angle BNA$<br>$\angle BNA = \angle toz - \angle xoy$<br>$\angle xoy = \angle toz - \angle BNA$<br>**<u>ឧទាហរណ៍:</u>**<br><br> |

| | | |
|---|---|---|
| - គ្រូទាញទំនាក់ទំនងនៃមុំ $\angle AOB$ និង $\angle CXE$ ដែលមុំ $\angle CXE$ បានពីការបូក $\angle AOB$ បីដងឬ $\angle AOB$ គុណ3 ។ | - $\angle CXE = \angle AOB + \angle AOB$<br>$= 2\angle AOB$<br>ឬ $\angle CXE = \frac{\angle CXE}{2}$<br>គេថា $\angle CXE$ ជាមេគុណនៃ $\angle AOB$<br>ឬ $\angle AOB$ ជាកន្លះនៃ $\angle CXE$<br><br>$\angle CXE = \angle AOB + \angle AOB + \angle AOB$<br>=3 $\angle AOB$ ឬ $\angle AOB = \frac{\angle CXE}{3}$<br>គេថា $\angle CXE$ ជាត្រីគុណនៃ $\angle AOB$<br>ឬ $\angle AOB$ ជា1/3នៃ $\angle CXE$<br> | - $\angle CXE = \angle AOB + \angle AOB$<br>$= 2\angle AOB$<br>ឬ $\angle CXE = \frac{\angle CXE}{2}$<br>គេថា $\angle CXE$ ជាមេគុណន $\angle AOB$<br>ឬ $\angle AOB$ ជាកន្លះនៃ $\angle CXE$<br><br>$\angle CXE = \angle AOB + \angle AOB \ \angle AOB$<br>=3 $\angle AOB$ ឬ $\angle AOB = \frac{\angle CXE}{3}$<br>គេថា $\angle CXE$ ជាត្រីគុណន $\angle AOB$<br>ឬ $\angle AOB$ ជា1/3នៃ $\angle CXE$<br> |

| | | |
|---|---|---|
| ឧទាហរណ៍:បើគេកាត់យកមុំ xoyមួយធ្វើពីក្រដាស រួចបត់មុំយ៉ាងណាឱ្យជ្រុងox ត្រួតស៊ីគ្នានិងជ្រុងoyផ្នត់ដែលបត់បាននោះគេសន្មត់ថាជ្រុងotនោះគេបាន មុំxot& toy ប៉ុនគ្នា ព្រោះវាត្រួតស៊ីគ្នា។ គេបាន otជាកន្លះបន្ទាត់ពុះនៃមុំ xoy។<br><br>**លំហាត់:**សង់កន្លះបន្ទាត់ពុះ(ot) នៃមុំ xoyដោយប្រើបន្ទាត់ និង ដៃកឈាន ។ | - $\angle CXE$ ជាផលបូករវាងមុំបីដែលមុំនីមួយៗមួយមានរង្វាស់ស្មើនិង $\frac{1}{2}\angle AOB$<br>- $\angle CXE = 3\frac{\angle CXE}{2}$<br>ឬ $\angle AOB = 2\frac{\angle CXE}{3}$<br>**4.សង់កន្លះបន្ទាត់ពុះមុំដោយប្រើបន្ទាត់និងដៃកឈាន**<br><br><br>**ចម្លើយ :**<br>របៀបសង់កន្លះបន្ទាត់ពុះ $\angle xoy$ គឺ:<br>**ក**.គូសធ្នូរង្វង់ផ្ចិតO ឱ្យកាត់តាមជ្រុងចំនុចA&B<br><br><br>**ខ**.គូសធ្នូនៃរង្វង់ផ្ចិតA (មានកាំរង្វង់ធំជាង1/3AB)(រក្សារង្វះ | - $\angle CXE$ ជាផលបូករវាងមុំបីដែលមុំនីមួយៗមួយមានរង្វាស់ស្មើនិង $\frac{1}{2}\angle AOB$<br>- $\angle CXE = 3\frac{\angle CXE}{2}$<br>ឬ $\angle AOB = 2\frac{\angle CXE}{3}$<br><br>ឧទាហរណ៍:បើគេកាត់យកមុំ xoyមួយធ្វើពីក្រដាស រួចបត់មុំយ៉ាងណាឱ្យជ្រុងox ត្រួតស៊ីគ្នានិងជ្រុងoyផ្នត់ដែលបត់បាននោះគេសន្មត់ថាជ្រុងotនោះគេបាន មុំxot& toy ប៉ុនគ្នា ព្រោះវាត្រួតស៊ីគ្នា។ គេបាន otជាកន្លះបន្ទាត់ពុះនៃមុំ xoy។<br><br>**ចម្លើយ :**<br>របៀបសង់កន្លះបន្ទាត់ពុះ $\angle xoy$ គឺ:<br>**ក**.គូសធ្នូរង្វង់ផ្ចិតO ឱ្យកាត់តាមជ្រុងចំនុចA&B<br><br><br>**ខ**.គូសធ្នូនៃរង្វង់ផ្ចិតA (មានកាំរង្វង់ |

| | | |
|---|---|---|
| <u>ឧទាហរណ៍:</u>គេមានមុំដូចខាងក្រោម:<br>-ចូរឪ្យនិយមន័យមុំទាំងនេះ? | ដែកឈាននៅដដែល)<br><br><br>**គ.**គូសធ្នូនៃរង្វង់ផ្ចិតB និងកាំមានរង្វាស់ស្មើរង្វង់សំណាង (ខ) (រង្វះដែកឈានដូចសំណាង់(ខ))។ ធ្នូទាំងពីរប៉ុនគ្នាត្រង់ចំនុច t គូសភ្ជាប់ otគេបានកន្លះបន្ទាត់ពុះមុំ xoy តាមបម្រាប់។<br><br><br>**<u>4.1.មុំផ្គុំ</u>**<br><br><br>$\angle A+B=90°$<br>មុំបំពេញជាមុំដែលមានរង្វាស់ផលបូកស្មើ $90°$ ។ គេថាមុំ $\angle A$ ជាមុំបំពេញនៃមុំ $\angle B$ ឬ $\angle B$ ជាមុំបំពេញនៃ $\angle A$<br><br> | ធំជាង1/3AB)(រក្សារង្វះដែកឈាននៅដដែល)<br><br><br>**គ.**គូសធ្នូនៃរង្វង់ផ្ចិតB និងកាំមានរង្វាស់ស្មើរង្វង់សំណាង (ខ) (រង្វះដែកឈានដូចសំណាង់(ខ))។ ធ្នូទាំងពីរប៉ុនគ្នាត្រង់ចំនុច t គូសភ្ជាប់ otគេបានកន្លះបន្ទាត់ពុះមុំ xoyតាមបម្រាប់។<br><br><br><br><br>$\angle A+B=90°$<br>មុំបំពេញជាមុំដែលមានរង្វាស់ផលបូកស្មើ $90°$ ។ គេថាមុំ $\angle A$ ជាមុំបំពេញនៃមុំ $\angle B$ ឬ $\angle B$ ជាមុំបំពេញនៃ $\angle A$<br><br> |

| | | |
|---|---|---|
| | $\angle M+\angle N=150°+30°$<br>$=180°$<br>-មុំបន្ថែមជាមុំពីរដែលមានរង្វាស់ផលបូកស្មើ$180°$ ។ គេថា $\angle M$ ជាមុំបន្ថែមនៃ $\angle N$ ឬ $\angle N$ ជាមុំបន្ថែមនៃ $\angle M$<br><br><br>-មុំទល់កំពូលជាមុំពីរមានជ្រុងនីមួយៗនៃមុំមួយជាបន្លាយនៃជ្រុងនីមួយៗនៃមុំមួយទៀតហៅថាមុំទល់កំពូល។ ដូចជាមុំ $\angle 0_1 \& \angle 0_3$ ជាមុំទល់កំពូល។ $\angle 0_4 \& \angle 0_2$ ជាមុំទល់កំពូល។ | $\angle M+\angle N=150°+30°$<br>$=180°$<br>-មុំបន្ថែមជាមុំពីរដែលមានរង្វាស់ផលបូកស្មើ$180°$ ។ គេថា $\angle M$ ជាមុំបន្ថែមនៃ $\angle N$ ឬ $\angle N$ ជាមុំបន្ថែមនៃ $\angle M$<br><br><br>-មុំទល់កំពូលជាមុំពីរមានជ្រុងនីមួយៗនៃមុំមួយជាបន្លាយនៃជ្រុងនីមួយៗនៃមុំមួយទៀតហៅថាមុំទល់កំពូល។ ដូចជាមុំ $\angle 0_1 \& \angle 0_3$ ជាមុំទល់កំពូល។ $\angle 0_4 \& \angle 0_2$ ជាមុំទល់កំពូល។ |
| **លំហាត់:**<br>គេឱ្យ<br>$a=25°, b=40°, c=135°$<br>$d=155°, k=50°, g=45°$<br>$h=65°$<br>។តើមុំណាខ្លះជាមុំបំពេញហើយមុំណាខ្លះជាមុំបន្ថែម? | <u>ជំហានទី៤</u><br>" ពង្រឹងពុទ្ធិ" | **ចម្លើយ :**<br>-មុំបំពេញគឺ:<br>$\angle b \& \angle k, \angle a \& \angle h$<br>-មុំបន្ថែមគឺ:<br>$\angle c \& \angle g, \angle a \& \angle d$ |

| | | |
|---|---|---|
| -ចូរប្អូនទៅផ្ទះវិញធ្វើលំហាត់ទី៦ និង ៧ នៅ ទំព័រទី ១៣៨ | ជំហានទី៥<br>" បណ្ដាំផ្ញើ" | -សិស្សកត់ទំព័រលំហាត់ទុក |

# កិច្ចតែងការបង្រៀន ( ថ្នាក់ទី7 )

## មេរៀនទី14 បន្ទាត់ស្រប និង បន្ទាត់កែង

I. វត្ថុបំណងក្រោយពីរៀនចប់សិស្សអាច

-ចំណេះដឹង: កំណត់បានពីបន្ទាត់ស្រប និង បន្ទាត់កែង ។

-ចំណេះធ្វើ: រកបន្ទាត់ស្រប & បន្ទាត់កែងបាន ។

II. ចំណងមេរៀនរង:

1. សញ្ញាណបន្ទាត់ស្រប
2. សញ្ញាណបន្ទាត់កែង
3. លក្ខណ:នៃបន្ទាត់ស្រប
4. លក្ខណ:នៃបន្ទាត់កែង

III. រយ:ពេលបង្រៀន ( 90នាទី )

IV. សម្ភារ:ឧបទេស:

-សៀវភៅគ្រូ ( page - 139 - 141)

-សៀវភៅសិស្ស ( 139 - 141 )

V. ដំណើរការបង្រៀន

| សកម្មភាពគ្រូ | ខ្លឹមសាមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| -គ្រូពិនិត្យ អនាម័យ សណ្តាប់ធ្នាប់ និង អវត្តមាន | -ជំហានទី I ( 5នាទី )<br>(រដ្ឋបាលថ្នាក់) | -ប្រធានថ្នាក់រាយការវត្តមាន |
| 1. ដូចម្តេចដែលហៅថាបន្ទាត់ ? | ជំហានទី II ( 5នាទី )<br>(រំលឹកមេរៀន) | 2. ខ្សែត្រង់ឥតព្រំដែន |
| តើសសរផ្ទះ ផ្លូវរថភ្លើងមានចំណុចរួមឬទេ ? | -ជំហាន់ទី III ( 65នាទី )<br>(ខ្លឹមសារមេរៀន)<br>14. បន្ទាត់ស្រប និងបន្ទាយ់កែង<br>I.សញ្ញាណបន្ទាត់ស្រប<br>ឧទាហរណ៍: សសរផ្ទះ ,ផ្លូវរថភ្លើង , គ្រោងទ្វារទាំងអស់នេះផ្តល់នូវសញ្ញណ<< បន្ទាត់ស្រប >> ។ | • សសរផ្ទះ ផ្លូវរថភ្លើង គ្មានចំណុចរួមទេ ។ |

| | | |
|---|---|---|
| • ក្រឡាសៀវភៅផ្លូវបំបែកជាបួនមានចំណុចរួមដែលអាចបង្កើតបានមុំដែលមានរង្វង់ 90° ឬទេ ? | ជាទូទៅ:<br>បន្ទាត់ពីរបិតក្នុងប្លង់តែមួយហើយគ្មានចំណុចរួមហៅថា បន្ទាត់ស្រប<br>ឧទាហរណ៍: បើបន្ទាត់ d & d' ស្ថិតនៅក្នុងប្លង់មួយគ្មានចំណុចរួមគេថា d & d' ស្របគ្នា ។<br>គេកំណត់<br>សរសេរ d // d' ។<br><br>II.សញ្ញាណបន្ទាត់កែង<br>ឧទាហរណ៍: ផ្លូវបំបែកជាបួន ក្រឡាឈើត្រង់ បន្ទាត់កែង......... ទាំងអស់នេះហៅថា<< បន្ទាត់កែង >>ជាទូទៅ: បន្ទាត់ ឬ កន្លះបន្ទាត់ ឬ អង្កត់ពីរនៅក្នុងប្លង់មួយកែងគ្នាកាលណាវាកាត់គ្នាហើយផ្តុំបានមុំកែងមួយ ។<br>III. លក្ខណ:នៃបន្ទាត់ស្រប<br>ក. តាមចំណុច A មួយមិនបិតនៅលើបន្ទាត់ d គេអាចគូសបានបន្ទាត់តែមួយគត់ដែលកាត់តាម A ហើយស្របនឹងបន្ទត់ d ។<br><br>ខ.បើបន្ទាត់ពីរស្របគ្នានោះគ្រប់បន្ទាត់ កាត់បន្ទាត់មួយត្រូវកាត់ | • ក្រឡាសៀវភៅផ្លូវបំបែកជាបួនមានចំណុចរួមដែលអាចបង្កើតបានមុំដែលមានរង្វង់90$^0$ ។ |

| | | |
|---|---|---|
| <br>គ្រូពន្យល់សិស្សពីលក្ខណៈ បន្ទាត់កែង ។<br><br><br><br>ចូរនិយាយពីលក្ខណៈនៃបន្ទាត់ | បន្ទាត់មួយ ទៀត ។<br><br>គ. បើបន្ទាត់ពីរស្របគ្នានោះគ្រប់បន្ទាត់ដែលស្របមួយត្រូវស្របបន្ទាត់មួយទៀត ។<br>IV. លក្ខណៈនៃបន្ទាត់កែង<br>ក. តាមចំណុច A មួយមិនស្ថិតនៅលើបន្ទាត់ d មួយគេអាចគូសបានបន្ទាត់តែមួយគត់កាត់តាម A ដែលកែងនឹងបន្ទាត់ d ។<br>ខ. បើបន្ទាត់ពីរស្របគ្នានោះគ្រប់បន្ទាត់ដែលកែងបន្ទាត់មួយត្រូវកែងនឹងបន្ទាត់មួយទៀត ។<br>បើ $\begin{cases} d \parallel d' \\ d \perp m \end{cases}$ នោះ $d \perp m$<br>គ. បើបន្ទាត់ពីរកែងទៅនឹង បន្ទាត់តែមួយនោះបន្ទាត់ទាំងពីរស្របគ្នា ។<br>បើ $\begin{cases} d \perp m \\ d' \perp m \end{cases}$ នោះ $d \parallel d'$ | សិស្សស្តាប់ និង សង្កេត ។<br>+ ក, ខ, គ ។<br>+ ក, ខ, គ ។ |

| | | |
|---|---|---|
| ស្រប ?<br><br>+ ចូរនិយាយពីលក្ខណៈនៃបន្ទាត់កែង ? | ជំហានទី IV<br>( ពង្រឹងចំណេះដឹង ) | |
| -ដាក់លំហាត់ទី1ក្នុងសៀវភៅសិស្ស ទំព័រទី150ឲ្យសិស្សធ្វើនៅផ្ទះ | -ជំហានទី5 ( កិច្ចការផ្ទះ )<br>លំហាត់ទី1 , ក, ខ, គ, ឃ | -សិស្សស្តាប់និង ធ្វើតាម ។ |

# កិច្ចតែងការបង្រៀន ( ថ្នាក់ទី7 )

## 14. បន្ទាត់ស្រប និង បន្ទាត់កែង ( ត )

I. វត្ថុបំណងក្រោយពីរៀនចប់សិស្សអាច

-ចំណេះដឹង: កំណត់បានពីសំណង់បន្ទាត់កែង និង បន្ទាត់ស្រប ។

-ចំណេះធ្វើ: សង់បានបន្ទាត់ស្រប និង បន្ទាត់កែងបាន ។

II. ចំណាងជើងរង:

5. សំណង់បន្ទាត់ស្របនិង បន្ទាត់កែងដោយប្រើបន្ទាត់កែងនិង ដែកឈាន

5.1, សំណង់បន្ទាត់កែងនឹងបន្ទាត់មួយ

5.2, សំណង់បន្ទាត់ស្របដោយប្រើកែង

III. រយៈពេល 90 នាទី

IV. សម្ភារៈឧបទេស

-សៀវភៅគ្រូទំព័រ ( 142 - 143 ) -ដែកឈាន

-សៀវភៅសិស្សទំព័រ ( 142 - 143 )

V. ដំណើរការបង្រៀន

| សកម្មភាពគ្រូ | ខ្លឹមសាមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| ពិនិត្យ អនាម័យ<br>សណ្តាប់ធ្នាប់ និង អវត្តមាន | ជំហានទី I<br>(លំនឹងថ្នាក់ ) | ប្រធានថ្នាក់រាយការវត្តមាន |
| •ចូរនិយាយពីលក្ខណៈបន្ទាត់ស្រប ? | ជំហានទី II<br>(រំលឹកមេរៀន) | ក. តាមចំណុច Aមួយមិនឋិតនៅលើបន្ទាត់ d គេអាចគូសបានបន្ទាត់តែមួយគត់ ដែលកាត់តាម A ហើយស្របនឹងបន្ទាត់ d ។<br>ខ. បើបន្ទាត់ពីរស្របគ្នានោះគ្រប់បន្ទាត់ដែលកាត់បន្ទាត់មួយ ត្រូវកាត់បន្ទាត់មួយទៀត ។ |

| | | |
|---|---|---|
| | | គ. បើបន្ទាត់ពីរស្របគ្នានោះគ្រប់បន្ទាត់ដែលស្របបន្ទាត់មួយត្រូវស្របបន្ទាត់មួយទៀត ។ |
| <br><br>គ្រូពន្យល់សិស្សពី សំណង់បន្ទាត់ស្រប និង បន្ទាត់កែង<br>-<br>ណែនាំសិស្សឲ្យសង់បន្ទាត់ស្របដោយប្រើកែង<br><br> | ជំហានទី III<br>(ខ្លឹមសារមេរៀន)<br>14.បន្ទាត់ស្រប បន្ទាត់កែង<br>V. សំណង់បន្ទាត់ស្របនិងបន្ទាត់កែង ដោយប្រើបន្ទាត់កែងនិង ដែកឈាន<br>1, សំណង់បន្ទាត់កែងនិងបន្ទាត់មួយ<br>គេគូសបន្ទាត់មួយដែលកាត់តាមចំណុច o ∈ xy ហើយកែង xy ។ គេដាក់ជ្រុងAB នៃកែងឲ្យត្រួតលើ xy ហើយគេរំកិលកែងឲ្យជ្រុងមុំកែង AC មួយទៀតកាត់តាមចំណុច oរួចគេគូសជ្រុង AC ហើយគេបន្លាយ AC ។គេបានcc'⊥ xy ហើយកាត់តាម o ។<br>2. សំណង់បន្ទាត់ស្របដោយប្រើកែង<br>ក, គេដឹងថា បន្ទាត់ពីរផ្សេងគ្នាកែងទៅនឹង<br>បន្ទាត់តែមួយជាបន្ទាត់ស្របគ្នា ។ តាមន័យនេះគេអាចសង់បន្ទាត់ពីរស្របគ្នាដោប្រើកែង<br>គេមានបន្ទាត់ xy មួយគេដាក់ជ្រុង | សិស្សស្តាប់ និង សង្កេតដោយប្រុងប្រយត្ន័ ។<br>សិស្សស្តាប់ និងធ្វើតាមដោយយកចិត្តទុកដាក់ ។ |

| | | |
|---|---|---|
|  | នៃកែងឲ្យត្រួតស៊ី លើបន្ទាត់ xy<br>រួចគូសបន្ទាត់ d ⊥ xy<br>គេរំកិលជ្រុងនៃកែងលើបន្ទាត់xy<br>រួសគូសបន្ទាត់ d' ⊥ xy ។<br>ដូចនេះគេបានបន្ទាត់ d//d' ។<br>គេសង្កេតឃើញថា បើគេបន្លាយ<br>អ៊ីប៉ូតេនុសនៃកែងគេក៏បានបន្ទាត់<br>ពីរ L // L ដែរ ។<br>ខ. តាមចំណុច A មិនបិតនៅលើ<br>បន្ទាត់ ó'ó គូសបន្ទាត់y'y / /óó' ។<br>ដំបូងគេគូសបន្ទាត់ d កាត់ឬកែង<br>ó'ó គេដាក់កែងយ៉ាងណាឲ្យ<br>ជ្រុងនៃកែងមួយត្រួតស៊ីគ្នាជាមួយ<br>បន្ទាត់ ó'ó និងជ្រុងមួយទៀតត្រួត<br>ស៊ីគ្នានិង d ។ គេរំកិលកែងរហូត<br>ដល់ជ្រុងនៃកែងត្រូវគ្នា នឹង ó'ó<br>កាត់តាមចំណុច A ។<br>គេគូសបន្ទាត់ y'Ayគេបានបន្ទាត់<br>y'y // ó'ó ដែលត្រូវសង់ ។ | |
| | ជំហានទី IV<br>( ពង្រឹងចំណេះដឹង )<br><u>លំហាត់</u><br>ក, គូសបន្ទាត់ d និងដៅចំណុច A<br>មួយនៅក្រៅបន្ទាត់ d<br>ខ, គូសបន្ទាត់ h កាត់តាមចំណុច A<br>ហើយកែងនិងបន្ទាត់ d ។<br>គ, ដៅចំណុច B | ចម្លើយ<br>( h ) ក, ខ, គ, ឃ<br> |

| | | |
|---|---|---|
| | មួយនៅក្រៅបន្ទាត់<br>d និង h ។<br>ឃ, គូសបន្ទាត់ k កាត់តាមចំណុច<br>B<br>ហើយកែងបន្ទាត់ h ។ | ង, ដោយ $\begin{cases}(d)\perp(h)\\(K)\perp(h)\end{cases}$<br>នោះគេបាន (d) // (k) ។<br>ចម្លើយប្រតិបត្តិ |
| | ង, តើគេថាយ៉ាងណាចំពោះ d និង k?<br><br>ប្រតិបត្តិ<br>1,គេមានបន្ទាត់ d មួយនិងចំណុច<br>A<br>មួយមិនស្ថិតនៅលើបន្ទាត់ d ។<br>សង់បន្ទាត់ d' កាត់តាមAហើយកែង<br>កែងនឹង d ហើយប្រើបន្ទាត់កែង<br>2, គេមានបន្ទាត់ dមួយនិង ចំណុច<br>A<br>មិនស្ថិតនៅលើបន្ទាត់ d ។ សង់<br>បន្ទាត់d' កាត់តាម Aហើយស្របនឹង<br>d ។ | 1,<br><br><br>2,<br><br> |
| គ្រូដាក់លំហាត់ លេខ 2<br>នៅទំព័រ ទី150 | ជំហានទី V ( កិច្ចការផ្ទះ )<br>ធ្វើលំហាត់លេខ 2 ទំព័រ ទី150 | បើសិស្សស្តាប់ហើយធ្វើតាម ។ |

# កិច្ចតែងការបង្រៀន

## មុខវិជ្ជា: គណិតវិទ្យាថ្នាក់ទី៧

I. មេរៀនទី ១៤ បន្ទាត់ស្រប និង បន្ទាត់កែង (ត)

៧. មុំផ្គុំដោយបន្ទាត់ស្របពីរ និង ខ្នាត់មួយ

II. វត្ថុបំណង: ចប់មេរៀនសិស្សអាច:

- បង្ហាញពីមុំដែលកើតឡើងដោយបន្ទាត់ស្របពីរ និង ខ្នាត់មួយបានយ៉ាងត្រឹមត្រូវ
- គណនាមុំត្រូវគ្នា មុំឆ្លាស់ក្នុង មុំឆ្លាស់ក្រៅ មុំទល់កំពូល និង ផលបូកមុំក្នុងរួមខាង និង ក្រៅរួមខាងស្មើ១៨០°
- អនុវត្តន៍មេរៀននេះក្នុងជីវភាពប្រចាំថ្ងៃ

III. រយៈពេល ២ ម៉ោង

IV. សម្ភារៈឧបទេស

- បន្ទាត់, បន្ទាត់កែង, រ៉ាប៉័រទ័រ និង ក្រដាសកាតុង
- សៀវភៅសិស្ស និងសៀវភៅគ្រូ

V. ដំណើកនាំមេរៀន

| សកម្មភាពគ្រូ | ខ្លឹមសាមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| -គ្រូតពិនិត្យវត្តមាន អនាម័យ សណ្ដាប់ធ្នាប់ | -ជំហានទី១<br>(រដ្ឋបាលថ្នាក់ ៥នាទី) | -ប្រធានថ្នាក់រាយការណ៍ |
| -ដូចម្ដេចដែលហៅថាមុំឆ្លាស់ក្នុង ឆ្លាស់ក្រៅ និង មុំត្រូវគ្នា ? | -ជំហានទី២<br>(រំលឹកមេរៀន៥នាទី) | -មុំឆ្លាស់ក្នុង ជាគូរនៃមុំផ្គុំឡើងដោយបន្ទាត់ពីរ និង ខ្នាត់មួយ ។ មុំទាំងពីរនេះត្រូវស្ថិតនៅផ្នែកខាងក្នុង ហើយនៅម្ខាងម្នាក់នៃខ្នាត់ និង មានកំពូលផ្សេងគ្នា ។<br>-មុំឆ្លាស់ក្រៅ ជាមុំពីរស្ថិតនៅផ្នែកខាងក្រៅ ហើយនៅផ្នែកម្ខាងម្នាក់នៃខ្នាត់ និង មានកំពូល ផ្សេងគ្នា ។<br>-មុំត្រូវគ្នា ជាមុំដែលមុំមួយស្ថិតនៅផ្នែកខាងក្នុង និង មុំមួយទៀតស្ថិតនៅខាងក្រៅ ហើយនៅម្ខាងម្នាក់នៃខ្នាត់ និង មានកំពូលផ្សេងគ្នា ។ |

| | | |
|---|---|---|
| -គ្រូឲ្យសិស្សអានឧទាហរណ៍ និង ណែនាំឲ្យសិស្សចុះលេខមុំ A និង B<br><br>-គ្រូបង្ហាញឲ្យសិស្សស្គាល់មុំឆ្លាស់ក្នុង មុំឆ្លាស់ក្រៅ មុំត្រូវគ្នានិង មុំទល់កំពូល បន្ទាប់មកឲ្យសិស្សសន្និដ្ឋាន<br><br>-គ្រូដាក់លំហាត់ឧទាហរណ៍២, ៣ និង ៤ ឲ្យសិស្សគណនាតាមក្រុមរួចឡើង សរសេរចំលើយលើក្តារខៀន<br>ឧទាហរណ៍២:<br>ក្នុងរូបខាងស្តាំនេះបញ្ជាក់ ថាតើគូរបន្ទាត់ណាស្របគ្នា។ហើយមុំ $\angle x, \angle y, \angle z$និង$\angle u$ ណាខ្លះប៉ុនគ្នា?<br><br>-លំហាត់គំរូ១: ក្នុងរូបខាងស្តាំគេមានបន្ទាត់a//bកាត់ដោយខ្នាត់m គណនារង្វាស់មុំ $\angle 1$និង$\angle 4$ | -ជំហានទី៣<br>(មេរៀនប្រចាំថ្ងៃ)<br>៧០នាទី<br>**៧. មុំផ្តុំឡើងដោយបន្ទាត់ស្របពីរ និង ខ្នាត់មួយ**<br>ឧទាហរណ៍១: ក្នុងរូបនេះគេមាន: បន្ទាត់ ប៉ហៅថាខ្នាត់<br>1. មុំក្នុង $\angle A_1, \angle A_2, \angle B_7, \angle B_8$<br>2. មុំក្រៅ $\angle A_3, \angle A_4, \angle B_5, \angle B_6$<br>3. មុំឆ្លាស់ក្រៅគឺគូរ $\angle A_3$និង $\angle B_5$, $\angle A_4$ និង $\angle B_6$<br>4. មុំឆ្លាស់ក្នុងគឺគូរ $\angle A_1$និង $\angle B_7$, $\angle A_2$ និង $\angle B_8$<br>5. មុំត្រូវគ្នាគឺគូរ $\angle A_1$ និង $\angle B_5$, $\angle A_2$និង $\angle B_6$, $\angle A_3$និង $\angle B_7$, $\angle A_4$ និង $\angle B_8$<br> | -សិស្សអានឧទាហរណ៍បន្ទាប់មកឡើង សង់រូប និង ចុះលេខ<br><br>-សិស្សទាញសន្និដ្ឋានជាទូទៅ:<br>បើបន្ទាត់ពីរស្របគ្នាហើយកាត់គ្នាដោយខ្នាត់មួយគេបាន៖<br>1. មុំឆ្លាស់ក្នុងប៉ុនគ្នា<br>2. មុំឆ្លាស់ក្រៅប៉ុនគ្នា<br>3.មុំត្រូវគ្នាប៉ុនគ្នា<br>4. មុំទល់កំពូលប៉ុនគ្នា<br>5. ផលបូកមុំក្នុងរួមខាងមានរង្វាស់ស្មើ $180^\circ$<br>6. ផលបូកមុំក្រៅរួមខាងមានរង្វាស់ ស្មើ $180^\circ$<br> |

| | | |
|---|---|---|
| -លំហាត់គំរូ២:ក្នុងរូបខាងស្តាំនេះគេមានបន្ទាត់ a//b ដោយខ្នាត់t។ គណនារង្វាស់មុំនីមួយៗនៃមុំទាំង៨ ដែលផ្តុំឡើងដោយបន្ទាត់ a//b កាត់ដោយខ្នាត់ t។ | <br> | បន្ទាត់ a//d និង b//c<br>មុំ∠x=∠u, ∠y=∠zមុំត្រូវគ្នា<br>-<u>ចំលើយ</u><br>មុំ∠5និង∠១ជាមុំត្រូវគ្នា<br>នោះគេបាន∠5=∠1<br>តែ $\angle 5=120^o$ នោះ $\angle 1=120^o$<br>ដូចនេះ $\angle 1=120^o$<br>$\angle 1+\angle 4=180^o$<br>$120^o+\angle 4=180^o$<br>$\angle 4=180^o-120^o$<br>$=60^o$<br>ដូចនេះ $\angle 4=60^o$<br>-ចំលើយ:<br>មុំ $\angle E_1$ និង $\angle F_5$ ជាមុំឆ្លាស់ក្រៅ<br>គេបាន 7x=2x+75<br>5x=75<br>$x=\frac{75}{5}=15$<br>ដូចនេះ $\angle E_1=\angle F_7=7x=105^o$<br>$\angle E_1=\angle F_7=105^o$ មុំត្រូវគ្នា<br>$\angle E_3=\angle F_7=105^o$ មុំឆ្លាស់ក្នុង<br>គេមាន $\angle E_1+\angle E_2=180^o$ មុំជាប់បន្ថែមនោះ<br>$105^o+\angle E_2=180^o$<br>$\angle E_2=180^o-105^o$<br>$\angle E_2=75^o$<br>ដូចនេះ $\angle E_2=\angle F_6=75^o$<br>$\angle E_4=\angle F_6=75^o$<br>$\angle E_2=\angle F_8=75^o$ |

| | | |
|---|---|---|
| -ក្នុងរូបខាងស្តាំ គេមានបន្ទាត់ a//b ។<br>គណនារង្វាស់មុំ $\angle x, \angle y$<br><br> | -ជំហានទី៤<br>(ពង្រឹងចំណេះដឹង)<br>(៥នាទី) | ចំលើយ<br>ក, $\angle z=80^o$ មុំត្រូវគ្នា<br>តែ $x+z+45^o=180^o$<br>$x+80^o+45^o=180^o$<br>$x=180^o-125^o$<br>$x=55^o$<br>$\angle y=\angle z+45^o$<br>$\angle y=80^o+45^o=125^o$<br>ដូចនេះ $\angle x=55^o$<br>$\angle y=125^o$<br>ខ, $\angle x+\angle z=117^o$(មុំឆ្លាស់ក្នុង)<br>តែ $\angle z=47^o$ មុំឆ្លាស់ក្នុង<br>$\angle x+47^o=117^o$<br>$\angle x=117^o-47^o$<br>$\angle x=70^o$<br>ដោយ $\angle y+\angle x+\angle z=180^o$<br>$\angle y=180^o-70^o-47^o$<br>$\angle y=63^o$<br>ដូចនេះ $\angle x=70^o$<br>$\angle y=63^o$ |
| -ចូរប្អូនធ្វើលំហាត់សៀវភៅសិស្ស ទំព័រ 150លំហាត់ទី4 | -ជំហានទី៥(បណ្តាំផ្ញើ)<br>(៥នាទី) | -សិស្សយកទៅអនុវត្តន៍ |

# កិច្ចតែងការបង្រៀន

## មុខវិជ្ជា: គណិតវិទ្យាថ្នាក់ទី៧

I. មេរៀនទី ១៤ បន្ទាត់ស្រប និង បន្ទាត់កែង (តចប់)

៨. មុំមានជ្រុងត្រូវគ្នាស្របរៀងគ្នា

៩. មុំមានជ្រុងត្រូវគ្នាកែងរៀងគ្នា

II. វត្ថុបំណងមេរៀន: សិស្សអាច.

- បង្ហាញឲ្យឃើញមុំមានជ្រុងត្រូវគ្នាស្របរៀងគ្នា និង មុំមានជ្រុងត្រូវគ្នាកែងរៀងគ្នាបានត្រឹមត្រូវ
- គណនារង្វាស់មុំដែលមានជ្រុងត្រូវគ្នាស្របរៀងគ្នា និងមុំដែលមានជ្រុងត្រូវគ្នាកែងរៀងគ្នាតាមរយ:ឧទាហរណ៍ លំហាត់គំរូ
- អនុវត្តន៍បានត្រឹមត្រូវក្នុងជីវភាពប្រចាំថ្ងៃ

III. រយ:ពេល២ម៉ោង

IV. សម្ភារ:ឧបទេស

- បន្ទាត់កែង រ៉ាប៉័ទ័រ ក្រដាសកាតុង

V. ដំណឹកនាំមេរៀន

| សកម្មភាពគ្រូ | ខ្លឹមសាមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| -គ្រូតពិនិត្យវត្តមាន អនាម័យ សណ្តាប់ធ្នាប់ | -ជំហានទី១(រដ្ឋបាលថ្នាក់) | -ប្រធានថ្នាក់រាយការណ៍ |
| បើគេមានបន្ទាត់ពីរស្របគ្នាហើយកាត់ ដោយខ្នាត់មួយ<br>តើគេបានមុំណាខ្លះ ស្មើគ្នា? | ជំហានទី២<br>(រំលឹកមេរៀនចាស់) | - មុំត្រូវគ្នាប៉ុនគ្នា<br>- មុំឆ្លាស់ក្នុងប៉ុនគ្នា<br>- មុំឆ្លាស់ក្រៅប៉ុនគ្នា<br>- មុំទល់កំពូលប៉ុនគ្នា |
| -គ្រូបង្ហាញប្រាប់សិស្សមុំត្រូវគ្នាស្របរៀងគ្នា | ជំហានទី៣<br>(មេរៀនប្រចាំថ្ងៃ)<br>**<u>៨.មុំមានជ្រុងត្រូវគ្នាស្របរៀងគ្នា</u>**<br><br> | -សិស្សសង្កេត |

| | | |
|---|---|---|
| -លំហាត់គំរូ<br>ក្នុងករណីនីមួយៗនៃរូបបង្ហាញថា<br>$\angle xoy=\angle x'o'y'$ ឬ $\angle xoy+\angle x'o'y'=180^o$<br><br>ឧទាហរណ៍: ក្នុងករណីនីមួយៗនៃរូប បង្ហាញថា $\angle xoy=\angle x'o'y'$<br>ឬ $\angle xoy+\angle x'o'y'=180^o$<br><br>រូប(b) | <br><br>បើ ox//o'x' , oy//o'y' នោះមុំ $\angle xoy$ និង $\angle x'o'y'$ ហៅថាមុំមានជ្រុងត្រូវគ្នាស្របរៀងគ្នា<br><br>**៩.មុំមានជ្រុងត្រូវគ្នា កែងរៀងគ្នា**<br><br>តាម o គូស ot//o'x'រួច(oy)n(o'x')={A} | ចំលើយ<br>បន្លាយជ្រុង ox កាត់ o'y' ត្រង់ A ។<br>គេបាន $\angle xoy=\angle xAy'$ មុំត្រូវគ្នា<br>$\angle x'o'y'=\angle xAy'$ មុំត្រូវគ្នា<br>ដូចនេះ $\angle xoy=\angle x'o'y'$<br>ជាទូទៅ:<br>មុំពីដែលមានជ្រុងត្រូវគ្នាស្របរៀងគ្នា៖<br>- ជាមុំប៉ុនគ្នាកាលណាវាស្រួចទាំងពីរ ឬ ទាលទាំងពីរ ។<br>- ជាមុំបន្ថែមគ្នាកាលណាមុំស្រួចមួយ ទាលមួយ ។ |

| | | |
|---|---|---|
| <br><br>រូប( c )<br><br> | គេបាន $\angle yot=\angle o'Ay$<br>ហើយ $\angle xoy=90^o-\angle toy$<br>$\angle x'o'y'=\angle o'Ay$<br>ដូចនេះ $\angle xoy=\angle x'o'y'$<br><br>តាម o គូស ot//o'y'<br>នោះគេបាន $ot\perp oy$<br>រួច (ot) n (o'x')={A}<br>គេបាន $\angle oAx'=\angle x'o'y'$ មុំត្រូវគ្នា<br>ហើយ $\angle xoy=90^o-\angle xoA$<br>$\angle x'o'y'=90^o-\angle xoA$<br>ដូចនេះ $\angle xoy=\angle x'o'y'$<br>បន្លាយ oÓ និង o'y' កាត់គ្នាត្រង់ A<br>គេបាន $\angle Aoy=\angle$ æ'o'y'<br>មុំមានជ្រុង<br>ត្រូវគ្នាកែងរៀងគ្នា<br>$\angle Aoy+\angle$ Óoy=$180^o$<br>ដូចនេះ $\angle$ Óoy+$\angle$ æ'o'y'=$180^o$ | ជាទូទៅ:<br>មុំពីរដែលមានជ្រុងត្រូវគ្នា<br>កែងរៀងគ្នា<br>-ជាមុំប៉ុនគ្នាកាលណាវាស្រួច<br>ទាំងពីរ<br>-ជាមុំបន្ថែមគ្នាកាលណាមុំ<br>មួយស្រួច មួយទាល ។ |
| លំហាត់: គេមានត្រីកោណ ABC<br>ដែលមុំទាំងបីជាមុំស្រួចហើយ H<br>ជាអរតូសង់ ។<br>បង្ហាញថា $\angle BAC+\angle BHC=180^O$ | ជំហានទី 4<br>( ពង្រឹងពុទ្ធិ ) | <br><br>គេមាន: $AB\perp CH$<br>$AC\perp BH$ |

| | | |
|---|---|---|
| | | នោះមុំ ∠BAC និង ∠BHCមុំមាន ជ្រុងត្រូវគ្នាកែងរៀងគ្នាដោយមុំ ∠BACជាមុំស្រួច ហើយ ∠BHC ជាមុំទាល<br>ដូចនេះ $\angle BAC+\angle BHC=180^{O}$ |
| ចូរប្អូនធ្វើលំហាត់ទី 5,6ទំព័រ150 | ជំហានទី 5<br>( បណ្តាំផ្ញើ ) | -សិស្សយកទៅអនុវត្តន៍ |

# កិច្ចតែងការបង្រៀន( ថ្នាក់ទី៧)

មេរៀនទី១៥ **រូបធរណីមាត្រដែលមានវិមាត្រពីរ**

+ខ្លឹមសារមេរៀន : **១ ពហុកោណ**

**១.១ សញ្ញាណពហុកោណ**

**១.២ ប្រភេទនៃពហុកោណប៉ោង**

+រយៈពេល០១ម៉ោង

I.វត្ថុបំណងនៃមេរៀន

-ចំណេះដឹង : កំណត់សញ្ញាណពហុកោណ

ស្គាល់ប្រភេទនៃពហុកោណប៉ោង

-បំណិន : គូសរូបពហុកោណប៉ោង

-ឥរិយាបថ : មានស្មារតីប្រុងប្រយ័ត្ន យកចិត្តទុកដាក់ស្តាប់គ្រូពន្យល់ ។

II.ពេលវេលា: ថ្ងៃ……………..ទី……………..ខែ…………..ឆ្នាំ………..

III.សម្ភារៈឧបទេស

-សៀវភៅសិស្ស និងសៀវភៅគ្រូ

-ផ្ទាំងក្រដាសបង្ហាញរូបពហុកោណនិងពហុកោណប៉ោង

IV.ដំណើកនាំមេរៀន

| សកម្មភាពគ្រូ | ខ្លឹមសាមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| -គ្រូត្រួតពិនិត្យវត្តមាន អនាម័យ សណ្តាប់ធ្នាប់និងវិន័យ | ជំហានទី១ (រដ្ឋបាលថ្នាក់)<br>(៥នាទី)<br>-គ្រូពីនិត្យវត្តមាន អនាម័យ សណ្តាប់ធ្នាប់ និង វិន័យ | តំណាងសិស្សឡើងរាយការណ៍ |
| ដាក់សំនួររំលឹបហាត់អោយសិស្សដើម្បីរំលឹកមេរៀនចាស់។ | ជំហានទី២ (រំលឹកមេរៀនចាស់)<br>(៥នាទី)<br>ចូរឲ្យលក្ខណនៃ មុំមានជ្រុងត្រូវគ្នាកែងរៀងគ្នា | មុំពីរដែលមានជ្រុងត្រូវគ្នា កែង រៀងគ្នា<br>-ជាមុំប៉ុនគ្នាកាលណាវាស្រួចទាំងពីរ ឬទាលទាំងពីរ<br>-ជាមុំបន្ថែមគ្នាកាលលណា |

| | | |
|---|---|---|
| តើពហុកោណជាអ្វី?<br>តើពហុកោណមានប៉ុន្មានប្រភេទ?<br>ឲ្យសិស្សគូសរូបចូលក្នុងសៀវភៅរបស់គេ<br>គូសបង្ហាញសិស្សនូវរូប ចតុកោណប៉ោង និងចតុកោណផត | <u>ជំហានទី៣</u> (ដំណឹកនាំមេរៀន)<br>(៨០នាទី)<br>មេរៀនទី១៥<br>**រូបធរណីមាត្រដែលមានវិ មាត្រពី**<br>**១ ពហុកោណ**<br>**១.១ សញ្ញាណពហុកោណ**<br>ពហុកោណជាផ្នែកមួយនៃប្លង់ខ័ណ្ឌដោយខ្សែបិទជិត។គេមានពហុកោណប៉ោង និងពហុកោណផត។<br><br>ពហុកោណប៉ោង<br><br>ពហុកោណផត | ផ្តោតអារម្មណ៍ និងយកចិត្តទុកដាក់គ្រូពន្យល់<br>សិស្សគូសរូបចូលក្នុងសៀវភៅ<br>សិស្សយកចិត្តទុកដាក់មើលគ្រូគូសបង្ហាញ<br>សិស្សយកចិត្តទុកដាក់គូសរូប |
| ចូរប្អូនឲ្យលក្ខណៈចតុកោណផត *OVUTSRXP* ។ | ពហុកោណប៉ោងជាពហុកោណដែលស្ថិតនៅតែម្ខាងធៀបនិងជ្រុងណា មួយ។<br>• ចំនុច $A,B,C,D,E\,\&\,F$ ជាកំពូល | ពហុកោណផតជាពហុកោណដែលមិនជាពហុកណប៉ោង។<br>• ចំនុចជាកំពូលនៃចតុកោណផត |

| | | |
|---|---|---|
| | នៃចតុកោណប៉ោង<br>• អង្កត់ $AB, BC, CD, DE, EF$ & $FA$ ជាជ្រុងនៃពហុកោណប៉ោង<br>• អង្កត់ $AC, AD, ..., FE$ ជាអង្កត់ទ្រូងនៃពហុកោណប៉ោង<br>• មុំ $\widehat{ABC}, \widehat{BCD}, ....$ ជាមុំក្នុងនៃពហុកោណប៉ោង $ABCDEF$ ។ | • អង្កត់ $OV, VU, UT, ...$ & $PO$ ជាជ្រុងនៃពហុកោណប៉ោង<br>• អង្កត់ $OV, VU, ..., PO$ ជាអង្កត់ទ្រូងនៃពហុកោណប៉ោង<br>• $\widehat{OVU}, \widehat{VUT}, ....$ ជាមុំក្នុងនៃពហុកោណប៉ោង $OVUTSRXP$ ។ |
| បង្ហាញផ្ទាំងរូបនៃប្រភេទពហុកោណនីមួយៗ | **១.២ ប្រភេទនៃពហុកោណ**<br>គេកំណត់ប្រភេទពហុកោណទៅតាមចំនួនជ្រុងរបស់វា។ | |
| តើពហុកោណដែលមានជ្រុង៣មានឈ្មោះអ្វី? | <br>ត្រីកោណ(ជ្រុង៣) | ពហុកោណដែលមានជ្រុង៣មានឈ្មោះត្រីកោណ |
| តើពហុកោណដែលមានជ្រុង៤មានឈ្មោះអ្វី? | <br>ចតុកោណ(ជ្រុង៤) | ពហុកោណដែលមានជ្រុង៤មានឈ្មោះ<br>ចតុកោណ |
| តើពហុកោណដែលមានជ្រុង៥មានឈ្មោះអ្វី? | <br>បញ្ចកោណ(ជ្រុង៥) | ពហុកោណដែលមានជ្រុង៥មានឈ្មោះ<br>បញ្ចកោណ |
| តើពហុកោណដែលមានជ្រុង៦មានឈ្មោះអ្វី? | | |

| | | |
|---|---|---|
| តើពហុកោណដែលមានជ្រុង ៨មានឈ្មោះអ្វី?<br><br>តើពហុកោណដែលមានជ្រុង ១០មានឈ្មោះអ្វី? | <br>ឆកោណ(ជ្រុង៦)<br><br>អដ្ឋកោណ(ជ្រុង៨)<br><br>ទសកោណ(ជ្រុង១០) | ពហុកោណដែលមានជ្រុង៦មាន ឈ្មោះ<br>ឆកោណ<br><br>ពហុកោណដែលមានជ្រុង៨មាន ឈ្មោះ<br>អដ្ឋកោណ<br><br>ពហុកោណដែលមានជ្រុង១០មាន ឈ្មោះ ទសកោណ |
| ចូរប្អូនរៀបរាប់ឈ្មោះប្រភេទ ពហុកោណ? | <u>ជំហានទី៤</u> (ពង្រឹងពុទ្ធិ)<br>(៥នាទី) | ត្រីកោណ ចតុកោណ បញ្ចកោណ ឆកោណ អដ្ឋកោណ ទសកោណ |
| -គ្រូដាក់លំហាត់ទី១ទី២ ទំព័រ១៦៦ឲ្យសិស្សធ្វើនៅ ផ្ទះនិងណែនាំសិស្សឲ្យគោរព វិន័យនិងច្បាប់ចរាចរណ៍ | <u>ជំហានទី៥</u> (កិច្ចការផ្ទះ)<br>(៥នាទី)<br><br>លំហាត់ទី១ និង ទី២ ទំព័រ១៦៦ | សិស្សកត់ត្រាលំហាត់និងស្តាប់ ដំបូន្មានគ្រូ |

# កិច្ចតែងការបង្រៀន(ថ្នាក់ទី៧)

មេរៀនទី១៥ **រូបធរណីមាត្រដែលមានវិមាត្រពីរ**

+ខ្លឹមសារមេរៀន : ២. **ត្រីកោណ**

២.១ **និយមន័យ**

២.២ **លក្ខណៈទូទៅនៃត្រីកោណ**

២.៣ **ប្រភេទត្រីកោណ**

+រយៈពេល០១ម៉ោង

I.វត្ថុបំណងនៃមេរៀន

-ចំណេះដឹង : កំណត់បានពីនិយមន័យត្រីកោណលក្ខណៈទូទៅនៃត្រីកោណ និងប្រភេទនៃ ត្រីកោណឲ្យបានត្រឹមត្រូវតាមរយៈការពន្យល់របស់គ្រូ។

-បំណិន : រៀបរាប់បានអំពីធាតុនៃត្រីកោណ សង់មេដ្យានកម្ពស់ មេដ្យាទ័រ កន្លះបន្ទាត់ ពុះមុំ និងប្រាប់ប្រពេទនៃត្រីកោណឲ្យបានត្រឹមត្រូវ តាមរយៈឧទាហរណ៍។

-ឥរិយាបថ : មានស្មារតីប្រុងប្រយ័ត្ន ពេលសង់លក្ខណៈទូទៅនៃត្រីកោណ និងកោណត់ ឈ្មោះនៃត្រីកោណទៅតាមប្រភេទឲ្យបានខ្ពស់។

II.ពេលវេលា: ថ្ងៃ……………..ទី……………..ខែ…………..ឆ្នាំ……….

III.សម្ភារៈឧបទេស

-សៀវភៅសិស្ស :ទំព័រទី១៥២ ដល់ទំព័រទី១៥៥ បោះពុម្ពឆ្នាំ២០០៩

-សៀវភៅគ្រូ : ទំព័រទី… ដល់ទំព័រទី….

-បន្ទាត់ឈើ ដែកឈាន រ៉ាប៉ទ័រ ឬកែង

-ផ្ទាំងក្រដាសបង្ហាញប្រភេទត្រីកោណ

IV.ដំណើកនាំមេរៀន

| សកម្មភាពគ្រូ | ខ្លឹមសាមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| -គ្រូពិនិត្យអវត្តមាន អនាម័យ សណ្តាប់ធ្នាប់ និង វិន័យ | ជំហានទី១<br>(១ទៅ២នាទី)(រដ្ឋបាលថ្នាក់)<br>-គ្រូពិនិត្យអវត្តមាន អនាម័យ សណ្តាប់ធ្នាប់ និង វិន័យ | ប្រធានថ្នាក់ឡើងរាយការណ៍ |
| គ្រូសួរ<br>-ដូចម្តេចដែលហៅថាពហុកោណ? | ជំហានទី២ (៣-៥នាទី)<br>(រំលឹកមេរៀនចាស់) | សិស្សឆ្លើយ<br>- |

| | | |
|---|---|---|
| -តើពហុកោណដែលមានជ្រុងបីមានឈ្មោះអ្វី? | | ជាផ្នែកមួយនៃប្លង់ខ័ណ្ឌដោយខ្សែកាច់បិទជិត។<br>-ពហុកោណមានជ្រុងបីជាត្រីកោណ |
| គ្រូសរសេរចំណងជើងមេរៀន<br><br>ចូរឲ្យនិយមន័យត្រីកោណ ណែនាំទីកំណត់សរសេរ<br><br>ណែនាំក្នុងត្រីកោណមួយមានធាតុ៩គឺ កំពូល៣ ជ្រុង៣ និងមុំ៣<br><br>ណែនាំ: $M$ កណ្តាល $BC$ ,$AM$ ជាមេដ្យាននៃ $\Delta ABC$ ត្រូវនឹងជ្រុង $BC$ | <u>ជំហានទី៣</u>(មេរៀនប្រចាំថ្ងៃ)<br>មេរៀនទី១៥<br>**រូបធរណីមាត្រដែលមានវិមាត្រពីរ**<br>២. **ត្រីកោណ**<br>២.១ **និយមន័យ**<br><br><br>-ពហុកោណមានជ្រុងបីហៅថាត្រីកោណ។ កំណត់សរសេរ<br>$\Delta ABC$<br>+ធាតុមាន៖<br>-មុំបី គឺ $\angle BAC$ ឬ $\angle A$<br>$\angle ACB$ ឬ $\angle C$ និង $\angle ABC$ ឬ $\angle B$<br>-កំពូលបីគឺ កំពូល $A, B, C$<br>-ជ្រុងបីគឺ $AB, AC, BC$ ។<br>២.២ **លក្ខណ:ទូទៅនៃត្រីកោណ**<br>ក. <u>មេដ្យាន</u><br><br> | -រៀបចំសម្ភារ:សិក្សា<br><br>ត្រីកោណជាពហុកោណដែលមានជ្រុងបី<br><br>កត់ត្រា<br><br>គូររូប<br>ស្តាប់ |

| | | |
|---|---|---|
| ណែនាំជាទូទៅ | +<u>ជាទូទៅ</u> មេដ្យាននៃត្រីកោណមួយគឺជាអង្កត់ដែលភ្ជាប់ពីកំពូលទៅចំនុចកណ្តាលនៃជ្រុងឈម។ | កត់ត្រា |
| ណែនាំ<br>$AH \perp BC$ គេថា $AH$ ជាកំពស់នៃ $\Delta ABC$ ចំពោះជ្រុង $BC$ | ខ.<u>កម្ពស់</u><br><br>+<u>ជាទូទៅ</u> កំពស់នៃត្រីកោណមួយជាអង្កត់ដែលគូសចេញពីកំពូលទៅកែងនឹងជ្រុងឈមបន្លាយនៃជ្រុងឈម។ | គូររូប<br>ស្តាប់<br>កត់ត្រា |
| ណែនាំគូររូប<br>$M$ កណ្តាល $BC$ ,$d \perp BC$ ត្រង់ $M$ នោះ $d$ ជាមេដ្យាទ័រត្រូវនឹងជ្រុង $BC$ | គ.មេដ្យាទ័រ<br><br>+<u>ជាទូទៅ</u> មេដ្យាទ័រនៃត្រីកោណមួយជាបន្ទាត់ដែលកែងនឹងជ្រុងត្រង់ចំនុចកណ្តាល។ | |
| ណែនាំគូររូប<br>$\angle BAI = \angle IAC, [AI)$ ហៅថាកន្លះបន្ទាត់ពុះមុំ $\angle A$ | ឃ. កន្លះបន្ទាត់ពុះមុំក្នុង<br><br>+<u>ជាទូទៅ</u> កន្លះបន្ទាត់ពុះមុំក្នុង | គូររូប<br>ស្តាប់ |

| | | |
|---|---|---|
| | នៃត្រីកោណមួយជាកន្លះបន្ទាត់ដែលចែកមុំក្នុងជាពីរផ្នែកស្មើគ្នា។<br>២.៣ ប្រភេទត្រីកោណ<br>-ត្រីកោណសាមញ្ញ | កត់ត្រា |
| បិតផ្ទាំងក្រដាសប្រភេទនៃត្រីកោណ រួចណែនាំ<br>តើមុំទាំងបីរបស់ត្រីកោណសាមញ្ញប៉ុនគ្នាឬទេ?ចុះជ្រុងទាំងបី? | $\angle A \neq \angle B \neq \angle C$<br>$AB \neq AC, AB \neq BC, AC \neq BC$<br> | សង្កេត<br>មុំទាំងបីមិនប៉ុនគ្នាទេ<br>ជ្រុងទាំបីក៏មិនប៉ុនគ្នាដែរ |
| តើ $\angle A$ ជាមុំអ្វី? | -ត្រីកោណកែង<br>$\angle A$ ជាមុំកែង<br>ជ្រុង $AB \perp AC$<br> | |
| | -ត្រីកោណសមបាត<br>មុំពីរប៉ុនគ្នាំ $\angle B = \angle C$<br>ជ្រុងពីរប៉ុនគ្នា $AB = AC$<br> | $\angle A$ ជាមុំកែង |
| តាមរូបតើមានមុំណាប៉ុនគ្នា?<br>ជ្រុងណាខ្លះប៉ុនគ្នា? | -ត្រីកោណសម័ង្ស<br>$\angle A = \angle B = \angle C$<br>$AB = AC = BC$<br> | មុំពីរប៉ុនគ្នាំ $\angle B = \angle C$<br>ជ្រុងពីរប៉ុនគ្នា $AB = AC$ |

| | | |
|---|---|---|
| តើមុំទាំងបីប៉ុនគ្នាឬទេ?ចុះជ្រុងទាំងបីវិញ?<br><br>បង្ហាញបន្ថែមប្រភេទនៃត្រីកោណកែង | -ត្រីកោណកែងសមបាត<br>$\angle B = \angle C = 45°$<br>ឬ $AB = AC$ & $\angle A = 90°$<br><br>-ត្រីកោណកែងកន្លះសម័ង្ស<br> | មុំទាំងបីប៉ុនគ្នា<br>ជ្រុងទាំងបីប៉ុនគ្នា<br><br>កត់ត្រា<br><br>ស្តាប់ |
| សួរ:<br>-ដូចម្តេចដែលហៅថាមេដ្យាន? មេដ្យាទ័រ? | <u>ជំហានទី៤</u> (ពង្រឹងចំណេះដឹង)<br>(៧ទៅ១០នាទី) | -មេដ្យានជាអង្កត់ភ្ជាប់ពីកំពូលទៅត្រង់ចំនុចកណ្តាលជ្រុងឈម។មេដ្យាទ័រគឺបន្ទាត់ដែលកែងនឹងជ្រុងត្រង់ចំនុចកណ្តាល។ |
| -គ្រូដាក់លំហាត់ ទី១១ ទី១២ទំព័រ១៦៦ឲ្យសិស្សធ្វើនៅផ្ទះ និងណែនាំសិស្សគោរពវិន័យ និងច្បាប់ចរាចរណ៍ | <u>ជំហានទី៥</u> (កិច្ចការផ្ទះ)<br>(២ទៅ៣នាទី)<br>-ដោះស្រាយលំហាត់ទី១១ ទី១២ ទំព័រ១៦៦ | -សិស្សកត់ត្រាលំហាត់ធ្វើនៅផ្ទះនិងស្តាប់ដំបូន្មានគ្រូ |

## កិច្ចតែងការបង្រៀន(ថ្នាក់ទី៧)

មេរៀនទី១៥ **រូបធរណីមាត្រដែលមានវិមាត្រពីរ**

+<u>ខ្លឹមសារមេរៀន :</u> ២.៤ ផលបូកមុំក្នុង និងក្រៅនៃត្រីកោណ

ក ផលបូកមុំក្នុងត្រីកោណ

ខ ទៅនាក់ទំនងរវាងមុំក្នុង និងមុំក្រៅ

២.៥ សំណង់ត្រីកោណ

៣ ចតុកោណ

៣.១ សញ្ញាណ

៣.២ លក្ខណៈទូទៅនៃចតុកោណ

៣.៣ ប្រភេទចតុកោណប៉ោង

+រយៈពេល០២ម៉ោង

I.<u>វត្ថុបំណងនៃមេរៀន</u>ក្រោយពីរៀនចប់ចំនុចនេះសិស្សអាច

-ចំណេះដឹង : ផលបូកមុំក្នុង និងក្រៅនៃត្រីកោណទៅនាក់ទំនងរវាងមុំក្នុង និងមុំក្រៅ លក្ខណៈទូទៅនៃចតុកោណនិងប្រភេទចតុកោណប៉ោង

-បំណិន :ចេះសង់ចតុកោណ

-ឥរិយាបថ : មានស្មារតីប្រុងប្រយ័ត្ន យកចិត្តទុកដាក់ស្តាប់គ្រូពន្យល់ ។

II.<u>ពេលវេលា:</u> ថ្ងៃ……………..ទី……………..ខែ…………..ឆ្នាំ……….

III.<u>សម្ភារ:</u>ឧបទេស

-សៀវភៅសិស្ស និងសៀវភៅគ្រូ

-ផ្ទាំងក្រដាសបង្ហាញរូបកាចតុកោណ

IV.<u>ដំណើកនាំមេរៀន</u>

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| -គ្រូត្រួតពិនិត្យវត្តមាន អនាម័យ សណ្តាប់ធ្នាប់និងវិន័យ | <u>ជំហានទី១</u> (រដ្ឋបាលថ្នាក់) (៥នាទី) -គ្រូពីនិត្យវត្តមាន អនាម័យ សណ្តាប់ធ្នាប់ និង វិន័យ | តំណាងសិស្សឡើងរាយការណ៍ |
| | <u>ជំហានទី២</u> (រំលឹកមេរៀនចាស់) (៥នាទី) | |

| | | |
|---|---|---|
| ដាក់សំនួរលំហាត់អោយសិស្សដើម្បីរំលឹកមេរៀន<br>ចូរប្អូនមើលសម្មតិកម្មតើមានសម្មកម្មអ្វីខ្លះ? | ប្រាប់ប្រភេទនៃត្រីកោណខាងក្រោម<br><br> | វាជាត្រីកោណកន្លះសម័ង្ស ព្រោះ មានមុំ $30^\circ$ &$90^\circ$<br><br>វាជាត្រីកោណសមបាទ ព្រោះមានមុំពីរប៉ុនគ្នា |
| បង្ហាញក្រដាសកាតុងដែមានរូប<br><br>បន្ទាត់ $xy \parallel BC$ តើយើងទទួលបានសម្មកម្មអ្វីខ្លះ?<br>តើ $\angle xAy$ ជាមុំអ្វី? ស្មើប៉ុន្មាន?<br>ស្មើនឹងមុំណាបូកមុំណា?<br><br>តើយើងបានសម្មតិកម្មអ្វីខ្លះ? | <u>ជំហានទី៣</u> (ជំណឹកនាំមេរៀន)<br>(៨០នាទី)<br>**មេរៀនទី៦ រូបធរណីមាត្រដែលមានវិមាត្រពីរ**<br>**២.៤ ផលបូកមុំក្នុងនិងមុំក្រៅនៃត្រីកោណ**<br>**ក) ផលបូកមុំក្នុងត្រីកោណ**<br><br>តាមកំពូល $A$ នៃត្រៃកោណ $ABC$ គេគូសបន្ទាត់ $xy \parallel BC$ ។គេបាន<br>$\angle A + \angle A_1 + \angle A_2 = 180^\circ$ (មុំជាប់បន្ថែម)<br>តែ $\angle A_1 = \angle B$ (មុំឆ្លាស់ក្នុង)<br>$\angle A_2 = \angle C$ (មុំឆ្លាស់ក្នុង)<br>ដូច្នេះ $\angle A + \angle B + \angle C = 180^\circ$<br>**លំហាត់គំរូ២** គណនាមុំ $x$ ក្នុងរូប<br> | ផ្តោតអារម្មណ៍ និងយកចិត្តទុកដាក់គ្រូពន្យល់ និងបង្ហាញរូប<br><br>សិស្សគូសរូបចូលក្នុងសៀវភៅ<br><br>$\angle A_1 = \angle B$ (មុំឆ្លាស់ក្នុង)<br>$\angle A_2 = \angle C$ (មុំឆ្លាស់ក្នុង)<br>$\angle xAy$ ជាមុំរាប ស្មើនឹង $180^\circ$<br>$\angle A + \angle A_1 + \angle A_2 = \angle xAy$<br>$= 180^\circ$<br><br>វាជាត្រីកោណសមបាត និង មានមុំកំពូល $2x$ និងមុំបាត $38^\circ$ |

| | | |
|---|---|---|
| | **ចម្លើយ** គេមាន $2x+38^\circ+38^\circ=180^\circ$<br>($38^\circ$ ជារង្វាស់មុំបាទនៃត្រីកោនសមបាទ)<br>ដូច្នេះ $x=52^\circ$ ។ | |
| តាមលំហាត់គំរូ២ ចូរប្អូនទាញ ជាទូទៅ | **ខ ទៅនាក់ទំនងរវាងមុំក្នុង និងមុំក្រៅ**<br> | **ជាទូទៅ** ផលបូកមុំក្នុងទាំងបីនៃត្រីកោណស្មើនឹង $180^\circ$ |
| តើត្រីកោណ $ABC$ មានមុំក្នុងណាខ្លះ?ផលបូកមុំទាំងនោះស្មើនិងប៉ុន្មាន?<br>តើមុំក្រៅនៃ $\Delta ABC$ មានអ្វីខ្លះ? | $\angle ACx$ ហៅថាមុំក្រៅត្រង់ $C$ នៃ $\Delta ABC$<br>$\angle CBy$ ហៅថាមុំក្រៅត្រង់ $B$ នៃ $\Delta ABC$<br>$\angle BAz$ ហៅថាមុំក្រៅត្រង់ $A$ នៃ $\Delta ABC$<br>គេដឹងថា $\angle A+\angle B+\angle C=180^\circ$<br>(ផលបូកមុំក្នុងត្រីកោណ) | ត្រីកោណ $ABC$ មានមុំក្នុង<br>$\angle CAB, \angle ABC \;\&\; \angle BCA$<br>$\angle A+\angle B+\angle C=180^\circ$<br>មុំក្រៅនៃ $\Delta ABC$ មាន $\angle ACx$<br>$\angle CBy$ និង $\angle BAz$ |
| តើផលបូកមុំជាប់បន្ថែមស្មើនិងប៉ុន្មាន? | $\angle A+\angle BAz=180^\circ$ (មុំជាប់បន្ថែម)<br>$\angle A+\angle BAz=\angle A+\angle B+\angle C$<br>$\Rightarrow \angle BAz=\angle B+\angle C$<br>ដូច្នេះ $\angle BAz=\angle B+\angle C$ | ផលបូកមុំជាប់បន្ថែមស្មើនិង $180^\circ$ |
| តាមលក្ខណៈទាំងនេះ ចូរប្អូនទាញ ជាទូទៅ | **២.៥ សំណង់ត្រីកោណ**<br>**ឧទាហរណ៍១** សង់ត្រីកោណ $ABC$ មួយដោយស្គាល់ $\angle A=60^\circ$ ,<br>$AB=4cm$ , $AC=5cm$<br>**សំណង់** គូស $AC=5cm$ ដោយប្រើរ៉ាប៉័ទ័រគូស $\angle CAx=60^\circ$ | **ជាទូទៅ** មុំក្រៅមួយនៃត្រីកោណស្មើនឹងផលបូកមុំក្នុងពីរទៀតដែលមិនជាប់និងវា។<br>គូស $AC=5cm$ ដោយប្រើរ៉ាប៉័ទ័រគូស $\angle CAx=60^\circ$ |
| ឲ្យសិស្សទាញយកបន្ទាត់ក្រិតនិងប្រើរ៉ាប៉័ទ័រដើម្បីវាស់មុំ |  |  |

| | | |
|---|---|---|
| | ដោយប្រើបន្ទាត់លេខដៅចំនុច $B$ នៅលើ $Ax$ ដែល $AB=4cm$ ទាញភ្ជាប់ឲ្យបានអង្កត់ $CB$ ។ គេបាន $\Delta ABC$ ដែលស្វូររក ។<br>**៣ ចតុកោណ**<br>**៣.១ សញ្ញាណ**<br>ចតុកោណគឺជាពហុកោណដែលមានជ្រុង៤។<br>**៣.២ លក្ខណៈទូទៅនៃចតុកោណ**<br>**ចតុកោណប៉ោង** គឺជាចតុកោណដែលស្ថិតនៅតែម្ខាងធៀបនិងជ្រុងណាមួយ<br><br>**លក្ខណៈ**<br>$A\&C, B\&D$ ជាកំពូលឈមគ្នា<br>$AB\&CD, AD\&BC$ ជាជ្រុងឈមគ្នា<br>$\angle A\&\angle B, \angle B\&\angle C$ ជាមុំជាប់នឹងជ្រុងតែមួយ $AC\&BD$ ជាអង្កត់ទ្រូង | |
| ចូរសង្កេតមើលចតុកោណប៉ោង តើចតុកោណមានលក្ខណៈអ្វីខ្លះ? | | មាន៤ចំនុច ដែលភ្ជាប់គ្នាដែលជ្រុងនីមួយៗស្ថិតនៅតែម្ខាងធៀបនិងជ្រុងណាមួយ |
| ចូរសង្កេតមើលចតុកោណប៉ោង តើចតុកោណមានលក្ខណៈអ្វីខ្លះ? | **ចតុកោណខ្វែង** គឺជាចតុកោណដែលមានជ្រុងកាត់គ្នាត្រង់ចំនុចមួយដែលមិនមែនជាកំពូលនៃចតុកោណ<br> | មានត្រីកោណពីរ ដែលមានមុំទល់កំពូលមួយ |

| | | |
|---|---|---|
| ចូរសង្កេតមើលចតុកោណប៉ោង តើចតុកោណមានលក្ខណៈអ្វីខ្លះ?<br><br>ឲ្យសិស្សគូសរូប ដោយប្រើបន្ទាត់ ប៉ាប់ទ័រ និងដៃកឈាន | **លក្ខណៈ**<br>ជ្រុង $BC$ & $AD$ កាត់គ្នាត្រង់ចំនុច $O$ ដែលមិនមែនជាកំពូលនៃជតុកោណ<br>**ចតុកោណផត** គឺជាចតុកោណដែលមានបន្លាយនៃជ្រុងមួយកាត់ជ្រុងមួយទៀតនៃចតុកោណ<br><br><br>**លក្ខណៈ**<br>បន្លាយនៃជ្រុង $AD$ កាត់ជ្រុង $BC$ ឬបន្លាយនៃជ្រុង $CD$ កាត់ជ្រុង $AB$<br>**៣ ប្រភេទចតុកោណប៉ោង**<br><br>ចតុកោណសាមញ្ញ<br><br>ចតុកោណព្នាយ<br><br>ចតុកោណព្នាយកែង | មានបន្លាយនៃជ្រុងមួយកាត់ជ្រុងមួយទៀតនៃចតុកោណ<br><br>ឲ្យសិស្សគូសរូបចូលក្នុងសៀវភៅ |

| | | |
|---|---|---|
| | <br>ចតុកោណព្នាយសមបាត<br><br>ប្រលេឡូក្រាម<br><br>ចតុកោណកែង<br><br>ការេ<br><br>ចតុកោណស្មើ | |
| គណនាមុំ $x$ ក្នុងរូបខាងស្តាំ | <u>ជំហានទី៤</u> (ពង្រឹងពុទ្ធិ)<br>(៥នាទី)<br> | គណនាមុំ $x$<br>$\angle MPN + 141^{\circ} = 180^{\circ}$ (មុំជាប់បន្ថែម) |

| | | |
|---|---|---|
| | | $\angle MPN = 180^\circ - 141^\circ = 39^\circ$<br>គេមាន $x = 99^\circ + 39^\circ$ (មុំក្រៅត្រីកោណ)<br>ដូច្នេះ មុំ $x = 138^{\circ\pm}$ |
| -គ្រូដាក់លំហាត់ទី១ទី២ ទំព័រ៧១ ឲ្យសិស្សធ្វើនៅផ្ទះ និងណែនាំសិស្សឲ្យគោរពវិន័យនិងច្បាប់ចរាចរណ៍ | <u>ជំហានទី៥</u> (កិច្ចការផ្ទះ)<br>(៥នាទី)<br><br>លំហាត់ទី១ និង ទី២ ទំព័រ៧១ | សិស្សកត់ត្រាលំហាត់និងស្តាប់ដំបូន្មានគ្រូ |

# កិច្ចតែងការបង្រៀន( ថ្នាក់ទី៧)

មេរៀនទី១៥ **រូបធរណីមាត្រដែលមានវិមាត្រពីរ**

+ខ្លឹមសារមេរៀន : **៤ ចតុកោណកែង**

**៤.១ សញ្ញាណ**

**៤.២ លក្ខណះ**

**៤.៣ សំណង់ចតុកោណកែង**

**៥ ការេ**

**៥.១ និយមន័យ**

**៥.២ លក្ខណះការេ**

**៥.៣ សំណង់ការេ**

+រយៈពេល០២ម៉ោង

I.វត្ថុបំណងនៃមេរៀន

-ចំណេះដឹង : កំណត់លក្ខណៈនៃចតុកោណកែងនិងការេ

-បំណិន : សង់ចតុកោណកែងនិងការេ

-ឥរិយាបថ : មានស្មារតីប្រុងប្រយ័ត្ន យកចិត្តទុកដាក់ស្តាប់គ្រូពន្យល់ ។

II.ពេលវេលា: ថ្ងៃ……………..ទី……………...ខែ…………..ឆ្នាំ………..

III.សម្ភារ:ឧបទេស

-សៀវភៅសិស្ស និងសៀវភៅគ្រូ

-ផ្ទាំងក្រដាសបង្ហាញរូបការេនិងចតុកោណកែង

-បន្ទាត់ក្រឹត រ៉ាប៉ទ័រ និងដែកឈាន

IV.ដំណើកនាំមេរៀន

| សកម្មភាពគ្រូ | ខ្លឹមសាមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| -គ្រូត្រួតពិនិត្យវត្តមាន អនាម័យ សណ្តាប់ធ្នាប់និងវិន័យ | ជំហានទី១ (រដ្ឋបាលថ្នាក់)<br>(៥នាទី)<br>-គ្រូពីនិត្យវត្តមាន អនាម័យ សណ្តាប់ធ្នាប់ និង វិន័យ | តំណាងសិស្សឡើងរាយការណ៍ |

| | | |
|---|---|---|
| ដាក់សំនួររើលំហាត់អោយសិស្សដើម្បីរំលឹកមេរៀនចាស់។ | <u>ជំហានទី២</u> (រំលឹកមេរៀនចាស់)<br>(៥នាទី)<br>តើចតុកោណមានប៉ុន្មានប្រភេទ? អ្វីខ្លះ?<br>តើចតុកោណកែង និងការេជាប្រភេទចតុកោណអ្វី? | ចតុកោណមានបីប្រភេទគឺ ចតុកោណប៉ោង ចតុកោណខ្វែង និងចតុកោណផត<br>ចតុកោណកែង និងការេជាប្រភេទចតុកោណប៉ោង |
| ឲ្យសិស្សសង្កេតនូវការបង្ហាញរបស់គ្រូ<br>បង្ហាញរូបចតុកោណកែងឲ្យសិស្ស<br>ប្រាប់សិស្សឲ្យប្រើប្រាស់បន្ទាត់ក្រឹត រឺដែកឈាន និងរ៉ាប៉ទ័រដើម្បីសង់ចតុកោណកែង<br><br>ចូរប្អូនសង្កេតមើលរូបតើចតុកោនកែងមានលក្ខណៈអ្វីខ្លះ? | <u>ជំហានទី៣</u> (ដំណឹកនាំមេរៀន)<br>(៨០នាទី)<br>មេរៀនទី៦**រូបធរណីមាត្រដែលមានវិមាត្រពីរ**<br>**៤ ចតុកោណកែង**<br>**៤.១ សញ្ញាណ**<br>បើមុំទាំងអស់នៃចតុកោណកែងជាមុំកែងនោះ គេថាចតុកោណនោះជា**ចតុកោណកែង** ។<br><br>**ជាទូទៅ** ចតុកោណកែង ជាចតុកោណដែលមានមុំកែង៤។<br>**៤.២ លក្ខណៈ**<br><br>-មុំទាំងបួនជាមុំកែង<br>-ជ្រុងជាប់កែងគ្នា | ផ្តោតអារម្មណ៍ និងយកចិត្តទុកដាក់គ្រូពន្យល់<br><br>សិស្សគូសរូបចូលក្នុងសៀវភៅ<br><br>-មុំទាំងបួនជាមុំកែង<br>-ជ្រុងជាប់កែងគ្នា<br>-ជ្រុងឈមស្របគ្នា<br>-មានជ្រុងពីរៗប៉ុនគ្នា |

| | | |
|---|---|---|
| ឲ្យសិស្សគិតនិងដោះស្រាយ លមហាត់គំរូ១ ដោយឲ្យ សិស្សសង់ដោយខ្លួនឯង | -ជ្រុងឈមស្របគ្នា<br><br>អង្កត់ទ្រូងមានរង្វាស់ស្មើគ្នា ហើយស្របគ្នាត្រង់ចំនុច កណ្តាលរៀងគ្នា។<br><br>មេដ្យាទ័រនៃជ្រុងឈមជាអ័ក្សឆ្លុះ ហើយកែងគ្នានិងប្រសព្វគ្នាត្រង់ ចំនុចកណ្តាលរៀងគ្នា។<br>**៤.៣ សមណង់ចតុកោណកែង**<br>លំហាត់គំរូ១<br>សង់ចតុកោណកែង $ABCD$ ដោយស្គាល់ $AB = 3.5cm$ , $AD = 5cm$ ។<br>**សំណង់** គូស $AD = 5cm$ តាម $A$ គូស $Ax$ ដែល $Ax \perp AD$ ដោយប្រើបន្ទាត់លេខដៅចំនុច $B$ នៅលើ $Ax$ ដែល $AB = 3.5cm$ ។ គូសធ្នូរង្វង់ផ្ចិត $B$ កាំ $5cm$ និងគូស ធ្នូរង្វង់ផ្ចិត $D$ កាំ $3.5cm$ ធ្នូរង្វង់ទាំងពីរប្រសព្វគ្នាត្រង់ $C$ គូសភ្ជាប់អង្កត់ $BC$ និង $CD$ គេបានចតុកោណកែង $ABCD$ ដែលសួររក។ | អង្កត់ទ្រូងមានរង្វាស់ស្មើគ្នា ហើយស្របគ្នាត្រង់ចំនុច កណ្តាលរៀងគ្នា។<br>មេដ្យាទ័រនៃជ្រុងឈមជាអ័ក្សឆ្លុះ ហើយកែងគ្នានិងប្រសព្វគ្នា ត្រង់ចំនុចកណ្តាលរៀងគ្នា។<br><br> |

| | | |
|---|---|---|
| បង្ហាញរូបការេឲ្យសិស្ស ប្រាប់សិស្សឲ្យប្រើប្រាស់ បន្ទាត់ក្រឹត រឺដែកឈាន និង រ៉ាប៉័ទ័រដើម្បីសង់ការេ<br><br>ចូរប្អូនសង្កេតមើលរូបតើ ចតុកោនកែងមានលក្ខណៈអ្វីខ្លះ? | **៥ ការេ**<br>**៥.១ និយមន័យ**<br>ការេ ជាចតុកោណកែងដែលមាន ជ្រុងជាប់ពីរប៉ុនគ្នា។<br>គេបាន $ABCD$ ជាចតុកោណកែង $AB = AD$<br>។ដូច្នេះ $ABCD$ ជាការេ។<br><br>**៥.២ លក្ខណៈការេ**<br><br>-មុំទាំងបួនជាមុំកែង<br>-ជ្រុងទាំងបួនប៉ុនគ្នា<br><br>អង្កត់ទ្រូងប៉ុនគ្នា ហើយកែងគ្នា ត្រង់ចំនុចកណ្តាលរៀងគ្នា។<br>អង្កត់ទ្រូងជាកន្លះបន្ទាត់ពុះនៃមុំ ឈមហើយជាអ័ក្សឆ្លុះ<br> | សិស្សគូសរូបចូលក្នុងសៀវភៅ<br><br>-មុំទាំងបួនជាមុំកែង<br>-ជ្រុងទាំងបួនប៉ុនគ្នា<br><br>អង្កត់ទ្រូងប៉ុនគ្នា ហើយកែងគ្នា ត្រង់ចំនុចកណ្តាលរៀងគ្នា។<br>អង្កត់ទ្រូងជាកន្លះបន្ទាត់ពុះនៃមុំ ឈមហើយជាអ័ក្សឆ្លុះ |

| | | |
|---|---|---|
| ឲ្យសិស្សគិតនិងដោះស្រាយលមហាត់គំរូ១ ដោយឲ្យសិស្សសង់ដោយខ្លួនឯង | មេដ្យាទ័រនៃជ្រុងឈមជាអ័ក្សឆ្លុះ<br>**៥.៣ សំណង់ការេ**<br>**លំហាត់គំរូ១**<br>សង់ការេ $ABCD$ ដោយជ្រុង $AD = 4cm$ ។<br>**សំណង់**<br>គូស $AD = 4cm$<br>តាម $A$ គូស $Ax \perp DA$<br>ដោយប្រើបន្ទាត់លេខដៅចំនុច $B$ លើ $Ax$ ដែល $AB = 4cm$ ។<br>គូសធ្នូរង្វង់ផ្ចិត $B$ កាំ $AD = 4cm$ និងគូសរង្វង់ផ្ចិត $D$ កាំ $AD = 4cm$<br>ធ្នូរង្វង់ទាំងពីរប្រសព្វគ្នាត្រង់ $C$<br>គូសភ្ជាប់ឲ្យបានអង្កត់ $BC$ និង $CD$ គេបាន<br>ការេ $ABCD$ ដែលត្រូវសង់។ | មេដ្យាទ័រនៃជ្រុងឈមជាអ័ក្សឆ្លុះ<br><br> |
| ចូររៀបរាប់ពីលក្ខណៈចតុកោណនិងការេ | ជំហានទី៤ (ពង្រឹងពុទ្ធិ)<br>(៥នាទី) | **ចតុកោណកែង**<br>-មុំទាំងបួនជាមុំកែង<br>-ជ្រុងជាប់កែងគ្នា<br>-ជ្រុងឈមស្របគ្នា<br>-មានជ្រុងពីរៗប៉ុនគ្នា<br>អង្កត់ទ្រូងមានរង្វាស់ស្មើគ្នា ហើយស្របគ្នាត្រង់ចំនុចកណ្តាលរៀងគ្នា។<br>មេដ្យាទ័រនៃជ្រុងឈមជាអ័ក្សឆ្លុះ |

| | | |
|---|---|---|
| | | ហើយកែងគ្នានិងប្រសព្វគ្នាត្រង់ចំនុចកណ្តាលរៀងគ្នា។<br>**ការេ**<br>-មុំទាំងបួនជាមុំកែង<br>-ជ្រុងទាំងបួនប៉ុនគ្នា<br>អង្កត់ទ្រូងប៉ុនគ្នា ហើយកែងគ្នាត្រង់ចំនុចកណ្តាលរៀងគ្នា។<br>អង្កត់ទ្រូងជាកន្លះបន្ទាត់ពុះនៃមុំឈមហើយជាអ័ក្សឆ្លុះ<br>មេដ្យាទ័រនៃជ្រុងឈមជាអ័ក្សឆ្លុះ |
| -គ្រូដាក់លំហាត់ទី១២ទី១៦ ទំព័រ១៦៦។ឲ្យសិស្សធ្វើនៅផ្ទះ និងណែនាំសិស្សឲ្យគោរពវិន័យនិងច្បាប់ចរាចរណ៍ | <u>ជំហានទី៥</u> (កិច្ចការផ្ទះ)<br>(៥នាទី)<br><br>លំហាត់ទី១២ និង ទី១៦<br>ទំព័រ១៦៦ | សិស្សកត់ត្រាលំហាត់និងស្តាប់ដំបូន្មានគ្រូ |

## កិច្ចតែងការបង្រៀន( ថ្នាក់ទី៧ )

មេរៀនទី១៦ **បរិមាត្រ និងផ្ទៃក្រឡាពហុកោណ**

+ខ្លឹមសារមេរៀន : **១. សញ្ញាណបរិមាត្រ**

**១.១ សញ្ញាណទូទៅនៃបរិមាត្រ**

**១.២ បរិមាត្រចតុកោណកែង**

**១.៣ បរិមាត្រការេ**

**១.៤ បរិមាត្រត្រីកោណ**

+រយៈពេល2ម៉ោង

I.វត្ថុបំណងនៃមេរៀន

-ចំណេះដឹង : កំណត់បានពីសញ្ញាណបរិមាត្រនៃចតុកោណបានត្រឹមត្រូវតាមរយៈឧទាហរណ៍។

-បំណិន : គណនាបរិមាត្រចតុកោណកែង ការេ ត្រីកោណបានត្រឹមត្រូវតាមរយៈការប្រតិបត្តិ។

-ឥរិយាបថ : មានស្មារតីប្រុងប្រយ័ត្ន ពេលសង់លក្ខណៈទូទៅនៃត្រីកោណ និងកោណត់ឈ្មោះនៃត្រីកោណទៅតាមប្រភេទឲ្យបានខ្ពស់។

II.ពេលវេលា: ថ្ងៃ……………..ទី……………..ខែ…………..ឆ្នាំ………..

III.សម្ភារៈឧបទេស

-បន្ទាត់ឈើ ដែកឈាន ប៉ាប៉ទ័រ ឬកែង

-ផ្ទាំងក្រដាសបង្ហាញរូបត្រីកោណ រូបពហុកោណ រូបចតុកោណកែង ការេ

IV.ដំណើកនាំមេរៀន

| សកម្មភាពគ្រូ | ខ្លឹមសាមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| -គ្រូពិនិត្យអវត្តមាន អនាម័យ សណ្តាប់ធ្នាប់ និង វិន័យ | ជំហានទី១ (រដ្ឋបាលថ្នាក់)<br>(១-២នាទី)<br>-គ្រូពិនិត្យអវត្តមាន អនាម័យ សណ្តាប់ធ្នាប់ និង វិន័យ | តំណាងសិស្សឡើងរាយការណ៍ |

| | | |
|---|---|---|
| ដូចម្តេចដែលហៅថាការេ?<br>ចតុកោណកែង?ត្រីកោណ? | <u>ជំហានទី២</u> (រំលឹកមេរៀនចាស់)<br>(៣-៥នាទី) | ការេជាចតុកោណកែងដែលមានជ្រុងជាប់ពីរប៉ុនគ្នា។ចតុកោណកែងជាចតុកោណដែលមានមុំ៤ជាមុំកែង។ត្រីកោណជាពហុកោណដែលមានជ្រុង៣។ |
| គ្រូសរសេរមេរៀនថ្មី<br><br><br><br>បង្ហាញខ្សែកាច់ធ្វើពីលួស រួចណែនាំ រកប្រវែងខ្សែកាច់ទាំងអស់<br><br><br><br>បង្ហាញរូបចតុកោណ ណែនាំរកប្រវែងជុំវិញ<br><br><br><br>ណែនាំទាញជាទូទៅ | <u>ជំហានទី៣</u>(មេរៀនថ្មី)<br>(២៥-៣០នាទី)<br>មេរៀនទី១៦<br>**បរិមាត្រនិងផ្ទៃក្រលាពហុកោណ**<br>**១.សញ្ញាណបរិមាត្រ**<br>**១.១ សញ្ញាណទូទៅនៃបរិមាត្រ**<br>$Ex_1$ រកប្រវែងខ្សែកាច់ $AE$<br>$AE = AB + BC + CD + DE$ ហៅថាប្រវែងខ្សែកាច់ $AE$ ។<br><br><br>$Ex_2$ រកប្រវែងជុំវិញពហុកោណ $ABCDE$<br>$P = AB + BCCD + DE + EA$<br>ហៅថាបរិមាត្រពហុកោណ<br><br><br>**ជាទូទៅ** បរិមាត្រនៃពហុកោណគឺជាប្រវែងខ្សែបិទជិតដែលកំណត់ពហុកោណនោះ។ | សិស្សត្រៀមសម្ភារៈសិក្សា<br><br><br><br>សិស្សសង្កេត<br><br><br><br>សិស្សកត់ត្រា<br><br>ប្រវែងជុំវិញបានពីផលបូកអង្កត់ខ្លីៗទាំងអស់<br><br><br><br>សិស្សទាញជាទូទៅ<br>បរិមាត្រនៃពហុកោណគឺជាប្រវែងខ្សែបិទជិតដែលកំណត់ |

<table>
<tr><td></td><td>១.២ បរិមាត្រចតុកោណកែង</td><td>ពហុកោណនោះ។</td></tr>
<tr><td>បង្ហាញរូបចតុកោណកែង រួចណែនាំរកបរិមាត្រដោយដឹងបណ្តោយនិងទទឹង</td><td>$Ex_1$ រកបរិមាត្រចតុកោណកែងដូចរូប<br><br>$15cm$<br>$25cm$</td><td>សង្កេត</td></tr>
<tr><td></td><td>$P = 25cm + 15cm + 25cm + 15cm = 80cm$</td><td>កត់ត្រា</td></tr>
<tr><td>ណែនាំរកបរិមាត្រ</td><td>$Ex_2$ រកបរិមាត្រចតុកោណកែងតាមរូប<br><br>$P = a + b + a + b = 2(a+b)$</td><td>រកបរិមាត្រ</td></tr>
<tr><td>ទាញជារូបមន្ត</td><td>បរិមាត្រចតុកោណកែង $P = 2(a+b)$<br>ដែលAB=$a$ ជាទទឹង<br>និងAD=$b$ ជាបណ្តោយ</td><td>ទាញរូបមន្ត $P = 2(a+b)$<br>បរិមាត្រចតុកោណកែង<br>$P = 2(a+b)$<br>ដែលAB=$a$ ជាទទឹង</td></tr>
<tr><td></td><td>១.៣ បរិមាត្រការេ</td><td></td></tr>
<tr><td>បង្ហាញរូបការេ ណែនាំរកបរិមាត្រដោយស្គាល់ប្រវែងជ្រុង</td><td>$Ex_1$ រកបរិមាត្រការេ ដោយដឹងរង្វាស់ជ្រុងមួយស្មើ$10cm$<br>$P = 10 + 10 + 10 + 10$<br>$P = 40$<br><br>$10cm$</td><td>$P = 10 + 10 + 10 + 10$<br>$P = 40$</td></tr>
<tr><td>ណែនាំទាញរូបមន្ត</td><td>$Ex_2$ គណនាបរិមាត្រការេតាមរូប<br>$P = a + a + a + a$<br>$= 4a$<br>រូបមន្តៈបរិមាត្រការេគឺ<br>$P = 4a$<br>ដែល $a$ ជាជ្រុង<br><br>$a$</td><td>$P = a + a + a + a$<br>$= 4a$<br>យើងទាញបានរូបមន្ត $P = 4a$<br>ដែល $a$ ជាជ្រុង<br>$P_{ABC} = 10cm + 11cm + 12cm$<br>$P_{ABC} = 33cm$</td></tr>
</table>

| | | |
|---|---|---|
| បង្ហាញរូបត្រីកោណណែនាំរកបរិមាត្រដោយស្គាល់ប្រវែងជ្រុងនីមួយៗ<br><br>ណែនាំរកបរិមាត្រ<br><br>ឲ្យទាញជារូបមន្ត | **១.៤ បរិមាត្រត្រីកោណ**<br>$Ex_1$ តាមរូបរកបរិមាត្រត្រីកោណ $ABC$ ។<br>$P_{ABC} = 10cm + 11cm + 12cm$<br>$P_{ABC} = 33cm$<br><br>$Ex_2$ តាមរូបរកបរិមាត្រនៃ $\Delta ABC$<br>$P_{ABC} = a + b + c$<br><br>រូបមន្ត បរិមាត្រនៃត្រីកោណដែលមានរង្វាស់ជ្រុង $a, b$ និង $c$ គឺ $P = a + b + c$ | $P_{ABC} = a + b + c$<br><br>រូបមន្ត $P = a + b + c$ |
| គ្រូសួរ: ឲ្យរូបមន្ត:<br>ក) បរិមាត្រចតុកោណកែង<br>ខ) បរិមាត្រការេ<br>គ) បរិមាត្រត្រីកោណ | <u>ជំហានទី៤</u> (ពង្រឹងចំណេះដឹង)<br>(៧-១០នាទី) | សិស្សឆ្លើយ:<br>ក) $P = 2(a + b)$<br>$a$ ជាទទឹង<br>និង $b$ ជាបណ្តោយ<br>ខ) $P = 4a$ , $a$ ជាជ្រុង<br>គ)<br>$P = a + b + c$ ,( $a,b,c$ ជាជ្រុង) |
| -គ្រូដាក់លំហាត់ទី១ទី២ ទំព័រ១៦៩។ឲ្យសិស្សធ្វើនៅផ្ទះនិងណែនាំសិស្សគោរពវិន័យនិងច្បាប់ចរាចរណ៍ | <u>ជំហានទី៥</u> (កិច្ចការផ្ទះ)<br>(២-៣នាទី)<br><br>លំហាត់ទី១ និង ទី២ ទំព័រ១៦៩ | សិស្សកត់ត្រាលំហាត់និងស្តាប់ដំបូន្មានគ្រូ |

# កិច្ចតែងការបង្រៀន(ថ្នាក់ទី៧)

មេរៀនទី១៦ **បរិមាត្រ និងផ្ទៃក្រឡាពហុកោណ**

+ខ្លឹមសារមេរៀន : **២.៤ ផ្ទៃក្រលាការេ**

**២.៥ ផ្ទៃក្រលាត្រីកោណ**

**៣ ចំណោទ**

+រយៈពេល2ម៉ោង

I.វត្ថុបំណងនៃមេរៀន

-ចំណេះដឹង : បកស្រាយបានពីរូបមន្តក្រលាផ្ទៃការេ និងត្រីកោណបានត្រឹមត្រូវតាមរយៈឧទាហរណ៍។

-បំណិន : គណនាក្រលាផ្ទៃការេ ត្រីកោណបានត្រឹមត្រូវតាមរយៈលំហាត់គំរូ និងការប្រតិបត្តិ។

-ឥរិយាបថ : មានស្មារតីប្រុងប្រយ័ត្ន ពេលសង់លក្ខណៈទូទៅនៃត្រីកោណ និងកោណត់ឈ្មោះនៃត្រីកោណទៅតាមប្រភេទឲ្យបានខ្ពស់។

II.ពេលវេលា: ថ្ងៃ…………..ទី…………..ខែ…………..ឆ្នាំ………..

III.សម្ភារៈឧបទេស

-បន្ទាត់ឈើ ដែកឈាន ប៉ាប៉ីរ៍ ឬកែង

-ផ្ទាំងក្រដាសបង្ហាញរូបត្រីកោណ ការេ

IV.ដំណើកនាំមេរៀន

| សកម្មភាពគ្រូ | ខ្លឹមសាមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| -គ្រូពិនិត្យអវត្តមាន<br>អនាម័យ<br>សណ្តាប់ធ្នាប់ និង វិន័យ | ជំហានទី១ (១-២នាទី)<br>(រដ្ឋបាលថ្នាក់) | តំណាងសិស្សឡើងរាយការណ៍ |
| គ្រូសួរ<br>រូបមន្តក្រលាផ្ទៃចតុកោណកែង<br>$1ca = ........m^2$ , $1a = .........m^2$ | ជំហានទី២ (៣-៥នាទី)<br>(រំលឹកមេរៀនចាស់) | សិស្សឆ្លើយ<br>$S =$ បណ្តោយ $\times$ ទទឹង<br>$1ca = 1m^2$ , $1a = 100m^2$ |
| | | |

| | | |
|---|---|---|
| | <u>ជំហានទី៣</u> (២៥-៣០នាទី)<br>(មេរៀនថ្មី)<br>មេរៀនទី១៦<br>**បរិមាត្រនិងផ្ទៃក្រលាពហុកោណ** | ឆ្លើយ |
| ដាក់ឧទាហរណ៍ណែនាំ<br>តើជ្រុងការេនេះមានរង្វាស់ប៉ុន្មាន ?<br>គេបានរូបមន្តទូទៅ | ២.៤ ផ្ទៃក្រលាការេ<br>$Ex_1$ គណនាផ្ទៃក្រលាការេដោយស្គាល់រង្វាស់ជ្រុង $a = 4cm$<br>ផ្ទៃក្រលាការេ $S = 4cm \times 4cm = 16cm^2$<br>រូបមន្ត ក្រលាផ្ទៃការេ<br>$S = a \times a = a^2$<br><br> | រង្វាស់ $a = 4cm$<br>$S = a \times a = a^2$<br><br>កត់ត្រា |
| ដាក់ឧទាហរណ៍ណែនាំ<br>រូបមន្តឲ្យស្គាល់កម្ពស់ និងបាត | **២.៥ ផ្ទៃក្រលាត្រីកោណ**<br>$Ex_1$ រកក្រលាផ្ទៃត្រីកោណតាមរូប<br><br><br><br><br><br> | សង្កេត<br><br>ស្តាប់ |

រូបមន្ត ក្រលាផ្ទៃត្រីកោណគឺ $S=\frac{1}{2}bh$

ដែល $b$ ជាបាតនិង $h$ ជាកម្ពស់។

ណែនាំឲ្យបំពេញ

**ប្រតិបត្តិ**

បំពេញតារាងខាងក្រោម

បំពេញ

| ជ្រុងទី១ | ជ្រុងទី២ | បាត | កម្ពស់ | ផ្ទៃក្រលា | បរិមាត្រ |
|---|---|---|---|---|---|
| 123 cm | 103 m | 188 cm | 73 m | 6862 $m^2$ | 414 m |
| 22 cm | 22 cm | 48 cm | 16 cm | 384 $cm^2$ | 92 cm |
| 26 dm | 199 dm | 201 dm | 204 dm | 20502 $dm^2$ | 426 dm |
| 0.8 km | 0.7 km | 1.3 km | 1.2 km | 78000 $m^2$ | 2800 m |

សង្កេត

កត់ត្រា

**៣ ចំណោទ**

*Ex* គណនាក្រឡាផ្ទៃតាមរូប

រកក្រលាផ្ទៃ $S$

ណែនាំឲ្យសង្កេតរូប និងក្រលាផ្ទៃផ្ទៃកខ្លះនៃរូប រួចបូក




ឡើងគណនា

$S=S_1+S_2$

$S_1=15cm\times22cm=330cm^2$

$S_2=\frac{1}{2}\times18cm\times22cm=198cm^2$

$\Rightarrow S=S_1+S_2=528cm^2$

**ប្រតិបត្តិ:** រកក្រលាផ្ទៃតាមរូប

ណែនាំដូចឧទាហរណ៍ខាងលើ




$S=S_1+S_2$

$S_1=14cm\times14cm=196cm^2$

$S_2=37cm\times18cm=666cm^2$

$\Rightarrow S=S_1+S_2=196cm^2+666cm^2$

$S=862cm^2$

| | | |
|---|---|---|
| -គ្រូដាក់លំហាត់<br>ចូរឲ្យរូបមន្តក្រលាផ្ទៃការេ<br>និងត្រីកោណ | <u>ជំហានទី៤</u> (៧-១០នាទី)<br>(ពង្រឹងចំណេះដឹង) | ផ្ទៃក្រលាការេ $S = a^2$ , $a$<br>ជាជ្រុង<br>ក្រលាផ្ទៃត្រីកោណ<br>$S = \frac{1}{2}bh$ ,$h$<br>ជាកម្ពស់ , $b$ ជាបាត |
| -គ្រូដាក់លំហាត់ទី៥ទី៦<br>ទំព័រ១៧៦ឲ្យសិស្សធ្វើនៅ<br>ផ្ទះនិងណែនាំសិស្សគោរព<br>វិន័យនិងច្បាប់ចរាចរណ៍ | <u>ជំហានទី៥</u> (២-៣នាទី)<br>(កិច្ចការផ្ទះ)<br><br>លំហាត់ទី៥ និង ទី២៦ទំព័រ១៧៦ | សិស្សកត់ត្រាលំហាត់និង<br>ស្តាប់<br>ដំបូន្មានគ្រូ |

# កិច្ចតែងការបង្រៀន

មុខវិជ្ជា: គណិតវិទ្យា ថ្នាក់ទី ៧

ថ្ងៃ.........ទី........ខែ.........ឆ្នាំ............

I.ចំណងជើងមេរៀន: មេរៀនទី១៧ **រង្វង់**

II. ចំណងជើងរង: ១.សញ្ញាណរង្វង់

២.វិមាត្ររង្វង់

៣.ផ្ទៃក្រលាថាស

III.រយៈពេល ២ម៉ោង

IV. វត្ថុបំណង ក្រោយពីរៀនចប់ចំនុចនេះសិស្សអាចៈ

-ពណ៌នាពីរង្វង់បានត្រឹមត្រូវ។

-បង្ហាញពីបរិមាត្ររង្វង់និងផ្ទៃក្រឡាថាសបានត្រឹមត្រូវ។

-អនុវត្តន៍ក្នុងការគណនាបរិមាត្រនិងផ្ទៃក្រឡាវត្ថុរាងជារង្វង់បានកម្រិតខ្ពស់។

V. សម្ភារៈ មុខនាឡិកា កងក្រដាសរាងរង្វង់ បន្ទាត់ម៉ែត្រ។

VI.ដំណើរការបង្រៀន

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| គ្រូតពិនិត្យវត្តមានសិស្ស វិន័យ<br><br>អនាម័យ សណ្តាប់ធ្នាប់ | **រដ្ឋបាលថ្នាក់** | ប្រធានថ្នាក់ឡើងរាយការណ៍ |
| តើបរិមាត្រជាអ្វី? | **រំលឹកមេរៀន**<br><br>បរិមាត្រជាប្រវែងមួយជុំ។ | ជាប្រវែងមួយជុំ។ |
| | **មេរៀនទី១៧ រង្វង់** | |

| | | |
|---|---|---|
| អោយនិយមន័យរង្វង់។ | **១សញ្ញាណរង្វង់រង្វង់**<br>ជាខ្សែកោងបិទជិតដែលគ្រប់ចំណុចនៃខ្សែកោងស្ថិតនៅស្មើចម្ងាយពីចំណុចនឹងមួយហៅថាផ្ចិតនៃរង្វង់។ | រង្វង់ជាខ្សែកោងបិទជិតដែលគ្រប់ចំណុចនៃខ្សែកោងស្ថិតនៅស្មើចម្ងាយពីចំណុចនឹងមួយហៅថាផ្ចិតនៃរង្វង់។ |
| អោយសិស្សរកឧទាហរណ៍វត្ថុរាងជារង្វង់។ | ឧទាហរណ៍រូបមុខនាឡិកា<br>មាត់កំប៉ុងទឹកសុទ្ធកងដៃ | រូបមុខនាឡិកាមាត់កំប៉ុងទឹកសុទ្ធកងដៃ |
| អោយសិស្សបង្ហាញពីធាតុសំខាន់ៗនៃរង្វង់។ |  | ចំណុចOជាផ្ចិចអង្កត់ធ្នូBC<br>ធ្នូ BCកាំ OCនិងអង្កត់ផ្ចិតAB |
| តើបរិមាត្ររង្វង់ជាអ្វី? | **២បរិមាត្ររង្វង់**<br>បរិមាត្ររង្វង់ជាប្រវែងមួយជុំរង្វង់។<br>ឧទាហរណ៍គេយកកង៥ដែលមានផ្ចិតខុសៗគ្នាគិតជាសង់ទីម៉ែត្រមកបង្វិលដោយមិនរអិលនៅលើម៉ែត្រឈើមួយរួចវាស់អង្កត់ផ្ចិតនិងបរិមាត្ររង្វង់នៃថាសនីមួយៗគេបានលទ្ធផលដូចតទៅ | បរិមាត្ររង្វង់ជាប្រវែងមួយជុំរង្វង់។<br>សិស្សសង្កេតយ៉ាងយកចិត្តទុកដាក់<br>ផលធៀបមានតម្លៃប្រហាក់ប្រហែលគ្នា។ |

<table>
<tr>
<td>អោយសិស្សសង្កេតឧទាហរណ៍រួចរកផលចែករវាងPនិងD ។<br><br>តាមរយៈផលចែកនេះតើគេសង្កេតឃើញតម្លៃវាដូចម្តេច?<br><br>តើគេបានp/dស្មើអ្វី?<br><br>អោយសិស្សទាញរូមមន្តបរិមាត្ររង្វង់។<br><br>អោយសិស្សដោះស្រាយលំហាត់ឧទាហរណ៍</td>
<td>

| រង្វង់ | a | b | c | d | e |
|---|---|---|---|---|---|
| អជd | 4 | 6 | 8 | 10 | 12 |
| បរិ.p | 12.5 | 19 | 25.1 | 31.4 | 37.8 |
| P:d | 3.12 | 3.16 | 3.13 | 3.14 | 3.15 |

ផលធៀបមានតម្លៃប្រហាក់ប្រហែលគ្នា។<br>តម្លៃប្រហែលនេះគេតាងដោយ $\pi$ អានថាផៃស្មើនិង3.1416.....។<br><br>គេបានp/d=$\pi$ , p=$\Pi$d<br>ជាទូទៅ p=2$\pi$Rរឺp= $\pi$d<br>ដែល -p ជាបរិមាត្រនិងR ជាកាំ<br>-d ជាអង្កត់ផ្ចិត(d=2R)<br><br>ឧទាហរណ៍<br>គណនាអង្កត់ផ្ចិតនៃរង្វង់ដោយស្គាល់បរិមាត្ររង្វង់p=25cm និង $\pi$=3.14។<br>ចម្លើយ d=7.96cm<br><br>ប្រតិបត្តិ កងបង្វិលមួយមានកាំ១0cm និង $\pi$=22/7<br>គណនាបរិមាត្រកងបបង្វិលនោះ?</td>
<td>p/d=$\pi$ និងp=2$\pi$R<br>រឺp= $\pi$d<br><br>p=$\pi$d នោះd=p/$\pi$<br>=25/3.14=7.96cm</td>
</tr>
</table>

| | | |
|---|---|---|
| អោយសិស្សដោះស្រាយលំហាត់ប្រតិបត្តិ<br><br>តាមរូប តើផ្ទៃក្រលាថាសស្មើផ្ទៃក្រលាចតុកោណកែងរឺទេ?<br><br>អោយសិស្សទាញរូបមន្តផ្ទៃក្រលាថាស តាមរយះក្រលាចតុកោណកែង<br><br>អោយសិស្សដោះស្រាយលំហាត់ឧទាហរណ៍ | ចម្លើយ p=2R$\pi$=220/7=31.42cm<br><br>3.ផ្ទៃក្រលាថាស<br><br>ផ្ទៃក្រលាថាស<br>ស្មើផ្ទៃក្រលាចតុកោណកែង។<br><br>S=$\pi$ R×R<br><br>ជាទូទៅ ផ្ទៃក្រលាថាស ដែលមានប្រវែងកាំR កំណត់ដោយ<br>$S=\pi R^2$<br><br>សម្គាល់ d=2R នោះ R=d/2<br><br>នាំអោយ $S=\frac{\pi d^2}{4}$<br><br>ឧទាហរណ៍<br>គណនាផ្ទៃក្រលាថាសដែលមានកាំ 10cm ដោយយក $\pi$=3.141។<br><br>ចម្លើយ<br><br>$S=\pi R^2 = 3.14\times 10^2$ =314.1$cm^2$<br><br>ប្រតិបត្តិ<br>គណនាផ្ទៃរង្វង់ដែលមានកាំ=3c | p=2R$\pi$=220/7=31.42cm<br><br>ស្មើ $S=\pi R^2$ |

| | | |
|---|---|---|
| អោយសិស្សដោះស្រាយលំហាត់ប្រតិបត្តិ | m ដោយយក $\pi$ =22/7។<br>ចម្លើយ<br>$S=\pi R^2$<br>=28.285cm$^2$ | $S=\pi R^2$<br>$=3.14\times10^2$ =314.1cm<br>$S=\pi R^2$ =28.285ccm |
| តើបរិមាត្ររង្វង់ជាអ្វី?<br>កំណត់រូបមន្តបរិមាត្ររង្វង់។<br>កំណត់រូបមន្តផ្ទៃក្រលាថាស។ | **ពង្រឹងពុទ្ធិ** | បរិមាត្ររង្វង់ជាប្រវែងមួយជុំរង្វង់។<br>p=2$\pi$R<br>$S=\pi R^2$ |
| ដាក់កិច្ចការផ្ទះ | **បណ្តាំផ្ញើ**<br>លំហាត់ 1,2,3,4 ទំព័រទី183 សៀវភៅសិស្ស | សិស្សកត់ |

កិច្ចតែងការបង្រៀន

មុខវិជ្ជា: គណិតវិទ្យា ថ្នាក់ទី ៧

ថ្ងៃ:..........ទី.........ខែ...........ឆ្នាំ.........

I.ចំណងជើងមេរៀន: រង្វង់ (ត)

ចំណងជើងរង: ៤.ផ្ទៃក្រលាចំម្រៀកថាស

៤.១ និយមន័យ

៤.២ប្រវែងធ្នូនៃរង្វង់

៤.៣ផ្ទៃក្រលាចំមៀកថាស

II. រយះពេល: ២ម៉ោង

III. វត្ថុបំណង ក្រោយពីរៀនចប់ចំនុចនេះសិស្សអាច:

-ពណ៌នាពីចម្រៀកថាសបានត្រឹមត្រូវ។

-បង្ហាញពីការគណនាប្រវែងធ្នូនៃរង្វង់និងផ្ទៃក្រឡាចម្រៀកថាសបានត្រឹមត្រូវ។

-អនុវត្តន៍ក្នុងការគណនាផ្ទៃក្រឡាវត្ថុរាងជាចម្រៀកថាសបានកម្រិតខ្ពស់។

IV. សម្ភារះក្រដាសកាតុងរាងរង្វង់ បន្ទាត់ម៉ែត្រ។

V.ដំណើរការបង្រៀន

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| គ្រូតពិនិត្យវត្តមានសិស្ស<br>វិន័យ សណ្តាប់ធ្នាប<br>អនាម័យ | ជំហានទី១(រដ្ឋបាលថ្នាក់) | តំណាងសិស្ស<br>ឡើងរាយការណ៍ |

| | | |
|---|---|---|
| តើរង្វង់ជាអ្វី?<br>ដើម្បីគណនាផ្ទៃក្រឡារង្វង់ គេប្រើរូបមន្តអ្វី? | **ជំហានទី២(រំលឹកមេរៀន)**<br>រង្វង់ជាខ្សែកោងបិទជិតដែលគ្រប់ចំណុចនៃខ្សែកោងស្ថិតនៅស្មើចម្ងាយពីចំណុចនឹងមួយហៅថាផ្ចិតនៃរង្វង់។ $S=\pi R^2$ | រង្វង់ជាខ្សែកោងបិទជិតដែលគ្រប់ចំណុចនៃខ្សែកោងស្ថិតនៅស្មើចម្ងាយពីចំណុចនឹងមួយហៅថាផ្ចិតនៃរង្វង់។ $S=\pi R^2$ |
| អោយនិយមន័យចម្រៀកថាស<br>អោយសិស្សដោះស្រាយលំហាត់ឧទាហរណ៍<br>តើមុំ $360^0$ ត្រូវនិងប្រវែងធ្នូបរិមាត្ររង្វង់ប៉ុន្មាន?<br>តើមុំ $1^0$ ត្រូវនិងប្រវែងធ្នូបរិមាត្ររង្វង់ប៉ុន្មាន?<br>តើមុំ $45^0$ ត្រូវនិងប្រវែងធ្នូបរិមា | **ជំហានទី៣(មេរៀនថ្មី)**<br>**មេរៀនទី១៧រង្វង់ (ត)**<br>**4 ផ្ទៃក្រឡាចម្រៀកថាស**<br>បំណិតនំគឺជាឧទាហរណ៍មួយនៃចម្រៀកថាស។<br>**4.1និយមន័យ**<br><br>ចម្រៀកថាស<br>គឺជាផ្ទៃកមួយនៃថាសខណ្ឌដោយកាំពីរ។មុំដែលផ្គុំឡើងដោយកាំទាំងពីរនៃរង្វង់ហៅថាមុំផ្ចិតនៃចម្រៀកថាស។<br>**4.2ប្រវែងធ្នូនៃរង្វង់**<br>ឧទាហរណ៍<br>គណនាប្រវែងធ្នូនៃរង្វង់ដែលមានកាំរង្វាស់5cm ត្រូវនិងមុំផ្ចិត $45^0$ ។ | $2\pi$ R<br>$\frac{2\pi R}{360}$<br>$\frac{2\pi R}{360}\times 45^0$ |

| | | |
|---|---|---|
| ត្រូវង្វង់ប៉ុន្មាន?<br><br>អោយសិស្សទាញរូបមន្តជាទូទៅ។ | មុំ $360^0$<br>ត្រូវនិងប្រវែងធ្នូបរិមាត្រវង្វង់ $2\pi$ R<br>មុំ $1^0$ ត្រូវនិងប្រវែងធ្នូបរិមាត្រវង្វង់ $\frac{2\pi R}{360}$<br>មុំ $45^0$ ត្រូវនិងប្រវែងធ្នូបរិមាត្រវង្វង់ $\frac{2\pi R}{360}\times 45^0$ | $AB = 2\pi R\times\frac{\alpha^0}{360}$<br><br>$AB = 2\pi R\times\frac{30^o}{360^o} = 2\pi 5\times\frac{30}{360} = \frac{5\pi}{6}cm$ |
| អោយសិស្សដោះស្រាយលំហាត់គំរូ1 | ជាទូទៅ<br>ប្រវែងធ្នូABនៃកាំវង្វង់Rនិង មុំផ្ចិត $\alpha^0$ កំណត់ដោយប្រវែងធ្នូ<br>$AB = 2\pi R\times\frac{\alpha^0}{360}$<br>លំហាត់គំរូ1 គណនាប្រវែងធ្នូAB នៃវង្វង់ដែលមានកាំរង្វាស់ 5cmត្រូវនិងមុំផ្ចិត $30^0$ ។<br>ចម្លើយ គេបាន<br>$AB = 2\pi R\times\frac{30^o}{360^o} = 2\pi 5\times\frac{30}{360} = \frac{5\pi}{6}cm$ | ចម្រៀកថាស<br>ដែលមានកាំរង្វាស់12cm<br>មុំផ្ចិតចម្រៀកថាស $45^0$ ។<br>មុំ $360^0$ ត្រូវនិងផ្ទៃក្រឡាថាស $\pi R^2$<br>មុំ $1^0$ ត្រូវនិងផ្ទៃក្រឡាចម្រៀកថាស $\frac{\pi R^2}{360^o}$<br>$45^0$ ត្រូវនិងផ្ទៃក្រឡាចម្រៀកថាស<br>$S = \frac{\pi R^2}{360^o}\times 45^o = 18\pi cm^2$ |
| អោយសិស្សដោះស្រាយលំហាត់ឧទាហរណ៍<br><br>តើមុំ $360^0$ ត្រូវនិងផ្ទៃក្រឡាថាសប៉ុន្មាន?<br>តើមុំ $1^0$ ត្រូវនិងផ្ទៃក្រឡាចម្រៀក | **4.3 ផ្ទៃក្រឡាចម្រៀកថាស**<br>ឧទាហរណ៍<br>គណនាផ្ទៃក្រឡាចម្រៀកថាស ដែលមានកាំរង្វាស់12cm<br>មុំផ្ចិតចម្រៀកថាស $45^0$ ។<br>មុំ $360^0$ ត្រូវនិងផ្ទៃក្រឡាថាស $\pi R^2$<br>មុំ $1^0$ ត្រូវនិងផ្ទៃក្រឡាចម្រៀកថាស<br>$\frac{\pi R^2}{360^o}$ | $S = \pi R^2\times\frac{\alpha^o}{360^o}$ |

| | | |
|---|---|---|
| ថាសប៉ុន្មាន?<br>តើមុំ $45^0$ ត្រូវនិងផ្ទៃក្រឡាចម្រៀកថាសប៉ុន្មាន?<br>អោយសិស្សទាញរូបមន្តជាទូទៅ។<br><br>អោយសិស្សដោះស្រាយលំហាត់គំរូ1 | $45^0$ ត្រូវនិងផ្ទៃក្រឡាចម្រៀកថាស<br>$S=\frac{\pi R^2}{360^o}\times 45^o=18\pi cm^2$<br>ជាទូទៅ<br>ផ្ទៃក្រឡាចម្រៀកថាសSនៃរង្វង់កាំ R និងមុំផ្ចិតនៃចម្រៀកថាស $\alpha^o$ កំណត់ដោយ $S=\pi R^2\times\frac{\alpha^o}{360^o}$ ។<br>លំហាត់គំរូ1<br>គណនាផ្ទៃក្រឡានៃចម្រៀកថាសដែលមានកាំរង្វាស់ 6cmត្រូវនិងមុំផ្ចិត $60^o$ ដោយយក $\pi=3.14$ ។<br>ចម្លើយ គេបាន<br>$S=\pi 6^2\times\frac{60^o}{360^o}=6\pi cm^2=18.84cm^2$ | $S=\pi 6^2\times\frac{60^o}{360^o}=6\pi cm^2=18.84cm^2$ |
| កំណត់ប្រវែងធ្នូ AB កំណត់ដោយរូបមន្តអ្វី?<br>រករូបមន្តផ្ទៃក្រលាចម្រៀកថាស? | **ជំហានទី៤(ពង្រឹងពុទ្ធិ)** | $AB=2\pi R\times\frac{\alpha^0}{360}$<br>$S=\pi R^2\times\frac{\alpha^o}{360^o}$ |
| ណែនាំសិស្សអោយគោរពច្បាប់ចរាចរណ៍ និង ដាក់កិច្ចការផ្ទះ | **ជំហានទី៥(បណ្តាំផ្ញើ)**<br>កិច្ចការផ្ទះ<br>លំហាត់៧ ៨១២ ទំព័រ១៨៣ ១៨៤ សៀវភៅសិស្ស | ស្តាប់ការទូន្មានយ៉ាងយកចិត្តទុកដាក់ និងកត់ត្រាកិច្ចការផ្ទះ |

# កិច្ចតែងការបង្រៀន

- មុខវិទ្យា : គណិតវិទ្យា
- ថ្នាក់ទី : 7
- មេរៀនទី18 :មាឌ និងក្រលាផ្ទៃខាងនៃសូលីត
- រយៈពេល :1ម៉ោង

*I.* **វត្ថុបំណង**

+ចំណេះដឹង : កំណត់សញ្ញាទូទៅនៃសូលីតអោយបានច្បាស់លាស់តាមរយៈឧទាហរណ៍
–បង្ហាញពីសូលីតដែលមានរាងធរណីមាត្រងាយ និងប្រាប់ប្រភេទព្រមទាំងធាតុរបស់វាអោយបានត្រឹមត្រូវតាមរយៈឧទាហរណ៍ ។

+ បំណិន : បកស្រាយសូលីតដែលមានរាងធរណីមាត្រងាយអោយបានច្បាស់លាស់តាមរយៈឧទាហរណ៍ និងពិភាគ្សាក្រុម ។

+ឥរិយាបទ : ឧស្សាហ៍ស្វែងយល់ពីប្រភេទនៃសូលីតដែលជួបប្រទះក្នុងជីវភាពប្រចាំថ្ងៃក្រោយពីសិក្សាផ្នែកនេះចប់ ។

*II.* **សំភារៈឧបទេស**

–សៀវភៅសិស្សទំព័រ 185–188

–ក្រដាសកាតុងមានគូសរូប និងបន្ទាត់ក្រិត

*III.* **ដំណើកនាំមេរៀន**

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| ពិនិត្យអវត្តមាន អនាម័យនិងសណ្តាប់ធ្នាប់ក្នុងថ្នាក់រៀន | **ជំហានទី ១** ( រដ្ឋបាលថ្នាក់ ) | ប្រធានថ្នាក់ឡើងរាយការណ៍ |
| សួរសំណួរជាលក្ខណៈបុគ្គល<br>–ដូចម្តេចដែលហៅថារង្វង់ ?<br>–គូសរូបមួយដាក់លើក្តារខៀន រួចហៅសិស្សម្នាក់អោយឡើងគណនា និងប្រាប់អោយសិស្សដ៏ទៀតធ្វើនៅកន្លែងរៀងៗខ្លួន | ជំហានទី ២ ( រំលឹកមេរៀនចាស់ )<br><br>12*cm*<br>6*cm* | –ដែលហៅថារង្វង់គឺជាខ្សែកោងបិទជិត ដែលគ្រប់ចំណុចនៃខ្សែកោងស្ថិតនៅស្មើចំងាយពីចំណុចនឹងមួយហៅថាផ្ចិតរង្វង់។<br><br>–សិស្សគណនាលើក្តាខៀន រកបរិមាត្រនៃរូប |

| | | |
|---|---|---|
| <br><br>អោយសិស្សមើលមេរៀនបាន 3 នាទីរួចសួរសិស្ស<br>– ដូចម្តេចដែលហៅថាសូលីត? ចូររកឧទាហរណ៍ ។<br><br><br><br>∗ ពន្យល់ និងអោយកត់ត្រា<br><br><br><br><br><br><br><br><br><br><br><br><br><br>∗ សង់រូបពន្យល់ និងអោយសិស្សកត់ត្រា | **ជំហានទី៣** (មេរៀនថ្មី)<br>មេរៀនទី18 មាត្រនិងក្រលាផ្ទៃខាងនៃសូលីត<br>១. មាឌសូលីត<br>– ដែលហៅថាសូលីតគឺជាប្រភេទធរណីមាត្រដែលមានធរណីមាត្រងាយនិងមានមាត្រ។<br>ឧទាហរណ៍: ធុងសាំង ប្រអប់ដីសរ<br>២. ត្រីកោណ<br>២.១ និយមន័យ<br><br><br>– $\Delta ABC$ អានថាត្រីកោណ $ABC$<br>– $A$ , $B$, $C$ ជាកំពូល<br>– $AB$, $BC$ ,$CA$ ជាជ្រុង<br>– $\angle A$ , $\angle B$ ,$\angle C$ ជាមុំ $\Delta ABC$<br>សំគាល់:ជ្រុងនិងមុំនៃត្រីកោណហៅថាធាតុ។ត្រីកោណមួយមានធាតុ 9 គឺ មុំ3 ជ្រុង3 កំពូល3 ។<br>$\angle A$ ឈម $BC$ , $\angle B$ ឈម $AC$<br>$\angle C$ ឈម $AB$ ។<br><br>២.២លក្ខណៈទូទៅនៃត្រីកោណ<br>∗ **មេដ្យាន**<br><br><br>– $M$ ជាចំណុចកណ្តាលនៃ $BC$<br>– $AM$ ហៅថាមេដ្យាននៃ $\Delta ABC$<br>ជាទូទៅ:មេដ្យាននៃត្រីកោណ $ABC$ ជាអង្កត់ភ្ជាប់ពីកំពូលមក | $P = P_1 + P_2$<br>$P_1 = 12 + 12 + 6 = 30$<br>$P_2 = \pi R = 3\times 4.14 = 9.42$<br>$\Rightarrow P_1 + P_2 = 30 + 9.42 = 39.42$<br><br><br>សិស្សមើលមេរៀន<br>– ដែលហៅថាសូលីតគឺជាប្រភេទធរណីមាត្រដែលមានធរណីមាត្រងាយនិងមានមាត្រ។<br>ឧទាហរណ៍:ធុងសាំងប្រអប់ដីស<br><br><br>– $\Delta ABC$ អានថាត្រីកោណ $ABC$<br>– $A$ , $B$, $C$ ជាកំពូល<br>– $AB$, $BC$ ,$CA$ ជាជ្រុង<br>– $\angle A$ , $\angle B$ ,$\angle C$ ជាមុំ $ABC$<br>សំគាល់:ជ្រុងនិងមុំនៃត្រីកោណហៅថាធាតុ។ត្រីកោណមួយមានធាតុ 9 គឺ មុំ3 ជ្រុង3 កំពូល3 ។<br>នោះ: $\angle A$ ឈម $BC$ $\angle B$ ឈម $AC$<br>$\angle C$ ឈម $AB$ ។<br><br><br><br>– $M$ ជាចំណុចកណ្តាលនៃ $BC$<br>– $AM$ ហៅថាមេដ្យាននៃ $\Delta ABC$<br>ជាទូទៅ:មេដ្យាននៃត្រីកោណ $ABC$ ជាអង្កត់ភ្ជាប់ពីកំពូលមក |

| | | |
|---|---|---|
| | ចំណុចកណ្ដាលនៃជ្រុងឈម ។ | ចំណុចកណ្ដាលនៃជ្រុងឈម ។ |
| * សង់រូបពន្យល់ និងអោយសិស្សកត់ត្រា | * **កម្ពស់**  <br>$-\ AH \perp BC$ អានថា $AH$ កែង $BC$<br>$-AH$ ហៅថាកម្ពស់ត្រូវនិង $BC$<br>ជាទូទៅ:កម្ពស់នៃ $\Delta ABC$ គូសចេញ<br>ពីកំពូលកែងនឹងជ្រុងឈម<br>បណ្ដោយនៃជ្រុងឈម ។ |  <br>$-\ AH \perp BC$ អានថា $AH$ កែង<br>$BC$<br>$-AH$ ហៅថាកម្ពស់ត្រូវនិង $BC$<br>ជាទូទៅ:កម្ពស់នៃ $\Delta ABC$ គូសចេញ<br>ពីកំពូលកែងនឹងជ្រុងឈម<br>បណ្ដោយនៃជ្រុងឈម ។ |
| * សង់រូបពន្យល់ និងអោយសិស្សកត់ត្រា | * មេដ្យាទ័រ  <br>$-\ M$ កណ្ដាល $BC$<br>$-(d) \perp BC$ ត្រង់ $M$ |  <br>$-\ M$ កណ្ដាល $BC$<br>$-(d) \perp BC$ ត្រង់ $M$ |
| **ឧទាហរណ៍**:ប្រលេពីប៉ែតកែងមានមាឌ $100352dm^3$ និងផ្ទៃក្រលាបាត $35840cm^2$ ។រកកំពស់ប្រលេពីប៉ែតកែងគិតជាម៉ែត និងមីលីម៉ែត ។ | $-$រកកម្ពស់ប្រលេពីម៉ែតកែងគិតជា $m$ និង $mm$<br>តាមរូបមន្ត: $V = B \times h \Rightarrow h = \frac{V}{B}$<br>ដោយ $V = 100352dm^3$<br>$B = 35840cm^2 = 358.40dm^2$<br>$\Rightarrow h = \frac{100352}{358.40} = 280dm$<br>យើងបាន:<br>$280dm = 28m, 280dm = 28000mm$<br>ដូចនេះ កម្ពស់នៃប្រលេពីម៉ែតកែង<br>$h = 28m$ , $h = 28000mm$ | $-$រកកម្ពស់ប្រលេពីម៉ែតកែងគិតជា $m$ និង $mm$<br>តាមរូបមន្ត: $V = B \times h \Rightarrow h = \frac{V}{B}$<br>ដោយ $V = 100352dm^3$<br>$B = 35840cm^2 = 358.40dm^2$<br>$\Rightarrow h = \frac{100352}{358.40} = 280dm$<br>យើងបាន:<br>$280dm = 28m, 280dm = 28000m$<br>កម្ពស់នៃប្រលេពីម៉ែតកែង<br>$h = 28m$ , $h = 28000mm$ |

| | | |
|---|---|---|
| *គ្រូគូសរូបគូបលើក្តាខៀន រួចសួរសិស្ស<br>–តើរូបនេះជារូបអ្វី ?<br><br>–ដូចម្តេចដែលហៅថាគូប?<br><br>–អោយសិស្សទាញជាទូទៅ | ២. គូប<br><br>–ដែលហៅថាគូបគឺប្រលេពីប៉ែតកែងដែលមានវិមាត្រទាំងបីមានទ្រនុងស្មើគ្នា ។<br>ជាទូទៅ:បើ $V$ ជាមាត្រហើយ $a$ ជាទ្រនុងនៃគូបនោះគេសរសេរ<br>$V = a\times a\times a = a^3$<br>សំគាល់:មាឌនៃគូបស្មើនិងស្វ័យគុណបីនៃទ្រនុងរបស់វា $V = a^3$<br>–ប្រវែងទ្រនុងគូបស្មើនឹងរឹសគូបនៃមាឌរបស់វា $a = \sqrt[3]{v}$ | <br>–ដែលហៅថាគូបគឺប្រលេពីប៉ែតកែងដែលមានវិមាត្រទាំងបីមានទ្រនុងស្មើគ្នា ។<br>ជាទូទៅ:បើ $V$ ជាមាត្រហើយ $a$ ជាទ្រនុងនៃគូបនោះគេសរសេរ<br>$V = a\times a\times a = a^3$<br>សំគាល់:មាឌនៃគូបស្មើនិងស្វ័យគុណបីនៃទ្រនុងរបស់វា $V = a^3$<br>–ប្រវែងទ្រនុងគូបស្មើនឹងរឹសគូបនៃមាឌរបស់វា $a = \sqrt[3]{v}$ |
| **ឧទាហរណ៍**:គូមួយមានវិមាត្រ $2.5dm$ ។គណនាមាឌគូបនេះ | គណនាមាឌនៃគូប<br>គេបាន $V = a\times a\times a$<br>$= 2.5\times 2.5\times 2.5 = 15.625dm^3$<br>ដូចនេះ: $\boxed{V = 15.625dm^3}$ | គណនាមាឌនៃគូប<br>គេបាន $V = a\times a\times a$<br>$= 2.5\times 2.5\times 2.5 = 15.625dm^3$<br>ដូចនេះ: $\boxed{V = 15.625dm^3}$ |
| ពន្យល់រូបក្នុងសៀវភៅ និង សិស្សសរសេរ | ៣. ស៊ីឡាំង<br><br>- មាឌនៃស៊ីឡាំងស្មើ ផ្ទៃក្រលាបាតគុណ និងកម្ពស់ ។<br>-បើ $h$ ជារង្វាស់កំពស់ហើយ $S$ ជា ផ្ទៃក្រលាបាត និង $V$ ជាមាឌស៊ីឡាំង នោះគេបាន:<br>$V = S\times h$ , $S = \pi R^2$<br>នាំអោយ $V = \pi R^2 h$<br>- គណនាមាឌដែកគិតជា $dm^3$<br>តាមរូបមន្ត: $V = \pi R^2 h$<br>ដោយ $\pi = 3.14, R = \frac{30}{2} = 15mm^2$ | <br>- មាឌនៃស៊ីឡាំងស្មើ ផ្ទៃក្រលាបាតគុណ និងកម្ពស់ ។<br>-បើ $h$ ជារង្វាស់កំពស់ហើយ $S$ ជា ផ្ទៃក្រលាបាត និង $V$ ជាមាឌស៊ីឡាំង នោះគេបាន:<br>$V = S\times h$ , $S = \pi R^2$<br>នាំអោយ $V = \pi R^2 h$<br>- គណនាមាឌដែកគិតជា $dm^3$<br>តាមរូបមន្ត: $V = \pi R^2 h$<br>$\pi = 3.14, R = \frac{30}{2} = 15mm^2$ |

| | | |
|---|---|---|
| **-ឧទាហរណ៍:**ដែកមួយកំនាត់មានរាងស៊ីឡាំងត្រង់មានប្រវែង $8m$ ។អង្កត់ផ្ចិតនៃមុខកាត់ស្មើនិង $30mm$ ។គណនមាឌដែកគិតជា $dm^3$ , $\pi = 3.14$ | $h = 8m = 8000mm$<br>$\Rightarrow V = 3.14\times 15^2 \times 8000$<br>$= 565200mm^3 = 5.62000dm^3$<br>ដូចនេះ: $\boxed{V = 5.65200dm^3}$ | $h = 8m = 8000mm$<br>$\Rightarrow V = 3.14\times 15^2 \times 8000$<br>$= 565200mm^3 = 5.62000dm$<br>ដូចនេះ: $\boxed{V = 5.65200dm^3}$ |
| **ប្រតិបត្តិ:**គេអោយប្រលេពីប៉ែតកែងមួយដែលមានបណ្តាយ $8cm$ ទទឹង $4cm$ និងកំពស់ $5cm$ ។រកមាឌប្រលេពីប៉ែត<br>**ប្រតិបត្តិ:**កំណាត់ឈើរមូយរាងស៊ីឡាំងមានប្រវែង $9m$ ។ផ្ទៃក្រលាបាតកំណាត់ឈើនោះ $9.42m^2$ ង។គណនាមាឌឈើ | **ជំហានទី៤** (ពង្រឹងពុទ្ធិ)<br>**ប្រតិបត្តិ:**គេអោយប្រលេពីប៉ែតកែងមួយដែលមានបណ្តាយ $8cm$ ទទឹង $4cm$ និងកំពស់ $5cm$ ។រកមាឌប្រលេពីប៉ែត<br>**ប្រតិបត្តិ:**កំណាត់ឈើរមូយរាងស៊ីឡាំងមានប្រវែង $9m$ ។ផ្ទៃក្រលាបាតកំណាត់ឈើនោះ $9.42m^2$ ង។គណនាមាឌឈើ | -រកមាឌប្រលេពីប៉ែតកែង<br>តាមរូបមន្ត:$V = a\times b\times h$<br>គេបាន $V = 8\times 4\times 5 = 160cm^3$<br>ដូចនេះ: $\boxed{V = 160dm^3}$<br>-គណនាមាឌឈើ<br>តាមរូបមន្ត: $V = S\times h = 9.42\times 9$<br>$= 83.88m^3$<br>ដូចនេះ: $\boxed{V = 83.88m^3}$ |
| ពេលប្អូនតៅផ្ទះវិញធ្វើលំហាត់ទំព័រទី១៩១ ពីលំហាត់ទី១-២ | **ជំហានទី៥** (បណ្តាំផ្ញើ ) | ស្តាប់ និងកត់ត្រា ។ |

# កិច្ចតែងការបង្រៀន

- មុខវិទ្យា : គណិតវិទ្យា
- ថ្នាក់ទី : 7
- មេរៀនទី 18 :មាឌ និងក្រលាផ្ទៃខាងនៃសូលីត
- រយៈពេល :1 ម៉ោង

*I.* **វត្ថុបំណង**

+ ចំណេះដឹង : កំណត់ផ្ទៃក្រលាខាងនៃសូលីតអោយបានច្បាស់លាស់តាមរយៈឧទាហរណ៍

+ បំណិន : គណនាក្រលាផ្ទៃខាងនៃសូលីតអោយបានត្រឹមត្រូវតាមរយៈអនុវត្តផ្ទាល់ ។

+ឥរិយាបទ : មានស្មារតីបម្រុងប្រយ័ត្នគណនាផ្ទៃក្រលាខាងនៃសូលីតនៅក្នុងលំហាត់ជីវភាពប្រចាំថ្ងៃក្រោយពីរៀនផ្នែកនេះចប់ ។

*II.* **សំភារៈឧបទេស**

– សៀវភៅសិស្សទំព័រ 188 – 191

– ក្រដាសកាតុងមានគូសរូប និងបន្ទាត់ក្រិត

*III.* **ដំណើកនាំមេរៀន**

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| ពិនិត្យអវត្តមាន អនាម័យ និងសណ្តាប់ធ្នាប់ក្នុងថ្នាក់រៀន | **ជំហានទី១** (រដ្ឋបាលថ្នាក់ ) | ប្រធានថ្នាក់ឡើងរាយការណ៍ |
| រកមាឌហិបមួយដែលមានវិមាត្រ $20dm$ , $18dm$ និងមានកំពស់ $8dm$ ។រកមាឌគូបមួយដែលមានវិមាត្រ $30dm$ ។ | **ជំហានទី ២** ( រំលឹកមេរៀនចាស់) | -រកមាឌនៃហិប<br>តាមរូបមន្ត: $V = a \times b \times h$<br>គេបាន<br>$V = 20 \times 18 \times 8 = 2880dm^3$<br>ដូចនេះ មាឌហិប $V = 2880dm^3$<br>-រកមាត្រគូប<br>តាមរូបមន្ត:$V = a^3$<br>គេបាន<br>$V = a^3 = 30^3 = 27000dm^3$<br>ដូចនេះ $V = 27000dm^3$ |

<table>
<tr>
<td>
អោយសិស្សអានមេរៀនត្រង់ចំណុច ៣ ។<br><br>
* ពន្យល់រូបភាពក្នុងសៀវភៅ និងទាញយករូបមន្ត<br>
-ណែនាំសិស្សអោយចេះមើលរូបនិង សង្កេតរូប ។<br>

<br>
(ប្រលេពីប៉ែតកែង)<br>

<br>
(គូប)<br><br>
ឧទាហរណ៍:គណនាផ្ទៃក្រលាខាងទាំងអស់នៃដុំសាប៊ូនៃរូបខាងក្រោម ។<br>


</td>
<td>
ជំហានទី ៣ ( មេរៀនថ្មី )<br>
មាឌនិងផ្ទៃក្រលាខាងនៃសូលីត<br>
៣. ផ្ទៃក្រលាខាងនៃសូលីត<br>
៣.១.ផ្ទៃក្រលាប្រលេពីប៉ែតកែងនិងគូប<br>
រូបមន្ត:ក្រលាផ្ទៃខាងប្រលេពីប៉ែត<br>
$S_L = P \times h = 2(a+b)h$<br>
$S_T = 2S_B + S_L$<br>
-$S_L$ ផ្ទៃក្រលាខាង<br>
-$S_T$ ផ្ទៃក្រលាទាំងអស់<br>
-$S_B$ ផ្ទៃក្រលាបាត<br>
សំគាល់:<br>
-បើព្រីសត្រង់មានបាតជាចតុកោណកែងនោះគេហៅថាប្រលេពីប៉ែតកែង ។<br>
-បើមុខទាំង 6 នៃប្រលេពីប៉ែតកែងជាការេប៉ុនគ្នានោះហៅថាគូប ។<br>
រូបមន្ត: ក្រលាផ្ទៃខាងនៃគូប<br>
$S_L = P \times h = 4a \times a = 4a^2$<br>
$S_T = 4a^2 + 2a^2 = 6a^2$<br>
-គណនាផ្ទៃក្រលាខាងទាំងអស់ដោយដុំសាប៊ូជាគូប<br>
គេបាន:<br>
-ក្រលាផ្ទៃបាត $S_B = 4 \times 4 = 16$<br>
-ក្រលាផ្ទៃខាង $S_L = 4 \times 4 \times 4 = 64$<br>
នាំអោយក្រលាផ្ទៃទាំងអស់<br>
$S_T = 2S_B + S_L$<br>
$= 2 \times 16 + 64 = 128cm^2$<br>
៣.២.ផ្ទៃក្រលាខាងនៃស៊ីឡាំង<br><br>
រូបមន្ត:
</td>
<td>
រូបមន្ត:ក្រលាផ្ទៃខាងប្រលេពីប៉ែត<br>
$S_L = P \times h = 2(a+b)h$<br>
$S_T = 2S_B + S_L$<br>
-$S_L$ ផ្ទៃក្រលាខាង<br>
-$S_T$ ផ្ទៃក្រលាទាំងអស់<br>
-$S_B$ ផ្ទៃក្រលាបាត<br>
សំគាល់:<br>
-បើព្រីសត្រង់មានបាតជាចតុកោណកែងនោះគេហៅថាប្រលេពីប៉ែតកែង ។<br>
-បើមុខទាំង 6 នៃប្រលេពីប៉ែតកែងជាការេប៉ុនគ្នានោះហៅថាគូប ។<br>
រូបមន្ត: ក្រលាផ្ទៃខាងនៃគូប<br>
$S_L = P \times h = 4a \times a = 4a^2$<br>
$S_T = 4a^2 + 2a^2 = 6a^2$<br>
-គណនាផ្ទៃក្រលាខាងទាំងអស់ដោយដុំសាប៊ូជាគូប<br>
គេបាន:<br>
-ក្រលាផ្ទៃបាត $S_B = 4 \times 4 = 16$<br>
-ក្រលាផ្ទៃខាង $S_L = 4 \times 4 \times 4 = 64$<br>
នាំអោយក្រលាផ្ទៃទាំងអស់<br>
$S_T = 2S_B + S_L$<br>
$= 2 \times 16 + 64 = 128cm^2$
</td>
</tr>
</table>

| | | |
|---|---|---|
| * ពន្យល់រូប និងទាញរករូបមន្ត  ស៊ីឡាំង<br><br>ឧទាហរណ៍:គណនាក្រលាផ្ទៃខាងនៃបំពងទឹកដែលមាន $R=0.8m$ , $h=17m$ ។<br><br>ឧទាហរណ៍:គណនាក្រលាផ្ទៃទាំងអស់នៃធុងមួយមានរាងស៊ីឡាំង ដែលមានកាំ $0.4m$ និងកំពស់ $1.50m$ ។ $(\pi=3.14)$ | $P_B=2\pi R$ , $S_B=\pi R^2$<br>$S_L=P_B\times h$<br>$S_T=S_L+2S_B$<br>- $P_B$ បរិមាត្ររង្វង់<br>, $S_B$ ក្រលាផ្ទៃបាត<br>- $S_L$ ក្រលាផ្ទៃខាង<br>- $S_T$ ក្រលាផ្ទៃទាំងអស់<br><br>-គណនាក្រលាផ្ទៃខាងនៃបំពង់ទឹក<br>តាមរូបមន្ត: $S_L=2\pi Rh$<br>$\Rightarrow S_L=2\times3.14\times0.8\times17=85.408$<br>ដូចនេះ $S_L=85.408m^2$<br>-គណនាក្រលាផ្ទៃទាំងអស់<br>តាមរូបមន្ត: $S_T=S_L+2S_B$<br>$S_L=2\pi Rh=2\times3.14\times0.4\times1.50$<br>$=3.768m^2$<br>$S_B=\pi R^2=3.14\times(0.4)^2=0.5m^2$<br>$\Rightarrow S_T=3.768+2\times0.5=4.768m^2$<br>ដូចនេះ $S_T=4.768m^2$ | **រូបមន្ត:**<br>$P_B=2\pi R$ , $S_B=\pi R^2$<br>$S_L=P_B\times h$<br>$S_T=S_L+2S_B$<br>- $P_B$ បរិមាត្ររង្វង់ , $S_B$ ក្រលាផ្ទៃបាត<br>- $S_L$ ក្រលាផ្ទៃខាង<br>- $S_T$ ក្រលាផ្ទៃទាំងអស់<br>-គណនាក្រលាផ្ទៃខាងនៃបំពង់ទឹក<br>តាមរូបមន្ត: $S_L=2\pi Rh$<br>$\Rightarrow S_L=2\times3.14\times0.8\times17=85.408$<br>ដូចនេះ $S_L=85.408m^2$<br>-គណនាក្រលាផ្ទៃទាំងអស់<br>តាមរូបមន្ត: $S_T=S_L+2S_B$<br>$S_L=2\pi Rh=2\times3.14\times0.4\times1.50$<br>$=3.768m^2$<br>$S_B=\pi R^2=3.14\times(0.4)^2=0.5m^2$<br>$\Rightarrow S_T=3.768+2\times0.5=4.768m^2$<br>ដូចនេះ $S_T=4.768m^2$ |
| ប្រតិបត្តិ:ស៊ីឡាំងមួយមានមាឌ $1550.25dm^3$ និងកម្ពស់ $12.5m$<br>ក. គណនាផ្ទៃក្រលាបាត<br>ខ. គណនាផ្ទៃក្រលាទាំងអស់ | **ជំហានទី ៤** (ពង្រឹងពុទ្ធិ )<br>ប្រតិបត្តិ:ស៊ីឡាំងមួយមានមាឌ $1550.25dm^3$ និងកម្ពស់ $12.5m$<br>ក. គណនាផ្ទៃក្រលាបាត<br>ខ. គណនាផ្ទៃក្រលាទាំងអស់ | ក. គណនាផ្ទៃក្រលាបាត<br>តាមរូបមន្ត: $V=S_B\times h$<br>$\Rightarrow S_B=\frac{V}{h}=\frac{1550.25}{12.5}=124.02$<br>ដូចនេះ $S_B=124.02dm^2$<br>ខ. គណនាក្រលាផ្ទៃទាំងអស់<br>តាមរូបមន្ត: $S_T=S_L+2S_B$<br>$S_L=V=1550.25, S_B=124.02$<br>$\Rightarrow S_T=1550.25+2\times124.02$<br>$=1798.29dm^2$<br>ដូចនេះ $S_T=1798.29dm^2$ |

| | | |
|---|---|---|
| ពេលប្អូនទៅផ្ទះវិញខិតខំរៀនសូត្រ និងជួយធ្វើការងារឪពុកម្តាយផង ។ | **ជំហានទី ៥** (បណ្តាំផ្ញើ ) | ស្តាប់និងធ្វើតាម ។ |

# កិច្ចតែងការបង្រៀន

- មុខវិជ្ជា: គណិតវិទ្យា
- ថ្នាក់ទី៧
- មេរៀនទី១៩: ភាពឆ្លុះ
- រយៈពេល: ១០០ នាទី

I វត្ថុបំណង: ក្រោយពីបញ្ចប់មេរៀននេះសិស្សអាច:

- ចំណេះដឹង: កំណត់ភាពឆ្លុះនិងរូបឆ្លុះធៀបនឹងចំណុច ឬ បន្ទាត់
- ចំណេះធ្វើ: សង់រូបឆ្លុះធៀបនឹងចំណុច ឬ បន្ទាត់ បានលឿនហើយត្រឹមត្រូវ។
- ឥរិយាបថ: មានបំរុងប្រយត្ន័និងទទួលខុសត្រូវខ្ពស់ក្នុងការសង់រូបឆ្លុះ៕

II សំភារ:ឧបទេស

- សៀវភៅសិស្ស សៀវភៅគ្រូ
- បន្ទាត់ ដែនឈាន និង ផ្ទាំងរូបភាពឆ្លុះគ្នា

III ដំណើរការបង្រៀន

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| ពិនិត្យអវត្តមាន អនាម័យ សណ្តាប់ធ្នាប់ | ជំហានទី១ (៥នាទី)<br>- រដ្ឋបាលថ្នាក់ | -ប្រធានថ្នាក់ឡើងរាយការណ៍ |
| -នៅពេលដែលយើងឆ្លុះកញ្ចក់តើឃើញអ្វី? | ជំហានទី២(៥នាទី)<br>រំលឹកមេរៀនចាស់ | -ឃើញរូបរបស់យើង |
| វត្ថុបំណងនៃមេរៀននេះគឺ ភាពឆ្លុះនិងរូបឆ្លុះធៀបនឹងចំណុច ឬ បន្ទាត់។ | ជំហានទី3 (៨០នាទី)<br><u>មេរៀនទី១៩</u> **ភាពឆ្លុះ**<br>១. <u>ភាពឆ្លុះធៀបនឹងចំណុច</u><br>១.១ <u>ភាពឆ្លុះធៀបនឹងចំណុច</u><br>គេមានចំណុចនឹង $O$មួយ និងចំណុច $M$ មួយនៅក្នុងប្លង់ ។គេគូសអង្កត់ $OM$ រួចបន្លាយខាង $O$ ឲ្យបាន $OM' = OM$ ។ | |

| | | |
|---|---|---|
| -តើ $O$ជាចំណុចអ្វីនៃ $MM'$ ? | -$O$ជាចំណុចកណ្តាលនៃ$MM'$ | -$O$ជាចំណុចកណ្តាលនៃ$MM'$ |
| -គេថា $M'$ឆ្លុះនឹង $M$ធៀបនឹងចំណុច $O$។ចំណុច $O$ហៅថា**ផ្ចិតឆ្លុះ** ។ ចូរកំណត់ទូទៅនៃភាពឆ្លុះធៀបនឹងចំណុច។ | ជាទូទៅ:ចំណុច $M'$ ឆ្លុះ $M$ ធៀបនឹងចំណុច $O$ មួយ កាលណា $O$ ជាចំណុចកណ្តាលនៃអង្កត់ $MM'$ ។ | -ចំណុច $M'$ ឆ្លុះ $M$ ធៀបនឹងចំណុច $O$ មួយ កាលណា $O$ ជាចំណុចកណ្តាលនៃអង្កត់ $MM'$។ |
| -ចំណុចឆ្លុះនៃចំណុច $O$ធៀបនឹង$O$គឺចំណុចអ្វី? | | -ចំណុច $O$ ។ |
| | ១.២ <u>សំណង់ចំណុច $M'$ ជាចំណុចឆ្លុះនៃ $M$ ធៀបនឹង $O$</u><br>ក. <u>ការប្រើប្រាស់បន្ទាត់លេខ</u> | |
| -ចូរគូសកន្លះបន្ទាត់ $MO$។<br>-បន្លាយ $MO$ ដែល $MO = OM'$ | គេគូសកន្លះបន្ទាត់ $MO$ រួចគេដៅចំណុច $M'$ ដោយឲ្យ $OM' = MO$<br><br> | <br> |
| -សង់កន្លះបន្ទាត់ $MO$និងកន្លះរង្វង់ផ្ចិត $O$ កាំ $OM$។ | ខ. <u>ការប្រើដៃកឈាននិងបន្ទាត់</u><br>កន្លះបន្ទាត់ $MO$និងកន្លះរង្វង់ផ្ចិត $O$ កាំ $OM$ ។កន្លះរង្វង់នេះបន្ទាត់ $MO$ ត្រង់ $M'$ ។ | |
| -បិទរូបភាពរូបឆ្លុះគ្នាធៀបនឹងចំណុច រួចឲ្យសិស្សសន្និដ្ឋានរូប $A$ និង $A'$ ។ | ២. <u>រូបឆ្លុះគ្នាធៀបនឹងចំណុច</u><br><br><br>រូប $A$ និង $A'$ ឆ្លុះគ្នាធៀបចំណុច $O$ ។ | -រូប $A$ និង $A'$ ឆ្លុះគ្នាធៀបចំណុច $O$ |
| -រូបឆ្លុះនៃបន្ទាត់ $d$ ធៀបចំណុច $O$ $(O \notin d)$គឺបន្ទាត់ $d'$ស្របបន្ទាត់ $d$<br>-បើចំណុច $O$ ស្ថិតនៅលើបន្ទាត់ $d$ នោះបន្ទាត់ $d'$ ត្រួតស៊ីលើបន្ទាត់ $d$<br>-បើចំណុច $A, B,$ និង $C$ រត់ត្រង់ជួរ នោះចំណុចឆ្លុះវា $A', B'$ និង $C'$ ក៏រត់ត្រង់ជួរដែរ។ | ២.១ <u>បន្ទាត់ឆ្លុះគ្នាធៀបនឹងចំណុច</u><br>-រូបឆ្លុះនៃបន្ទាត់ $d$ ធៀបចំណុច $O$ $(O \notin d)$គឺបន្ទាត់ $d'$ស្របបន្ទាត់ $d$<br>-បើចំណុច $O$ ស្ថិតនៅលើបន្ទាត់ $d$ នោះបន្ទាត់ $d'$ ត្រួតស៊ីលើបន្ទាត់ $d$<br>-បើចំណុច $A, B,$ និង $C$ រត់ត្រង់ជួរ នោះចំណុចឆ្លុះវា $A', B'$ និង $C'$ ក៏រត់ត្រង់ជួរដែរ។<br>២.២ <u>អង្កត់ឆ្លុះគ្នាធៀបនឹងចំណុច</u><br>គេមានចំណុច$A', B', I'$ ជាចំណុចឆ្លុះនៃចំណុច $A, B, I$ ធៀបចំណុច $O$។ | សង្កេតនិងកត់ត្រា |

| | | |
|---|---|---|
| -បើ $A'B'$ ឆ្លុះ $AB$ធៀបចំណុច $O$នោះ គេបានអ្វី? | បើ $A'B'$ ឆ្លុះ $AB$ធៀបចំណុច $O$គេ បាន $A'B' \parallel AB$ និង $A'B' = AB$។ | -គេបាន $A'B' \parallel AB$ និង $A'B' = AB$ |
| -បើ $I$ ជាចំណុចកណ្ដាលនៃ $AB$ នោះ $I'$ជាចំណុចអ្វីនៃ $A'B'$ | បើ $I$ ជាចំណុចកណ្ដាលនៃ $AB$ នោះ $I'$ជាចំណុចកណ្ដាលនៃ $A'B'$<br>២.៣ មុំឆ្លុះគ្នាធៀបនឹងចំណុច | - $I'$ជាចំណុចកណ្ដាលនៃ $A'B'$ |
| -រូបមុំឆ្លុះគ្នាធៀបនឹងចំណុចមួយ ជាមុំអ្វី? | -រូបមុំឆ្លុះគ្នាធៀបនឹងចំណុចមួយ ជាមុំមួយទៀតដែលប៉ុនគ្នា ។ | -ជាមុំមួយទៀតដែលប៉ុនគ្នា ។ |
| -រូបឆ្លុះនៃមុំកែងមួយធៀបនឹងចំណុចមួយ ជាមុំអ្វី? | -រូបឆ្លុះនៃមុំកែងមួយធៀបនឹងចំណុចមួយ ជាមុំកែងមួយទៀត ។<br>***ជាទូទៅ***រូបពីរឆ្លុះធៀបនឹងចំណុចជារូបប៉ុនគ្នា ។<br>-បន្ទាត់ឆ្លុះគ្នាធៀបនឹងចំណុចមួយជាបន្ទាត់ស្របគ្នា(បើបន្ទាត់មិនកាត់តាមផ្ចិតឆ្លុះ)។<br>-អង្កត់ពីរឆ្លុះគ្នាធៀបនឹងចំណុចមួយជាអង្កត់ស្របគ្នា និងប៉ុនគ្នា។<br>-មុំពីរឆ្លុះគ្នាធៀបនឹងចំណុចមួយជាមុំប៉ុនគ្នា។<br>៣ ភាពឆ្លុះធៀបនឹងបន្ទាត់<br>៣.១ ចំណុចឆ្លុះធៀបនឹងបន្ទាត់ | -ជាមុំកែងមួយទៀត ។ |
| -គេលាតក្រដាសនោះវិញតើគេសង្កេតឃើញដូចម្ដេចចំពោះ ចំណុច $A'$ និងចំណុច $A$តាមស្នាមនៃបន្ទាត់ដែលបត់ដោយបន្ទាត់ $d$ ? | Ex បើយកក្រដាសមួយសន្លឹកបត់ជាពីរ។គេយកខ្មៅដៃចុចលើក្រដាសនោះត្រង់ចំណុចមួយតាងដោយ$A$ រួចឲ្យឆ្លុះទៅម្ខាងទៀតតាងដោយចំណុច$A'$។គេលាតក្រដាសនោះវិញ | -ចំណុច $A'$ឆ្លុះចំណុច $A$តាមស្នាមនៃបន្ទាត់ដែលបត់ដោយបន្ទាត់ $d$។ |
| -គេថាចំណុច $A'$ឆ្លុះនឹងចំណុច $A$ ធៀបនឹងបន្ទាត់ $d$ ។ចូរកំណត់ជាទូទៅ។ | -ជាទូទៅ ចំណុច $A'$ឆ្លុះនឹងចំណុច $A$ ធៀបនឹងបន្ទាត់ $d$ កាលណាបន្ទាត់ $d$ កែងនឹងអង្កត់ $AA'$ ត្រង់ចំណុចកណ្ដាល $O$។ បន្ទាត់ $d$ ហៅថា មេដ្យាទ័រ $AA'$ ។<br>សំគាល់ បើចំណុច$M \in d$នោះ ចំណុចឆ្លុះ$M'$ ត្រួតលើ$M$។<br>៣.២ សង់ចំណុច $A'$ឆ្លុះចំណុច $A$ ធៀបនឹងបន្ទាត់ $d$ | -ចំណុច $A'$ឆ្លុះនឹងចំណុច $A$ធៀបនឹងបន្ទាត់ $d$ កាលណាបន្ទាត់ $d$ កែងនឹងអង្កត់ $AA'$ ត្រង់ចំណុចកណ្ដាល $O$។ បន្ទាត់ $d$ ហៅថា មេដ្យាទ័រ $AA'$ ។ |

| | | |
|---|---|---|
| តាមចំណុច$A$ គេគូស$AA'$ កែងនឹង$d$ ត្រង់$O$ ដែល $OA = OA'$។<br><br>-បិទរូបភាពរូបឆ្លុះគ្នាធៀបនឹង បន្ទាត់ រួចឲ្យសិស្សសន្និដ្ឋានរូប $A$ និង $A'$ ។<br><br>-រូប $A$ និង $A'$ជារូបប៉ុនគ្នាដែរឬទេ?<br><br>-តើប្អូនសន្និដ្ឋានបានដូចម្តេចចំពោះ<br>• រូបពីរឆ្លុះគ្នាធៀបនឹងបន្ទាត់មួយជារូបអ្វីនឹងគ្នា?<br>• រង្វង់ពីរឆ្លុះគ្នាធៀបនឹងបន្ទាត់មួយជារង្វង់អ្វីនឹងគ្នា?<br>• អង្កត់ពីរឆ្លុះគ្នាធៀបនឹងបន្ទាត់មួយជាអង្កត់អ្វីនឹងគ្នា?<br>• មុំពីរឆ្លុះគ្នាធៀបនឹងបន្ទាត់មួយជាមុំអ្វីនឹងគ្នា? | គេមានចំណុច $A$មួយ និងបន្ទាត់ $d$ មួយដែល $A \notin d$ នៅក្នុងប្លង់ $P$។ សង់ចំណុច $A'$ឆ្លុះចំណុច $A$ធៀបនឹងបន្ទាត់ $d$ ។<br><u>៩.រូបឆ្លុះគ្នាធៀបនឹងបន្ទាត់</u><br><br>**ជាទូទៅ**<br>• រូបពីរឆ្លុះគ្នាធៀបនឹងបន្ទាត់មួយជារូបប៉ុនគ្នា<br>• រង្វង់ពីរឆ្លុះគ្នាធៀបនឹងបន្ទាត់មួយជារង្វង់ប៉ុនគ្នា<br>• អង្កត់ពីរឆ្លុះគ្នាធៀបនឹងបន្ទាត់មួយជាអង្កត់ប៉ុនគ្នា<br>• មុំពីរឆ្លុះគ្នាធៀបនឹងបន្ទាត់មួយជាមុំប៉ុនគ្នា | <br>-រូប $A$ និង $A'$ ឆ្លុះគ្នាធៀបបន្ទាត់ $\Delta$ ។<br><br>-រូប $A$ និង $A'$ជារូបប៉ុនគ្នា<br><br>•ជារូបប៉ុនគ្នា<br>•ជារង្វង់ប៉ុនគ្នា<br>•ជាអង្កត់ប៉ុនគ្នា<br>•ជាមុំប៉ុនគ្នា |
| សង់រូបឆ្លុះនៃត្រីកោណ ABC ធៀបនឹងបន្ទាត់Δ ។<br> | ជំហានទី៤ (៥នាទី)<br><br>ពង្រឹងពុទ្ធិ |  |
| -ប្អូនៗទៅផ្ទះវិញធ្វើលំហាត់ទី១ដល់ទី៧ទំព័រ២០០ | ជំហានទី៥ (៥នាទី)<br>-បណ្តាំផ្ញើ | -សិស្សយកបណ្តាំផ្ញើរបស់គ្រូទៅអនុវត្តន៍។ |

# កិច្ចតែងការបង្រៀន
# គណិតវិទ្យា ថ្នាក់ទី៧

*មេរៀនទី ២០* **ប្រូបាប**

1.*វិញ្ញាសា*

2.*លទ្ធផលនៃវិញ្ញាសា*

3.*ព្រឹត្តិការណ៍*

I.**<u>វត្ថុបំណងនៃមេរៀនៈ សិស្សអាច</u>**

-ចំណេះដឹង : -ប្រាប់បានពីសកម្មភាពដែលជាវិញ្ញាសា

-ប្រាប់បានពីលទ្ធផលនៃវិញ្ញាសា

-ប្រាប់បានពីសញ្ញាណព្រឹត្តិការណ៍

-បំណិន :-កំណត់លទ្ធផលនៃវិញ្ញាសាបានត្រឹមត្រូវ

-រកចំនួនករណីនៃព្រឹត្តិការណ៍

-ឥរិយាបថ :-ទម្លាប់សិស្សឱ្យប្រកាន់យកឥរិយាបថ មិនចង់លេងល្បែងស៊ីសង

II.**<u>រយៈពេលបង្រៀនៈ</u>** ២ម៉ោង

III.**<u>សម្ភារៈឧទេស</u>**

-កាក់ គ្រាប់ឡុកឡាក់ កូនឃ្លី

IV.**<u>ដំណើរការនាំមេរៀន</u>**

| សកម្មភាពគ្រូ | ខ្លឹមសាមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| -គ្រូពិនិត្យអវត្តមាន<br>អនាម័យ<br>សណ្តាប់ធ្នាប់ និង វិន័យ | <u>*ជំហានទី១*</u> (រដ្ឋបាលថ្នាក់)<br>(៣នាទី) | តំណាងសិស្សឡើងរាយការណ៍ |
| -តើគូបមានមុខប៉ុន្មាន?<br>ហើយមុខនីមួយៗមានរាងជាអ្វី?<br>-ក្នុងការលេងកីឡា<br>តើកីឡាករម្នាក់ៗ ដឹងមុនថាខ្លួន<br>នឹងចាញ់ ឬឈ្នះឬទេ?<br>-តើប្រភេទកីឡានីមួយៗ គេហៅ<br>ថាអ្វី? | <u>*ជំហានទី២*</u> (រំលឹកមេរៀន)<br>(៧នាទី) | -គូបមានមុខ ៦ ហើយមុខនី<br>មួយៗមានរាងជាការេ<br>-មិនដឹងទេ<br><br><br>-ហៅថាវិញ្ញាសា |

| | | |
|---|---|---|
| -បង្ហាញកាក់មួយ រួចសួរៈ តើកាក់មានមុខប៉ុន្មាន? បង្ហញគ្រាប់ឡុកឡាក់រួចសួរៈតើគ្រាប់ឡុកឡាក់មានមុខប៉ុន្មាន? បើគេបោះកាក់ឬគ្រាប់ឡុកឡាក់ តើគេដឹងលទ្ធផលមុនឬទេ? -បង្ហាញថង់មួយមានឃ្លី១០ បើគេចាប់ឃ្លីមួយដោយចៃដន្យ តើគេដឹងថាចាប់បានឃ្លីមួយណាដែរឬទេ? -បញ្ជាក់ៈសកម្មភាពបោះកាក់ បោះគ្រាប់ឡុកឡាក់ ចាប់កូនឃ្លី ដែលមិនដឹងលទ្ធផលជាមុន បែបនេះហៅថាវិញ្ញាសា។ តើអ្វីទៅជាវិញ្ញាសា? -បើគេបោះកាក់មួយ តើវាអាចចេញខាងរូប ឬខាងលេខដែរឬទេ? មានប៉ុន្មានករណី? -បើគេបោះគ្រាប់ឡុកឡាក់មួយ តើវា អាចចេញលេខអ្វីខ្លះ? មានប៉ុន្មានករណី? -បើគេចុះលេខឃ្លីពីលេខ១ ដល់១០ រួចគេចាប់យកឃ្លីមួយ តើអាចចេញ លេខអ្វីខ្លះ? -បញ្ជាក់ៈ ចម្លើយទាំងអស់ខាងលើ ហៅថាលទ្ធផលនៃវិញ្ញាសា។ តើអ្វីទៅជាលទ្ធផលនៃវិញ្ញាសា? | *ជំហានទី៣* (មេរៀនថ្មី) (៦០នាទី) **មេរៀនទី.២០.ប្រូបាប** **1. *វិញ្ញាសា*** ឧទាហរណ៍ៈ សកម្មភាព -បោះកាក់ -បោះគ្រាប់ឡុកឡាក់ -ចាប់កូនឃ្លី សុទ្ធតែជាវិញ្ញាសា ជាទូទៅៈ វិញ្ញាសាគឺជាសកម្មភាពដែលគេធ្វើដោយមិនបានដឹងពីលទ្ធផលជាមុន។ **2.លទ្ធផលនៃវិញ្ញាសា** ឧទាហរណ៍១ វិញ្ញាសាបោះកាក់ ឧទាហរណ៍2 វិញ្ញាសាបោះគ្រាប់ឡុកឡាក់ ឧទាហរណ៍៣ វិញ្ញាសាចាប់កូនឃ្លី ជាទូទៅៈ លទ្ធផលនៃវិញ្ញាសាមួយគឺជាករណីទាំងអស់ដែលអាចកើតឡើងនៅក្នុងវិញ្ញាសាមួយដោយ | -កាក់មានមុខពីរ -គ្រាប់ឡុកឡាក់មានមុខ ៦ -មិនដឹងទេ -មិនដឹងទេ -វិញ្ញាសាគឺជាសកម្មភាពដែលគេធ្វើដោយមិនបានដឹងពីលទ្ធផលជាមុន។ -អាចចេញខាងរូប ឬខាងលេខ។ មានពីរករណី -អាចចេញលេខ 1, 2, 3, 4, 5, 6 មាន ៦ករណី -អាចបានលេខ 1, 2, 3, 4, 5, 6, 7, 8, 9, 10។ -លទ្ធផលនៃវិញ្ញាសាមួយគឺជាករណីទាំងអស់ដែលអាចកើតឡើងនៅក្នុងវិញ្ញាសាមួយដោយចៃដន្យ។ |

| | | |
|---|---|---|
| -ក្នុងវិញ្ញាសាបោះកាក់ តើអាចចេញ ខាងរូបដែរឬទេ?<br><br>-ការចេញខាងរូបហៅថាព្រឹត្តិការណ៍ មួយដែលកើតឡើង។<br>-ការបោះគ្រាប់ឡុកឡាក់ តើអាចបោះបានលេខ ៥ ដែរឬទេ?<br>-ការបោះបានលេខ ៥ ហៅថា ព្រឹត្តិការណ៍ដែលចេញលេខ ៥។<br>-តើព្រឹត្តិការណ៍ជាអ្វី?<br><br>-គ្រូដាក់លំហាត់គំរូ រួចណែនាំសិស្ស ឱ្យពិភាក្សាធ្វើតាមក្រុម។ | ចៃដន្យ។<br>**3.ព្រឹត្តិការណ៍**<br>ឧទាហរណ៍:<br>-ការបោះកាក់ចេញខាងរូប<br>-បោះគ្រាប់ឡុកឡាក់ចេញ លេខ៥<br>...<br>ហៅថាព្រឹត្តិការណ៍<br>***ជាទូទៅ:***<br>*ព្រឹត្តិការណ៍ជាលទ្ធផលដែលបានកើតមានឡើងដោយចៃដន្យ*<br><br>លំហាត់គំរូ១<br>បូណាបោះគ្រាប់ឡុកឡាក់មួយ។ បូណាបោះបានលេខគូ។ ចូរបញ្ជាក់ថា អ្វីជាវិញ្ញាសា? ជាលទ្ធផល? និងជាព្រឹត្តិការណ៍?<br>លំហាត់គំរូ២<br>ក្នុងថង់មួយមានប័ណ្ណអក្សរនៃពាក្យ MONDAY។ ធីតាលូកចាប់យកអក្សរមួយដោយចៃដន្យ។ ធីតាចាប់បានអក្សរ O។ តើអ្វីជាវិញ្ញាសា?ជាលទ្ធផល? និងជាព្រឹត្តិការណ៍? | -អាចចេញខាងរូប<br><br><br><br>-អាចបោះបានលេខ ៥<br><br><br>- ព្រឹត្តិការណ៍ជាលទ្ធផលដែលបានកើតមានឡើងដោយចៃដន្យ<br><br>-ចម្លើយ:<br>1.វិញ្ញាសាគឺជាការបោះគ្រាប់ឡុកឡាក់មួយ<br>លទ្ធផល: 1, 2, 3, 4, 5, 6<br>(មាន ៦ករណី)<br>ព្រឹត្តិការណ៍: 2, 4, 6<br>(មាន ៣ ករណី)<br>2.វិញ្ញាសាគឺជាការចាប់យកអក្សរមួយពីថង់ដោយចៃដន្យ<br>លទ្ធផល: M, O, N, D, A, Y<br>(មាន ៦ ករណី)<br>ព្រឹត្តិការណ៍: O (មាន១ករណី) |
| -អ្វីទៅជាវិញ្ញាសា?<br><br><br>-អ្វីទៅជាលទ្ធផល? | <u>*ជំហានទី៤*</u> (ពង្រឹងចំណេះដឹង)<br>(១០នាទី)<br>វិញ្ញាសា<br>លទ្ធផល<br>ព្រឹត្តិការណ៍ | - វិញ្ញាសាគឺជាសកម្មភាពដែលគេធ្វើដោយមិនបានដឹងពី លទ្ធផលជាមុន។<br>- លទ្ធផលនៃវិញ្ញាសាមួយគឺជា |

| | | |
|---|---|---|
| -អ្វីទៅជាព្រឹត្តិការណ៍? | | ករណីទាំងអស់ដែលអាចកើតឡើងនៅក្នុងវិញ្ញាសាមួយដោយចៃដន្យ។<br>- ព្រឹត្តិការណ៍ជាលទ្ធផលដែលបានកើតមានឡើងដោយចៃដន្យ |
| -គ្រូដាក់លំហាត់ ទី៤, ៥ ទំព័រ ២០៧ ឲ្យសិស្សធ្វើនៅផ្ទះ | ជំហានទី៥ (កិច្ចការផ្ទះ)(៥នាទី)<br>- លំហាត់ទី៤, ៥ ទំព័រ២០៧ | -សិស្សកត់ត្រាលំហាត់ |

កិច្ចតែងការបង្រៀន

គណិតវិទ្យា ថ្នាក់ទី៧

មេរៀនទី ២០ ប្រូបាប (ត)

៤.សញ្ញាណប្រូបាប

I.វត្ថុបំណងនៃមេរៀន: សិស្សអាច

-ចំណេះដឹង : -ប្រាប់បានពីបញ្ញត្តិប្រូបាប

-បំណិន :-រកប្រូបាបនៃព្រឹត្តិការណ៍មួយ

-ឥរិយាបថ :-ទម្លាប់សិស្សឱ្យប្រកាន់យកឥរិយាបថ មិនចង់លេងល្បែងស៊ីសង

II.រយៈពេលបង្រៀន: 1ម៉ោង

III.សម្ភារៈឧទេស

-កាក់ គ្រាប់ឡុកឡាក់ កូនឃ្លី ផ្ទាំងរូបភាពថាសបង្វិល

IV.ដំណើកនាំមេរៀន

| សកម្មភាពគ្រូ | ខ្លឹមសាមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| -គ្រូពិនិត្យអវត្តមាន<br>អនាម័យ<br>សណ្តាប់ធ្នាប់ និង វិន័យ | ជំហានទី១ (រដ្ឋបាលថ្នាក់)<br>(5នាទី) | តំណាងសិស្សឡើងរាយការណ៍ |
| -អ្វីទៅជាលទ្ធផល?<br><br>-អ្វីទៅជាព្រឹត្តិការណ៍? | ជំហានទី២ (រំលឹកមេរៀន)<br>(5នាទី) | - លទ្ធផលនៃវិញ្ញាសាមួយគឺជាករណីទាំងអស់ដែលអាចកើតឡើងនៅក្នុងវិញ្ញាសាមួយដោយចៃដន្យ។<br>- ព្រឹត្តិការណ៍ជាលទ្ធផលដែលបានកើតមានឡើងដោយចៃដន្យ |
| | ជំហានទី៣ (មេរៀនថ្មី) | |

| | | |
|---|---|---|
| ដាក់ឧទាហរណ៍រួចសួរះ<br>-តើចំនួនព្រឹត្តិការណ៍ស្រប តាមបំណងមានប៉ុន្មានករ ណី?អ្វីខ្លះ?<br>-តើចំនួនលទ្ធផលដែលអាច កើតមានឡើងមានប៉ុន្មាន ករណី? អ្វីខ្លះ?<br>-បើគេធ្វើផលធៀបរវាង ចំនួន ព្រឹត្តិការណ៍ស្របតាម បំណង<br>និងចំនួនលទ្ធផលដែលអាច កើត មានឡើង គេបានអ្វី?<br>-ដាក់ឧទាហរណ៍ទី២ រួចឲ្យ សិស្ស រកចំនួនករណីស្រប តាមបំណងនិងចំនួនលទ្ធផ ល<br>ដែលអាចកើតមានឡើងនិង ធ្វើផលធៀបដូចឧទាហរណ៍ ទី១<br>-បញ្ជាក់ប្រាប់សិស្សថា៖<br>ផល ធៀប $\frac{1}{3}$ និង<br>$\frac{1}{2}$ ខាងលើហៅ<br>ថាប្រូបាប។គេសរសេរ | (30នាទី)<br>**មេរៀនទី.២០.ប្រូបាប (ត)**<br>**៤.សញ្ញាណប្រូបាប**<br>ឧទាហរណ៍1:<br>គេប្រាថ្នាបោះគ្រាប់ ឡុកឡាក់ឲ្យចេញតូចជាង 3។<br>រកផលធៀបរវាងចំនួនករណីនៃ ព្រឹត្តិការណ៍ស្របតាមបំណង ប្រា ថ្នា<br>និងចំនួនករណីនៃលទ្ធផល ដែលអាចកើតមានឡើង។<br><br>-ឧទាហរណ៍២៖ គេបោះកាក់ មួយដោយចង់បានខាងរូប។<br>រកផលធៀបរវាងចំនួនករណីនៃ ព្រឹត្តិការណ៍ស្របតាមបំណង ប្រាថ្នា<br>និងចំនួនករណីនៃលទ្ធផល ដែលអាចកើតមានឡើង។<br><br>***ជាទូទៅ:***<br>ប្រូបាបនៃព្រឹត្តិការណ៍មួយជាផ ល | -ចំនួនព្រឹត្តិការណ៍ស្របតាម បំណងមាន 2 ករណីគឺ 1, 2<br>-ចំនួនលទ្ធផលដែលអាចកើត មានឡើងមាន 6ករណីគឺ 1, 2, 3, 4, 5, 6<br>-គេបានផលធៀប $\frac{2}{6}=\frac{1}{3}$<br><br>-ចម្លើយ<br>ចំនួនព្រឹត្តិការណ៍ស្របតាមបំ ណងប្រាថ្នាមាន 1 ករណីគឺ ខាងរូប<br>ចំនួនលទ្ធផលដែលអាចកើតមា នឡើង មាន 2 ករណី គឺ ខាងរូប និងខាងលេខ<br>គេបានផលធៀបស្មើ $\frac{1}{2}$<br><br>-<br>ប្រូបាបនៃព្រឹត្តិការណ៍មួយជាផ ល<br>ធៀបរវាងចំនួនករណីនៃព្រឹត្តិ ការណ៍ ស្របតាមបំណងប្រាថ្នា |

| | | |
|---|---|---|
| P(លេខតូចជាង៣)= $\frac{1}{3}$<br>P(ខាងរូប)= $\frac{1}{2}$<br>រួចសួរៈ តើអ្វីទៅជាប្រូបាបនៃព្រឹត្តិការណ៍មួយ?<br>-ដាក់លំហាត់គំរូ និងលំហាត់ ប្រតិបត្តិ រួចណែនាំសិស្សឲ្យពិភាក្សាគ្នាតាមក្រុម | ធៀបរវាងចំនួនករណីនៃព្រឹត្តិការណ៍ ស្របតាមបំណងប្រាថ្នា និង ចំនួនករណីនៃលទ្ធផលដែលអាចកើត មានឡើង។<br><br>**លំហាត់គំរូ១៖**<br>ក្នុងការបង្វិលថាស មួយដែលមានអក្សរ A, B, C, D (ដូចរូប)។ រកប្រូបាបដែលឲ្យចុងព្រួញចង្អុលត្រង់អក្សរ A។<br><br>**លំហាត់គំរូ២៖**<br>គេបោះគ្រាប់ឡុកឡាក់មួយ។រកប្រូបាបនៃព្រឹត្តិការណ៍បោះបានលេខពហុគុណនៃ 2។<br>**ប្រតិបត្តិ**<br>សន្លឹកប័ណ្ណមួយត្រូវបានជ្រើសរើសដោយចៃដន្យពីសន្លឹកប័ណ្ណដែលបង់លេខពី 1 ដល់ 9។ រកប្រូបាបនៃព្រឹត្តិការណ៍ដែលជ្រើសរើសបានសន្លឹកប័ណ្ណមានលេខជាពហុគុណនៃ 3។ | និងចំនួនករណីនៃលទ្ធផលដែលអាចកើត មានឡើង។<br>ចម្លើយ<br>១. ព្រឹត្តិការណ៍ស្របតាមបំណងប្រា ថ្នាមាន 1 ករណី លទ្ធផលដែលអាចកើតមានឡើង មាន 4 ករណី ប្រូបាបដែលចុងព្រួញចង្អុលត្រង់ A<br>គឺ P(អក្សរA) = $\frac{1}{4}$<br>២. គ្រាប់ឡុកឡាក់មានលេខ 1, 2, 3, 4, 5, 6 ។<br>លទ្ធផលដែលអាចកើតមានឡើងមាន 6 ករណី<br>លេខដែលជាពហុគុណនៃ 2 មាន 2, 4, 6<br>។ព្រឹត្តិការណ៍ដែលបោះបានលេខជាពហុគុណនៃ 2 មាន 3 ករណី។ ដូចនេះ P(គូ)= $\frac{3}{6}=\frac{1}{2}$<br>ចម្លើយប្រតិបត្តិ<br>លេខជាពហុគុណនៃ 3 មានលេខ 3, 6, 9។ព្រឹត្តិការណ៍ស្របតាមបំណងប្រាថ្នាមាន 3 ករណី<br>លទ្ធផលដែលអាចកើតមានឡើ |

| | | |
|---|---|---|
| | | ង មាន 9 ករណី<br>ដូចនេះ P(ពហុគុណនៃ3)=<br>$\frac{3}{9}=\frac{1}{3}$ |
| តើអ្វីទៅ ជាប្រូបាបនៃព្រឹត្តិការណ៍មួយ? | <u>ជំហានទី៤</u> (ពង្រឹងចំណេះដឹង)<br>(5នាទី) | -<br>ប្រូបាបនៃព្រឹត្តិការណ៍មួយជាផល<br>ធៀបរវាងចំនួនករណីនៃព្រឹត្តិការណ៍ ស្របតាមបំណងប្រាថ្នា និងចំនួន<br>ករណីនៃលទ្ធផលដែលអាចកើត មានឡើង។ |
| -គ្រូដាក់លំហាត់ ទី6 ទំព័រ 207 ឲ្យសិស្សធ្វើនៅផ្ទះ | <u>ជំហានទី៥</u> (កិច្ចការផ្ទះ)(5នាទី)<br>- លំហាត់ទី6 ទំព័រ207 | -សិស្សកត់ត្រាលំហាត់ |

កិច្ចតែងការបង្រៀន

គណិតវិទ្យា ថ្នាក់ទី៧

មេរៀនទី ២០ ប្រូបាប (តចប់)

៥.ការតាងប្រូបាបដោយប្រើចំនួនទសភាគ និងភាគរយ

I.វត្ថុបំណងនៃមេរៀន: សិស្សអាច

-ចំណេះដឹង : -ប្រាប់បានពីការប្រើចំនួនទសភាគនិងភាគរយសម្រាប់តាងប្រូបាប

-បំណិន :-រកប្រូបាបនៃព្រឹត្តិការណ៍មួយដោយប្រើចំនួនទសភាគនិងភាគរយ

-ឥរិយាបថ :-ទម្លាប់សិស្សឱ្យប្រកាន់យកឥរិយាបថ មិនចង់លេងល្បែងស៊ីសង

II.រយៈពេលបង្រៀន: 1ម៉ោង

III.សម្ភារៈឧទេស

-កាក់ គ្រាប់ឡុកឡាក់ កូនឃ្លី

IV.ដំណើកនាំមេរៀន

| សកម្មភាពគ្រូ | ខ្លឹមសាមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| -គ្រូពិនិត្យអវត្តមាន អនាម័យ សណ្តាប់ធ្នាប់ និង វិន័យ | ជំហានទី១ (រដ្ឋបាលថ្នាក់) (5នាទី) | តំណាងសិស្សឡើងរាយការណ៍ |
| -តើអ្វីទៅ ជាប្រូបាបនៃព្រឹត្តិការណ៍មួយ? | ជំហានទី២ (រំលឹកមេរៀន) (5នាទី) | ប្រូបាបនៃព្រឹត្តិការណ៍មួយជាផល ធៀបរវាងចំនួនករណីនៃព្រឹត្តិការណ៍ ស្របតាមបំណងប្រាថ្នា និងចំនួន ករណីនៃលទ្ធផលដែលអាចកើត មានឡើង។ |
| | ជំហានទី៣ (មេរៀនថ្មី) (30នាទី) **មេរៀនទី.២០.ប្រូបាប (តចប់)** | |

| | | |
|---|---|---|
| ដាក់ឧទាហរណ៍១៖<br>-ណែនាំសិស្សឲ្យរកប្រូបាប នៃព្រឹត្តិការណ៍បោះបានលេខសេស<br>-តើគេអាចប្តូរប្រភាគជា$\frac{1}{2}$ ចំនួនទសភាគនិងភាគរយបានឬទេ? ស្មើប៉ុន្មាន?<br>-ណែនាំសិស្សឲ្យសរសេរប្រូបាបជាចំនួនទស្សភាគនិងភាគរយ?<br>-តើគេអាចបោះគ្រាប់ឡុកឡាក់ មួយគ្រាប់ឲ្យចេញលេខ 7 បាន ដែរឬទេ?<br>-តើប្រូបាបវាស្មើប៉ុន្មាន?<br>-ដាក់ឧទាហរណ៍ទី២ រួចឲ្យសិស្ស រកប្រូបាប<br><br>-គ្រូគូសដ្យាក្រាមបង្ហាញកម្រិតសង្ឃឹមនៃប្រូបាបតាមភាគរយ<br>រួចបញ្ជាក់ដូចខាងក្រោម:<br>-<br>ប្រូបាបនៃព្រឹត្តិការណ៍មួយមាន តម្លៃស្មើ 0 មានន័យថា | **៥.ការតាងប្រូបាបដោយប្រើចំនួនទសភាគនិងភាគរយ**<br>ឧទាហរណ៍1:<br>គេបោះគ្រាប់ឡុកឡាក់មួយ។ រកប្រូបាបនៃព្រឹត្តិការណ៍បោះបានលេខសេស។<br>-ឧទាហរណ៍២៖<br>គេបោះគ្រាប់ឡុកឡាក់មួយគ្រាប់។<br> | -ចំនួនករណីនៃព្រឹត្តិការណ៍ស្រប តាមបំណងមាន ៣ ករណីគឺ 1,3,5<br>-ចំនួនលទ្ធផលដែលអាចកើតមាន ឡើងមាន 6ករណីគឺ 1, 2, 3, 4, 5, 6<br>-គេបានP(សេស)= $\frac{3}{6}=\frac{1}{2}$<br>-បាន $\frac{1}{2}=0.5=50\%$<br>- គេបានP(សេស)= $\frac{1}{2}=0.5=50\%$<br><br>-មិនបានទេ<br><br>-គេបាន P(7)=0<br>-<br>ចំនួនករណីនៃព្រឹត្តិការណ៍ស្រប តាមបំណងប្រាថ្នាមាន 6 ករណី<br>ចំនួនករណីលទ្ធផលដែលអាចកើតមានឡើងមាន 6 ករណី ដូចនេះ<br>P(លេខតូចជាង6)= $\frac{6}{6}=1$<br>-ស្តាប់ និងកត់ត្រា |

| | | |
|---|---|---|
| ព្រឹត្តិ<br>ការណ៍នេះមិនអាចកើតឡើង<br>-<br>ប្រូបាបនៃព្រឹត្តិការណ៍មួយមាន តម្លៃស្មើ 0.25 មានន័យថាសង្ឃឹមតិចអាចកើតឡើង<br>-<br>ប្រូបាបនៃព្រឹត្តិការណ៍មួយមាន តម្លៃស្មើ 0.5 មានន័យថាសង្ឃឹមស្មើអាចកើតមានឡើង<br>-ប្រូបាបនៃព្រឹត្តិការណ៍មួយមាន តម្លៃស្មើ 0.75 មានន័យថាសង្ឃឹមខ្លាំងអាចកើតមានឡើង<br>-ប្រូបាបនៃព្រឹត្តិការណ៍មួយមាន តម្លៃស្មើ 1 មានន័យថាព្រឹត្តិការណ៍នេះប្រាកដជាកើតឡើង<br>ដាក់លំហាត់គំរូនិងលំហាត់ប្រ តិបត្តិឲ្យសិស្សដោះស្រាយ | **លំហាត់គំរូ១**:ក្នុងថង់មួយមានប័ណ្ណនៃពាក្យ BANANA ។ គេលូកចាប់យកអក្សរមួយដោយចៃដន្យ។ រកប្រូបាបដែលចាប់បានអក្សរនីមួយៗដោយឲ្យចម្លើយជាប្រភាគ ជាចំនួនទសភាគ រួចជាភាគរយ។<br>**លំហាត់គំរូ២**:<br>ក្នុងវិញ្ញាសាបោះកាក់មួយអាចចេញអក្សរ H និង T ។ បើគេឲ្យធីតាបោះកាក់នោះពីរដង តើគេសង្ឃឹមប៉ុន្មានភាគរយដើម្បីបោះបានអក្សរ T ។<br>**ប្រតិបត្តិ**<br>ថង់មួយមានឃ្លីពណ៌ក្រហម 6 ឃ្លីពណ៌ស 5 ឃ្លីពណ៌បៃតង8 និងឃ្លីពណ៌លឿង 3 ។ គេចាប់យកឃ្លីមួយចេញពីថង់ដោយចៃដន្យ។ រកប្រូបាបដែលគេចាប់បាន ដោយឲ្យ ចម្លើយជាប្រភាគ ជាចំនួនទសភាគ រួចជាភាគរយ:<br>ក. ឃ្លីពណ៌ក្រហម<br>ខ. ឃ្លីពណ៌ស<br>គ. ឃ្លីពណ៌បៃតង<br>ឃ. ឃ្លីពណ៌លឿង។ | **ចម្លើយ**<br>១. ក្នុងពាក្យ BANANA មានអក្សរ:<br>B ចំនួន 1<br>នោះព្រឹត្តិការណ៍ចាប់បានអក្សរ B មាន 1 ករណី<br>NN ចំនួន 2<br>នោះព្រឹត្តិការណ៍ចាប់បានអក្សរ N មាន 2 ករណី<br>AAA ចំនួន 3<br>នោះព្រឹត្តិការណ៍ចាប់បានអក្សរ A មាន 3 ករណី<br>អក្សរទាំងអស់មាន 6 តួ<br>នោះលទ្ធផលដែលអាចកើតឡើងមាន 6 ករណី<br>ដូចនេះប្រូបាបដែលចាប់បានអក្សរ B គឺ $P(B)=\frac{1}{6}=0.17=17\%$<br>ប្រូបាបដែលចាប់បានអក្សរ N គឺ $P(N)=\frac{2}{6}=\frac{1}{3}=0.33=33\%$<br>ប្រូបាបដែលចាប់បានអក្សរ A គឺ $P(A)=\frac{3}{6}=\frac{1}{2}=0.5=50\%$<br>២. ធីតាបោះកាក់ពីរដង:<br>លទ្ធផលដែលអាចកើតឡើងមាន 4 ករណីគឺ $TT, TH, HH, HT$ |

| | | |
|---|---|---|
| | | ព្រឹត្តិការណ៍ស្របតាមបំណងប្រាថ្នាមាន 3 ករណីគឺ<br>$TH, HT, TT$<br>ដូចនេះប្រូបាបដែលបោះបានអក្សរ T កំណត់ដោយ<br>$P(T)=\frac{3}{4}=0.75=75\%$<br>មានន័យថា<br>ក្នុងការបោះកាក់ពីរដង<br>ធីតាមានសង្ឃឹមបោះបានអក្សរ T ដល់ទៅ 75%<br><u>ចម្លើយប្រតិបត្តិ</u><br>ដោយក្នុង ថង់មួយមានឃ្លីពណ៌ក្រហម 6 ឃ្លីពណ៌ស 5 ឃ្លីពណ៌ បៃតង8 និងឃ្លីពណ៌លឿង 3 នោះ<br>ព្រឹត្តិការណ៍ចាប់បានឃ្លីពណ៌ក្រហម មាន 6 ករណី<br>ព្រឹត្តិការណ៍ចាប់បានឃ្លីពណ៌ស មាន 5 ករណី<br>ព្រឹត្តិការណ៍ចាប់បានឃ្លីពណ៌បៃតង មាន 8 ករណី<br>ព្រឹត្តិការណ៍ចាប់បានឃ្លីពណ៌លឿង មាន 3 ករណី<br>ឃ្លីទាំងអស់មាន 22<br>នោះលទ្ធផលដែលអាចកើតមានឡើងមាន 22 ករណី |

| | | |
|---|---|---|
| | | ដូចនេះប្រូបាបដែលគេចាប់បាន<br>ក. ឃ្លីពណ៌ក្រហមគឺ<br>P(ក្រហម)=<br>$\frac{6}{22}=0.2727=27.27\%$<br>ខ. ឃ្លីពណ៌សគឺ<br>P(ស)= $\frac{5}{22}=0.2272=22.72\%$<br>គ. ឃ្លីពណ៌បៃតង P(បៃតង)=<br>$\frac{8}{22}=0.3636=36.36\%$<br>ឃ. ឃ្លីពណ៌លឿង<br>P(លឿង)=<br>$\frac{3}{22}=0.1363=13.63\%$ |
| តើកម្រិតសង្ឃឹមនៃព្រឹត្តិការណ៍តាមតម្លៃប្រូបាបមានអ្វីខ្លះ? | <u>ជំហានទី៤</u> (ពង្រឹងចំណេះដឹង)<br>(5នាទី) | -បើ p= 0 មានន័យថា ព្រឹត្តិការណ៍នេះមិនអាចកើតឡើង<br>-បើ p= 0.25 មានន័យថា សង្ឃឹមតិចអាចកើតឡើង<br>-បើ p=0.5 មានន័យថា សង្ឃឹមស្មើអាចកើតមានឡើង<br>-បើ p=0.75 មានន័យថា សង្ឃឹមខ្លាំងអាចកើតមានឡើង<br>-បើ p=1 មានន័យថា ព្រឹត្តិការណ៍នេះប្រាកដជាកើតឡើង |
| -គ្រូដាក់លំហាត់ ទី7 ទំព័រ 207 ឲ្យសិស្សធ្វើនៅផ្ទះ | <u>ជំហានទី៥</u> (កិច្ចការផ្ទះ)(5នាទី)<br>- លំហាត់ទី7 ទំព័រ207 | -សិស្សកត់ត្រាលំហាត់ |

# កិច្ចតែងការបង្រៀន

ថ្ងៃទី......... ខែ ............ ឆ្នាំ.........

## មុខវិជ្ជា: គណិតវិទ្យា

- មុខវិជ្ជា : គណិតវិទ្យាថ្នាក់ទី ៧
- មេរៀនទី ២១ : ក្រាបសរសរ
- រយៈពេល : ០២ម៉ោង

I. **វត្ថុបំណង** : ក្រោយពីរៀនចប់សិស្សអាចៈ

- ចំណេះដឹង : - ធ្វើតារាងបំណែកចែកទិន្នន័យ។
  - បកស្រាយទិន្នន័យតាមក្រាបសរសរ។
- ចំណេះធ្វើ : - សង់ក្រាបសរសរ និង សរសរភ្លោះ។
- ឥរិយាបទ : -មានបម្រុងប្រយ័ត្នក្នុងការប្រមូលទិន្នន័យនិងសង់ក្រាបសរសរ។

II. **ខ្លឹមសារមេរៀន** :

មេរៀនទី21 : ក្រាបសរសរ

1. ក្រាបសរសរ
2. ក្រាបសរសរភ្លោះ

III. **សម្ភារឧបទេស** :

-សៀវភៅសិស្សទំព័រទី 209 ដល់ទំព័រទី 214។

-ផ្ទាំងក្រដាសកាតុងរូបភាព និងក្រដាសកម្រងសំណួរ។

IV. **វិធីសាស្រ្តបង្រៀន** :

- សិស្សមជ្ឈមណ្ឌល

V. **ដំនឹកនាំមេរៀនថ្មី** :

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| -គ្រូតពិនិត្យវិន័យ អនាម័យ សណ្តាប់ធ្នាប់ និងអវត្តមាន | **ជំហានទី1** :<br>(លំនឹងថ្នាក់)<br>(5mn) | -ប្រធានថ្នាក់ឡើងរាយការណ៍។ |
| | **ជំហានទី2**<br>(រំលឹកមេរៀន) | |

<table>
<tr>
<td>-តើទិន្នន័យគឺជាអ្វី?<br><br>-តើគេបកស្រាយទិន្នន័យបានប៉ុន្មានប្រភេទ?<br>-តើគេស្រង់ទិន្នន័យដើម្បីអ្វី?</td>
<td>(10mn)</td>
<td>-ទិន្នន័យ គឺជាការប្រមូលផ្តុំ ឬស្រង់ ពត៌មានលំអិតអំពីការអង្កេត។<br>-គេបកស្រាយទិន្នន័យបានច្រើនប្រភេទ។<br>-គេស្រង់ទិន្នន័យដើម្បីវិភាគទៅលើស្ថិតិអំពីចំនួនអ្វីមួយ។</td>
</tr>
<tr>
<td>-គ្រូកត់ឧទាហរណ៍:<br>គេស្រង់អាយុសិស្ស 40 នាក់ក្នុងថ្នាក់រៀនមួយបានដូចខាងក្រោម:<br>11 11 12 13 14 12 13<br>14 11 12 12 12 14 13<br>11 12 13 12 14 11 13<br>12 13 12 12 13 12 12<br>12 13 12 11 11 13 11<br>14 14 13 14 13<br><br>-តើអាយុសិស្សស្រង់បានខាងលើគេហៅថាអ្វី?<br><br>-តើយើងអាចដឹងបានយ៉ាងងាយស្រួលអំពីអាយុសិស្សណាមួយដែលមានច្រើន</td>
<td><u>ជំហានទី3</u><br>(មេរៀនប្រចាំថ្ងៃ)<br>(90mn)<br>មេរៀនទី21 :<br>ក្រាបសរសេរ<br><br>1). <u>ក្រាបសរសេរ:</u>
<table>
<tr><td>អាយុសិស្ស</td><td>ចំនួយសិស្ស</td></tr>
<tr><td>11</td><td>9</td></tr>
<tr><td>12</td><td>14</td></tr>
<tr><td>13</td><td>11</td></tr>
<tr><td>14</td><td>6</td></tr>
</table>
-សិស្សភាគច្រើនអាយុ 12 ឆ្នាំ។<br>-សិស្សភាគតិចអាយុ 14 ឆ្នាំ។<br>


</td>
<td>- សិស្សកត់ត្រា<br><br>-អាយុសិស្សដែលស្រង់បានខាងលើនេះហៅថាទិន្នន័យ។<br>-ទិន្នន័យខាងលើគឺពិតជាពិបាកអោយគេដឹងថាតើសិស្សអាយុប៉ុន្មានឆ្នាំមានចំនួនច្រើនជាងគេ ហើយ</td>
</tr>
</table>

<table>
<tr>
<td>ជាងគេ ឬ តិចជាងគេដែរឬទេ?<br><br>-តើយើងត្រូវធ្វើដូចម្តេចដើម្បីងាយស្រួលក្នុងការដឹងថាសិស្សមួយណាអាយុប៉ុន្មានឆ្នាំ មានចំនួនច្រើនជាងគេ ឬ តិចជាងគេ?<br><br><br><br>-តើតារាងនេះហៅថាតារាងអ្វី?<br><br>-តាមតារាងនេះយើងអាចដឹងអំពីអ្វី?<br><br><br>-ដើម្បីអោយកាន់តែងាយស្រួលជាងនេះទៅទៀតគេអាចបកស្រាយតារាងបំណែងចែកទិន្នន័យជាក្រាប ក្នុងករណីនេះគេយក<br>. បន្ទាត់ដេកសម្រាប់តាងអាយុសិស្ស<br>. បន្ទាត់ឈរសម្រាប់តាងចំនួនសិស្សដោយយក 1ឯកតា តាងសិស្សម្នាក់។</td>
<td></td>
<td>សិស្សប៉ុន្មានឆ្នាំមានអាយុតិចជាងគេ។<br>-យើងត្រូវរៀបចំទិន្នន័យនៃអាយុរបស់សិស្សទាំងនេះដាក់ក្នុងតារាង
<table>
<tr><th>អាយុសិស្ស</th><th>ចំនួយសិស្ស</th></tr>
<tr><td>11</td><td>9</td></tr>
<tr><td>12</td><td>14</td></tr>
<tr><td>13</td><td>11</td></tr>
<tr><td>14</td><td>6</td></tr>
</table>
<br>-តារាងនេះហៅថា<br>តារាងបំណែងចែកទិន្នន័យ។<br>-តាមតារាងនេះគេអាចដឹងថា:<br>+សិស្សភាគច្រើនអាយុ 12 ឆ្នាំ<br>+សិស្សភាគតិចអាយុ 14 ឆ្នាំ<br>- សិស្សកត់ត្រា<br>


</td>
</tr>
</table>

<table>
<tr>
<td>-តើរូបតាងនេះគេហៅថាអ្វី?<br><br>-តើអ្នកណាអាចបកស្រាយថាសរសរទី1,2,3,4 បង្ហាញពីអ្វី?</td>
<td></td>
<td>-តាមតារាងនេះហៅថា ក្រាបសរសរ។<br>-សរសរទី1បង្ហាញថាសិស្សអាយុ11ឆ្នាំមានចំនួន9នាក់។<br>-សរសរទី2 បង្ហាញថាសិស្សអាយុ12 ឆ្នាំមានចំនួន 14 នាក់។<br>-សរសរទី3 បង្ហាញថាសិស្សអាយុ13 ឆ្នាំមានចំនួន 11 នាក់។<br>-សរសរទី4 បង្ហាញថាសិស្សអាយុ14 ឆ្នាំមានចំនួន 6នាក់។<br>-ក្រាបសរសរ អាចសង់ជាទំរង់ផ្ដេកបាន។</td>
</tr>
<tr>
<td>-តើក្រាបសរសរអាចសង់ជាទំរង់ផ្ដេកបានដែរ រឺទេ?<br>-តើយើងត្រូវសង់យ៉ាងដូចម្ដេច?<br><br>-តើយើងអាចសន្និដ្ឋានបានយ៉ាងដូចម្ដេច?<br>-គ្រូកត់ឧទាហរណ៍:
<table>
<tr><td>ខែ</td><td>VCD</td><td>CD</td></tr>
<tr><td>មករា</td><td>350</td><td>300</td></tr>
<tr><td>កុម្ភ:</td><td>310</td><td>240</td></tr>
<tr><td>មីនា</td><td>360</td><td>350</td></tr>
<tr><td>មេសា</td><td>200</td><td>200</td></tr>
</table>
ក). បកស្រាយទិន្នន័យខាងលើជាក្រាបសរសរភ្លោះ។ តើក្នុងខែណាគេលក់បាន</td>
<td>-យើងអាចសន្និដ្ឋានបានថាគេប្រើក្រាបសរសរសំរាប់បង្ហាញពត៌មាន<br>2). <u>ក្រាបសរសរភ្លោះ</u><br>
<br>ក).គេបកស្រាយទិន្នន័យដោយក្រាបសរសរភ្លោះខាងលើក្នុងខែមីនាគេលក់បានថាស VCD ច្រើនជាងគេ មានចំនួន360 បន្ទះ។<br>ខ).ក្នុងខែកុម្ភ:គេលក់ VCD</td>
<td>-ដោយយកបន្ទាត់ដេកតាងចំនួនសិស្ស ហើយយើងយកបន្ទាត់ឈរតាងអាយុសិស្ស។<br>-យើងអាចសន្និដ្ឋានបានថាគេប្រើក្រាបសរសរសំរាប់បង្ហាញពត៌មាន។</td>
</tr>
</table>

| | | |
|---|---|---|
| VCDច្រើនជាងគេហើយមានចំនួនប៉ុន្មានបន្ទះ?<br>ខ). តើក្នុងខែកុម្ភៈគេលក់ VCD លើស CD ប៉ុន្មានបន្ទះ?<br>-តើមុននឹងយើងឈានទៅរកការបកស្រាយទិន្នន័យ យើងត្រូវធ្វើដូចម្ដេច?<br>-តើយើងអាចតាងថាសចម្រៀងលើអ័ក្សដេក ហើយចំនួនខែលើអ័ក្សឈរបានដែរ រឺទេ? ព្រោះអ្វី?<br>-ក៏ប៉ុន្តែប្រភេទថាសចម្រៀងមានពីរប្រភេទខុសគ្នា តើយើងត្រូវធ្វើដូចម្ដេច?<br>-ការតាងចំនួនថាសចម្រៀងទាំងពីរប្រភេទដោយក្រាបសរសរជាប់គ្នាទៅតាមខែនីមួយៗ ក្រាបសរសរដែលជាប់គ្នាតាមផ្នែកៗហៅថា **ក្រាបសរសរភ្លោះ**។<br>-បើគេបកស្រាយទិន្នន័យដោយក្រាបសរសរភ្លោះ តើក្នុងខែណាគេលក់បាន VCDច្រើនជាងគេហើយមានចំនួនប៉ុន្មានបន្ទះ? | លើសCDចំនួន<br>310-240 = 70 បន្ទះ។ | -យើងត្រូវតាងខែលើអ័ក្សដេក ហើយចំនួនថាសចម្រៀងនៅលើអ័ក្សឈរ។<br>-យើងអាចតាងថាសចម្រៀងលើអ័ក្សដេក ហើយចំនួនខែលើអ័ក្សឈរបានព្រោះក្រាបសរសរអាចសង់ជាទំរង់ផ្ដេកបាន។<br>-ដោយប្រភេទថាសចម្រៀងមានពីរខុសគ្នាគេត្រូវប្រើសរសរពីរដែលមានពត៌មានខុសគ្នា ដែលកម្ពស់សរសរបង្ហាញពីចំនួនថាសចម្រៀង។<br>-សិស្សកត់ត្រា<br><br><br>-គេបកស្រាយទិន្នន័យដោយក្រាបសរសរភ្លោះខាងលើក្នុងខែមីនា គេលក់បានថាស VCD ច្រើនជាងគេមានចំនួន 360 បន្ទះ។<br>-ក្នុងខែកុម្ភៈគេលក់ VCD |

<table>
<tr><td>-តើក្នុងខែកុម្ភៈវិញគេលក់ VCD លើស CD បានប៉ុន្មានបន្ទះ?<br>-សន្និដ្ឋានៈ គេប្រើក្រាបសរសរភ្លោះសំរាប់ប្រៀបធៀបទិន្នន័យលើសពីមួយប្រភេទក្នុងអំឡុងពេលតែ1។</td><td>-សន្និដ្ឋានៈ គេប្រើ ក្រាបសរសរភ្លោះ សំរាប់ប្រៀបធៀបទិន្នន័យលើសពីមួយប្រភេទក្នុងអំឡុងពេលតែ1។</td><td>លើស CDចំនួន 310 -240 = 70 បន្ទះ។<br>-សិស្សកត់ត្រា</td></tr>
<tr><td>-លំហាត់គំរូ:<br>តារាងបង្ហាញពីទិន្នផលដំណាំ 3 មុខដែលសំបូរជាងគេនៅប្រទេសកម្ពុជា<br><table><tr><td></td><td>កំពង់ចាម</td><td>ព្រៃវែង</td></tr><tr><td>ពោត</td><td>130</td><td>70</td></tr><tr><td>សណ្តែក</td><td>120</td><td>40</td></tr><tr><td>ស្រូវ</td><td>55</td><td>95</td></tr></table>បកស្រាយទិន្នន័យខាងលើជាក្រាបសរសរភ្លោះ។</td><td><u>ជំហានទី4</u><br>(ពង្រឹងពុទ្ធិ)<br>(10mn)</td><td>ចម្លើយ: ក្រាបសរសរភ្លោះ<br></td></tr>
<tr><td>-ត្រឡប់ទៅផ្ទះវិញធ្វើលំហាត់នៅទំព័រទី 215 លេខ 2, 3, 4, 5។</td><td><u>ជំហានទី5</u><br>(បណ្តាំផ្ញើ)<br>(5mn)</td><td>-សិស្សកត់ត្រា</td></tr>
</table>

# កិច្ចតែងការបង្រៀន
# គណិតវិទ្យា ថ្នាក់ទី ៧
# ថ្ងៃ ទី ខែ ឆ្នាំ

I.ចំណងជើងមេរៀន : **ដ្យាក្រាមផ្លិត**

II. វត្ថុបំណង : ក្រោយពេលរៀនចប់សិស្សអាច

+ ចំណេះដឹង: សិស្សអាចបង្កើតតារាងបែងចែកទិន្នន័យ
+ បំនិន(ចំណេះធ្វើ) សិស្សអាចបកស្រាយតារាងបែងចែកទិន្នន័យតាមក្រាបដោយតាមរយ:ឧទាហរណ៍
+ ឥរិយាបទ:សិស្សមានបំរុងប្រយ័ត្នក្នុងការស្តាប់គ្រូពន្យល់យ៉ាងយកចិត្តទុកដាក់និងស្ទៀមស្ទាត់អាចធ្វើលំហាត់បានត្រឹមត្រូវ

III.រយះពេលបង្រៀន ២ ម៉ោង

IV.សម្ភារះឧបទេស សៀវភៅសិស្ស ទំព័ ២១៨

V.ដំណឹកនាំមេរៀន : ២ ម៉ោង

| សកម្មភាពគ្រូ | ខ្លឹមសារបង្រៀន | សកម្មភាពសិស្ស |
|---|---|---|
| គ្រូតពិនិត្យអនាម័យអវត្តមាន<br>-សណ្តាប់ធ្នាប់និង វិន័យ | ជំហានទី១<br>(រដ្ឋបាលថ្នាក់) | តំណាងថ្នាក់ឡើងរាយការណ៍ |
| -តើថ្ងៃមុនរៀនមេរៀនអ្វី? ហើយចែកចេញជាប៉ុន្មាន?<br><br>គេប្រើក្រាបសសរសម្រាប់ធ្វើអ្វី? គេប្រើក្រាបសសរភ្លោះសម្រាប់ធ្វើអ្វី? | ជំហានទី២<br>(រំលឹកមេរៀនចាស់) | -រៀនអំពីក្រាបសសរ។ហើយចែកចេញជាពីរចំនុចគឺ:<br>1. ក្រាបសសរ<br>2. ក្រាបសសរភ្លោះ<br>-គេប្រើក្រាបសសរសម្រាប់បង្ហាញពត៍មានហើយ គេប្រើក្រាបសសរភ្លោះសម្រាប់ ប្រៀបធៀបទិន្នន័យលើសពីមួយប្រភេទ ក្នុងអំឡុងពេលតែមួយ |
| អ្វីទៅជាដ្យាក្រាមផ្លិត? | ជំហានទី៣(មេរៀនប្រចាំថ្ងៃ)<br>មេរៀនទី២២ ក្រាបផ្លិត<br>១.ក្រាបផ្លិត | ដ្យាក្រាមផ្លិតគឺជាតម្រៀបទិន្នន័យ |

<table>
<tr>
<td>
គ្រូដាក់ឧទាហរណ៍អោយសិស្សសង្កេត<br><br>
ចម្លើយ<br>
តាងចំនួនសត្វទាំងអស់ជារូបថាស នោះចំនួនសត្វទាំងអស់គឺ:<br>
60+40+20=120ក្បាល<br>
-មាន់មាន $60 = \frac{60}{120} = \frac{1}{2}$ នៃចំនួនសត្វទាំងអស់ មានន័យថា 1ភាគ2 នៃថាស។<br>
បើយើងគិតជាមុំ $\frac{1}{2} \times 360' = 180'$<br><br>
-ទាមាន $\frac{40}{120} = \frac{1}{3}$ នៃចំនួន សត្វទាំង អស់  មានន័យថា 1ភាគ3នៃថាស។<br>
បើយើងគិតជាមុំ $\frac{1}{2} \times 360' = 120'$<br>
ទាមាន $\frac{20}{120} = \frac{1}{6}$ នៃចំនួន សត្វទាំង អស់  មានន័យថា 1ភាគ6នៃថាស។<br>
បើយើងគិតជាមុំ $\frac{1}{6} \times 360' = 60'$<br>
គេបានតារាងទិន្នន័យ<br>
<table>
<tr><td>សត្វ</td><td>ចំនួនសត្វ</td><td>មុំចំរៀកថាស</td></tr>
<tr><td>មាន់</td><td>60</td><td>180</td></tr>
<tr><td>ទា</td><td>40</td><td>120</td></tr>
<tr><td>ក្ងាន</td><td>20</td><td>60</td></tr>
</table>
</td>
<td>
ឧទាហរណ៍<br>
ពូចាន់ជាម្ចាស់កសិដ្ឋានសត្វមួយកន្លែង។ក្នុងនោះមានសត្វមាន់60ក្បាលទា60ក្បាលក្ងាន60ក្បាល។<br>








ចំនួនសត្វទាំងអស់តាមផ្នែកនីមួយៗដែលគេបានតាងមានរាងជាផ្ចិត គេហៅថាដ្យាក្រាមផ្ចិត។
</td>
<td>
រាងជាចំរៀកថាស។
</td>
</tr>
</table>

+គ្រូដាក់ឧទាហរណ៍ឲ្យសិស្សឡើងធ្វើ។

ឧទាហរណ៍:គេបានធ្វើការកត់ត្រាការលក់សាំង (លិតជាពាន់លីត)ក្នុងស្ថានីយ៍លក់សាំងចំនួន 4 កន្លែងដែលគេតាង $A,B,C$ និង $D$ នៅសប្តាហ៍ទី១នៃខែមករា

| ស្ថានីយ៍សាំង | A | B | C | D |
|---|---|---|---|---|
| សាំង(ពាន់លីត) | 90 | 140 | 30 | 20 |




+សង់ក្រាបផ្ចិតនេះគឺប្រើរាប៉ាទ័រ

សិស្សពិភាក្សាជាក្រុមនិងឡើងដោះស្រាយ

ចម្លើយ

បង្ហាញទិន្នន័យខាងលើជាក្រាបផ្ចិត:

រកចំនួនសាំងសរុបទាំង ៤ស្ថានីយ៍

គេបាន $90+140+30+20=280$ ពាន់លីត។

ចំនួនសរុបទាំងនេះគេតាងជារង្វង់ ឬថាសមួយ។

ហេតុនេះ 280 ពាន់លីតត្រូវនឹងមុំផ្ចិតរង្វង់គឺ $360^0$ ។

គេបាន

90 ត្រូវនឹងមុំ $\frac{360}{280}\times 09 = 115.7^0$

140 ត្រូវនឹងមុំ $\frac{360}{280}\times 140 = 180^0$

30 ត្រូនឹងមុំ $\frac{360}{280}\times 30 = 38.6^0$

20 ត្រូវនឹង $\frac{360}{280}\times 20 = 25.7^0$

គេតាងតារាងបែងចែកទិន្នន័យ

| ស្ថានីយ៍សាំង | ចំនួនសាំង (ពាន់លីត) | មុំចំរៀកថាស |
|---|---|---|
| A | 90 | $115.7^0$ |
| B | 140 | $180^0$ |
| C | 30 | $38.6^0$ |
| D | 20 | $25.7^0$ |

<table>
<tr>
<td>លោកគ្រូប្រាប់សិស្សឲ្យបិទសៀវភៅពុម្ពទាំងអស់គ្នា ។ហើយបន្ទាប់មកគាត់បានដាក់លំហាត់គំរូឲ្យសិស្សពិភាក្សាជាក្រុមនិងឡើងដោះស្រាយនៅលើដក្ដាខៀន។</td>
<td>ជំហាន់ទី៤ (ពង្រឹងពុទ្ធិ)<br>លំហាត់គំរូ
<table>
<tr><td>មធ្យោបាយធ្វើដំនើរ</td><td>អត្រាជាភាគរយ</td></tr>
<tr><td>ឡាន</td><td>10</td></tr>
<tr><td>ម៉ូតូ</td><td>75</td></tr>
<tr><td>កង់</td><td>15</td></tr>
</table>
ខាងលើនេះជាតារាងទិន្នន័យនៃមធ្យោបាយធ្វើដំនើរបស់និស្សិតនៅសកលវិទ្យាល័យមួយ។ ចូរតាងនិន្នន័យខាងលើជាក្រាបផ្លិត។</td>
<td>សិស្សពិភាក្សាជាក្រុមហើយឡើងសរសេរលើក្ដាខៀន<br>ចម្លើយ<br>តាងអត្រា 100% ដោយរូបថាសទាំងមូល ឬរង្វង់ ។ គេដឹងថា 100% ត្រូវនឹងមុំផ្ចិត $360^0$ ។<br>ហេតុនេះគេបាន<br>+ឡាន 10% នៃថាសគឺ<br>$\frac{360}{100}\times 10 = 36^0$<br>+ ម៉ូតូ 75% នៃថាសគឺ<br>$\frac{360}{100}\times 75 = 270^0$<br>+ កង់ 15% នៃថាសគឺ<br>$\frac{360}{100}\times 15 = 54^0$<br>រូបតាងក្រាបនៃផ្លិតគឺ<br><br></td>
</tr>
<tr>
<td>គ្រូដាក់លំហាត់ឲ្យសិស្សយកទៅផ្ទះធ្វើ:<br>ប្រតិបត្តិ: ក្នុងកសិដ្ឋានមួយមានចញ្ចឹមសត្វទាំងអស់ចំនួន 75 ក្បាល ក្នុងនោះមានគោ15ក្បាល ជ្រូក 28ក្បាល ក្របី 10ក្បាល និងទា 22ក្បាល ។<br>ក) បង្កើតតារាងបំលែងចែកទិន្នន័យ?<br>ខ) សង់ក្រាផ្លិតតាងទិន្នន័យខាងលើ?</td>
<td>ជំហានទី ៥ (បណ្ដាំផ្ញើរ)</td>
<td>សិស្សកត់ត្រាចូលសៀវភៅ</td>
</tr>
</table>

# អបអរសាទរពិធីតាំងពិពណ៌វិទ្យាសាស្ត្រ

# របស់គរុនិស្សិតកម្រិតឧត្តម

# បរិញ្ញា +១ ជំនាន់ទី១៧

# នៅវិទ្យាស្ថានជាតិអប់រំ

# ថ្ងៃទី ៦-៧ ខែកក្កដា ឆ្នាំ ២០១២